# ការពិចារណាពិស្តារផ្នែកគតិយុត្តិ

## សៀវភៅសិក្សាផ្នែកទី៣

# ប្រព័ន្ធតុលាការ

**CRITICAL LEGAL THINKING**

A Study Text Book Part (III)

**Judiciary**

Dr. Wilhelm Treiber / Andrea Behm / Hout Sotheary

វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ

KHMER INSTITUTE OF DEMOCRACY

# ប្រព័ន្ធតុលាការនៃព្រះរាជាណាចក្រកម្ពុជា

## ក) សិទ្ធិដើម្បីមាននូវការគ្រប់គ្រងផ្នែកតុលាការ

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ (ICCPR) ដែលត្រូវបានប្រើដោយប្រទេសកម្ពុជា ហើយជាផ្នែកមួយនៃច្បាប់ជាតិកម្ពុជា (តាមមាត្រា ៣១ I រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា )លើកឡើងថា មនុស្សគ្រប់រូបមានសិទ្ធិទទួលការដោះស្រាយប្រកបដោយប្រសិទ្ធិភាព ដែលផ្តល់ដោយអង្គការតុលាការឯករាជ្យមួយ ក្នុងករណីមានការរំលោភសិទ្ធិដល់ពួកគេ ។

មាត្រា៨ UDHR:

មនុស្សគ្រប់រូប មានសិទ្ធិទទួលបាននូវការដោះស្រាយដោយតុលាការជាតិ ដែលមានសមត្ថកិច្ចចំពោះអំពើទាំងឡាយដែលរំលោភសិទ្ធិសំខាន់ៗរបស់ខ្លួន ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ឬដែលមានចែងនៅក្នុងច្បាប់ ។

មាត្រា១០ UDHR:

បុគ្គលគ្រប់រូប ត្រូវមានសិទ្ធិមានភាពស្មើគ្នាពេញលេញ ក្នុងការសុំឱ្យតុលាការ ឯករាជ្យ និងមិនលំអៀងមួយ កាត់សេចក្តីដោយគតិយុត្តិធម៌ និងជាសាធារណៈ ក្នុងការកំណត់សិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន ហើយនិងការចោទប្រកាន់ជាបទព្រហ្មទណ្ឌណាមួយមកលើគេ ។

មាត្រា ១៤ I ICCPR:

នៅចំពោះមុខតុលាការ ឬនៅក្នុងសាលាជំនុំជំរះក្តី មនុស្សគ្រប់រូបមានសិទ្ធិស្មើៗគ្នា ។ ក្នុងការសំរេចផ្តន្ទាទោសឧក្រិដ្ឋទៅលើជនណាម្នាក់ និងក្នុងការសំរេចអំពីសិទ្ធិ និងករណីយកិច្ចរបស់ជនណាម្នាក់ ក្នុងករណីដែលមានការប្តឹងផ្តល់ សាមីខ្លួន ត្រូវមានសិទ្ធិស្នើសុំឱ្យមានការកាត់សេចក្តីឱ្យ បានសមរម្យជាសាធារណៈ ។ ការសំរេចក្តីនេះត្រូវរៀបចំ និងដឹកនាំដោយក្រុមជំរះក្តីដែលតែងតាំងឡើងតាមលក្ខណៈច្បាប់ ។

វាជាកាតព្វកិច្ចរបស់រដ្ឋហត្ថលេខី ដែលត្រូវបង្កើតប្រព័ន្ធតុលាការមួយ ដែលអាចឆ្លើយតបនឹងសិទ្ធិប្រជាពលរដ្ឋ ក្នុងការទទួលបាននូវការត្រួតពិនិត្យខាងតុលាការ ។ សិទ្ធិនេះ **ក៏រួមបញ្ចូលយ៉ាងជាក់លាក់នូវសិទ្ធិត្រួតពិនិត្យខាងតុលាការ លើការប្រតិបត្តិរបស់មន្ត្រីរដ្ឋបាល ។**

មាត្រា ២ III ICCPR:

រដ្ឋជាភាគីនិមួយៗនៃកតិកាសញ្ញាមានភារកិច្ច :
ក) ត្រូវធានាថា បើមានការរំលោភលើសិទ្ធិ ឬសេរីភាពរបស់ប្រជាជនណាម្នាក់ រដ្ឋមានភារកិច្ចរកវិធីដោះស្រាយបញ្ហានេះឱ្យបានស័ក្តិសិទ្ធិ ទោះបីការរំលោភនេះបានប្រព្រឹត្តឡើងដោយភ្នាក់ងារ ដែលបំពេញបេសកកម្មជាផ្លូវការក៏ដោយ ។
ខ) ត្រូវធានាថាជនរងគ្រោះដោយអំពើរំលោភលើសិទ្ធិ និងសេរីភាពត្រូវមានសិទ្ធិប្តឹងទាមទាររកយុត្តិធម៌ ។ ការរកយុត្តិធម៌ក្នុងករណីនេះ ត្រូវធ្វើឡើងដោយតុលាការមានសមត្ថកិច្ច ឬដោយអាជ្ញាធរនានាក្នុងផ្នែករដ្ឋបាល ឬផ្នែកច្បាប់ ឬដោយក្រសួងមានសមត្ថកិច្ចឯទៀតដែលក្រសួងយុត្តិធម៌បានចាត់តាំង ។
គ) ដើម្បីធានាយុត្តិធម៌ជូនប្រជារាស្ត្រ អាជ្ញាធរមានសមត្ថកិច្ច ត្រូវបំពេញបេសកកម្មឱ្យបានមឹងម៉ាត់ទៅតាមការចាត់តាំងរបស់ក្រសួង ។

**រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា** (CC) ក៏ទទួលស្គាល់យ៉ាងជាក់លាក់នូវសិទ្ធិជាមូលដ្ឋាននេះ ទៅនឹងការការពារខាងតុលាការ ប្រឆាំងទៅនឹងការរំលោភសិទ្ធិគ្រប់បែបយ៉ាងដោយមិនប្រកាន់ថា សិទ្ធិនេះត្រូវបានរំលោភដោយភាគីទីបី ឬដោយរដ្ឋាភិបាលឡើយ ។

មាត្រា៣៨ VIII CC:

ជនគ្រប់រូប មានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។

មាត្រា៣៩ CC:

ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាត ជាសមត្ថកិច្ចរបស់តុលាការ ។

នៅក្នុងការធានាឱ្យមានការការពារសិទ្ធិតាមផ្លូវច្បាប់ ដោយស្ថាប័នឯករាជ្យមួយ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ធានាឱ្យមានតុលាការ**ឯករាជ្យ**មួយ ។

មាត្រា១២៨ CC:

អំណាចតុលាការជាអំណាចឯករាជ្យ ។

អំណាចតុលាការ ធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ។

អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ។

## ២) ការវិភាគទៅលើរចនាសម្ព័ន្ធនៃប្រព័ន្ធតុលាការដោយសង្ខេប:

ប្រព័ន្ធតុលាការ គឺជាប្រព័ន្ធស្មុគស្មាញមួយ ដោយរួមមាន ទំនាក់ទំនងរវាងអំណាចរដ្ឋ ស្ថាប័ន និងតួអង្គជាច្រើន ។ ដើម្បី ធ្វើការវិភាគ និងយល់ដឹងឱ្យបានស៊ីជំរៅលើប្រព័ន្ធមួយថែមទៀតនោះ យើងគួរតែបែងចែកនូវទិដ្ឋភាពរួមជា បីផ្នែក ហើយពិនិត្យលើផ្នែកនីមួយៗដាច់ដោយឡែកពីគ្នា:

### I) អំណាច:

ដោយតុលាការ ជាអំណាចមួយក្នុងចំណោមអំណាចទាំងបីរបស់រដ្ឋ យើងអាចពិនិត្យមើលដំបូងទៅលើតួនាទីរបស់តុលាការ ដែលដើរតួនៅក្នុងរចនាសម្ព័ន្ធអំណាចនេះ ហើយមើលទៅលើទំនាក់ទំនងរបស់តុលាការជាមួយនឹងអំណាចនីមួយៗ (រួមទាំងទំនាក់ទំនងជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយដែលជួនកាលត្រូវគេហៅថា "អំណាចទីបួន" ដោយសារតែឥទ្ធិពលដ៏ខ្លាំងរបស់វា) ។




### II) ស្ថាប័ន:

នៅចំនុចទី ២ នេះ យើងមើលទៅលើមុខងាររបស់ស្ថាប័នសាធារណៈផ្សេងៗដូចខាងក្រោម ដែលជាផ្នែកនៃប្រព័ន្ធតុលាការ:




### III) តួអង្គ:

ជាចុងក្រោយ យើងមើលទៅលើ តួនាទី សិទ្ធិ និងភារកិច្ចរបស់តួអង្គផ្សេងៗគ្នាដូចខាងក្រោម:



## IV) ក្នុងន័យពិស្តារ:

### ១) ទំនាក់ទំនងនៃតុលាការទៅនិងអំណាចផ្សេងទៀត:

តួនាទីរបស់តុលាការ និងទំនាក់ទំនងរបស់ខ្លួនចំពោះអំណាចផ្សេងទៀត អាចត្រឹមតែត្រូវបានគេយល់ដឹង ប្រសិនបើ វាមានលក្ខណៈច្បាស់ថាហេតុអ្វីបានជាគេត្រូវការអំណាចទាំងនោះ ។ ចំលើយចំពោះសំនួរនេះគឺ: មនុស្សទាំងអស់មិនល្អ១០០%ទេ ហើយក៏មិនអាក្រក់១០០%ដែរ ។ អ្នកណាក៏អាចមានកំហុស ។ វាត្រូវបានឆ្លុះបញ្ចាំងដោយពាក្យស្លោកជាច្រើន:

> "មនុស្សត្រូវបានធ្វើឡើងដោយឈើកោង ដែលគ្មានអ្វីត្រង់ល្អគេអាចរំពឹងបាននោះឡើយ ។"
>
> "ព្រះផ្តល់រស្មីព្រះអាទិត្យដល់មនុស្សទាំងអស់ទាំងមនុស្សត្រឹមត្រូវ និងមនុស្សមិនត្រឹមត្រូវ"
>
> "គ្មានអ្នកណាម្នាក់ល្អឥតខ្ចោះឡើយ"

ដូច្នេះ មនុស្សត្រូវការអំណាចមួយដែលបង្កើតនូវបទបញ្ញា និងច្បាប់សំរាប់គ្រប់គ្រងឥរិយាបថរបស់ខ្លួន គឺ**អំណាចនីតិបញ្ញត្តិ** អំណាចមួយដែលអនុវត្តច្បាប់ទាំងនេះ គឺ**អំណាចនីតិប្រតិបត្តិ** ហើយនិងអំណាចមួយទៀតដែលត្រួតពិនិត្យថា តើការអនុវត្តន៍ និងប្រតិបត្តិច្បាប់នោះត្រឹមត្រូវដែរឬទេ គឺ**អំណាចតុលាការ** ។ ដោយហេតុថា "អំណាចទីបួន" គឺជា **ប្រព័ន្ធផ្សព្វផ្សាយ** ដែលនៅទីបញ្ចប់វាដើរតួជាអ្នកតាមដានដោយយកចិត្តទុកដាក់លើការអនុវត្តន៍នៃអំណាចទាំងបី ហើយផ្តល់មតិទិតៀនកែលំអ ។

ប៉ុន្តែស្ថាប័នទាំងនេះ ត្រូវបានដំណើរការដោយមនុស្សដែលអាចធ្វើអោយមានកំហុសបាន ហើយអាចធ្វើអ្វីលើសពីអំណាចរបស់ខ្លួនបាន ។ ដូច្នេះ **ស្ថាប័ននីមួយៗ ត្រូវការការត្រួតពិនិត្យ និងការកំណត់** ហើយ អំណាចផ្សេងៗ មិនត្រឹមតែត្រូវបានបែងចែកយ៉ាងជាក់លាក់នោះទេ តែត្រូវទទួលការត្រួតពិនិត្យ និងការធ្វើឱ្យមានតុល្យភាពនឹងគ្នាផងដែរ ។ ករណីនេះគេហៅថាជា **"គោលការណ៍នៃការត្រួតពិនិត្យ និងតុល្យភាព"** យើងត្រូវតែប្រកាន់ខ្ជាប់នូវគោលការណ៍នេះ នៅពេលដែលធ្វើការពិនិត្យទៅលើទំនាក់ទំនង រវាងតុលាការ និងអំណាចផ្សេងទៀត ។

បទបញ្ញាជាក់លាក់មួយអំពីទំនាក់ទំនងនេះគឺថា គ្មានអំណាចណាអាចដើរតួជាអំណាចតុលាការបានឡើយ ។

> មាត្រា១២៩ ប្រយោគទី ២ CC:
> ... <u>មានតែចៅក្រមទេ</u>ដែលមានសិទ្ធិជំរះក្តី ។ ចៅក្រមត្រូវបំពេញភារកិច្ចនេះដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។
>
> មាត្រា១៣០ CC:
> គ្មានអង្គការណាមួយ នៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិ អាចទទួលអំណាចតុលាការអ្វីបានឡើយ។
>
> មាត្រា១៣១ CC:
> មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។

# គោលការណ៍នៃ
# ការត្រួតពិនិត្យ និងតុល្យភាព

ម្ខាងជាប្រព័ន្ធតុលាការ មានឥទ្ធិពលលើអំណាចដទៃៗ

ម្ខាងទៀត នៅពេលជាមួយគ្នានោះ អំណាចទាំងនេះមានឥទ្ធិពលលើតុលាការៈ

## តុលាការ



## នីតិបញ្ញត្តិ



តុលាការ ស្នើទៅ ក្រុមប្រឹក្សាធម្មនុញ្ញ ឱ្យពិនិត្យធម្មនុញ្ញភាពនៃច្បាប់ (មាត្រា១៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និងមាត្រា១៣៦ I CC

អង្គនីតិបញ្ញត្តិ ត្រួតពិនិត្យតុលាការ (មាត្រា១២៩ I, II ២ CC) ដោយចងភ្ជាប់តុលាការទៅនឹងច្បាប់ដែលអនុម័តរួច ។ អ្នកធ្វើច្បាប់បានបង្កើតផងដែរនូវច្បាប់ស្តីពី តួនាទី និងភារកិច្ចរបស់តុលាការ: លក្ខន្តិកៈរបស់ចៅក្រម និងព្រះរាជអាជ្ញា ច្បាប់ស្តីពី ឧត្តមក្រុមប្រឹក្សាអង្គចៅក្រម ។ (មាត្រា ១៣៤ I, ១៣៥ CC)

## នីតិប្រតិបត្តិ



តុលាការ ត្រួតពិនិត្យលើសកម្មភាពរបស់អង្គ នីតិប្រតិបត្តិ និងរដ្ឋបាល ។ សមាជិករដ្ឋាភិបាល អាចត្រូវបានដាក់ទោសដោយតុលាការព្រហ្មទណ្ឌ (មាត្រា ៣៩,១២៦ I CC)

អង្គនីតិប្រតិបត្តិត្រួតពិនិត្យតុលាការៈ ស្ថាប័ននេះ អនុវត្តសាលក្រម បញ្ជូនសមាជិកម្នាក់ពីក្រសួងយុត្តិធម៌ ទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (មាត្រា២ ចំនុចទី២ ច្បាប់ SCM) និងអាចផ្តួចផ្តើមនូវគំនិតធ្វើច្បាប់ដែល ពាក់ព័ន្ធនឹងប្រព័ន្ធតុលាការបាន (មាត្រា ៩១ CC) ។

## ប្រព័ន្ធផ្សព្វផ្សាយ



តុលាការត្រួតពិនិត្យប្រព័ន្ធផ្សព្វផ្សាយដោយការអនុវត្តន៍នូវច្បាប់សារពត៌មាន នីតិរដ្ឋប្បវេណី (ឧ. បទបង្ខូចកេរ្តិ៍ឈ្មោះ) និងនីតិព្រហ្មទណ្ឌ (ឧ. បទបរិហារកេរ្តិ៍)

ប្រព័ន្ធផ្សព្វផ្សាយត្រួតពិនិត្យអំណាចតុលាការ ដោយការចូលរួមសវនាការ ហើយរាយការណ៍ពីតុលាការ និងធ្វើការទិតៀនកែលំអ លើការអនុវត្តន៍របស់តុលាការ ។ (មាត្រា៤១ I ១ CC, ១៩ ICCPR)

## ២) ស្ថាប័នផ្សេងៗគ្នានៃតុលាការកម្ពុជា៖

ក) តុលាការ (មាត្រា១៣៥ រួមទាំងច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃ រដ្ឋកម្ពុជា [LCO] ឆ្នាំ១៩៩៣)

**តុលាការជាន់ខ្ពស់**

**តុលាការថ្នាក់ទី ៣**

**តុលាការកំពូល** (មាត្រា១៤-១៦ LCO)



ចៅក្រម ៥រូប

ពិនិត្យអង្គច្បាប់ឡើងវិញ

(ករណី មាត្រា១៤ II និង ១៦ ឃ្លាទី ២ LCO មានចៅក្រម ៩រូប ពិនិត្យ អង្គហេតុ និងអង្គច្បាប់)

ភ្ជាប់

**អង្គការអយ្យការ**

- ការិយាល័យអង្កេត
- ការិយាល័យព្រហ្មទណ្ឌ
- ការិយាល័យរដ្ឋប្បវេណី (ក្តីរដ្ឋប្បវេណីដែលពាក់ព័ន្ធនឹងប្រយោជន៍រដ្ឋ៖ អនីតិជន អសមត្ថជន)

**តុលាការថ្នាក់ទី ២**

**សាលាឧទ្ធរណ៍** (មាត្រា១០-១៣ LCO)

ចៅក្រម ៣រូប

ពិនិត្យឡើងវិញទាំងអង្គហេតុ និង អង្គច្បាប់

**តុលាការជាន់ទាប**

**សាលាដំបូង**

**តុលាការខេត្ត-ក្រុង** (មាត្រា៦-៨ LCO)

ចៅក្រម ១រូប

ពិនិត្យទាំងអង្គហេតុ និងអង្គច្បាប់

| ការិយាល័យ រដ្ឋប្បវេណី | ការិយាល័យ ព្រហ្មទណ្ឌ |
|---|---|

**តុលាការយោធា**

(មាត្រា៩ LCO)



នៅក្រោមការមើលខុសត្រូវរបស់ក្រសួងការពារជាតិ

**អនាគត**

**តុលាការពិសេស**

- តុលាការរដ្ឋបាល
- តុលាការគ្រួសារ
- តុលាការការងារ
- តុលាការពាណិជ្ជកម្ម (ច្បាប់បានពង្រាងរួចហើយដោយសារការចូល WTO)

## ខ) ស្ថាប័នជួយត្រួតពិនិត្យដល់តុលាការ

**ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម**

(មាត្រា១៣៤ CC រួមទាំងច្បាប់ស្តីពី SCM)



- **តែងតាំងចៅក្រម** (មាត្រា១៣៤ មាត្រា១១ III CC នៃច្បាប់ស្តីពី SCM)
- **ការដាក់ទោសផ្នែកវិន័យលើ ចៅក្រម** (មាត្រា១៣៣ ប្រយោគទី ២, ១៣៤ IV CC និងមាត្រា១២ នៃច្បាប់ស្តីពី SCM)
- **ត្រូវលើកកំពស់ឯករាជភាពនៃតុលាការ** (មាត្រា១៣២ ប្រយោគទី ២ CC)

បញ្ហា:
ឯករាជភាពគ្រប់-
គ្រាន់សំរាប់ SCM?

**ក្រសួងយុត្តិធម៌**

ច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌ (ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦) និង អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌ (ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០)



- **ត្រួតពិនិត្យលើពន្ធនាគារ**
- **ធានានូវភាពស្របនៃពង្រាងច្បាប់ ទៅនឹងច្បាប់ជាធរមាន**
- **ថែរក្សាកំណត់ហេតុក្តីព្រហ្មទណ្ឌ**

## ៣. តួអង្គ:

**ចៅក្រម**

ពង្រាងច្បាប់ស្តីពីលក្ខន្តិកៈ ចៅក្រម និងព្រះរាជអាជ្ញា (អត្ថបទចុងក្រោយ: ខែមីនា ឆ្នាំ២០០៣)



បញ្ហា:
ឯករាជភាព?
អព្យាក្រឹត្យ?
ចំណេះដឹងច្បាប់?

**មេធាវី**

លក្ខន្តិកៈមេធាវីកម្ពុជា និង ក្រមសីលធម៌សំរាប់មេធាវី



បញ្ហា:
ការចូលដោយសេរី
ទៅគណៈមេធាវី?
ជំនួយផ្នែកច្បាប់?

**ព្រះរាជអាជ្ញា**

ពង្រាងច្បាប់ស្តីពីលក្ខន្តិកៈ ចៅក្រម និងព្រះរាជអាជ្ញា (អត្ថបទចុងក្រោយ: ខែមីនា ឆ្នាំ២០០៣)



បញ្ហា:
ឯករាជភាព?
អព្យាក្រឹត្យ?
ចំណេះដឹងច្បាប់?

**សាការី**

អនុក្រឹត្យលេខ ៥០៥ រៀបចំ ដោយនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០១



បញ្ហា:
មិនមានច្បាប់ទេ!
តើសាការីអាចជាមេ
ធាវីនៅពេលតែ១?

## គ) តុលាការ៖

ការមកដល់របស់អ៊ុនតាក់ (UNTAC) នៅក្នុងឆ្នាំ១៩៩២ បាននាំមកនូវការផ្លាស់ប្តូរដ៏សំខាន់នៅក្នុងប្រព័ន្ធតុលាការកម្ពុជា ។ សាលាឧទ្ធរណ៍ ត្រូវបានបង្កើតឡើង ដែលជាលទ្ធផលកើតជា **ប្រព័ន្ធតុលាការបីថ្នាក់** គឺ៖

- តុលាការខេត្ត-ក្រុង (តុលាការថ្នាក់ទី ១)
- សាលាឧទ្ធរណ៍ និង (តុលាការថ្នាក់ទី ២)
- តុលាការកំពូល (តុលាការថ្នាក់ទី ៣ និងជាថ្នាក់ចុងក្រោយ) ។

ពត៌មានលំអិតមានចែងនៅក្នុង **"ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី"** ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ១៩៩៣ ។

### I) សាលាដំបូង៖

សាលាដំបូង គឺជាតុលាការជាន់ទាបបំផុត ដែលរួមមាន តុលាការខេត្ត ក្រុង និងតុលាការយោធា ។ **យុត្តាធិការ** របស់តុលាការនីមួយៗ **គ្របដណ្តប់លើតំបន់ភូមិសាស្ត្រជាក់លាក់ណាមួយ** ដែលតុលាការស្ថិតនៅ ។ លើកលែងតែតុលាការយោធាមួយប៉ុណ្ណោះ ដែលមានយុត្តាធិការគ្របដណ្តប់លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាទាំងមូល ។

<u>ការអធិប្បាយ៖</u>

គុណសម្បត្តិនៃយុត្តាធិការភូមិសាស្ត្រគឺថា តុលាការស្គាល់ពី តំបន់ បញ្ហា និងប្រជាជននៃតំបន់នេះច្បាស់លាស់ ។ ដូច្នេះ ពួកគេអាចធ្វើការវាយតម្លៃលើអង្គហេតុនានាប្រកបដោយភាពយុត្តិធម៌ និងភាពសមស្របច្រើន ។

ផ្ទុយទៅវិញ នៅក្នុងប្រព័ន្ធតុលាការមួយដែលមានចៅក្រមពុករលួយ ការមានតុលាការមួយដែលមានយុត្តាធិការភូមិសាស្ត្រដែលត្រូវបានកំណត់ច្បាស់លាស់ ក៏អាចជាគុណវិបត្តិផងដែរ ដូចជា ប្រជាជនមូលដ្ឋាន (ក្នុងស្រុក) ស្គាល់ចៅក្រមច្បាស់ ហើយអ្នកដែលមានបំណងសូកប៉ាន់ (ផ្តល់ប្រាក់សំណូក) ចៅក្រមទាំងនោះ ក៏អាចទំនាក់- ទំនងពួកគេបានដែរ ។ ដើម្បីចៀសវាងនូវគុណវិបត្តិបែបនេះ យើងត្រូវប្រើយុទ្ធសាស្ត្រពីរគឺ៖

- **ការផ្លាស់ប្តូរចៅក្រម** ឱ្យបានទៀងទាត់ ពីតុលាការមួយទៅតុលាការមួយទៀត និងដោយមានការយល់ព្រមជាមុនពីពួកគេ នៅពេលតែងតាំង ជួយកាត់បន្ថយឱកាសប្រព្រឹត្តិអំពើពុករលួយបាន ។
- គេត្រូវបង្កើត**ប្រព័ន្ធចៅក្រមមណ្ឌលមួយ** ដែលមានន័យថា ចៅក្រមត្រូវធ្វើដំណើរពីថ្នាក់កណ្តាលទៅកាន់ថ្នាក់ស្រុកនានាឱ្យបានជាប្រចាំ ដើម្បីរៀបចំសវនាការនៅទីនោះ ។ ដូច្នេះ ពុំមានភាគីណាម្នាក់មានឱកាសដើម្បីទាក់ទងពួកគេជាមុន ដើម្បីដោះស្រាយបញ្ហាកាត់ក្តីឡើយ ។

នៅក្នុងតុលាការទទួលពាក្យបណ្តឹងលើកទី១ មានតែ**ចៅក្រមតែម្នាក់** ប៉ុណ្ណោះដែលជាអ្នកវិនិច្ឆ័យក្តី និងគ្រប់គ្រងពាក្យបណ្តឹង ។

<u>ការអធិប្បាយ៖</u>

ការពិតដែលមនុស្សម្នាក់អាចសម្រេចរឿងក្តីមួយតែម្នាក់ឯង បង្កឱ្យមានឱកាសពុករលួយច្រើន ពីព្រោះគ្មានអ្នកផ្សេងទៀតចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងអាចគ្រប់គ្រងវាបាន ។ លើសពីនេះទៀត ការទំនាក់-

ទំនង និងការផ្តល់សំណូកដល់មនុស្សម្នាក់មានការងាយស្រួល និងអស់លុយតិចជាងការទាក់ទង និងសូកលុយទៅលើមនុស្សច្រើននាក់ ។ អាស្រ័យហេតុនេះ ប្រព័ន្ធតុលាការជាច្រើននៅក្នុងពិភពលោក បានបង្កើតគណៈកម្មការតុលាការដែលមានចៅក្រមចំនួន បីនាក់ ឬច្រើនជាងនេះ ។ ប្រព័ន្ធតុលាការមួយចំនួនទៀតបញ្ចូលឱ្យមានការចូលរួមពីសំណាក់ប្រជាជនសាមញ្ញ ដែលត្រូវបានជ្រើសតាំងចេញពីសាធារណជនឱ្យមកអង្គុយធ្វើការ និងធ្វើសេចក្តីសម្រេចជាមួយចៅក្រមអាជីព ។ (ឧទាហរណ៍ៈ ប្រព័ន្ធបែបនេះ ត្រូវបានចាប់ផ្តើមក្រោយសម័យបដិវត្តន៍នៅប្រទេសបារាំង ពីព្រោះ ប្រជាជននៅទីនោះ អស់ជំនឿលើចៅក្រមដែលពួកគេសង្ស័យថាចៅក្រមទាំងនេះនៅតែគាំទ្រវណ្ណៈមូលធន និងអធិរាជដែលគេបោះបង់ចោល ។)

ចៅក្រមត្រូវតែប្រមូល**អង្គហេតុ** និងភស្តុតាងនានា រួចហើយយកច្បាប់មកប្រើចំពោះអង្គហេតុទាំងនោះ ដំណើររឿងទាំងមូលត្រូវតែគោរពតាមគោលការណ៍នៃ**ការកាត់ក្តីដ៏ត្រឹមត្រូវ**[១] ។

### ១) តុលាការខេត្ត-ក្រុងៈ

តុលាការនេះ គឺជាតុលាការកាត់ក្តីថ្នាក់ទាបបំផុត ។ ជាគោលការណ៍ តុលាការក្រុង ឬតុលាការខេត្តមានពីរផ្នែកគឺ ផ្នែករដ្ឋប្បវេណី និងផ្នែកព្រហ្មទណ្ឌ ។ ប៉ុន្តែនៅក្នុងការអនុវត្តន៍ ដោយសារចំនួនចៅក្រមនៅមានកំរិតនៅឡើយនោះ គេពុំទាន់ឃើញមានការបែងចែកច្បាស់លាស់រវាងផ្នែកទាំងពីរនេះនៅឡើយទេ។ ចៅក្រមអាចដោះស្រាយទាំងករណីរដ្ឋប្បវេណី និងករណីព្រហ្មទណ្ឌ ។ ចៅក្រម តែងតែសម្រេចលើករណីទាំងអស់ក្នុងនាមជាចៅក្រមតែមួយ[២] ។

### ២) តុលាការយោធាៈ

តុលាការយោធា មានទីតាំងនៅក្នុងរាជធានីភ្នំពេញ ។ តុលាការនេះ គឺជាតុលាការដំបូងដែលមានយុត្តាធិការផ្តាច់មុខលើករណីទាំងឡាយ ដែល**ប្រព្រឹត្តឡើងដោយកងយោធា** ដែលពាក់ព័ន្ធនឹង

- **បទល្មើសយោធា** (ការរំលោភករណីយកិច្ចយោធា ការប្រព្រឹត្តិខុសវិន័យយោធា ។ល។) ឬ
- **បទល្មើសណាមួយដែលប៉ះពាល់ដល់ទ្រព្យសម្បត្តិកងទ័ព** ។

បទល្មើសធម្មតាផ្សេងៗទៀត (ដូចជា មនុស្សឃាត អំពើប្លន់ ។ល។) ដែលបង្កឡើងដោយកងយោធា គឺត្រូវនៅក្រោមយុត្តាធិការរបស់តុលាការខេត្ត-ក្រុង ។ តុលាការយោធា ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រសួងការពារជាតិ ខាងផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងផ្នែកបរិក្ខា ។

<u>ការអធិប្បាយៈ</u>

ដោយក្រសួងការពារជាតិជារឿយៗដើរតួជាភាគីមួយដែលពាក់ព័ន្ធនឹងទំនាស់ បញ្ហានេះ**បានលើកជាសំនួរថា តើគេអាចចាត់ទុកថា តុលាការមួយដែលពឹងផ្អែកលើក្រសួងនេះពិតជាមានឯករាជភាព** ដែរឬយ៉ាងណា?

[១] ពង្រាងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ត្រូវបានសរសេរឡើងដោយមានជំនួយពីប្រទេសបារាំង ហើយការធ្វើពង្រាងច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណី ធ្វើឡើងដោយមានជំនួយមកពីប្រទេសជប៉ុន ។ ក្រមនីតិវិធីទាំងពីរនេះ ត្រូវផ្តល់ការណែនាំដល់ចៅក្រមអំពីរបៀបរៀបចំការកាត់ក្តីប្រកបដោយភាពត្រឹមត្រូវ ។ **វិន័យសំរាប់ដំណើរការ ច្បាស់លាស់ធ្វើឱ្យ**ចៅក្រម**ពិបាកធ្វើសេចក្តីសម្រេចដោយអត្តនោម័ត**បាន ។

[២] នៅក្នុងឆ្នាំ២០០២ ចៅក្រមកម្ពុជាប្រមាណ ១៩០នាក់ បានដោះស្រាយករណីព្រហ្មទណ្ឌចំនួន ៩៣០៣ ករណី និងករណីរដ្ឋប្បវេណីចំនួន ២៦១៩៩ ករណី ។

ការព្រួយបារម្ភមួយទៀតនោះគឺថា តុលាការយោធា ត្រូវគោរពយ៉ាងតឹងរឹងចំពោះព្រំដែនយុត្តាធិការរបស់ខ្លួន ។ តុលាការយោធា **ពុំត្រូវបានអនុញ្ញាតឱ្យពង្រីកយុត្តាធិការរបស់ខ្លួនទៅលើជនស៊ីវិលឡើយ** ដូចតុលាការនេះ ធ្លាប់បានធ្វើកន្លងមកនៅក្នុងប្រទេសកម្ពុជា ទោះបីជាជនស៊ីវិលណាម្នាក់ បានបង្កការខូចខាតដល់កងទ័ព ក៏ដោយ ។

### ៣) អនាគតតុលាការពិសេសៈ
### តុលាការរដ្ឋបាល តុលាការគ្រួសារ តុលាការការងារ និងតុលាការពាណិជ្ជកម្មៈ

វិស័យច្បាប់មួយចំនួនមានភាពសាំញ៉ាំណាស់ ហើយថែមទាំងទាមទារនូវ**វិធាននីតិវិធីពិសេស** ដើម្បីដោះស្រាយបញ្ហាទាំងនេះឱ្យបានត្រឹមត្រូវទៀតផង ។ ឧទាហរណ៍ វិស័យទាំងនេះរួមមាន តុលាការរដ្ឋបាល តុលាការគ្រួសារ តុលាការការងារ និងតុលាការពាណិជ្ជកម្ម ។ ដើម្បីអនុវត្តច្បាប់ទាំងនេះឱ្យបានត្រឹមត្រូវ ទាមទារឱ្យមាន**ចំណេះដឹង និងការបណ្តុះបណ្តាលពិសេស** ។ ដូច្នេះ ដើម្បីដោះស្រាយបញ្ហាច្បាប់ទាំងនេះ ឱ្យបានត្រឹមត្រូវតាមធម្មតាវាមិនគ្រប់គ្រាន់ឡើយ ដោយគ្រាន់តែមានចំណេះដឹងអំពីក្រមរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌ ដែលពាក់ព័ន្ធតែប៉ុណ្ណោះនោះ ។ អាស្រ័យហេតុនេះ យើងមានបំណងចង់ឱ្យចៅក្រមជំនាញ **ដែលមានចំណេះដឹងជ្រៅជ្រះ** ដោះស្រាយរឿងក្តី និងទំនាស់ដែលពាក់ព័ន្ធ ។ ដោយមានបំណងដោះស្រាយបញ្ហាទាំងនេះ ប្រទេសជាច្រើនបានបង្កើតតុលាការជំនាញជាច្រើន ដើម្បីដោះស្រាយរឿងក្តីពិសេសទាំងនេះ ។

<u>ការអធិប្បាយៈ</u>

- ដោយមាត្រា១២៨ III CC និងមាត្រា២ III (ក) ICCPR បានចែងថា ការត្រួតពិនិត្យផ្នែកតុលាការទៅលើសកម្មភាពរដ្ឋបាល ត្រូវតែធានាឱ្យបាន នោះប្រទេសកម្ពុជាស្ថិតក្នុងដំណាក់កាលដែលត្រូវការ **តុលាការរដ្ឋបាល**មួយជាចាំបាច់ ។ ប្រជាពលរដ្ឋ ត្រូវមានលទ្ធភាពដាក់ពាក្យបណ្តឹងទៅតុលាការបែបនេះ ដោយប្តឹងតវ៉ាអំពីរាល់សកម្មភាពរដ្ឋបាលទាំងអស់ (ដូចជា ការហាមឃាត់មិនឱ្យធ្វើបាតុកម្មអហិង្សា បំរាមលើលិខិតអនុញ្ញាតសាងសង់ ថ្លៃឈ្នួលរដ្ឋបាលហួសហេតុ សេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដី[៣] ទៅលើវិវាទដីធ្លី សកម្មភាពក្រុមប្រឹក្សាឃុំ-សង្កាត់ វិញ្ញាបនបត្រសាលារដ្ឋ ជាដើម) ។ ការត្រួតពិនិត្យដោយឯករាជ្យទៅលើសកម្មភាពទាំងនេះ នឹងរួមចំណែកយ៉ាងខ្លាំងចំពោះការប្រយុទ្ធប្រឆាំងអំពើពុករលួយ ។
- ការបង្កើត**តុលាការគ្រួសារ** ដោយរួមបញ្ចូលទាំងវិធាននីតិវិធីពិសេសមួយសម្រាប់ទំនាស់ច្បាប់គ្រួសារ មិនទាន់មាននៅក្នុងបញ្ហានយោបាយនៅឡើយ ។ ក៏ប៉ុន្តែ ផ្នែកជំនាញនៃតុលាការមួយបែបនេះ ហាក់ដូចជាគួរតែបង្កើតឡើងឱ្យបាន ពីព្រោះស្ត្រី កុមារ និងជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ គឺជាកូនក្តីដែលមានភាពទន់ខ្សោយនៃប្រព័ន្ធតុលាការ ។ ពួកគេទាំងនេះ មិនត្រឹមតែត្រូវការការពារពិសេសប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង ត្រូវការនូវដំណោះស្រាយពិសេសផងដែរ (ដូចជា បញ្ហាតុលាការក្នុងការបណ្តេញប្តីដ៏ឃោរឃៅចេញពីផ្ទះឱ្យបានឆាប់រហ័ស) និងចៅក្រមដែលបានទទួលការបណ្តុះបណ្តាលជាពិសេស ដើម្បីស្វែងយល់ពីស្ថានភាពរបស់ពួកគេ និងស្តាប់ពួកគេ ដោយយកចិត្តទុកដាក់ទៀតផង ។

[៣] ច្បាប់ភូមិបាលថ្មី មានចែងរួចជាស្រេចហើយ អំពីនីតិវិធីដែលស្ទើរតែដូចតុលាការ នៅចំពោះមុខគណៈកម្មការសុរិយោដីដែលជាផ្នែកមួយនៃក្រសួងគ្រប់គ្រងដែនដី) ។

- **តុលាការការងារ** មានការចាំបាច់ក្នុងការដោះស្រាយវិវាទការងាររួម ដែលជួនកាលមានការពិបាកដោះស្រាយបំផុតដែលអាចឈានទៅដល់ការធ្វើកូដកម្ម និងការបញ្ឈប់ការងារខុសច្បាប់ ប្រសិនបើ គេពុំបានដោះស្រាយឱ្យបានត្រឹមត្រូវទេនោះ ។ បច្ចុប្បន្ននេះ **ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលបន្ទុកវិវាទការងាររួម** បានបំពេញគម្លាតនេះរហូតទាល់តែតុលាការការងារជំនាញដែលប្រព្រឹត្តិទៅបានល្អ ត្រូវបានបង្កើតឡើង[៤] ។
- **តុលាការពាណិជ្ជកម្ម** មិនទាន់ត្រូវបានបង្កើតឡើងនៅឡើយទេ ។ ប៉ុន្តែយោងតាមកាតព្វកិច្ចនៃកិច្ចសន្យាដែលប្រទេសកម្ពុជា ត្រូវបំពេញក្នុងការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ប្រទេសកម្ពុជា ចាំបាច់ត្រូវតែបង្កើតតុលាការបែបនេះ ។ តុលាការពាណិជ្ជកម្ម ដោះស្រាយបញ្ហាពាណិជ្ជកម្មតែម្យ៉ាងប៉ុណ្ណោះ ។ តុលាការនេះ ប្រហែលជាអាចនឹងត្រូវបង្កើតឡើងនៅក្នុងរាជធានីភ្នំពេញ ។ យុត្តាធិការភូមិសាស្ត្ររបស់តុលាការនេះ នឹងគ្របដណ្តប់លើប្រទេសកម្ពុជាទាំងមូល ។ **ពង្រាងច្បាប់**ស្តីពីការបង្កើត និងការប្រព្រឹត្តទៅរបស់តុលាការពាណិជ្ជកម្ម **មានរួចជាស្រេចហើយ**[៥] ។

## II) តុលាការថ្នាក់ទី ២: សាលាឧទ្ធរណ៍

យុត្តាធិការនៃសាលាឧទ្ធរណ៍ **គ្របដណ្តប់លើដែនដីទាំងមូលនៃប្រទេសកម្ពុជា** ។ តុលាការនេះ មានទីតាំងនៅរាជធានីភ្នំពេញ តុលាការនេះ ជំនុំជំរះរាល់ករណីទាំងអស់ដែលត្រូវបានប្តឹងឧទ្ធរណ៍មកពីសាលាដំបូង គឺតុលាការក្រុង-ខេត្ត និងតុលាការយោធា ។ សាលាឧទ្ធរណ៍ **ពិនិត្យទាំង អង្គច្បាប់ និងអង្គហេតុផង** ។ ដូច្នេះប្រសិនបើ ភាគីណាមួយ មិនពេញចិត្តចំពោះសាលក្រម ឬសេចក្តីសម្រេច របស់សាលាដំបូង ភាគីនោះមានសិទ្ធិដាក់ពាក្យបណ្តឹងឧទ្ធរណ៍ទៅសាលាឧទ្ធរណ៍តាមរយៈការិយាល័យក្រឡាបញ្ជីនៃតុលាការនេះ ដែលកាត់សេចក្តីលើសាលក្រម ឬសេចក្តីសម្រេចនោះ ។ នៅពេលនោះ សាលាឧទ្ធរណ៍ នឹងធ្វើ**ការវិនិច្ឆ័យទោសថ្មីមួយ**ដែលអាច**គោរពតាម កែប្រែ ឬទុកជាមោឃភាព** លើសាលក្រម ឬ សេចក្តីសម្រេចរបស់តុលាការជាន់ទាប ។ សាលាឧទ្ធរណ៍ប្រើនីតិវិធីកាត់ក្តី ស្រដៀងទៅនឹងនីតិវិធីរបស់តុលាការជាន់ទាបដែរ ។ អ្វីដែលខុសគ្នានោះគឺករណីនោះ ត្រូវបានជំនុំជំរះដោយចៅក្រមចំនួន **បីនាក់** ដែលហៅថា "ក្រុមប្រឹក្សាវិនិច្ឆ័យទោស" ហើយគេអាចធ្វើការស៊ើបអង្កេតបន្ថែម ដើម្បីរកដំណោះស្រាយចំពោះគម្លាតកត្តានានាដែលតុលាការថ្នាក់ទាបបានបន្សល់ទុក ។ ការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមរបស់តុលាការថ្នាក់ទាប មិនកំណត់លក្ខខណ្ឌទេ ។ ពុំមានច្បាប់ណាមួយចែងអំពីមូលបទដែលគេត្រូវការដើម្បីប្តឹងឧទ្ធរណ៍ ឬដាក់ពិន័យ ចំពោះការប្តឹងឧទ្ធរណ៍មិនសមហេតុផលឡើយ ។ ដូច្នេះ ពុំមានយន្តការណាមួយ ដែលត្រូវកាត់បន្ថយលំហូរនៃបណ្តឹងឧទ្ធរណ៍ដែលគ្មានមូលបទ ឬដែលមិនសមហេតុផល ចូលមកក្នុងសាលាឧទ្ធរណ៍ឡើយ ។

ការអធិប្បាយ:

ការឱ្យតុលាការថ្នាក់ទី២ ពិនិត្យមើលសេចក្តីសម្រេចរបស់សាលាដំបូង យ៉ាងហោចណាស់ ក៏ជួយប្រយុទ្ធនឹងអំពើពុករលួយក្នុងចំណោមចៅក្រមដែរ ។ ដើម្បីធ្វើឱ្យតុលាការថ្នាក់ទី២ អាចពិនិត្យមើលលើនីតិវិធី និង

[៤] សម្រាប់ពត៌មានលំអិតស្តីពីតួនាទី ការប្រព្រឹត្តិទៅ និងលក្ខន្តិកៈនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ព្រមទាំងសេចក្តីសម្រេចដែលក្រុមប្រឹក្សានេះ បានទទួលរួចហើយនោះ សូមមើលគេហទំព័រ: www.arbitrationcouncil.org

[៥] ពង្រាងធ្វើនៅខែសីហា ឆ្នាំ២០០៣ និងមានជូនអាននៅបណ្ណាល័យ ឱមរាជ្ជសាឱ្ខ នៃវិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ ។

សេចក្តីសម្រេចរបស់តុលាការថ្នាក់ទាប **វាមានសារៈសំខាន់ណាស់ដែលតុលាការថ្នាក់ទាប ត្រូវរក្សាឯកសារអំពីជំហានទីមួយៗនៃនីតិវិធីរបស់ពួកគេឱ្យបានសមស្របនៅក្នុងបញ្ជីបានយ៉ាងល្អ** ។ លើសពីនេះទៀត វាមានសារៈ-សំខាន់ដែលតុលាការទាំងនេះ ត្រូវពន្យល់ហេតុផលជាលាយល័ក្ខណ៍អក្សរចំពោះសេចក្តីសម្រេចរបស់ពួកគេ ។ បើមិនដូច្នោះទេ គេមិនអាចគ្រប់គ្រង សេចក្តីសម្រេចរបស់ខ្លួន និងមិនអាចពិនិត្យមើលថា តើសេចក្តីសម្រេចនេះស្ថិតក្រោមឥទ្ធិពលច្បាប់ និងអង្គហេតុ តែម្យ៉ាងឬក៏អត់? ការពិតដែលថា សាលាឧទ្ធរណ៍ត្រូវមានចៅក្រមចំនួនបីរូប នោះបង្កើតបាននូវឧបសគ្គមួយបន្ថែមទៀត **ចំពោះការប៉ុនប៉ងដើម្បីផ្តល់ប្រាក់សំណូកដល់តុលាការនេះ** ព្រោះថា វាជាការពិបាក និងត្រូវចំណាយប្រាក់ច្រើនដើម្បីផ្តល់សំណូកដល់ចៅក្រមទាំង បីនាក់ ហើយយ៉ាងហោចណាស់ យើងមានឱកាសច្រើនដែលថា ចៅក្រមម្នាក់ក្នុងចំណោមទាំងបីនាក់នេះអាចមានភាពស្មោះត្រង់ ។

### III) តុលាការថ្នាក់ទី៣ៈ តុលាការកំពូល

តុលាការកំពូលមានទីតាំងនៅក្នុងរាជធានីភ្នំពេញ ។ តុលាការនេះគឺជាសាលាឧទ្ធរណ៍ខ្ពស់ជាងគេបំផុតនៅក្នុងប្រទេស ហើយយុត្តាធិការរបស់តុលាការនេះគ្របដណ្តប់លើដែនដីនៃប្រទេសកម្ពុជាទាំងមូល ។

ចាប់តាំងពី ឆ្នាំ១៩៩៤ តុលាការកំពូលដែលមាន**ក្រុមចៅក្រមចំនួន ៩នាក់** បានវិនិច្ឆ័យទោសនូវ**បញ្ហាច្បាប់** លើករណីទាំងអស់ ដែលសាលាឧទ្ធរណ៍បានបញ្ជូនទៅ ។

នៅពេលបានទទួលបណ្តឹងសារទុក្ខលើកទី ២ ពីសាលាឧទ្ធរណ៍ ដែលតុលាការនោះមិនគោរពតាមសាលក្រមរបស់តុលាការកំពូល នោះ**ក្រុមចៅក្រមចំនួន ៩នាក់** ត្រូវវិនិច្ឆ័យទោសទាំងលើ**អង្គច្បាប់ និងអង្គហេតុផង** ។

បច្ចុប្បន្ន តុលាការកំពូលត្រូវបានដឹកនាំដោយប្រធានមួយរូប ហើយមានពីរផ្នែកគឺៈ ផ្នែករដ្ឋប្បវេណី និងសង្គម និងផ្នែកព្រហ្មទណ្ឌ ។ ផ្នែករដ្ឋប្បវេណី និងសង្គម ដោះស្រាយទំនាស់រដ្ឋប្បវេណី បញ្ហាអាពាហ៍ពិពាហ៍ គ្រួសារ និងបញ្ហារដ្ឋបាល ព្រមទាំងទំនាស់ការងារ និងពាណិជ្ជកម្ម ។ ផ្នែកព្រហ្មទណ្ឌ ដោះស្រាយតែបញ្ហាព្រហ្មទណ្ឌប៉ុណ្ណោះ ។

តុលាការកំពូល **ពុំមាន**អំណាចដើម្បីពិនិត្យលើច្បាប់នីតិបញ្ញត្តិ បទបញ្ញានីតិប្រតិបត្តិ ឬអំណាចដើម្បីធ្វើច្បាប់ផ្ទាល់ខ្លួនឡើយ ។ តុលាការនេះមានសិទ្ធិត្រឹមតែអនុវត្តច្បាប់ដែលផ្នែកនីតិបញ្ញត្តិបានតាក់តែងឡើងតែប៉ុណ្ណោះ ។ តុលាការកំពូលកំពុងបោះពុម្ពផ្សាយនូវទស្សនាវដ្តីប្រចាំត្រីមាសឈ្មោះ "ព្រឹត្តិប័ត្រសាលក្រមរបស់តុលាការកំពូល" ដែលមានបំណងដើម្បីប្រើប្រាស់ ជាគំរូសាលដីកាដែលតុលាការថ្នាក់ក្រោមត្រូវយកទៅអនុវត្តតាម ។ ប៉ុន្តែវាមិនទាន់ច្បាស់ថា តើសាលក្រមរបស់តុលាការមុនៗ អាចមានភ្ជាប់ទៅលើករណីស្រដៀងគ្នានៅពេលក្រោយមែន ដែរ ឬក៏អត់?

### ឃ) អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលៈ

អគ្គព្រះរាជអាជ្ញា គឺនៅអមតុលាការកំពូល ។ យោងតាមមាត្រា១៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ចែងថាមានតែព្រះរាជាអាជ្ញាប៉ុណ្ណោះ ដែលមានសិទ្ធិដាក់ពាក្យបណ្តឹងអាជ្ញានៅតុលាការផ្សេងៗបាន ។

ស្ថាប័នអគ្គព្រះរាជអាជ្ញា រួមមាន បីផ្នែក ជាចម្បងគឺ:

| **ការិយាល័យស៊ើបអង្កេត** | **ការិយាល័យព្រហ្មទណ្ឌ** | **ការិយាល័យរដ្ឋប្បវេណី** |
|---|---|---|
| ជួយនៅក្នុង<br>• ការធានានូវនីត្យានុកូលភាពនៃការស៊ើបអង្កេត<br>• ពិនិត្យមើលឯកសារនៃស្ថាប័ន ឬអង្គភាពស៊ើបអង្កេត ពាក់ព័ន្ធនឹងបទល្មើស និងការរំលោភច្បាប់.<br><br>ហើយធ្វើការស៊ើបអង្កេតដោយផ្ទាល់នៅពេលដែលចាំបាច់ ឬត្រូវធ្វើការស៊ើបអង្កេតបន្ថែម ។ | ជួយ និងទទួលខុសត្រូវ ចំពោះអគ្គ-ព្រះរាជអាជ្ញា នៅក្នុងការប្រើសិទ្ធិជាព្រះរាជអាជ្ញានៅក្នុងនីតិវិធីព្រហ្មទណ្ឌ ដូចជា<br>• ការពិនិត្យការចោទប្រកាន់នានា<br>• ការធ្វើសេចក្តីសន្និដ្ឋាន<br>• ការសួរចម្លើយ<br>• ការដើតួជាភាគីសំខាន់<br>• ការធ្វើការចោទប្រកាន់ ឬការដកការចោទប្រកាន់ ។ល។ | ជួយ និងទទួលខុសត្រូវ ចំពោះអគ្គ-ព្រះរាជអាជ្ញាក្នុងរឿងក្តីរដ្ឋប្បវេណីទាំងឡាយដែលប៉ះពាល់ដល់ផលប្រយោជន៍ជាតិ អនីតិជន ឬអស-មត្ថជន ។<br>ការិយាល័យនេះ ទទួលខុសត្រូវចំពោះការប្រមូលពតិមាន និង ភស្តុ-តាងសម្រាប់អគ្គព្រះរាជអាជ្ញា ដើម្បីធ្វើសេចក្តីសន្និដ្ឋាននៅពេលកាត់ទោស ។ |

<u>បញ្ហា:</u>

នៅក្នុងករណីដែល បទល្មើសព្រហ្មទណ្ឌត្រូវបានប្រព្រឹត្តដោយ**មន្ត្រីរាជការម្នាក់** ព្រះរាជអាជ្ញា អាចធ្វើការចោទប្រកាន់បានទាល់តែមានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ឬក្រសួងពាក់ព័ន្ធ ដែលមន្ត្រីនោះធ្វើការ ។ ព្រះរាជអាជ្ញា ត្រូវស្នើសុំការយល់ព្រមនោះតាមរយៈក្រសួងយុត្តិធម៌ (មាត្រា៥១ នៃច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការ) ។

នីតិវិធីនេះ ផ្តល់អំណាចឱ្យ**អង្គនីតិប្រតិបត្តិជាអ្នកសម្រេចចុងក្រោយថា ត្រូវធ្វើការចោទប្រកាន់ឬអត់**ទេវិញ ។ ឥទ្ធិពលនៃផ្នែកនីតិប្រតិបត្តិនេះ អាចរំលោភលើគោលការណ៍សមភាពចំពោះមុខច្បាប់ (មាត្រា៣១ II CC) ព្រមទាំងគោលការណ៍នៃការបែងចែកអំណាច (មាត្រា៥១ IV CC) ។

យោងតាមមាត្រា១៣៤ III និង IV CC ចែងថា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ទទួលខុសត្រូវចំពោះការតែងតាំងព្រះរាជអាជ្ញា និងការដាក់ទោសផ្នែកវិន័យដល់ពួកគេក្នុងករណីដែលពួកគេប្រព្រឹត្តិខុសឆ្គង ។

## ខ) <u>ស្ថាប័នដែលពិនិត្យតាមដាន និងជួយដល់តុលាការ:</u>

### I) ក្រសួងយុត្តិធម៌:

ក្រសួងយុត្តិធម៌ មានភារកិច្ចចម្បងៗដូចខាងក្រោម (សូមមើល មាត្រា៣ នៃអនុក្រិត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងយុត្តិធម៌ ចុះថ្ងៃទី ៧ ខែមេសា ឆ្នាំ ២០០០):

- ធានាប្រតិបត្តិការដ៏រលូនរបស់តុលាការក្នុងបញ្ហារដ្ឋប្បវេណី ព្រហ្មទណ្ឌ រដ្ឋបាល និងពាណិជ្ជកម្ម
- ពិនិត្យតាមដានការអនុវត្តន៍សាលក្រមតាមរយៈការធ្វើអធិការកិច្ចនៅតាមពន្ធនាគារ
- ធានាភាពរលូន និងភាពស៊ីសង្វាក់គ្នានៅក្នុងការធ្វើពង្រាងច្បាប់រដ្ឋប្បវេណី ច្បាប់ព្រហ្មទណ្ឌ ច្បាប់រដ្ឋបាល ច្បាប់ការងារ ច្បាប់ពាណិជ្ជកម្ម និងការអនុវត្តន៍ច្បាប់ទាំងនេះ និង
- រក្សាឯកសារព្រហ្មទណ្ឌ និងចេញផ្សាយសេចក្តីដកស្រង់នៃឯកសារទាំងនេះ

ការអធិប្បាយ:

ក្រសួងយុត្តិធម៌ **ពុំមានសមត្ថកិច្ចដើម្បីចេញសារាចរ ដែលផ្ដល់ការណែនាំដល់ចៅក្រមអំពីរបៀបសម្រេចលើរឿងក្ដី ជាទូទៅ ឬជាក់លាក់ទេ** ។ ម្យ៉ាងវិញទៀត នៅក្នុងអនុក្រិត្យដែលបានពោលមកខាងលើនេះ **ពុំមានមាត្រាណាមួយ ដែលផ្ដល់ឱ្យក្រសួងនូវសិទ្ធិក្នុងការណែនាំ ផ្ដល់ឱវាទ ឬចំលើយ ចំពោះសំនួរ របស់ចៅក្រមទាក់ទងនឹងរបៀបសម្រេចលើករណីណាមួយ ឬរបៀបបកស្រាយច្បាប់ណាមួយឡើយ** ។ ការអនុវត្តន៍ពីមុនដែលមានឥទ្ធិពលលើចៅក្រមតាមមធ្យោបាយបែបនោះ ពុំស្របច្បាប់ទៀតឡើយ បើគិតទៅតាមក្របខ័ណ្ឌនៃបទបញ្ញត្តិជាធរមាននោះ ។

## II) ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម:

មាត្រា១៣២ ដល់ ១៣៤ CC បានចែងថា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (SCM) ត្រូវជួយដល់ព្រះមហាក្សត្រ ក្នុងការធានានូវភាពឯករាជ្យរបស់តុលាការ ។ ស្ថាប័ននេះ ត្រូវធ្វើសំណើសម្រាប់**ការតែងតាំងចៅក្រម** (១៣៤ III CC) ។ លើសពីនេះទៀត ស្ថាប័ននេះ ត្រូវធ្វើសេចក្ដីសម្រេចអំពីការដាក់ទណ្ឌកម្មផ្នែកវិន័យទៅលើចៅក្រម (មាត្រា ១៣៣ ប្រយោគទី ២ CC និងមាត្រា១៣៤ IV CC) ។

ដូចមានចែងនៅក្នុងមាត្រា១៣៤ I CC **ច្បាប់ពិសេសមួយស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (ច្បាប់ SCM)** ត្រូវបានអនុម័តនៅក្នុងឆ្នាំ១៩៩៤ ។ ច្បាប់នេះ បានចែងថា សមាជិករបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវតែងតាំងដោយព្រះរាជក្រិត្យ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានសមាសភាពដូចតទៅ:

- ព្រះមហាក្សត្រ ប្រធាន
- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សមាជិក
- ប្រធានតុលាការកំពូល សមាជិក
- អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល សមាជិក
- ប្រធានសាលាឧទ្ធរណ៍ សមាជិក
- ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ សមាជិក
- ចៅក្រមបីរូប ជ្រើសរើសដោយចៅក្រម សមាជិក
- ចៅក្រមបីរូប ជ្រើសរើសដោយចៅក្រមដែរ សមាជិកបំរុង ។ សមាជិកទាំងនេះជំនួសសមាជិកពេញសិទ្ធិ ដែលអវត្តមាន (ចៅក្រមដែលត្រូវបានជ្រើសតាំង)

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនេះ បានកោះប្រជុំជាលើកដំបូងនៅថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ១៩៩៧ ។

តួនាទីមួយក្នុងចំណោមតួនាទីចម្បង២របស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គឺត្រូវធានានូវការប្រព្រឹត្តិទៅដ៏រលូនរបស់តុលាការ ។

ក្នុងន័យនេះ មាត្រា១១ នៃច្បាប់ SCM បានចែងថា SCM មានតួនាទីក្នុង"ការសម្រេច និងស្នើសុំព្រះមហាក្សត្រឱ្យតែងតាំង ផ្ទេរ បញ្ជូន ឈប់សំរាក ពិពណ៌នាអំពីភារកិច្ច និងការបណ្តេញចេញនូវចៅក្រម ឬព្រះរាជអាជ្ញា" ។

មាត្រា១០ នៃច្បាប់ SCM បានចែងបន្ថែមទៀតថា រាល់ច្បាប់ និងពង្រាងច្បាប់ដែលបានស្នើឡើងទាក់ទងទៅនឹងការរៀបចំ និងការប្រព្រឹត្តិទៅរបស់តុលាការ តម្រូវឱ្យមានការពិគ្រោះយោបល់ជាមួយ SCM ។ SCM គួរផ្តល់មតិរបស់ខ្លួន ក្នុងរយៈពេល ៣០ថ្ងៃ ឬក្នុងរយៈពេល ១០ថ្ងៃ ក្នុងករណីបន្ទាន់ ចាប់ពីថ្ងៃដែលបានទទួលសេចក្តីស្នើច្បាប់ ឬពង្រាងច្បាប់ ដែលបានស្នើឡើងពីក្រសួងយុត្តិធម៌ ។

<u>ការអធិប្បាយ:</u>

SCM គឺជា**ស្ថាប័នដ៏មានអំណាចមួយ** ដែលមានឥទ្ធិពលយ៉ាងខ្លាំងទៅលើចៅក្រម ទាក់ទងនឹង**ការតែងតាំង ការតម្លើងឋានន្តរស័ក្តិ វិន័យ និងបណ្តេញចេញពីតំណែង ដែលជាបញ្ហាដែលតែងតែប៉ះពាល់ដល់ភាពឯករាជ្យរបស់ចៅក្រម**[៦] ។

ជាគោលការណ៍ វាជាការល្អណាស់ ដែលយើងត្រូវឱ្យស្ថាប័ននេះ មានឯករាជភាពជាផ្លូវការពីអំណាចផ្សេងទៀតណាមួយ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមឯករាជ្យ ជាឧទាហរណ៍មាននៅក្នុងប្រទេសជាច្រើននៃទ្វីបអឺរ៉ុប ដូចជា ប្រទេសអេស្បាញ និងអ៊ីតាលី ព្រមទាំង នៅក្នុងប្រទេសអតីតប្លុកលោកខាងកើតមួយចំនួនដែលទទួលយកលទ្ធិប្រជាធិបតេយ្យ បន្ទាប់ពីការដួលរលំនៃរបបគ្រប់គ្រងបែបកុម្មុយនីស្ត ។ ដើម្បីពង្រឹងស្ថាប័ននេះឱ្យបានរឹងមាំដោយខ្លួនឯង គេចាំបាច់ត្រូវតែធានាថា **សមាជិកនៃស្ថាប័ននេះត្រូវបាន ជ្រើសរើសជាសាធារណៈ និងប្រកបដោយតម្លាភាព** ។

ម្យ៉ាងវិញទៀត សមាជិកទាំងនេះមិនគួរត្រូវបាន ជ្រើសរើសដោយចៅក្រមខ្លួនឯងតែប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំង ដោយអ្នកធ្វើច្បាប់មកពីគ្រប់គណបក្សទាំងអស់ ដែលមានអាសនៈនៅក្នុងសភាជាតិ និងដោយគណៈ-មេធាវីទៀតផង ។

នៅក្នុងករណីណាក៏ដោយ សំខាន់ជាងគេ បំផុតនោះគឺថា ស្ថាប័ននេះមិនទទួលរងឥទ្ធិពលពីសំណាក់ផ្នែកនីតិប្រតិបត្តិ ហើយយ៉ាងហោចណាស់ ឥទ្ធិពលរបស់នីតិប្រតិបត្តិចុះខ្សោយច្រើន ។ **ពង្រាងច្បាប់ថ្មីមួយស្តីពីវិសោធនកម្មច្បាប់ SCM**[៧] ព្យាយាមកែលំអឯករាជភាពរបស់ SCM ពិតប្រាកដ ប៉ុន្តែ នៅតែមានចំណុចចន្លោះប្រហោងជាច្រើន ទាក់ទិននឹងការតែងតាំងសមាជិក SCM ខ្លួនឯង ។

[៦] ជាឧទាហរណ៍ នៅខែមីនា ឆ្នាំ២០០៤ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានដកចៅក្រមតុលាការក្រុង ២រូប លោក ហ៊ីង ធីឫទ្ធិ និង លោក អ៊ុន បុណ្ណា ចេញពីគណៈវិនិច្ឆ័យ ៣ថ្ងៃក្រោយពី ចៅក្រមទាំងពីរ បានសំរេចដោះលែងជនសង្ស័យដោយគ្មានភស្តុតាងគ្រប់គ្រាន់ ថាជាឃាតករដែលបានសំលាប់លោក ជា វិជ្ជា ចៅក្រមទាំងពីរ មិនបានទទួលនូវឱកាសយុត្តិធម៌មួយ នៅក្នុងការដឹងអំពីការចោទប្រកាន់ទៅលើពួកគេ ឬឱកាសមានវត្តមាន និងបានការពារខ្លួន នៅពេលដំណើរការនីតិវិធីជំនុំជំរះរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នោះទេ ។ គោលការណ៍មួយនៃតុលាការឯករាជ្យ គេត្រូវទុកការដកមុខតំណែងចៅក្រម ជាវិធានចុងក្រោយបង្អស់ សំរាប់តែករណីដែលចៅក្រម ជាបុគ្គលអសមត្ថភាព ឬត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋមួយ ឬបានប្រព្រឹត្តបំពានក្រមសីលធម៌ ដែលករណីទាំងនេះមានលក្ខណៈធ្ងន់ធ្ងរដែលបង្ហាញឱ្យឃើញថា ចៅក្រមមិនសមធ្វើជាចៅក្រម ទៀតទេ ។

[៧] អត្ថបទចុងក្រោយបំផុត ធ្វើនៅខែមេសា ឆ្នាំ២០០២ និងមិនទាន់បានអនុម័តដោយរដ្ឋសភានៅឡើយទេ ។

## ? សំនួរសិក្សាទី ១

ចូរមើលក្រាហ្វិកស្តីពីទំនាក់ទំនងរវាងតុលាការ និងអំណាចផ្សេងទៀត ( មើលទំព័រទី ៥) ។

តាមក្រាហ្វិកនេះ អំណាចនីតិប្រតិបត្តិ មានឥទ្ធិពលលើការតែងតាំងចៅក្រមដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ក) តើករណីនេះស្របនឹងគោលការណ៍នៃការបែងចែកអំណាចដែរឬទេ?

ខ) តើឥទ្ធិពលនៃអង្គនីតិប្រតិបត្តិដែលបានបញ្ជាក់ខាងលើ មានគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះ?

## ? សំនួរសិក្សាទី ២

ហេតុអ្វីបានជាសាលក្រមកម្ពុជាទាំងអស់ មានឃ្លាផ្តើមថា "តាងនាមប្រជារាស្ត្រខ្មែរ"?

ចូរផ្តល់នូវហេតុផលចំពោះចំលើយរបស់អ្នក និងដកស្រង់នូវមាត្រានានាដែលពាក់ព័ន្ធ ពីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

## ? សំនួរសិក្សាទី ៣

តើចាំបាច់បង្កើតឱ្យមានតុលាការរដ្ឋបាលនៅប្រទេសកម្ពុជាដែរឬទេ?

ចូរផ្តល់ហេតុផលចំពោះចំលើយរបស់អ្នក និងដកស្រង់នូវមាត្រាដែលពាក់ព័ន្ធពីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

## ? សំនួរសិក្សាទី ៤

ចូរមើលមាត្រា៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (ច្បាប់ SCM) ហើយធ្វើការប្រៀបធៀបជាមួយមាត្រា៧ថ្មី នៃពង្រាងច្បាប់ស្តីពីវិសោធនកម្មលើច្បាប់ SCM ( មើលឧបសម្ព័ន្ធ) ។

តើអ្នកគិតថា អ្វីជាគោលបំណងនៃវិសោធនកម្មដែលស្នើមកនោះ?

## ? សំនួរសិក្សាទី ៥

ចូរចាត់ប្រភេទឱ្យមុខងារនៃបុគ្គលដែលមានរៀបរាប់ខាងក្រោម ចូលក្នុងៈ

អំណាចនីតិបញ្ញត្តិ: តើគាត់កំពុង ធ្វើការជំរុញ និងអនុវត្តច្បាប់?

អំណាចតុលាការ: តើគាត់កំពុងតែធ្វើការត្រួតពិនិត្យការអនុវត្តន៍ច្បាប់លើរឿងក្តីណាមួយ ដែរឬទេ?

អំណាចនីតិប្រតិបត្តិ: តើគាត់កំពុងធ្វើការអនុម័តវិធានច្បាប់ដែលមានលក្ខណៈចាប់បង្ខំ ដែរឬទេ?

១- ជំនួយការក្រលាបញ្ជី

២- អគ្គលេខាធិការនៃសភាជាតិ

៣- ព្រះរាជអាជ្ញា

៤- ប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់

៥- ប្រធានគណៈមេធាវី

៦- នាយកនៃ "វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ"

៧- ប្រធានពន្ធនាគារ

៨- ចៅក្រមស៊ើបអង្កេត

៩- ប្រធានគណៈវិនិច្ឆ័យ

១០- អធិការការងារនៃក្រសួងការងារក្នុង ការដោះស្រាយវិវាទការងារ

១១- ប្រធានសមាគមនៃបណ្ដាម្ចាស់រោងចក្រ

# ក្រុមប្រឹក្សាធម្មនុញ្ញ[៨]




## ក) សេចក្តីផ្តើម:

ក្រុមប្រឹក្សាធម្មនុញ្ញ មិនត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៣ នៅពេលដែលរដ្ឋធម្មនុញ្ញបានចូលជាធរមានឡើយ ។ គេបានប្រើពេលអស់ជាង ៥ឆ្នាំ រហូតដល់ ឆ្នាំ១៩៩៨ ដើម្បីតែងតាំងសមាជិកទាំង ៩រូប របស់ក្រុមប្រឹក្សាធម្មនុញ្ញ ពីព្រោះ ស្ថាប័នតែងតាំងមួយ គឺឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មិនបានកោះប្រជុំមុនឆ្នាំ១៩៩៧ ។

ទោះបីជា ភារកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបកស្រាយរដ្ឋធម្មនុញ្ញ និងពិនិត្យមើលធម្មនុញ្ញភាពនៃច្បាប់ក៏ដោយ ក្រុមប្រឹក្សាធម្មនុញ្ញ គឺជាស្ថាប័ន**ដែលមានលក្ខណៈនយោបាយ**ខ្លាំងជាងស្ថាប័នតុលាការ ។ ក្រុមប្រឹក្សាធម្មនុញ្ញ ជា**អង្គការធម្មនុញ្ញឯករាជ្យ**មួយ ហើយដូចនៅក្នុងប្រទេសផ្សេងទៀតជាច្រើនដែរ[៩] - ក្រុមប្រឹក្សាធម្មនុញ្ញ មិនមែនជាដំណាក់កាលទីបួននៃតុលាការទេ ។ ដូច្នេះហើយ ទើបគេហៅថា "ក្រុមប្រឹក្សាធម្មនុញ្ញ" គឺមិនមែនជា "តុលាការធម្មនុញ្ញ" ទេ ។

ក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យមើលធម្មនុញ្ញភាពនៃសេចក្តីព្រាងច្បាប់ និងច្បាប់ដែលត្រូវបាន ពាក់តែងដោយអង្គនីតិបញ្ញត្តិ ( មាត្រា១៤០ និង ១៤១ CC )




ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមើលធម្មនុញ្ញភាពនៃសកម្មភាពផ្នែករដ្ឋបាលរបស់អង្គនីតិប្រតិបត្តិ
មាត្រា១៩ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

[៨] ព័ត៌មានបន្ថែមសូមមើល: www.ccc.gov.kh
[៩] ឧទាហរណ៍ នៅប្រទេស អាល្លឺម៉ង់ "តុលាការធម្មនុញ្ញសហព័ន្ធ" គឺជាស្ថាប័នរដ្ឋបាលកំពូលផ្នែកយុត្តិធម៌ និងយុត្តាធិការ ។

ការពិតដែលថា ក្រុមប្រឹក្សាធម្មនុញ្ញ មិនប្រតិបត្តិការជាតុលាការពិតប្រាកដមួយនោះ ត្រូវបានបញ្ជាក់ច្បាស់ផងដែរ ដោយមាត្រា១៣៨ CC ដែលចែងថា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មិនចាំបាច់ត្រូវការក្រឹត្យ-ច្បាប់ ឬត្រូវតែជាសមាជិកនៃប្រព័ន្ធតុលាការឡើយ ។ ពួកគេ អាចមានបរិញ្ញាប័ត្រផ្នែករដ្ឋបាល ការទូត និងសេដ្ឋកិច្ច ។ ប៉ុន្តែ ពួកគេត្រូវតែជាអ្នកមានអាជីព ដែលមានបទពិសោធន៍ទៅតាមវិស័យរៀងៗខ្លួនដោយមានការអនុវត្តន៍ ១៥ឆ្នាំ យ៉ាងតិច ( មាត្រា៣ I ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ LOFCC ចុះនៅខែមីនា ឆ្នាំ ១៩៩៨) ។

ក្នុងកំឡុងពេលបំពេញអាណត្តិរបស់ខ្លួន សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មិនអាចកាន់តំណែងផ្សេងទៀតបានទេ ដូចជា តំណែងនៅក្នុងរដ្ឋាភិបាល សភាជាតិ គណបក្សនយោបាយ ឬសហជីពកម្មករ ។ល។ ហើយត្រូវតែលាឈប់ពីអាជីពវិជ្ជាជីវៈទាំងអស់ ។ ( មាត្រា១៣៩ CC និងមាត្រា៥ LOFCC) ។

ក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិក ៩នាក់ ដែលត្រូវបានតែងតាំងដោយស្ថាប័នផ្សេងៗគ្នា ។

> មាត្រា១៣៧ I ៣ CC:
>
> សមាជិក បី(៣)រូប ត្រូវតែងតាំងដោយព្រះមហាក្សត្រ បី(៣)រូប ត្រូវតែងតាំង ដោយរដ្ឋសភា និង បី(៣)រូប ទៀតត្រូវតែងតាំង ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ព្រះមហាក្សត្រ រដ្ឋសភា និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមម្នាក់ៗតែងតាំងសមាជិក ១រូប សំរាប់ ៣ឆ្នាំ ១រូប សំរាប់ ៦ ឆ្នាំ និង ១រូបទៀត សំរាប់ ៩ឆ្នាំ ( មាត្រា៣៨ II, III និង IV LOFCC)[១០] ។

## ខ) មុខងារនៃក្រុមប្រឹក្សាធម្មនុញ្ញ៖

ដើម្បីការពាររដ្ឋធម្មនុញ្ញ ( មាត្រា១៣៦ I CC) ក្រុមប្រឹក្សាធម្មនុញ្ញ មានមុខងារចម្បងពីរគឺៈ ទី១ ពិនិត្យធម្មនុញ្ញភាពនៃសេចក្តីព្រាងច្បាប់ ច្បាប់ជាធរមាន និងសកម្មភាពរដ្ឋបាល និងទី២ សម្រេចសេចក្តីលើវិវាទនៃការបោះឆ្នោត ។ **ក្រុមប្រឹក្សា មិនមានសិទ្ធិដើម្បីធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញទេ ( មាត្រា១៥១ CC និង មាត្រា១៥ LOFCC)!**




[១០] ការតែងតាំងសមាជិកដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម SCM ចោទជាសំនួរឡើងចំពោះ អព្យាក្រិត្យភាព និងឯករាជភាពរបស់សមាជិកក្រុម-ប្រឹក្សាធម្មនុញ្ញ ក៏ដូចជា SCM ផ្ទាល់ ពុំមែនជាស្ថាប័នដែលត្រូវបានបោះឆ្នោតឡើង ជាសាធារណៈ និងមានតម្លាភាពនៅឡើយទេ ។

## I) ធម្មនុញ្ញភាពនៃច្បាប់

### ១) នីតិវិធីនៃការពិនិត្យ :

ដើម្បីផ្តើមគំនិតលើនីតិវិធីនៃការពិនិត្យជាមួយក្រុមប្រឹក្សាធម្មនុញ្ញ បុគ្គល ឬស្ថាប័នខាងក្រោមនេះ អាចធ្វើការស្នើសុំទៅក្រុមប្រឹក្សាធម្មនុញ្ញ (មាត្រា១៤០ I, ១៤១ I ១ CC និងមាត្រា១៧, ១៨ I និង១៩ LOFCC):




<u>ឧទាហរណ៍:</u>

មានពេលមួយ ពលរដ្ឋកម្ពុជាម្នាក់ ត្រូវការការបកស្រាយនូវ មាត្រា៣៨ នៃច្បាប់ស្តីពីគណបក្សនយោបាយ ដែលចែង អំពីការដាក់ពិន័យចំពោះគណបក្សដែលមិនគោរពតាមច្បាប់នេះ ។ មាត្រា៣៨ នៃច្បាប់ស្តីពីគណបក្សនយោបាយ មិនបានចែងច្បាស់ថា តើនរណាអាចដាក់ការដាក់ពិន័យនេះពិតប្រាកដ តើអាជ្ញាធរ ឬតុលាការឡើយ ។

ពលរដ្ឋនោះបានសរសេរថ្វាយព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ព្រះប្រធានរដ្ឋសភាស្នើសុំទ្រង់សំណូមពរទៅក្រុមប្រឹក្សាធម្មនុញ្ញឱ្យធ្វើការបកស្រាយ ។ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ទ្រង់បានសរសេរពាក្យបណ្តឹងជំនួសពលរដ្ឋរូបនោះ ហើយក្រោយមក ត្រូវបានសម្រេចថា គេត្រូវតែមើលមាត្រា៣៨ នៃច្បាប់ស្តីពីគណបក្សនយោបាយរបៀបនេះថា មានតែតុលាការប៉ុណ្ណោះ អាចដាក់ការដាក់ពិន័យទៅលើគណបក្សបាន ពីព្រោះមាត្រា១២៨ II និង ១២៩ II CC ចែងថា មានតែចៅក្រមប៉ុណ្ណោះ ដែលអាចវិនិច្ឆ័យទោសបាន[១១] ។

[១១] សេចក្តីសំរេច ធ្វើនៅថ្ងៃទី ៥ ខែសីហា ឆ្នាំ២០០២ នៅក្នុងរឿងក្តីលេខ ០៤៩/០០៣/២០០២

ក្រោយពីបានទទួលពាក្យបណ្តឹង ក្រុមប្រឹក្សាធម្មនុញ្ញជាធម្មតា ត្រូវធ្វើសេចក្តីសម្រេចក្នុងរយៈពេល ៣០ថ្ងៃ (មាត្រា១៤០ II ២ CC និងមាត្រា២២ I LOFCC) នៅក្នុងករណីបន្ទាន់ក្នុងរយៈពេល ៨ថ្ងៃ ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញយ៉ាងតិច ៧នាក់ ត្រូវកោះប្រជុំដើម្បីពិភាក្សាលើករណីនោះ (មាត្រា១៤ II LOFCC) និងដើម្បីធ្វើសេចក្តីសន្និដ្ឋាន ។

មិនមានការបើកសវនាការជាសាធារណៈទេ ក៏ប៉ុន្តែក្រុមប្រឹក្សាធម្មនុញ្ញ អាចអញ្ជើញជំនាញការឱ្យជួយបំភ្លឺលើបញ្ហា ដែលពាក់ព័ន្ធបាន (មាត្រា ២១ I LOFCC) ។

<u>ឧទាហរណ៍</u> :

ក្រោយពីការបោះឆ្នោតជាតិលើកទី៣ ដែលបានប្រព្រឹត្តទៅនៅក្នុងខែកក្កដា ឆ្នាំ២០០៣ ព្រះមហាក្សត្រទ្រង់បានសំណូមពរឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ផ្តល់យោបល់ថ្វាយព្រះអង្គថា តើព្រះអង្គត្រូវកោះប្រជុំសភាលើកទី១ ស្របទៅតាមមាត្រា៨២ I CC ដែរឬអត់ ។

ក្រុមប្រឹក្សាធម្មនុញ្ញ បានស្វែងរកជំនាញការពីមេធាវីម្នាក់ដែលបានសន្និដ្ឋានថា ព្រះមហាក្សត្រមិនមានសិទ្ធិស្នើសុំយោបល់ប្រឹក្សាពីក្រុមប្រឹក្សាធម្មនុញ្ញទេ ប៉ុន្តែ ព្រះអង្គ អាចសំណូមពរនូវការពិនិត្យមើលធម្មនុញ្ញភាពនៃច្បាប់បាន ។

ទោះបីជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេចថា

- ព្រះមហាក្សត្រ មានសិទ្ធិស្នើសុំការបកស្រាយរដ្ឋធម្មនុញ្ញ និង
- ត្រូវតែកោះប្រជុំសភាជាតិលើកទី១ ពីព្រោះ ព្រះរាជវត្តមានរបស់ព្រះអង្គមានសារៈសំខាន់សំរាប់ជាតិទាំងមូល និងសំរាប់ស្ថាប័នកំពូលនេះ និងដោយហេតុថា កាលពីអតីតកាល អធិបតីភាពរបស់ព្រះមហាក្សត្រតែងតែផ្តល់កិត្តិយសចំពោះសម័យប្រជុំលើកទី ១ នេះ ។

សេចក្តីសម្រេចនេះ ទាមទារនូវ**សម្លេងភាគច្រើនដាច់ខាតនៃសមាជិកទាំង ៩រូប** (មាត្រា២២ III LOFCC) និងត្រូវតែ**ធ្វើលាយលក្ខណ៍អក្សរ** និង**មានហេតុផល** (មាត្រា២២ I និង V LOFCC) ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ គឺជាសេចក្តីសម្រេច**ស្ថាពរ** (មាត្រា១៤២ II CC) និងមាន**អានុភាពជាប់កាតព្វកិច្ចសម្រាប់អំណាចរដ្ឋទាំងអស់** (មាត្រា២៣ LOFCC) ។ ដើម្បីធានាថា អំណាចរដ្ឋទាំងអស់ដឹងអំពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា សេចក្តីសម្រេចទាំងនេះ ត្រូវតែចុះផ្សាយនៅក្នុង "សារព័ត៌មានផ្លូវការ" (មាត្រា២៤ I LOFCC) ហើយប្រធានរដ្ឋសភា ត្រូវជូនដំណឹងដល់អ្នកធ្វើច្បាប់ទាំងអស់ ដល់នាយក-រដ្ឋមន្ត្រី សមាជិករដ្ឋាភិបាលទាំងអស់ និងប្រធានតុលាការកំពូល ត្រូវជូនដំណឹងដល់តុលាការទាំងអស់ ។

### ២) កម្មវត្ថុនៃការពិនិត្យ:

សមត្ថកិច្ចត្រួតពិនិត្យរបស់ក្រុមប្រឹក្សាធម្មនុញ្ញ គ្របដណ្តប់លើសេចក្តីព្រាងច្បាប់ ច្បាប់ជាធរមាន ព្រមទាំងបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា និងព្រឹទ្ធសភា ។

វាហាក់បីដូចជាថា វាមិនមានសមត្ថកិច្ច ដើម្បីពិនិត្យធម្មនុញ្ញភាពនៃៈ

- **សេចក្តីសំរេចរដ្ឋបាល** (ដែលក្រោយមកត្រូវបានបំលែងជាសកម្មភាពរដ្ឋបាល ដូចជា ការដាក់បំរាម លើបាតុកម្ម ការចាប់ខ្លួនបាតុករអហិង្សា ការបដិសេធ មិនឱ្យបើកការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ។ល។) ឬ
- **ប្រកាស ឬ អនុក្រឹត្យ** ផងទេ ។

ប៉ុន្តែ រឿងនេះមិនពិតទេ ដោយហេតុថា រាល់សេចក្តីសំរេចរដ្ឋបាល ព្រមទាំងប្រកាស និងអនុក្រឹត្យ ដែលជាមូលដ្ឋានស្របច្បាប់នៃសកម្មភាពរដ្ឋបាល ត្រូវតែស្របតាមរដ្ឋធម្មនុញ្ញ (មាត្រា១៥០ II CC) ។ ហើយដើម្បីធានាធម្មនុញ្ញភាពនៃសេចក្តីសំរេចរដ្ឋបាល អ្នកទទួលដែលត្រូវសេចក្តីសំរេចរដ្ឋបាលដាក់កាតព្វកិច្ចលើខ្លួន មានសិទ្ធិទទួលបានការពិនិត្យឡើងវិញដោយតុលាការលើសេចក្តីសំរេចទាំងនេះ (មាត្រា៣៨ VIII និង ៣៩ CC) និងមានសិទ្ធិប្តឹងសុំមោឃភាព ។ ប្រជាពលរដ្ឋ (ដើមបណ្តឹង) ត្រូវតែអះអាងថា សិទ្ធិជាបុគ្គលផ្ទាល់ខ្លួន ត្រូវបានរំលោភដោយសេចក្តីសំរេចរដ្ឋបាលដែលស្ថិតនៅក្រោមបណ្តឹង ។ គេតែងតែត្រូវបានផ្តល់ភាពក្លាហាន ដើម្បីដាក់ពាក្យបណ្តឹងជានិច្ច ពីព្រោះ គេអាចអះអាងជានិច្ចកាលថា សេចក្តីសំរេចរដ្ឋបាលដែលត្រូវបានគេប្តឹង បានដាក់កំហិតយ៉ាងហោចណាស់លើសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ ក្នុងការធ្វើបណ្តឹងដោយសេរី (មាត្រា៣២ I CC) ។

ជាយថាហេតុ ដោយការប្រើអស់លទ្ធភាពនូវតុលាការគ្រប់កំរិត ប្រជាពលរដ្ឋ នឹងអាចដាក់ជូននូវ សេចក្តីសំរេចរដ្ឋបាល ប្រកាស ឬអនុក្រឹត្យផ្សេងៗដែលត្រូវបានគូសបញ្ជាក់ ទៅក្រុមប្រឹក្សាធម្មនុញ្ញ តាមរយៈតុលាការកំពូល ។

> មាត្រា១៩ LOFCC:
>
> បុគ្គលដែលជាប់ពាក់ព័ន្ធក្នុងរឿងក្តីណាមួយ ហើយរឿងក្តីនោះឡើងដល់តុលាការ បុគ្គលនោះអាចលើកអំពីអធម្មនុញ្ញភាពនូវបទប្បញ្ញត្តិណាមួយនៃច្បាប់ ឬសេចក្តីសំរេចរបស់ស្ថាប័ននានា ដែលគេអះអាងថាប៉ះពាល់ដល់សិទ្ធិសេរីភាពជាសារវន្តណាមួយរបស់គេជូនតុលាការបាន ។
>
> បើយល់ឃើញថា ការលើកឡើងនេះ មានមូលដ្ឋានគ្រប់គ្រាន់ តុលាការត្រូវលើកករណីនេះទៅតុលាការកំពូលក្នុងរយៈពេល ១០ថ្ងៃ យ៉ាងយូរ ។
>
> តុលាការកំពូល ត្រូវចាត់ការពិនិត្យ និងប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ១៥ថ្ងៃយ៉ាងយូរ លើកលែងតែ តុលាការកំពូលយល់ឃើញថា ពាក្យប្តឹងតវ៉ានោះ មិនអាចទទួលបាន។

ជាអកុសល រហូតដល់បច្ចុប្បន្ននេះ មិនមានពាក្យប្តឹងតវ៉ាបុគ្គលណាមួយចេញពីតុលាការកំពូលបានទៅដល់ក្រុមប្រឹក្សាធម្មនុញ្ញឡើយ[១២] ។

[១២] ប្រភពព័ត៌មានមកពី ឯកឧត្តម សឺន ស៊ូប៊ែរ្តិ៍ សមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញ នៅថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០០៤

### ៣) ផលវិបាកផ្លូវច្បាប់នៃសេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ :

ក្រុមប្រឹក្សាធម្មនុញ្ញ ចេញសាលក្រមរបស់ខ្លួនផ្អែកលើបញ្ហានានាដែលពាក់ព័ន្ធនឹងរដ្ឋធម្មនុញ្ញ ដែលជាប្រភពច្បាប់ដ៏ខ្ពស់បំផុត នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ។

ក្រុមប្រឹក្សាធម្មនុញ្ញះ

- **បកស្រាយ** ពាក្យពេចន៍មិនច្បាស់លាស់ ឬដែលមានន័យផ្ទុយគ្នា នៅក្នុងរដ្ឋធម្មនុញ្ញ និងដែលមានផលវិបាកដល់ច្បាប់នានាដែលពាក់ព័ន្ធ ត្រូវតែកែប្រែដោយរដ្ឋសភា (មាត្រា១៥១ II CC)
- **ប្រកាសថា** ច្បាប់ ឬសេចក្តីព្រាងច្បាប់ **ស្របតាមរដ្ឋធម្មនុញ្ញ ឬមិនស្របតាមរដ្ឋធម្មនុញ្ញ** ។ បើសិនជា ច្បាប់ ឬសេចក្តីព្រាងច្បាប់ទាំងនេះ មិនស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ ឬសេចក្តីព្រាងច្បាប់នោះ មិនអាចត្រូវបានប្រកាសឱ្យប្រើ ឬអនុវត្តបានឡើយ (មាត្រា១៤២ CC) ។

<u>ឧទាហរណ៍</u> :

មាត្រា៣ នៃសេចក្តីព្រាងច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ចែងថា ទង្វើដែលស្របតាម "ប្រពៃណីល្អរបស់ខ្មែរ" មិនអាចចាត់ទុកថា ជាអំពើហិង្សាក្នុងគ្រួសារបានទេ ។

ប៉ុន្តែ តើ "ប្រពៃណីល្អរបស់ខ្មែរ" ជាអ្វី? ប្រហែលជា ប្រជាជនកម្ពុជាស្ទើរតែគ្រប់គ្នា នឹងឱ្យនិយមន័យនៃពាក្យនេះដោយខ្លួនឯង ។ អ្នកធ្វើច្បាប់ បានប្រើពាក្យមិនច្បាស់ ហើយតាមរយៈពាក្យមិនច្បាស់លាស់នេះ ពួកគេ បានរំលោភលើគោលការណ៍នៃការបែងចែកអំណាច (មាត្រា៥១ IV CC) ពីព្រោះថា ពួកគេ (ក្នុងនាមជាអង្គនីតិបញ្ញត្តិ) មិនអាចទុកឱ្យអង្គនីតិប្រតិបត្តិ ដូចជា អាជ្ញាធរ ឬប្រព័ន្ធយុត្តិធម៌ គឺតុលាការបំពេញពាក្យមិនច្បាស់នេះបានឡើយ ។

នៅក្នុងករណីនេះ ក្រុមប្រឹក្សាធម្មនុញ្ញគួរប្រកាសថា មាត្រានេះមិនស្របតាមរដ្ឋធម្មនុញ្ញ ។ មិនតែប៉ុណ្ណោះ ក្រុមប្រឹក្សានេះ ក៏អាចផ្តល់អនុសាសន៍បន្ថែមដល់អ្នកធ្វើច្បាប់ អំពីវិធីបកស្រាយមាត្រានេះតាមរដ្ឋធម្មនុញ្ញផងដែរ ។ ប៉ុន្តែ វាជាភារកិច្ចរបស់រដ្ឋសភា ដែលត្រូវធ្វើវិសោធនកម្មមាត្រានេះ មុនពេលច្បាប់នេះត្រូវបានប្រកាសឱ្យប្រើ ។

- **ប្រកាសថា សេចក្តីសំរេចរដ្ឋបាល ប្រកាស និងអនុក្រឹត្យ មិនស្របតាមរដ្ឋធម្មនុញ្ញ** (តាមរយៈនីតិវិធីនៃមាត្រា១៩ LOFCC) ដោយមានផលវិបាកដែលតុលាការកំពូល – ជាតុលាការដែលអាចដាក់ពាក្យប្តឹងតវ៉ា (មាត្រា១៩ III LOFCC) – ត្រូវប្រកាស សេចក្តីសំរេចរដ្ឋបាល ប្រកាស និងអនុក្រឹត្យទាំងនេះ ទុកជា**មោឃៈ** (មាត្រា១៥០ II CC) ។

## II) វិវាទទាក់ទងនឹងការបោះឆ្នោត

មុខងារចម្បងទី ២ របស់ក្រុមប្រឹក្សាធម្មនុញ្ញ គឺ**ការត្រួតពិនិត្យសកម្មភាពរដ្ឋបាលរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** ដោយធានាថា ការបោះឆ្នោតជាតិប្រព្រឹត្តទៅដោយសេរី និងត្រឹមត្រូវ (មាត្រា១៣៦ II CC) ។

មាត្រា២៦ LOFCC:

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសំរេចៈ

១- លើបណ្តឹងតវ៉ារបស់គណបក្សនយោបាយ ឬរបស់បេក្ខជន ប្តឹងមិនសុខចិត្តនឹងសេចក្តី-សំរេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសំរេចបដិសេធលើការតវ៉ាពីបេក្ខភាព ឬសំរេចបដិសេធលើការតវ៉ាពីបញ្ជីរាយនាមបេក្ខជន ។...

២- លើបណ្តឹងតវ៉ារបស់បុគ្គល ប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសំរេចបដិសេធការតវ៉ាសុំចុះឈ្មោះបោះឆ្នោត (នៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត) ។...

៣- លើបណ្តឹងតវ៉ារបស់បុគ្គល ឬអ្នកតំណាង ប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសំរេចបដិសេធអំពីការបាត់ឈ្មោះ ឬអំពីការជំទាស់នឹងការចុះឈ្មោះ ឬអំពីការរក្សាទុកឈ្មោះក្នុងបញ្ជីបោះឆ្នោតនូវបុគ្គលណាម្នាក់ ដែលគេយល់ឃើញថា មានលក្ខណៈមិនត្រឹមត្រូវតាមលក្ខខណ្ឌនៃច្បាប់បោះឆ្នោត ។

៤- លើបណ្តឹងតវ៉ារបស់គណបក្សនយោបាយ ពីការបដិសេធមិនឱ្យខ្លួនចុះបញ្ជីនៅក្នុងបញ្ជី គណបក្សនយោបាយ ។

មាត្រា២៧ LOFCC:

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសំរេចៈ

១- លើបណ្តឹងតវ៉ាដោយផ្ទាល់ អំពីលទ្ធផលនៃការបោះឆ្នោតដែលបុគ្គល ឬ គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោត មិនសុខចិត្តនឹងលទ្ធផលនៃ ការបោះឆ្នោត ។ ...

២) លើបណ្តឹងតវ៉ារបស់បុគ្គល ឬគណបក្ស ដែលមិនសុខចិត្តនឹងសេចក្តីសំរេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសំរេចបដិសេធការតវ៉ាអំពីលទ្ធផលនៃការបោះឆ្នោត ។ ...

ដើម្បីស៊ើបអង្កេតលើបណ្តឹងតវ៉ាពាក់ព័ន្ធនឹងការបោះឆ្នោត ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបើក**សវនាការសាធារណៈ** (មាត្រា៣២ LOFCC) និងអាចធ្វើសេចក្តីសំរេច ដូចតទៅ (មាត្រា៣៤ LOFCC):

- យល់ព្រម ឬមិនយល់ព្រមលើសេចក្តីសំរេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ប្រកាសថាការបោះឆ្នោតមិនបានការ (មោឃៈ)
- ប្រកាសថាបេក្ខជនម្នាក់បានជាប់ឆ្នោតដោយស្របច្បាប់ ឬដោយមិនស្របច្បាប់ ។

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវមានហេតុផល ។ សេចក្តីសំរេចទាំងនេះ គឺជាសេចក្តីសំរេចស្ថាពរ (មាត្រា៣៤ IV CC) បិទផ្លូវតវ៉ា និងត្រូវតែចុះផ្សាយនៅក្នុង "សារព័ត៌មានផ្លូវការ" ផង ។

## ? សំនួរសិក្សាទី ៦

តើក្រុមប្រឹក្សាធម្មនុញ្ញមានមុខងារសំខាន់ៗអ្វីខ្លះ?
ចូរដកស្រង់នូវមាត្រានានាដែលពាក់ព័ន្ធ ។

## ? សំនួរសិក្សាទី ៧

សមាជិកសភាចំនួន ១ ភាគ ១០ ស្នើទៅក្រុមប្រឹក្សាធម្មនុញ្ញ ឱ្យធ្វើការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ដែលពាក់ព័ន្ធនឹងសេរីភាពក្នុងការបញ្ចេញមតិ ។

ក) ក្នុងនាមជាសមាជិកមួយរូបនៃក្រុមប្រឹក្សាធម្មនុញ្ញ តើអ្នកនឹងធ្វើការបកស្រាយលើពាក្យថា "សេរីភាពក្នុងការបញ្ចេញមតិ" យ៉ាងដូចម្តេច ?
ចូរឱ្យនិយមន័យនៃពាក្យនេះ ។

ខ) ប្រសិនណា សមាជិកសភាមិនយល់ស្របនឹងសេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ តើសមាជិក-សភាទាំងនោះ អាចប្តឹងតបនឹងសេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែរឬទេ?
ចូរផ្តល់ហេតុផលសំរាប់ចំលើយរបស់អ្នក និងដកស្រង់នូវមាត្រានានាដែលពាក់ព័ន្ធ ។

# តួនាទីរបស់ចៅក្រម ភាពឯករាជ្យ និងភាពមិនលំអៀង

## ក) សេចក្តីផ្តើម:

ប្រព័ន្ធតុលាការដែលឯករាជ្យ គឺជាប្រព័ន្ធតុលាការមួយដែលការពារប្រព័ន្ធលទ្ធិប្រជាធិបតេយ្យដ៏សំខាន់បំផុត ។ នីតិរដ្ឋ មានលើសលុបបានតែនៅពេលណាដែលការអនុវត្តន៍ និងការប្រតិបត្តិនូវវិធាន ហើយនិងច្បាប់ត្រូវបានគ្រប់គ្រងដោយចៅក្រមឯករាជ្យប៉ុណ្ណោះ ។ តម្លាភាពរបស់រដ្ឋាភិបាលជ្រើសតាំង មិនអាចសម្រេចបានឡើយ នៅពេលដែលសកម្មភាពរបស់ខ្លួនមិនត្រូវបានពិនិត្យមើលភាពស្របច្បាប់ដោយស្ថាប័នមួយដែលមិនស្ថិតក្រោមឥទ្ធិពលរបស់សាខានីតិប្រតិបត្តិខ្លួនឯងទេនោះ ។ ដូច្នេះ គេត្រូវតែអនុវត្តគោលការណ៍នៃការបែងចែក **អំណាចដោយភាពតឹងរឹងដាច់ខាតទៅលើទំនាក់ទំនងរវាងអំណាចតុលាការ និងអំណាចនីតិប្រតិបត្តិ ។**

នៅក្នុងប្រទេសកម្ពុជា បន្ទាត់បែងចែករវាងអំណាចទាំងពីរនេះ នៅតែមិនទាន់ត្រូវបានគូរច្បាស់លាស់នៅឡើយ ។ ដោយទទួលមរតកនៃប្រព័ន្ធតុលាការសង្គមនិយមដែលត្រូវអនុវត្តមកលើប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ១៩៧៩ រហូតដល់ ឆ្នាំ១៩៩៣ **ឥទ្ធិពលនៃអំណាចនីតិប្រតិបត្តិ មកលើអំណាចតុលាការ**នៅតែមានសម្ពាធខ្លាំងនៅឡើយ ។ នៅកំឡុងពេលនោះ សូម្បីតែក្រសួងយុត្តិធម៌ក៏មានអំណាច ដើម្បីឱ្យក្រុមប្រឹក្សារដ្ឋសំរេចមោឃភាពលើសាលក្រមផ្សេងៗបានដែរ ។ បន្ទាប់ពីពេលនោះមក ក្រសួងយុត្តិធម៌ ក៏នៅតែមានសមត្ថកិច្ចក្នុងការចេញគោលការណ៍ និងសារាចរណែនាំផ្សេងៗ ដើម្បីណែនាំដល់ពួកចៅក្រមអំពី របៀបបកស្រាយច្បាប់ឱ្យស្របតាមពង្រាងអនុក្រឹត្យមួយដែលត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ១៩៩៤ ដែលអនុក្រឹត្យ នេះពុំដែលត្រូវបានអនុម័តម្តងណាសោះ ក៏ប៉ុន្តែបានឆ្លុះបញ្ចាំងនូវការអនុវត្តន៍ទូទៅ[១៣] ។ ទោះបីជាបច្ចុប្បន្ន "អនុក្រឹត្យស្តីពីមុខងាររបស់ក្រសួងយុត្តិធម៌" ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២000 មិនបានផ្ទេរអំណាចនេះទៅឱ្យក្រសួងនេះទៀតក៏ដោយ ក៏អំណាចនីតិប្រតិបត្តិនៅតែប្រើឥទ្ធិពលដ៏លេចធ្លោរមួយ ទៅលើប្រព័ន្ធតុលាការតាមរយៈសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដដែល ។ ក្រុមប្រឹក្សានេះ មិនមានភាពឯករាជ្យពិតប្រាកដពីអង្គនីតិបញ្ញត្តិឡើយ ពីព្រោះវាមិនបញ្ចូលសមាជិកសភា ឬគណៈមេធាវី ឬសាស្ត្រាចារ្យច្បាប់ ឬសមាជិកសង្គមស៊ីវិលទេ ប៉ុន្តែ សមាជិកភាគច្រើនរបស់ក្រុមប្រឹក្សានេះ គឺជាអតីតកម្មាភិបាលចៅក្រមចាស់ៗដែលមានបុណ្យស័ក្តិខ្ពស់ ដែលបានទទួលសមាជិកភាពរបស់ខ្លួននៅក្នុងក្រុមប្រឹក្សានៃអង្គចៅក្រមនេះ ដោយសារតែ តួនាទីរបស់ខ្លួននៅក្នុងប្រព័ន្ធច្បាប់តែប៉ុណ្ណោះ ប៉ុន្តែមិនមែនបានទទួលតួនាទីទាំងនេះតាមរយៈការបោះឆ្នោតឡើយ ។

[១៣] សម្រាប់ព័ត៌មានលំអិតស្តីពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ សូមមើលសៀវភៅ: កុយ នៀម ប្រព័ន្ធតុលាការកម្ពុជា ឆ្នាំ១៩៩៨ (ជាភាសាខ្មែរ និងអង់គ្លេស) ទំព័រ ៣, ៤, ៩-១១

**ប្រវត្តិនយោបាយនេះ** យើងត្រូវតែចងចាំទុកក្នុងខួរក្បាលជានិច្ច នៅពេលដែលយើងពិនិត្យមើលលើគោលការណ៍ជាមូលដ្ឋាននៃប្រព័ន្ធតុលាការឯករាជ្យ និងមិនលំអៀងមួយ និងផលវិបាកជាក់លាក់មួយចំនួនរបស់គោលការណ៍នេះនៅក្នុងប្រទេសកម្ពុជា[១៤] ។

យើងក៏ត្រូវតែពិចារណាលើកត្តាពីរទៀត ដែលធ្វើឱ្យខ្សោយដល់ឯករាជភាពរបស់ចៅក្រម នៅពេលដែលយើងនិយាយអំពីឯករាជភាពរបស់តុលាការនៅក្នុងប្រទេសកម្ពុជា គឺ :

ដោយសារប្រាក់បៀវត្សចៅក្រមមិនគ្រប់គ្រាន់ ប្រព័ន្ធតុលាការបច្ចុប្បន្នទទួលរងគ្រោះដោយសារ**អំពើពុករលួយមានកំរិតខ្ពស់** ដែលត្រូវបានដកស្រង់នៅក្នុងរបាយការណ៍ស្តីពីសិទ្ធិមនុស្សជាច្រើន រាប់បញ្ចូលទាំងរបាយការណ៍នៃអ្នកតំណាងពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សផង ។

លើសពីនេះទៀត ចៅក្រមជាច្រើននៃចៅក្រមទាំងនេះ មិនបានទទួលការបណ្តុះបណ្តាលផ្នែកច្បាប់ត្រឹមត្រូវ ហើយជួបប្រទះនូវ**កង្វះខាតការបណ្តុះបណ្តាល និងជំនាញ** ពីព្រោះពួកគេត្រូវបានជ្រើសរើស និងតែងតាំងយ៉ាងឆាប់រហ័សភ្លាមៗ បន្ទាប់ពីរបបផ្តាច់ការ ប៉ុល ពត បានសម្លាប់សមាជិកនៃអាជីពអ្នកច្បាប់ស្ទើរតែទាំងអស់ ដោយទុកឱ្យអ្នកដែលបានទទួលការបណ្តុះបណ្តាលផ្នែកច្បាប់នៅរស់តែមួយចំនួនតូចប៉ុណ្ណោះ ។

## ១) តើពាក្យថា "ឯករាជភាព" និង "ភាពមិនលំអៀង" មានន័យដូចម្តេច?

ទាំងពាក្យថា ឯករាជភាព និង ភាពមិនលំអៀង (មាត្រា១២៨ I និង II CC) មានន័យថា **មិនមានឥទ្ធិពលមិនសមស្រប** ទៅលើសេចក្តីសម្រេចរបស់ចៅក្រម ដែលអាចកើតឡើងដោយសារសាច់ញាតិរបស់**គូភាគីមានទំនាស់** ("ភាពលំអៀង") ឬដោយសារ**ភាគីទីបី ឬប្រភពខាងក្រៅ** (ដូចជាឥទ្ធិពលនយោបាយ ការណែនាំតាមរូបភាពជាសារាចររបស់ក្រសួងយុត្តិធម៌ជាដើម ។ល។) ។

ផ្ទុយទៅវិញ **ឥទ្ធិពល "ដែលសមស្រប" តែមួយគត់ទៅលើ សេចក្តីសម្រេចរបស់ចៅក្រម** ត្រូវកើតចេញពី**អង្គច្បាប់**ដែលចៅក្រមមានកាតព្វកិច្ចអនុវត្ត និងកើតចេញពី**អង្គហេតុ**ជាក់ស្តែងដែលចៅក្រមត្រូវពិនិត្យ ។

ឯករាជភាព ក៏អាចត្រូវបានគេអធិប្បាយថាជា **សភាវៈចិត្ត**មួយផងដែរ ។ ចៅក្រម **ត្រូវកុំភ័យខ្លាច និងកុំសង្ឃឹម** នៅពេលដែលគាត់សម្រេចរឿងក្តីនីមួយៗ ។ (មានសិលាចារឹកមួយផ្ទាំងនៅពីលើក្លោងទ្វារចូលតុលាការបុរាណមួយនៅក្នុងប្រទេសអ៊ីតាលី ដែលសរសេរថា : "ដោយគ្មានការភ័យខ្លាច និងដោយគ្មានសង្ឃឹម" ។ សិលាចារឹកនេះបានរំលឹកដល់ចៅក្រមគ្រប់រូប ដែលត្រូវចូលទៅក្នុងតុលាការតាមទ្វារនេះជារៀងរាល់ថ្ងៃឱ្យយកចិត្តទុកដាក់ចំពោះសភាពនៃចិត្តឯករាជ្យរបស់ខ្លួន) ។ ដូច្នេះ ចៅក្រមមិនត្រូវភ័យខ្លាចចំពោះការដាក់ទោស ឬការដាក់ទណ្ឌកម្មពីភាគីណាមួយឡើយ នៅពេលដែលខ្លួនធ្វើសេចក្តីសម្រេចណាមួយនោះ ។ ការធ្វើសេចក្តីសម្រេចរបស់គាត់ត្រូវតែធ្វើឡើងដោយគ្មានការបំភិតបំភ័យ ការធ្វើទុកបុកម្នេញ ឬសម្ពាធខាងក្រៅឡើយ ។ លើសពីនេះទៀត សេចក្តីសម្រេចនេះត្រូវតែធ្វើឡើងដោយគ្មានការរំពឹងចង់បានអត្ថប្រយោជន៍ គុណប្រយោជន៍ និងប្រយោជន៍ផ្ទាល់ខ្លួនឡើយ ។

[១៤] សម្រាប់ព័ត៌មានបន្ថែមស្តីពីស្ថានភាពនៃប្រព័ន្ធតុលាការកម្ពុជានៅក្នុងទសវត្សន៍ឆ្នាំ ១៩៩០ សូមអានសៀវភៅរបស់ បាស៊ីល ហ្វៃណានដូ ស្តីពី "បញ្ហាដែលប្រឈមមុខចំពោះប្រព័ន្ធកម្ពុជា" (គណៈកម្មការសិទ្ធិមនុស្សអាស៊ី ខែកក្កដា ឆ្នាំ ១៩៩៨)




គតិបណ្ឌិតព្រះពុទ្ធសាសនាប្រៀនប្រដៅយើងនូវតម្លៃដូចគ្នាអំពីរដ្ឋបាលយុត្តិធម៌ស្អាតស្អំ[១៥] :



**ព្រះពុទ្ធោវាទសម្រាប់ការវិនិច្ឆ័យទោស**

- ចៅក្រមណាក៏ដោយត្រូវប្រកាន់យកអនាគតិធម៌ និងចៀសវាងអគតិធម៌ ។
- ចៅក្រមត្រូវចៀសវាងការកាត់ក្ដីប្រកបដោយអគតិធម៌៤ យ៉ាង គឺ :
  - ឆន្ទាគតិ - លំអៀងព្រោះការស្រលាញ់
  - ទោសាគតិ - លំអៀងព្រោះការស្អប់
  - មោហាគតិ - លំអៀងព្រោះការវង្វេង
  - ភយាគតិ - លំអៀងព្រោះការភ័យខ្លាច
- ចៅក្រមត្រូវកុំគិតពីអំពើពុករលួយ ។ ចៅក្រម មិនត្រូវទទួលសំណូកទេ ។
- ចៅក្រមមិនត្រូវធ្វើការបែងចែករវាងញាតិសន្ដាន និងបុគ្គលដទៃទៀតទេ ។
- ចៅក្រមត្រូវត្រងត្រាប់ស្ដាប់រាល់ចំណុចទាំងអស់ ទាំងតូច ទាំងធំឱ្យបានល្អិតល្អន់ ហើយពិនិត្យមើលទាំងចំណុចដែលខុស និងចំណុចដែលត្រូវដោយការពិចារណាឱ្យបានហ្មត់ចត់

## គ) ក្របខ័ណ្ឌច្បាប់ ដើម្បីធានា និងពង្រឹងឯករាជភាពរបស់តុលាការ

### I) គោលដៅចម្បងនៃក្របខ័ណ្ឌច្បាប់ដ៏សបនោះ:

ឯករាជភាព មិនគ្រាន់តែកើតមកពីសភាវៈចិត្តរបស់ចៅក្រមប៉ុណ្ណោះទេ ប៉ុន្តែ វាថែមទាំងកើតចេញមកពីការរៀបចំគោលជំហរផ្ទាល់ខ្លួនរបស់ចៅក្រមផងដែរ ។ គេត្រូវប្រើប្រាស់ **ក្របខ័ណ្ឌច្បាប់ សង្គមកិច្ច និងហិរញ្ញវត្ថុ** ដើម្បីធានា លើកទឹកចិត្ត ការពារ និង**ធានានូវឯករាជភាពរបស់ចៅក្រម** ។ ចំណុចនេះមានន័យថា គេត្រូវតែបង្កើតលក្ខខណ្ឌដែលអាចជួយដល់ចៅក្រមក្នុងការថែរក្សាឯករាជភាពរបស់ខ្លួន ។

[១៥] សូមមើលសៀវភៅរបស់លោកសិទ្ធិ បុត្រ "សង្គមទស្សនៈវិជ្ជានៃព្រះពុទ្ធសាសនា" - ជំពូកទី៥ ទស្សនៈនយោបាយរបស់ព្រះពុទ្ធ ឆ្នាំ១៩៩៥ ទំព័រ ១៤-១៥

ឯករាជភាពនៃតុលាការ មិនគ្រាន់តែទទួលរងគ្រោះថ្នាក់ដោយសារឥទ្ធិពល និងសម្ពាធខាងក្រៅ ទៅលើចៅក្រមស្មោះត្រង់ដែលប្រាថ្នានូវឯករាជភាពឡើយ ។ ឯករាជភាព ក៏ត្រូវបានធ្វើឱ្យគ្រោះថ្នាក់ដោយសារចៅក្រមខ្លួនឯងផងដែរ នៅពេលដែលពួកគេប្រព្រឹត្តិអំពើពុករលួយ មានអគតិធម៌ និងធ្វើការសម្រេចដោយលំអៀងនោះ។ ដូច្នេះ វាមានសារៈសំខាន់ណាស់ ដែលត្រូវកត់សំគាល់ថា **ឯករាជភាព មិនមែនជាបុព្វសិទ្ធិផ្ទាល់ខ្លួនរបស់ចៅក្រម** ដែលគាត់ត្រូវតែការពារសំរាប់ប្រយោជន៍ផ្ទាល់ឡើយ ។ ប៉ុន្តែ ដើម្បីបានចៅក្រមឯករាជ្យ គឺជា**សិទ្ធិរបស់ប្រជាពលរដ្ឋ** ។ នេះមានន័យថា ចៅក្រមម្នាក់ៗ មាន**ករណីយកិច្ច**ធ្វើជាចៅក្រមឯករាជ្យ ធ្វើសកម្មភាព និងសម្រេចដោយឯករាជ្យ និងមិនលំអៀង ពីព្រោះ ប្រជាពលរដ្ឋមានសិទ្ធិក្នុងការទទួលបាននូវចៅក្រមឯករាជ្យ ។ អាស្រ័យហេតុនេះ ក្របខ័ណ្ឌច្បាប់ត្រូវតែបង្កើតឧបសគ្គ និងព្រំដែនសម្រាប់ចៅក្រមនីមួយៗ ដើម្បីរារាំងគាត់កុំឱ្យធ្វើសេចក្ដីសម្រេចលំអៀង និងដើម្បីធ្វើឱ្យចៅក្រមពិបាកទទួលសំណូក និងរំលោភច្បាប់ ។

ដូច្នេះ ដើម្បីធានានូវឯករាជភាពរបស់តុលាការ ក្របខ័ណ្ឌច្បាប់ណាមួយដែលបង្កើត និងរៀបចំតួនាទីរបស់ចៅក្រមតាមរយៈការរៀបរាប់ពីករណីយកិច្ច និងសិទ្ធិរបស់ចៅក្រមនោះ ត្រូវតែបំពេញតម្រូវការ ពីរខាងក្រោម។

ក្របខ័ណ្ឌច្បាប់ ដើម្បីការពារ និងធានាឯករាជភាព (របស់ចៅក្រម) ត្រូវតែ :

- **ពង្រឹង និងការពារចៅក្រមពីឥទ្ធិពល និងសម្ពាធ** ពីខាងក្រៅ និង**ឥទ្ធិពលមិនសមស្របណាមួយ**
- **បង្កើតឧបសគ្គផ្សេងៗ** ដែលធ្វើឱ្យចៅក្រមពិបាកក្នុងការធ្វើសកម្មភាព ប្រកបដោយ**អគតិធម៌ ពុករលួយ ឬលំអៀង** ។

## II) បទដ្ឋានគតិយុត្ត (ក៏វិតស្តង់ដារ) អន្តរជាតិសម្រាប់ក្របខ័ណ្ឌច្បាប់នៃបទនោះ

ប្រទេសនីមួយៗ ប្រឈមមុខចំពោះបញ្ហាដូចគ្នា នៅក្នុងការបង្កើត និងរៀបចំក្របខ័ណ្ឌច្បាប់មួយដើម្បីធានានូវភាពឯករាជ្យដល់ចៅក្រមរបស់ខ្លួន ។ ប្រទេសផ្សេងៗគ្នា ធ្វើការសន្និដ្ឋានផ្សេងៗគ្នា ហើយរកបាននូវដំណោះស្រាយផ្សេងៗគ្នាចំពោះបញ្ហានោះ ។ ឧទាហរណ៍ ប្រទេសមួយចំនួន បានបោះឆ្នោតជ្រើសតាំងចៅក្រមរបស់ពួកគេ ប្រទេសមួយចំនួនទៀត មានប្រព័ន្ធមួយនៃការចូលរួមពីប្រជាពលរដ្ឋដែលគ្មានចំណេះដឹងជំនាញ ចំណែកឯប្រទេសមួយចំនួនទៀត ជ្រើសរើសសមាជិកចាស់ៗ ដែលមានបទពិសោធន៍ផ្នែកវិជ្ជាជីវៈច្បាប់ប៉ុណ្ណោះ (ឧ. សមាជិកគណៈមេធាវី) ដើម្បីឱ្យធ្វើជាចៅក្រម ។

ប៉ុន្តែ មាន**បទដ្ឋានរួម** និងសេចក្តីសន្និដ្ឋានមួយចំនួន ដែលប្រទេសភាគច្រើនបានយល់ឃើញថាសមស្រប ក្រោយពីបានធ្វើការពិភាក្សា ការផ្លាស់ប្តូរចំណេះដឹងជាអន្តរជាតិ និងបទពិសោធន៍ជាប្រវត្តិសាស្ត្រអស់រយៈពេលដ៏យូរ ដោយមានគំរូផ្សេងៗគ្នានៃការបង្កើតប្រព័ន្ធតុលាការឯករាជ្យមួយ ។ **ការសិក្សាស៊ីជម្រៅ**

ដ៏គួរឱ្យចាប់អារម្មណ៍មួយចំនួនអំពីបញ្ហាជាមូលដ្ឋាន និងការការពារនូវប្រព័ន្ធតុលាការឯករាជ្យមួយ ដែលផ្តល់នូវការណែនាំជាច្រើន ហើយឧទាហរណ៍ជាក់ស្តែងមានផ្សព្វផ្សាយនៅតាមអ៊ីនធើណិត[១៦] ។

ឧទាហរណ៍ អង្គការសហប្រជាជាតិ បានអនុម័ត

## គោលការណ៍ជាមូលដ្ឋាន ស្តីពីភាពឯករាជ្យរបស់តុលាការ (ឆ្នាំ១៩៨៥)[១៧]

និងសន្និបាតនៃចៅក្រមតុលាការកំពូលនៃប្រទេសផ្សេងៗគ្នាចំនួន២០ នៅទូទាំងទ្វីបអាស៊ីបានអនុម័តៈ

## សេចក្តីថ្លែងការណ៍ក្រុងបេកាំង ស្តីពីគោលការណ៍ឯករាជភាពរបស់តុលាការ នៅក្នុងតំបន់អាស៊ី (ឆ្នាំ១៩៩៥)[១៨]

ឯកសារទាំងនេះ មិនមែនជាអនុសញ្ញាដែលចងភ្ជាប់កាតព្វកិច្ចទេ ក៏ប៉ុន្តែ វាបានផ្តល់នូវឧបករណ៍ដ៏មានប្រយោជន៍មួយនៃការបកស្រាយពាក្យថា "ឯករាជភាពរបស់តុលាការ" ។ សេចក្តីប្រកាសទាំងនេះកំណត់នូវប្រធានបទទាំងអស់ដែលបង្កបញ្ហាជាប្រចាំដល់ភាពឯករាជ្យរបស់តុលាការ ។ សេចក្តីប្រកាសទាំងនេះដាក់ចេញនូវសំណូមពរ និងអនុសាសន៍មួយចំនួន អំពីមធ្យោបាយក្នុងការចៀសវាង និងដោះស្រាយបញ្ហាពាក់ព័ន្ធនានា ។

អ្នកតាក់តែងច្បាប់កម្ពុជា បានទទួលស្គាល់យ៉ាងច្បាស់នូវគោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីឯករាជភាពរបស់តុលាការ នៅក្នុងមាត្រា ១ នៃក្រមព្រហ្មទណ្ឌអន្តរកាល ។

**អង្គការសហប្រជាជាតិ (UN)** មានបំណងដើម្បីលើកកំពស់ភាពឯករាជ្យរបស់តុលាការ ពីព្រោះ វាគឺជាការការពារមួយដ៏សំខាន់បំផុតសំរាប់ការការពារសិទ្ធិមនុស្សប្រកបដោយប្រសិទ្ធិភាព និងជាវិធានការតែមួយគត់ដើម្បីដោះស្រាយទំនាស់ដោយសន្តិវិធី[១៩] ។ ដូច្នេះ អង្គការសហប្រជាជាតិ បានបង្កើតការិយាល័យមួយសំរាប់ **អ្នករាយការណ៍ពិសេសអំពីឯករាជភាពរបស់តុលាការ** នៅក្នុងឆ្នាំ ១៩៩៤ ។ អ្នករាយការណ៍ពិសេសនេះពិនិត្យ

[១៦] ឧទាហរណ៍ៈ
- "ការណែនាំសំរាប់ការលើកកំពស់ភាពឯករាជ្យ និងភាពមិនលំអៀងនៃប្រព័ន្ធតុលាការ" ដោយ USAID :ខែមករា ឆ្នាំ២០០២, ១៧៦ទំព័រ រួមទាំង ការសិក្សា ស្រាវជ្រាវក្នុងតំបន់, ឧបសម្ព័ន្ធនៃគោលការណ៍ទាំងអស់ និងទំនាក់ទំនងទៅនឹងវិបសាយ =www.dec.org/pdf_docs/pnacm007.pdf
- "តួនាទីរបស់ប្រព័ន្ធតុលាការឯករាជ្យ" ដោយ Susan Sullivan Lagon, វិទ្យាស្ថានសំរាប់ការសិក្សាសហសម័យ, សាន់ហ្វ្រាន់ស៊ីស្កូ (San Francisco) ខែកក្កដា ឆ្នាំ១៩៩៣= http://usinfo.state.gov/products/pubs/archive/freedom/freedom4.htm
- "ប្រព័ន្ធតុលាការឯករាជ្យ" របាយការណ៍នៃគណៈកម្មការគណៈមេធាវីអាមេរិក ស្តីពីការបែងចែកអំណាច និងឯករាជភាពរបស់តុលាការ ដោយមានប្រធានបទដ៏មានសារៈប្រយោជន៍ = www.abanet.org/govaffairs/judiciary/report.html

[១៧] សូមមើល : www.umn.edu/humanrts/instree/i5bpij.htm

[១៨] សូមមើល : wwwlaw.murdoch.edu.au/icjwa/beijst.htm;
សូមមើលធម្មនុញ្ញចៅក្រមអឺរ៉ុបផង (=www.richtervereinigung.at/international/eurojus1/eurojus15a.htm)

[១៩] សូមមើលសេចក្តីណែនាំអំពីការងាររបស់អង្គការសហប្រជាជាតិ ស្តីពីឯករាជភាពរបស់តុលាការ : "ឯករាជភាពរបស់តុលាការ" : "អាទិភាពសិទ្ធិមនុស្ស" (=www.un.org/rights/dpi1837e.htm)

និងវាយតម្លៃលើ ស្ថានភាពនៃតុលាការនៅក្នុងប្រទេសដែលស្ថិតក្នុងការបារម្ភផ្សេងៗ នៅទូទាំងពិភពលោក និងបោះពុម្ពផ្សាយនូវរបាយការណ៍អំពីអ្វីដែលគាត់បានរកឃើញ ។ អ្នករាយការណ៍ពិសេសនេះ ក៏ផ្តល់នូវអនុសាសន៍ និងយោបល់ដល់រដ្ឋាភិបាល និងស្ថាប័នផ្សេងៗផងដែរ ។ អ្នករាយការណ៍ពិសេស មិនត្រឹមតែរាយការណ៍អំពីប្រទេសដែលកំពុងអភិវឌ្ឍន៍ប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងប្រទេសអភិវឌ្ឍន៍ទៀតផង ។

ឧទាហរណ៍:

របាយការណ៍បែបរិះគន់មួយ ត្រូវបានរៀបចំឡើងដោយអ្នករាយការណ៍ពិសេសអំពីស្ថានភាពតុលាការនៅក្នុងប្រទេស**អ៊ីតាលី** ដោយសារ រដ្ឋាភិបាលអ៊ីតាលី បានផ្តួចផ្តើមគំនិតបង្កើតច្បាប់មួយចំនួន ដែលបានធ្វើឱ្យគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ឯករាជភាពរបស់តុលាការ ។

ចាប់ពីឆ្នាំ១៩៩៤ មកដល់ ខែកក្កដា ឆ្នាំ២០០៣ តំណែងនេះត្រូវបានកាន់កាប់ដោយជនជាតិម៉ាឡេស៊ីម្នាក់ ឈ្មោះលោក កុមារស្វាមី ។ អ្នកស្នងតំណែងរបស់គាត់ គឺជនជាតិអាហ្សង់ទីន ឈ្មោះលោក ដេសពួយ ដែលបានចូលកាន់តំណែងនៅក្នុងខែសីហា ឆ្នាំ២០០៣[២០] ។

**គណៈកម្មការនៃគណៈវិនិច្ឆ័យអន្តរជាតិ (ICJ)** ដែលជាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិមួយដែលត្រូវបានគាំទ្រដោយចៅក្រម និងមេធាវីទូទាំងពិភពលោក ក៏យកចិត្តទុកដាក់អំពីបមាណីយសំរាប់ឯករាជភាពរបស់តុលាការផងដែរ ។ **មជ្ឈមណ្ឌលសំរាប់ឯករាជភាពរបស់ចៅក្រម និងមេធាវីរបស់អង្គការនេះ** ផ្តល់នូវកម្មវិធីបណ្តុះបណ្តាលដល់ចៅក្រម ។ មជ្ឈមណ្ឌលនេះ ធ្វើការបណ្តុះបណ្តាលផងដែរ ដល់ចៅក្រមនិងព្រះរាជអាជ្ញាកម្ពុជា នៅទសវត្សទី ៩០[២១] ។

## III) សំនួរជាមូលដ្ឋានពាក់ព័ន្ធនឹងភាពឯករាជ្យរបស់តុលាការ:

ដោយពិនិត្យមើលតុលាការ ថាជាប្រព័ន្ធមួយដែលត្រូវការប្រព្រឹត្តិទៅដោយឯករាជ្យ និងដោយមានសេរីភាព រួចពីឥទ្ធិពលមិនសមស្របណាមួយនោះ យើងអាចរកឃើញនូវចំណុចខ្សោយចំនួន៦ នៅក្នុងប្រព័ន្ធនេះ ដែលអាចបើកឱកាសឱ្យមានឥទ្ធិពលមិនសមស្របបែបនោះ ។ ចំណុចទាំងនេះ ត្រូវការពិនិត្យដោយយកចិត្តទុកដាក់ ហើយបទបញ្ញាពិសេស ច្បាប់ ឬក្រមសីលធម៌ត្រូវបង្កើតឡើង ដើម្បីកាត់បន្ថយគ្រោះថ្នាក់ពាក់ព័ន្ធដល់ឯករាជភាព ។

ចំណុចខ្សោយទាំងនោះ អាចត្រូវបានរកឃើញបានយ៉ាងងាយ ដោយការសួរសំនួរចំនួន៦ ដូចខាងក្រោម:

[២០] វិបសាយរបស់អង្គការសហប្រជាជាតិស្តីពីអ្នករាយការណ៍ពិសេស = www.unhchr.ch/html/menu2/7/b/mijl.htm

[២១] គណៈកម្មការនៃគណៈវិនិច្ឆ័យអន្តរជាតិ (មជ្ឈមណ្ឌលសំរាប់ភាពឯករាជ្យរបស់ចៅក្រម និងមេធាវី = www.icj.org) និងគណៈកម្មការនៃគណៈវិនិច្ឆ័យ អន្តរជាតិ - សាខាអូស្រ្តាលីខាងលិច = wwwlaw.murdoch.edu.au/icjwa/ ។ សូមមើលបន្ថែមនូវៈ ច្រកអភិវឌ្ឍន៍ - កំណែទំរង់ច្បាប់ និងតុលាការ = www.developmentgateway.org/ node/130655/ )

## សំនួរជាមូលដ្ឋានចំនួន៦ អំពីឯករាជភាពរបស់តុលាការ

| | |
|---|---|
| **១. តើចៅក្រមត្រូវបានជ្រើសរើស ដូចម្ដេច?** | ដំណើរការនៃ**ការជ្រើសរើស ការតែងតាំង** និងជាពិសេស**ការដំឡើង**ឋានៈចៅក្រម អាចធ្វើឱ្យចៅក្រមពឹងផ្អែកលើអ្នកដទៃយ៉ាងខ្លាំង ។ សេចក្ដីសង្ឃឹមរបស់ចៅក្រមចំពោះការដំឡើងឋានៈ ឋានន្តរស័ក្តិ និងប្រាក់បៀវត្សខ្ពស់ អាចជះឥទ្ធិពលមិនសមស្របដល់សេចក្ដីសំរេចរបស់ចៅក្រម ។ |
| **២. តើ តួនាទីផ្ទាល់ខ្លួនរបស់ចៅក្រមរឹងមាំ ដូចម្ដេច?** | ចៅក្រម មានការពឹងផ្អែក (លើអ្នកដទៃ) ច្រើនបំផុត ប្រសិនបើ **ជំហរផ្ទាល់ខ្លួន**របស់គាត់មានលក្ខណៈទន់ខ្សោយ ប្រសិនបើ គាត់មិនមានប្រាក់បៀវត្សគ្រប់គ្រាន់ ប្រសិនបើ គ្មាននរណាម្នាក់ការពារគាត់ពីការធ្វើឃាដ ឬប្រសិនបើ សិទ្ធិក្នុងការបង្កើតសមាគមរបស់គាត់ ត្រូវបានគេបដិសេធនោះ ។ |
| **៣. តើចៅក្រមណាសម្រេចលើរឿងក្ដីមួយណា?** | ប្រសិនបើ គ្មាន**វិធានចាត់តាំងច្បាស់លាស់**នោះទេ វាពឹងផ្អែកលើអំណាចឆន្ទានុសិទ្ធិរបស់ប្រធានតុលាការ (ឬក្រឡាបញ្ជី) ថាតើ**រឿងក្ដីណា** ត្រូវបានព្ទ និងសម្រេចដោយ**ចៅក្រមណា?** ប្រការនេះ អាចផ្ដល់ឱកាសឱ្យចៅក្រមជ្រើសរើសរឿងក្ដីទាំងឡាយណា ដែលគាត់មានចំណាប់អារម្មណ៍ផ្ទាល់ខ្លួន ពីព្រោះចៅក្រម មានសម្ព័ន្ធភាពផ្ទាល់ខ្លួនជាមួយភាគីជំលោះណាមួយ ។ល។ |
| **៤. តើចៅក្រម ត្រូវធ្វើការកាត់ទោស ដូចម្ដេច?** | **វិធាននីតិវិធីច្បាស់លាស់** ក៏ដូចជាវិធានស្ដីពីករណីយកិច្ចក្នុងការស៊ើបអង្កេត លើកបង្ហាញភស្តុតាង និងពន្យល់ហេតុផលជាលាយល័ក្ខអក្សរចំពោះសាលក្រមដែរ វាចាប់បង្ខំឱ្យចៅក្រមគោរពតាមអង្គច្បាប់ និងអង្គហេតុ ។ បើមិនដូច្នោះទេ វានឹងធ្វើឱ្យចៅក្រមមានភាពងាយស្រួល ក្នុងការបិទបាំងនូវហេតុផលប្រកបដោយអគតិធម៌ នៅក្នុងសេចក្ដីសម្រេចរបស់គាត់ ។ |
| **៥. តើ នរណាអាចត្រួតពិនិត្យការអនុវត្តន៏ការងាររបស់ចៅក្រមបាន?** | ដូចអំណាចផ្សេងទៀតដែរ តុលាការត្រូវការ **ការគ្រប់គ្រង ការត្រួតពិនិត្យ និងដាក់ទណ្ឌកម្ម** ឬថែមទាំងការដាក់ទណ្ឌកម្ម នៅពេលដែលខ្លួនមិនបានបំពេញករណីយកិច្ចរបស់ខ្លួនបានល្អប្រសើរ ។ គ្មានការត្រួតពិនិត្យ ចៅក្រមធ្វើសេចក្ដីសំរេចដោយមានទំនោរទៅរកអំពើពុករលួយ និងប្រកបដោយអគតិធម៌ ។ ប៉ុន្តែការត្រួតពិនិត្យនេះត្រូវតែមានព្រំដែនតឹងរឹង និងមិនប៉ះពាល់ដល់ឯករាជភាពនៃសេចក្ដីសំរេច ។ ដូច្នេះហើយ បានជាតួនាទីត្រួតពិនិត្យនេះ ត្រូវបានអនុវត្តដោយតួអង្គផ្សេងៗគ្នាជាច្រើន (ដូចជា តុលាការជាន់ខ្ពស់ជាងមេធាវី បណ្ដាញសារព័ត៌មាន ។ល។) ដែលតួអង្គម្នាក់ៗ ត្រូវមានការត្រួតពិនិត្យដែលមានព្រំដែនកំណត់[២១] ។ |
| **៦. តើនរណាផ្ដល់មូលនិធិដល់ថវិកាតុលាការ និង គ្រប់គ្រងរដ្ឋបាលតុលាការ?** | ពុំមានតុលាការណាមួយ អាចដំណើរការដោយគ្មាន**ថវិកា**បានឡើយ ។ ប្រសិនបើ ថវិកាមានមិនគ្រប់គ្រាន់ សំរាប់ចំណាយលើតំរូវការជាមូលដ្ឋានរបស់ចៅក្រម ដូចជា តុ ទូ កៅអី អត្ថបទច្បាប់ និងសៀវភៅ ហើយចៅក្រម ត្រូវបង្ខំចិត្តចំណាយថវិកាផ្ទាល់ខ្លួនដើម្បីទិញឧបករណ៍ទាំងនេះ និងអាចទទួលសំណូកយ៉ាងងាយស្រួល ឬបាត់បង់ការប្ដេជ្ញាចិត្ត និងទឹកចិត្តល្អចំពោះការងារ ។ លើសពីនេះទៀត អំណាចណាមួយដែលត្រួតពិនិត្យថវិការបស់តុលាការ ឬបុ**គ្គលិករដ្ឋបាល**របស់តុលាការ អាចជះឥទ្ធិពលដោយផ្ទាល់ទៅលើប្រសិទ្ធភាព និងការគ្រប់គ្រង ដំរលូននៃរឿងក្ដីជាក់លាក់ជាច្រើនបាន ។ |

.

[២២] ការត្រួតពិនិត្យស្ថាប័ននៅក្នុងប្រទេសកម្ពុជា ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានសម្ព័ន្ធភាពខ្លាំងពេកហើយជាមួយនឹងអង្គនីតិបញ្ញត្តិ ឬជាមួយនឹងបុគ្គលនានាមកពីគណបក្សនយោបាយណាមួយ ។ ដូច្នេះហើយ ចៅក្រម ក្លាយជាអាយ៉ងយ៉ាងងាយស្រួលសំរាប់ប្រយោជន៏ខាងក្រៅ ដែលនាំឱ្យបាត់បង់ឯករាជភាពរបស់ចៅក្រម ។

ប្រសិនបើ សំនួរទាំងនោះ មិនត្រូវបាននិយាយឱ្យបានត្រឹមត្រូវទេ តុលាការនឹងមិនមានឯករាជភាពទេ ប៉ុន្តែ នឹងក្លាយជាអាយ៉ងមួយដែលមានការពឹងផ្អែកទៅលើឥទ្ធិពលមិនសមស្រប ដោយផ្ទាល់ ដោយមិនផ្ទាល់ មកពីតួអង្គ ជាច្រើន។




(រូបភាពផ្តល់ដោយមជ្ឈមណ្ឌលអភិវឌ្ឍសង្គម CSD)

បញ្ជីត្រួតពិនិត្យខាងក្រោម បង្ហាញយ៉ាងពិស្តារនូវចំណុចខ្សោយមួយចំនួនក្នុងរៀបចំ និងការប្រព្រឹត្តិទៅរបស់តុលាការ និងផ្តល់នូវយុទ្ធសាស្ត្រមួយចំនួន ដើម្បីកាត់បន្ថយគ្រោះថ្នាក់ដែលពាក់ព័ន្ធដល់ឯករាជភាព និងភាពមិនលំអៀង ។

# បញ្ជីត្រួតពិនិត្យ
# ឯករាជភាព និងភាពមិនលំអៀងរបស់តុលាការ

| ចំណុចខ្សោយ | យុទ្ធសាស្ត្រការពារ |
|---|---|
| **តើគេធ្វើការជ្រើសរើសចៅក្រមយ៉ាងដូចម្ដេច?** | |
| ជំនាញ ការអប់រំ បទពិសោធន៍ | • ការអប់រំល្អនៅមហាវិទ្យាល័យច្បាប់<br>• ការជ្រើសរើសមានតម្លាភាព ក្នុងចំណោមនិស្សិតឆ្នើមដែលបញ្ចប់ការសិក្សា រាប់បញ្ចូលទាំងការវាយតម្លៃលើបុគ្គលិកលក្ខណៈរបស់ពួកគេផងដែរ |
| ដំណើរការតែងតាំង | • វិធានដែលមានតម្លាភាព<br>• ស្ថាប័នតែងតាំងចំរុះ: (សភា, ចៅក្រម, មេធាវី, សង្គមស៊ីវិល) |
| ដំឡើងឋានន្តរស័ក្តិ | ការដំឡើងស័ក្តិទៅតាមអាយុ និងស្នាដៃបំពេញការងារ |
| **តើស្ថានភាពផ្ទាល់ខ្លួនរបស់ចៅក្រមមានលក្ខណៈរឹងមាំយ៉ាងណា?** | |
| ប្រាក់បៀវត្ស | ប្រាក់ខែគ្រប់គ្រាន់ ដើម្បីទ្រទ្រង់ជីវភាពល្អប្រសើរ សំរាប់ចៅក្រម និងគ្រួសារ ដើម្បីចៀសវាងការទទួលសំណូក |
| សេចក្ដីណែនាំ/បទបញ្ជាពីថ្នាក់លើ | • គ្មានសារាចរណែនាំពីក្រសួងនានាទេ<br>• ការដាក់ទោសចំពោះការប៉ុនប៉ងចេញបញ្ជា<br>• ច្បាប់ច្បាស់លាស់ដែលបដិសេធនូវលទ្ធភាពដែលអាចធ្វើការណែនាំ |
| ការផ្ទេរចៅក្រម | គ្មានការផ្ទេរទៅតុលាការផ្សេងទៀត ដោយគ្មានការយល់ព្រមជាមុនពីចៅក្រមនោះទេ |
| ការដកចៅក្រមចេញ | មានការតែងតាំងសំរាប់មួយជីវិតទៀងទាត់ រីឯការបណ្ដេញចេញអាចធ្វើបានតែក្នុងករណី បទល្មើសព្រហ្មទណ្ឌកិតធ្ងន់ ពាក់ព័ន្ធនឹងមុខងារតុលាការតែប៉ុណ្ណោះ |
| សន្តិសុខផ្ទាល់ខ្លួនរបស់ចៅក្រម | • នគរបាលការពារចៅក្រម និងគ្រួសារ ប្រសិនបើចាំបាច់<br>• ការស៊ើបអង្កេត និងការកាត់ទោសលើការប៉ុនប៉ងដែលប៉ះពាល់ដល់ចៅក្រម |
| សេរីភាពក្នុងបង្កើតសមាគម និង ការបញ្ចេញមតិ | ការធានាច្បាស់លាស់នៅក្នុងច្បាប់អំពីសិទ្ធិសេរីភាពរបស់ចៅក្រមក្នុងការបញ្ចេញមតិ និងការបង្កើតសមាគម (ត្រូវបានកំណត់ព្រំដែនដោយភាពសំងាត់នៃវិជ្ជាជីវៈនៅក្នុងករណីជាក់លាក់) =មធ្យោបាយខ្លាំងបំផុតនៃការការពារខ្លួន ដើម្បីឱ្យចៅក្រមការពារឯករាជភាពរបស់ខ្លួនបាន និងការពារប្រឆាំងនឹងឥទ្ធិពលមិនសមស្រប (ប្រសិន បើចាំបាច់ស្វែងរកការគាំទ្រពី ប្រព័ន្ធផ្សព្វផ្សាយ) |
| សមាជិកភាពគណបក្ស | ការហាមឃាត់មិនឱ្យចូលសមាជិកគណបក្សនយោបាយណាមួយ សំរាប់តែរយៈពេលអន្តរកាលមួយប៉ុណ្ណោះ នៅក្នុងប្រទេសដែលមានប្រវត្តិសាស្ត្រយូរអង្វែង នៃការគ្រប់គ្រងដោយគណបក្សតែមួយ ។ |
| **តើចៅក្រមណាមួយនឹងសម្រេចរឿងក្ដីណា?** | |
| ទំហំនៃយុត្តាធិការ | យុត្តាធិការសំរាប់ទំនាស់ផ្លូវច្បាប់ទាំងអស់ គ្មានករណីពិសេសណាត្រូវបានផាត់ចេញពីការត្រួតពិនិត្យដោយតុលាការឡើយ |
| ការបែងចែករឿងក្ដីក្នុងចំណោមចៅក្រម | • ការបង្គាប់ជាទូទៅ និងជាមុន អំពីការបែងចែករឿងក្ដីថ្មីៗ<br>• តុលាការមណ្ឌលដែលធ្វើដំណើរទៅកាន់ថ្នាក់ស្រុក ឱ្យបានទៀងទាត់<br>• ការផ្លាស់ប្ដូរទីកន្លែងរបស់ចៅក្រម ដោយមានការយល់ព្រមពីចៅក្រមជាមុន ។ |
| សម្ព័ន្ធភាពជាមួយភាគីមានទំនាស់/ភាគី | • សិទ្ធិរបស់គូភាគីក្នុងការបដិសេធចៅក្រម<br>• ករណីយកិច្ចផ្លូវច្បាប់សំរាប់ចៅក្រម ដើម្បីដករឿងក្ដីនេះចេញ នៅពេលដែលមានផលប្រយោជន៍ផ្ទាល់ខ្លួន ឬសម្ព័ន្ធភាពជាមួយភាគីមានទំនាស់ ។ |

| ចំនុចខ្សោយ | យុទ្ធសាស្ត្រការពារ | |
|---|---|---|
| **តើចៅក្រមត្រូវបានគេអនុញ្ញាតឱ្យរៀបចំសវនាការដូចម្តេច?** | | |
| វិធាននៃច្បាប់នីតិវិធី | ១)ករណីយកិច្ចដែលត្រូវអនុញ្ញាតឱ្យភាគីទាំងអស់បញ្ចេញមតិរបស់ពួកគេ<br>២) ករណីយកិច្ចត្រូវផ្តល់ពេលវេលាគ្រប់គ្រាន់ឱ្យភាគីទាំងពីរដើម្បីបង្ហាញពីអំណះអំណាងរបស់ពួកគេ<br>៣) ករណីយកិច្ចដែលត្រូវស្តាប់ភាគីទាំងអស់<br>៤) ករណីយកិច្ចក្នុងការចែកឯកសារពាក់ព័ន្ធដល់ភាគីទាំងអស់ | |
| ការបង្ហាញភស្តុតាង | វិធាននៃភស្តុតាងច្បាស់លាស់ | |
| វិធាននៃច្បាប់សំភារៈ | • ឯកសារច្បាប់ត្រូវតែមានភាពច្បាស់លាស់<br>• ច្បាប់សំភារៈត្រូវតែចងភ្ជាប់កាតព្វកិច្ច (លទ្ធភាពនៃច្បាប់ដែលចេញដោយចៅក្រម ក្នុងករណីមានចន្លោះនៃច្បាប់) | |
| ការចេញសាលក្រម | • សាលក្រម ត្រូវតែធ្វើឡើងជាលាយល័ក្ខអក្សរ និងបង្ហាញហេតុផលក្នុងការសម្រេចចិត្ត<br>• សាលក្រម ត្រូវចេញឱ្យភាគីទាំងពីរ | |
| **តើអ្នកណាត្រួតពិនិត្យការអនុវត្តន៍ការងាររបស់ចៅក្រម?** | | |
| ដោយគូភាគី និងមេធាវីរបស់ពួកគេ | • សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ជំទាស់នឹងសាលក្រម<br>• សិទ្ធិក្នុងការដាក់ពាក្យបណ្តឹងអំពីការជំនុំជំរះរបស់ចៅក្រមនៅស្ថាប័នថ្នាក់លើ (ឧ.ប្រធានតុលាការ SCM) | **យុទ្ធសាស្ត្រការពារទាំងនេះ ទាមទារនូវដំណើរការនីតិវិធីតុលាការជាសាធារណៈ និង ផ្ទាល់មាត់** |
| ដោយសាធារណជន និងសារព័ត៌មាន | បើកសិទ្ធិសេរីភាពឱ្យសាធារណជនចូលរួមការជំនុំជំរះទាំងអស់ (វៀរលែងតែករណីត្រូវការពារ លក្ខណៈបុគ្គល ដូចជារឿងក្តីពាក់ព័ន្ធនឹង អនីតិជន ឬរឿងក្តីរំលោភ) | |
| ដោយចៅក្រមដែលមានចំណេះដឹងទូទៅ | • ការជ្រើសរើសចៅក្រមប្រកបដោយតម្លាភាព<br>• សន្លឹកឆ្នោតដែលត្រូវបានគាំទ្រចៅក្រម | |
| ដោយសហការី សហការិនី របស់ចៅក្រមមកពីក្រុមដូចគ្នា | • ក្រុមដែលមានចៅក្រមលើសពីមួយរូប<br>• ប៉ុន្តែគ្មានឋានានុក្រម និងលំដាក់ថ្នាក់ផ្ទៃក្នុង ក្នុងចំណោមសមាជិកក្រុមទេ<br>• សន្លឹកឆ្នោតដូចគ្នាគាំទ្រប្រធាន និងសមាជិកក្រុមផ្សេងៗទៀត | |
| ដោយប្រធានតុលាការ | គ្មានឥទ្ធិពលមិនសមស្របលាក់បាំង ដោយផ្តល់នូវ ការណែនាំអំពីវិធីសម្រេចរឿងក្តី (= គ្មានការត្រួតពិនិត្យលើការអនុវត្តន៍ច្បាប់នីតិវិធី ឬច្បាប់សម្ភារៈ) ។ គួរមានតែការណែនាំអំពីការបំពាន ក្រមសីលធម៌ប៉ុណ្ណោះ ។ | **យន្តការត្រួតពិនិត្យទាំងនេះ ទាមទារជាលាយល័ក្ខអក្សរនូវ:**<br>• **នីតិវិធីពិធីការ**<br>• **ឯកសារនីតិវិធី**<br>• **សាលក្រម** |
| ដោយក្រុមប្រឹក្សាវិន័យ | • ដាក់ទណ្ឌកម្មដោយគណៈចៅក្រមដែលបានជ្រើសតាំង<br>• ការជុំនំជុំរះដោយយុត្តិធម៌សំរាប់ចៅក្រមដែលត្រូវបានគេចោទប្រកាន់<br>• ការបោះពុម្ពផ្សាយលទ្ធផលនៃការជំនុំជំរះ | |
| ដោយព្រះរាជអាជ្ញា | គ្មានការលើកលែងដល់ចៅក្រមពីការកាត់ទោសពីបទល្មើសព្រហ្មទណ្ឌឡើយ (ចំពោះការទទួលសំណូក ឬមានចេតនាបកស្រាយច្បាប់ពុំត្រឹមត្រូវ) ប៉ុន្តែត្រូវមានការការពារពីការចោទប្រកាន់មិនសមស្របពីបទបរិហារកេរ្តិ៍ | |
| ដោយការទទួលខុសត្រូវនៃច្បាប់រដ្ឋប្បវេណី | គ្មានការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់ចៅក្រម ប៉ុន្តែ ការទទួលខុសត្រូវរបស់រដ្ឋ ក្នុងករណីមានការបំពានច្បាប់ដោយមានឆន្ទៈ និងដោយមានចេតនា ។ | |

| ចំនុចខ្សោយ | យុទ្ធសាស្រ្តការពារ |
|---|---|
| **តើអ្នកណាផ្តល់ថវិកាឱ្យតុលាការ និង ត្រួតពិនិត្យការចំណាយ និងរដ្ឋបាលរបស់តុលាការ?** | |
| មូលនិធិសំរាប់សកម្មភាពរបស់តុលាការ | • តុលាការ ត្រូវមានថវិកាផ្ទាល់ខ្លួន ដើម្បីគ្រប់គ្រងខ្លួនឯង<br>• ត្រូវមានវិភាជន៍ថវិការដ្ឋឱ្យបានគ្រប់គ្រាន់ សំរាប់តុលាការដើម្បីបំពេញការងារឱ្យបានល្អ |
| ការតែងតាំង ការត្រួតពិនិត្យ និង វិន័យសំរាប់បុគ្គលិកតុលាការ | ចៅក្រម/ប្រធានតុលាការ ត្រួតពិនិត្យលើបុគ្គលិករដ្ឋបាលតុលាការដោយខ្លួនឯង ។ |

## ? សំនួរសិក្សាទី ៨

ចូរអានបណ្ដាមាត្រាដូចខាងក្រោម នៃពង្រាងច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញានៃព្រះរាជាណាចក្រកម្ពុជា (ខែមីនា ឆ្នាំ ២០០៣):

មាត្រា ១៦:

អាចនឹងត្រូវបានអនុញ្ញាតិឱ្យប្រលងជ្រើសរើសជានិស្សិតចៅក្រម ដែលត្រូវប្រព្រឹត្តទៅជាធម្មតា នៅសាលាភូមិន្ទចៅក្រម នូវបេក្ខភាពជានិស្សិត ឬមន្ត្រីរាជការក្របខ័ណ្ឌ ដែលបានបំពេញលក្ខខណ្ឌ ដូចខាងក្រោមនេះ:

១- ត្រូវមានសញ្ជាតិខ្មែរ

២- មានអាយុ ៣០ឆ្នាំ យ៉ាងច្រើន គិតមកដល់ថ្ងៃប្រលង

៣- ត្រូវមានបរិញ្ញាបត្រច្បាប់

៤- មិនដែលធ្លាប់ជាប់ទោសមជ្ឈឹម ឬឧក្រិដ្ឋ

៥- ត្រូវមានកាយសម្បទាគ្រប់គ្រាន់អាចបំពេញការងារបាន

ចំពោះបេក្ខភាពជាមន្ត្រីក្របខ័ណ្ឌ ដែលលក្ខខណ្ឌខាងលើអាចប្រលងជ្រើសរើសជាចៅក្រមបាន ប៉ុន្តែត្រូវមានអាយុមិនលើសពី ៣៨ឆ្នាំ គិតមកទល់នឹងថ្ងៃប្រលង ។

មាត្រា ៣៣:

ការតម្លើងថ្នាក់របស់ចៅក្រមត្រូវផ្អែកលើមូលដ្ឋាន :

- គោរពវិន័យការងារបានត្រឹមត្រូវ
- សំរេចភារកិច្ចបានល្អ
- មានកិរិយាមាយាទ និង សីលធម៌ មិនធ្វើឱ្យប៉ះពាល់ដល់កិត្តិយសនៃអង្គចៅក្រម
- ឆ្លងកាត់ការបណ្ដុះបណ្ដាលរយៈពេលវែងនៅសកលវិទ្យាល័យ ឬនៅមហាវិទ្យាល័យ ឬនៅមជ្ឈមណ្ឌលបណ្ដុះបណ្ដាលមុខវិជ្ជាជីវៈ
- ធ្វើការនៅតំបន់ដាច់ស្រយាល តំបន់ប៉ះពាល់ដល់សុខភាព ឬគ្រោះថ្នាក់ ។

មាត្រា ៩៤:

មុននឹងចូលបំរើការងារ ចៅក្រម ត្រូវធ្វើសច្ចាប្រណិធានតាមព្រះពុទ្ធសាសនានៅព្រះវិហារ ព្រះកែវមរកត។

សម្បថត្រូវធ្វើទៅតាមការណែនាំ និងតាមរូបមន្តរបស់ប្រធានពិធីការ ក្រោមការចាត់ចែងរបស់ក្រសួងព្រះបរមរាជវាំង ។

ក) មាត្រា១៦ នៃពង្រាងច្បាប់ រៀបរាប់អំពីលក្ខខណ្ឌដើម្បីក្លាយជាចៅក្រម ។

តើអ្នកយល់ស្របនឹងលក្ខខណ្ឌទាំងអស់នោះដែរឬទេ?

ចូរផ្តល់ហេតុផលចំពោះចំលើយរបស់អ្នក ។

ខ) ចូរមើលមាត្រា៣៣ នៃពង្រាងច្បាប់ដដែល ។

តើអ្នកយល់ស្របនឹងលក្ខខណ្ឌទាំងអស់ក្នុងការតម្លើងសក្តិ និងឋានន្តរស័ក្តិដែរឬទេ?

ចូរផ្តល់ហេតុផលចំពោះចំលើយរបស់អ្នក ។

គ) មើលមាត្រា៩៤ នៃពង្រាងច្បាប់ដដែល ។

តើបទបញ្ញត្តិនេះ ស្របជាមួយនឹង "សេចក្តីថ្លែងការណ៍នាទីក្រុងប៉េកាំងស្តីពីគោលការណ៍ឯករាជភាពនៃតុលាការ" (ឆ្នាំ ១៩៩៥) ដែរឬទេ?

ចូរដកស្រង់មាត្រាមួយនៃសេចក្តីថ្លែងការណ៍នាទីក្រុងប៉េកាំង ។

# តួនាទីរបស់មេធាវី



## ក) សេចក្ដីផ្ដើម:

អស់រយៈពេលជាច្រើនទសវត្សមកហើយ ប្រទេសកម្ពុជាមានការខ្វះខាតនូវមេធាវីដែលឯករាជ្យ ដែលបានទទួលនូវការបណ្ដុះបណ្ដាលត្រឹមត្រូវ និងដែលមានទំនុកចិត្តលើខ្លួនឯង ។

បន្ទាប់ពីរបប ប៉ុល ពត ត្រូវបានបញ្ចប់នៅក្នុងឆ្នាំ១៩៧៩ មានតែអ្នកដែលបានទទួលការបណ្ដុះបណ្ដាលផ្នែកច្បាប់មួយចំនួនតូចប៉ុណ្ណោះដែលនៅរស់រានមានជីវិត អ្នកច្បាប់ភាគច្រើនបានភៀសខ្លួនទៅរស់នៅបរទេស ។

ចាប់តាំងពី ឆ្នាំ១៩៧៩ រហូតដល់ ឆ្នាំ១៩៩៣ គេពុំឃើញមានការបង្កើតឡើងនូវការអប់រំផ្នែកច្បាប់ទេ ចំណែកឯវិជ្ជាជីវៈជា "មេធាវី" ក៏ពុំត្រូវបានគេទទួលស្គាល់ថាជាអាជីពឯករាជ្យដែរ ។ មុនពេលដែល "គណៈ-មេធាវីនៃព្រះរាជាណាចក្រកម្ពុជា" ត្រូវបានគេបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៥ គេចាំបាច់ត្រូវតែសុំការអនុញ្ញាតដើម្បីអនុវត្តការងារជាមេធាវី ពីអគ្គព្រះរាជអាជ្ញាដែលនៅអមសាលាឧទ្ធរណ៍ ។ នៅពេលនោះ មន្ត្រីតុលាការទាំងអស់ ជាពិសេសមន្ត្រីដែលមានស័ក្តិខ្ពស់ជាអគ្គព្រះរាជអាជ្ញា មានសម្ព័ន្ធភាពយ៉ាងជិតដិតជាមួយគណបក្សកាន់អំណាច ហើយត្រូវបានជ្រើសរើសសំរាំងដោយមន្ត្រីរដ្ឋាភិបាល ។ វិជ្ជាជីវៈផ្លូវច្បាប់ដែលឯករាជ្យ មិនអាចលូតលាស់ នៅក្រោមការត្រួតត្រាដ៏តឹងរឹងបែបកុម្មុយនីស្តនេះបានឡើយ ។

ប្រព័ន្ធនេះបានផ្លាស់ប្តូរយ៉ាងខ្លាំង ពេលដែលគណៈមេធាវីបានចាប់ផ្ដើមដំណើរការនៅក្នុងឆ្នាំ១៩៩៥[២៣] ។ ចាប់ពីពេលនោះរៀងមក ស្ថាប័នក្រៅរដ្ឋាភិបាលនេះ បានធ្វើសេចក្ដីសម្រេចចិត្តដោយឯករាជ្យលើការអនុវត្តន៍ច្បាប់ទាំងអស់[២៤] ។ នៅក្នុងឆ្នាំ១៩៩៥ នេះដដែល មេធាវីមួយក្រុមដំបូងបំផុតដែលមានចំនួន ៣៨នាក់

[២៣] អ្នកអាចរកឃើញ បទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីតាមរយៈ www.ifrance.com/cambodialaw/judicial/jud008g.htm

[២៤] សូមមើលមាត្រា ៣១-៣៩ នៃលក្ខន្តិកៈមេធាវីដែលកំណត់នូវការយល់ព្រមចូលក្នុងវិជ្ជាជីវៈច្បាប់ និងការបណ្ដុះបណ្ដាលផ្នែកច្បាប់ ។ លក្ខន្តិកៈមេធាវីក៏បានចែងនៅក្នុងមាត្រា១ និងមាត្រា៤ ផងដែរថា គ្មានជនណាអាចប្រកបមុខរបរជាមេធាវីបានទេ ប្រសិនបើជននោះមិនមែនជាសមាជិកនៃគណៈមេធាវី ។ ចំណុចនេះ ធានានូវឯករាជភាពរបស់គណៈមេធាវីពីឥទ្ធិពលណាមួយរបស់រដ្ឋាភិបាល ។

បានធ្វើសច្ចាប្រណិធានចូលកាន់អាជីពជាមេធាវីរបស់ពួកគេ ហើយបានក្លាយសមាជិករបស់គណៈមេធាវី[២៥] ។ នៅក្នុងឆ្នាំ១៩៩៦ ចំនួនមេធាវីសរុបបានកើនឡើងដល់ ៥៤នាក់ ។ នៅក្នុងឆ្នាំ ២០០៣ មានមេធាវីចំនួន ១៩៧នាក់កំពុង អនុវត្តវិជ្ជាជីវៈរបស់ពួកគេ[២៦] ។

## ខ. ការការពារសំរាប់វិជ្ជាជីវៈផ្លូវច្បាប់ឯករាជ្យ

ការដែលសំខាន់បំផុត គឺមេធាវីអាចបំពេញមុខងាររបស់ខ្លួន ដោយគ្មានការកំហិត ឬការជ្រៀតជ្រែកដែលមិនសមស្រប ពីព្រោះ ជាទូទៅពួកគេ ដើរតួនាទីដ៏សំខាន់នៅក្នុងរដ្ឋបាលយុត្តិធម៌ត្រឹមត្រូវ និងក្នុងការបង្កើតនីតិរដ្ឋ ។

ស្ថាប័នដែលតំណាងឱ្យមេធាវី គឺគណៈមេធាវី មិនមែនជាផ្នែកមួយនៃអំណាចរដ្ឋទេ (អង្គនីតិប្រតិបត្តិ អង្គនីតិបញ្ញត្តិ និងស្ថាប័នតុលាការ) ប៉ុន្តែ វាជាផ្នែកមួយនៃសង្គមស៊ីវិល ។ គណៈមេធាវីជាអង្គការក្រៅរដ្ឋាភិបាល ដែលត្រូវបានការពារដោយច្បាប់ជាក់លាក់មួយ (ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី) ពីព្រោះថា វាមានតួនាទីដែលឋិតថេរ នៅក្នុងការពង្រឹងនីតិរដ្ឋ និងការពារសិទ្ធិរបស់ប្រជាពលរដ្ឋ ។




នីតិរដ្ឋពុំអាចប្រព្រឹត្តិទៅបានឡើយ នៅក្នុងប្រទេសណាក៏ដោយ ប្រសិនបើមេធាវីមិនបានដើរតួនាទីសំខាន់ក្នុងការប្រើច្បាប់ ការបកស្រាយច្បាប់ ពន្យល់អំពីច្បាប់ដល់ប្រជាជន និងក្នុងការជួយធ្វើវិសោធនកម្មច្បាប់ក្នុងករណីដែលច្បាប់នោះ មិនអាចបំពេញតំរូវការរបស់ប្រជាពលរដ្ឋបានតទៅទៀតនោះ ។ មេធាវីត្រូវតែដើរតួនាទីដ៏សកម្មនៅក្នុងសាខានៃអំណាចទាំងអស់: នៅក្នុង**ដំណើរការនីតិកម្ម** ដោយការផ្តល់បទពិសោធន៏ផ្នែកច្បាប់ក្នុងជីវិតប្រចាំរបស់ពួកគេដល់អ្នកធ្វើច្បាប់ នៅក្នុង**ដំណើរការនៃការប្រតិបត្តិច្បាប់** ដោយការការពារសិទ្ធិរបស់ប្រជាពលរដ្ឋ និងដាក់ពាក្យបណ្តឹងទៅអាជ្ញាធរ ក្នុងករណីមានការរំលោភច្បាប់ និងនៅក្នុង**ដំណើរការតុលាការ** ដោយធ្វើជាតំណាងកូនក្តីរបស់ខ្លួននៅចំពោះមុខតុលាការ និង បញ្ចេញមតិជំទាស់តាមផ្លូវច្បាប់ទាមទារសិទ្ធិឱ្យពួកគេ ។

[២៥] សំរាប់ព័ត៌មានលំអិតបន្ថែមអំពីប្រវត្តិនៃវិជ្ជាជីវៈមេធាវីកម្ពុជា សូមមើល : "ប្រព័ន្ធច្បាប់កម្ពុជា" បោះពុម្ពផ្សាយនៅក្នុងឆ្នាំ១៩៩៨ដោយមជ្ឈមណ្ឌលអភិវឌ្ឍន៏ធនធានច្បាប់កម្ពុជា (CLRDC) ទំព័រ១៥០-១៥២ ។

[២៦] របាយការប្រចាំឆ្នាំរបស់គណៈមេធាវីឆ្នាំ២០០៣ - នៅក្នុងឆ្នាំ២០០៣ គណៈមេធាវីមានសមាជិកសរុបចំនួន ៣២៨នាក់ ដែលក្នុងនោះ ៥៣នាក់ជាស្ត្រី ។

មេធាវីមាន**ឋានៈដូចគ្នានឹងចៅក្រម ឬព្រះរាជអាជ្ញាដែរ** ។ ឧទាហរណ៍ ឋានៈដូចគ្នានេះក៏ត្រូវតែឆ្លុះបញ្ចាំងនៅក្នុងការរៀបចំបន្ទប់តុលាការផងដែរ ។ ការងាកចេញពីគោលការណ៍នៃ "សមភាពផ្នែកអាវុធ" (មានន័យថា ជាវិធានការក្នុងការតវ៉ាក្តីដូចៗគ្នា) ដែលថា ភាគីជំលោះទាំងពីរ ត្រូវទទួលបានឱកាស និងសិទ្ធិដូចគ្នា ។



ឧទាហរណ៍:

វាមិនសមស្របទៅនឹងសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មេធាវី ប្រសិនបើគេដាក់ឱ្យមេធាវីអង្គុយលើតុកញ្ចាស់តូចមួយនៅកៀនបន្ទប់តុលាការ ខណៈដែលចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជីអង្គុយនៅលើតុ និងកៅអីដែលមានការតុបតែងលំអស្អាតខ្ពស់ជាងជនជាប់ចោទ និងមេធាវី ដូចដែលគេនៅតែអនុវត្តនៅក្នុងបន្ទប់តុលាការជាច្រើននៅក្នុងប្រទេសកម្ពុជានៅឡើយនោះ[២៧] ។

ជាគំរូល្អមួយនៅតុលាការខេត្តសៀមរាប ដែលតុរបស់មេធាវី និងព្រះរាជអាជ្ញា ដាក់នៅកំពស់ស្មើគ្នា[២៨] ។

**ករណីយកិច្ច និងសិទ្ធិ**របស់មេធាវីខាងក្រោមនេះ គឺជាប្រព័ន្ធមួយនៃ**ការពិនិត្យ និងតុល្យភាព** ដើម្បីផ្តល់និងធានាឱ្យបាននូវអំណាចចំពោះពួកគេ ក៏ប៉ុន្តែស្របពេលជាមួយគ្នានេះដែរ ក៏ដើម្បីបង្កា ការពារកុំឱ្យពួកគេប្រើអំណាចខុសផងដែរ ។

ករណីយកិច្ច និងសិទ្ធិទាំងនេះ មានចែងនៅក្នុង:

**"គោលការណ៍ណែនាំជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពី តួនាទីរបស់មេធាវីកម្ពុជា" ឆ្នាំ១៩៩០**[២៩]

នៅក្នុង

**"លក្ខន្តិកៈមេធាវីកម្ពុជា"**[៣០]

នៅក្នុង

**"ក្រមសីលធម៌សំរាប់មេធាវី"**[៣១]

និងនៅក្នុង**ច្បាប់នីតិវិធី**ផងដែរ ។

[២៧] ឧទាហរណ៍ នៅតុលាការខេត្តកណ្តាល
[២៨] មើលសៀវភៅស្តីពី "ការកាត់ក្តីនៅកម្ពុជា" សរសេរដោយលោក សុក សំអឿន នៅក្នុងផ្នែក "ការធ្លាក់ចុះនៃតុលាការយុត្តិធម៌នៅអាស៊ី" ទំព័រទី ១៣៩
[២៩] សូមមើល www1.umn.edu/humanrts/instree/i3bprl.htm
[៣០] សូមមើល http://www.cdpcambodia.org/bar_law.asp
[៣១] សូមមើល http://www.bigpond.com.kh/Council of Jurists/Judicial/jud002g.htm

## I) ករណីយកិច្ចរបស់មេធាវី[៣២] :

ជាទូទៅនៅក្នុងការអនុវត្តន៍ការងាររបស់ពួកគេ មេធាវីត្រូវពិចារណាអំពីភារកិច្ច ៣ សំខាន់ៗ: ភារកិច្ចចំពោះវិជ្ជាជីវៈមេធាវីផ្ទាល់ ចំពោះអតិថិជន និងចំពោះតុលាការ ។




### ១) ករណីយកិច្ចចំពោះវិជ្ជាជីវៈ

មេធាវីគួរចេះរក្សាកេរ្តិ៍ឈ្មោះ និងភាពឋិតថេរនៃវិជ្ជាជីវៈ ហើយមិនគួរជ្រើសរើសវិជ្ជាជីវៈនេះ ព្រោះតែវិជ្ជាជីវៈនេះ អាចធ្វើឱ្យខ្លួនមានកេរ្តិ៍ឈ្មោះខ្ពង់ខ្ពស់ មានឥទ្ធិពល និងអាចមានប្រាក់ចំណូលច្រើនឡើយ ។ ជាដំបូងមេធាវីត្រូវប្រកាន់ខ្ជាប់នូវបមាណីយ (កំរិត) ខ្ពស់នៃការប្រព្រឹត្ត និងត្រូវចងចាំជានិច្ចថា ខ្លួនត្រូវបំរើសាធារណជនជាមុនសិន ។

| |
|---|
| មាត្រា១ នៃលក្ខន្តិកៈមេធាវីៈ |
| វិជ្ជាជីវៈមេធាវី គឺជាវិជ្ជាជីវៈឯករាជ្យ និងសេរី ដែលចូលរួមបំរើវិស័យយុត្តិធម៌ ។ វិជ្ជាជីវៈមេធាវី ប្រព្រឹត្តទៅបានតែក្នុងក្របខ័ណ្ឌនៃគណៈមេធាវី ។ |

| |
|---|
| ប្រការ១២ នៃគោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី (BPRL): |
| នៅគ្រប់កាលៈទេសៈ មេធាវីត្រូវរក្សាកិត្តិយស និងសេចក្តីថ្លៃថ្នូរនៃវិជ្ជាជីវៈ របស់ខ្លួន ថាជាទីភ្នាក់ងារដ៏សំខាន់នៃរដ្ឋបាលយុត្តិធម៌ ។ |

មេធាវីម្នាក់ អាចលើកកំពស់កិត្តិយស និងសេចក្តីថ្លៃថ្នូរនៃវិជ្ជាជីវៈរបស់ខ្លួនបានដោយៈ

**ក) ការចៀសវាងជាដាច់ខាតនូវទំនាស់រវាង ករណីយកិច្ចវិជ្ជាជីវៈ និងផលប្រយោជន៍ផ្ទាល់ខ្លួនៈ**

ផលប្រយោជន៍យុត្តិធម៌ ត្រូវស្ថិតនៅពីលើផលប្រយោជន៍ដទៃទៀតទាំងអស់ ។

[៣២] សំរាប់ព័ត៌មានបន្ថែម សូមមើល "ការទទួលខុសត្រូវផ្នែកវិជ្ជាជីវៈ" ដោយលោក និក រីន និង លី យូម៉េង (មជ្ឈមណ្ឌលអប់រំច្បាប់សហគមន៍ - CLEC)

ឧទាហរណ៍:

- មេធាវីម្នាក់ មិនអាចលាយឡំផលប្រយោជន៍ផ្ទាល់ខ្លួន តួនាទីនយោបាយ ឬតំណែងសាធារណៈរបស់ខ្លួន ជាមួយការអនុវត្តន៍ច្បាប់បានឡើយ ។ សកម្មភាពទាំងនេះ នឹងមានទំនាស់ដោយស្វ័យប្រវត្តិជាមួយកាតព្វកិច្ចផ្លូវច្បាប់ ជាមេធាវីរបស់ខ្លួន ក្នុងការបំរើវិស័យយុត្តិធម៌ និងផលប្រយោជន៍នៃកូនក្តីរបស់ខ្លួន (សូមមើលមាត្រា៥៣ និងមាត្រា៥៤ នៃលក្ខន្តិកៈមេធាវី) ។

នៅក្នុងសង្គមដែលឆ្លងកាត់អន្តរកាលដូចជាប្រទេសកម្ពុជា ដែលនៅតែកំពុងកសាងលទ្ធិប្រជាធិបតេយ្យនៅឡើយ ការបំពេញមុខងារផ្នែកនយោបាយផ្សេងៗ ដូចជា ការធ្វើជាសមាជិករដ្ឋសភា ឬការធ្វើជាប្រធានគណបក្សនយោបាយ គួរតែស្ថិតនៅដាច់ដោយឡែកពីការប្រកបវិជ្ជាជីវៈមេធាវី ពីព្រោះគ្រោះថ្នាក់នៃការលាយបញ្ចូលគ្នានៃផលប្រយោជន៍ផ្ទុយគ្នាមានច្រើនបំផុត ហើយអាចធ្វើឱ្យខូចខាតដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋបាន ។ ដូច្នេះ សំរាប់ផលប្រយោជន៍សាធារណៈ មេធាវីលះបង់ជាបណ្តោះអាសន្ន នូវផ្នែកខ្លះនៃសិទ្ធិក្នុងការបង្កើតសមាគម និងសិទ្ធិក្នុងការប្រមូលផ្តុំ និងសេរីភាពក្នុងការបញ្ចេញមតិរបស់ខ្លួន ។ នៅក្នុងសង្គម ដែលមានរចនាសម្ព័ន្ធប្រជាធិបតេយ្យដំណើរការរលូន ការផ្តុំបញ្ចូលគ្នានៃការប្រកបវិជ្ជាជីវៈជាមេធាវី និងជាអ្នកនយោបាយនៅពេលតំណាលគ្នា មិនបង្កឱ្យមានបញ្ហាណាមួយឡើយ ហើយត្រូវបានគេអនុញ្ញាត ព្រមទាំងមានការស្នើសុំឱ្យបញ្ចូលជំនាញការមេធាវីទៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តធំៗរបស់សង្គមទៀតផង ។

- នៅពេលដែលមេធាវីណាម្នាក់ មានការងារច្រើនពេកហើយនោះ ឬនៅពេលដែលករណីដែលត្រូវបានដាក់ជូនស្ថិតនៅក្រៅសមត្ថភាពរបស់ខ្លួននោះ មេធាវីមិនគួរទទួលការប្រគល់សិទ្ធិឱ្យជាតំណាងឡើយ ប៉ុន្តែគួរណែនាំកូនក្តីនោះ ឱ្យទៅរកមេធាវីម្នាក់ទៀត ។
- មេធាវីម្នាក់ គួរតែតំណាងចុងចោទម្នាក់បានហើយ នៅក្នុងរឿងក្តីមួយដែលមានចុងចោទច្រើន (មាត្រា ១៩ III នៃក្រមសីលធម៌សំរាប់មេធាវី) ពីព្រោះ ចុងចោទម្នាក់ៗ មានវិធីសាស្ត្រការពារ និងប្រយោជន៍រៀងៗខ្លួន ។ មេធាវី ត្រូវតែចៀសវាងឱ្យបាននូវឱកាសតិចតួចនៃទំនាស់ផលប្រយោជន៍ សូម្បីតែ មេធាវីត្រូវបាត់បង់អតិថិជន និងឱកាសរកប្រាក់ចំណូលក៏ដោយ ។

**ខ) សហប្រតិបត្តិការជាមួយគណៈមេធាវី** ដែលជាសមាគមវិជ្ជាជីវៈមេធាវីមួយ និងមេធាវីទាំងអស់ត្រូវតែជាសមាជិកនៃគណៈមេធាវីនេះ (មាត្រា៤ និងមាត្រា៨ I នៃលក្ខន្តិកៈមេធាវី) ។

ឧទាហរណ៍:

មេធាវី មានកាតព្វកិច្ចគោរពឱ្យបានដាច់ខាតនូវបំរាមនៃការផ្សាយពាណិជ្ជកម្ម (មាត្រា៥៧ នៃលក្ខន្តិកៈមេធាវី) ពីព្រោះ ការផ្សាយពាណិជ្ជកម្មជ្រុលហួសហេតុ អាចបណ្តាលឱ្យមានអ្នកយល់ខុស ហើយអាចប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរនៃវិជ្ជាជីវៈដែលមិនមែនជាពាណិជ្ជកម្ម ឬអាជីវកម្មមួយនោះឡើយ ប៉ុន្តែជាសេវាមួយដែលបំរើដល់វិស័យយុត្តិធម៌ ។

**គ) ការពង្រឹងនីតិរដ្ឋ:**

មេធាវីត្រូវធានាថា បុគ្គលគ្រប់រូបមានលទ្ធភាពទទួលបានសេវាផ្លូវច្បាប់ ។ មេធាវី គួរតែចូលរួមក្នុងកម្មវិធីជំនួយផ្លូវច្បាប់ ។

**ជំនួយផ្លូវច្បាប់** មិនមែនជាបញ្ហាសប្បុរសធម៌ទេ ប៉ុន្តែវាជាសិទ្ធិមនុស្សជាមូលដ្ឋាន[៣៣] ។

[៣៣] សូមមើល មាត្រា៧៦ II ចំនុច៤ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ (រដ្ឋកម្ពុជា ឆ្នាំ១៩៩៣) ដែលផ្តល់ការណាត់ជួបជាមួយមេធាវីដោយស្វ័យប្រវត្តិតែម្តង ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋមួយ (មិនមែនពីបទមជ្ឈឹមទេ) និងមិនអាចមានលទ្ធភាពជួលមេធាវីបានទេ ។

មាត្រា៧ UDHR:

មនុស្សគ្រប់រូបមានភាពស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិទទួលបាននូវការការពារផ្លូវច្បាប់ស្មើគ្នា ដោយគ្មានការរើសអើង ។

មាត្រា១៤ III (ឃ) ប្រយោគទី៣ ICCPR:

ក្នុងករណីនៃការសំរេចវិនិច្ឆ័យទោសឧក្រិដ្ឋ ជនជាប់ចោទគ្រប់ៗរូប មានសិទ្ធិស្មើៗគ្នាក្នុងការទទួលនូវកិច្ចធានាខ្លះៗដូចជា :

(ឃ) ...សាមីជនមានសិទ្ធិរើសស្មាក្តីដោយខ្លួនឯង ប្រសិនបើ ខ្លួនមានប្រាក់គ្រប់គ្រាន់សំរាប់បង់ថ្លៃឈ្នួល ។ ក្នុងករណីណាដែលចាំបាច់ តុលាការត្រូវតែងតាំងឱ្យស្មាក្តីឱ្យតំណាងជនជាប់ចោទដោយឥតគិតឈ្នួល ប្រសិនបើ សាមីជននេះ គ្មានមធ្យោបាយ ឬប្រាក់កាសគ្រាប់គ្រាន់ ។

ដូច្នេះ រដ្ឋាភិបាល ត្រូវផ្តល់ថវិកាឱ្យបានគ្រប់គ្រាន់ ព្រមទាំងធនធានដទៃទៀត ដើម្បីបំរើសេវាផ្លូវច្បាប់សំរាប់ប្រជាពលរដ្ឋក្រីក្រ និងជាចាំបាច់សំរាប់ជនដែលបាត់បង់ឱកាសដទៃទៀត មាត្រា៣ BPRL ។

បច្ចុប្បន្ននេះ ថវិកាជាតិនៃរដ្ឋាភិបាលកម្ពុជាមិនបានផ្តល់ការគាំទ្រផ្នែកស្ថាប័ន និងហិរញ្ញវត្ថុដល់ជនទាំងឡាយ ដែលមិនអាចការពារសិទ្ធិរបស់ពួកគេដោយខ្លួនឯងបានឡើយ ។ មានអង្គការតែ បី ប៉ុណ្ណោះដែលជួយដល់ជនក្រីក្រ និងជនបាត់បង់ឱកាសនានា ដូចជាកុមារ ជនជាតិភាគតិច ជនភៀសខ្លួន ឬជនពិការ ក្នុងការការពារសិទ្ធិរបស់ពួកគេ នៅចំពោះមុខតុលាការ គឺ:

- **"អង្គការជំនួយផ្លូវច្បាប់កម្ពុជា"** (LAC) ជាអង្គការក្រៅរដ្ឋាភិបាលមួយដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៥[៣៤] ។
- **"ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា"** (CDP) ជាអង្គការក្រៅរដ្ឋាភិបាលមួយដែលបានដំណើរការតាំងពីឆ្នាំ១៩៩៥[៣៥]
- **គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា** មាត្រា២៩ នៃលក្ខន្តិកៈមេធាវី ។

ការបរាជ័យរបស់រដ្ឋាភិបាលក្នុងការផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ ឬក្នុងការបំពេញតួនាទីផ្នែកស្ថាប័ន របស់ខ្លួននោះ មិនធ្វើឱ្យមេធាវី ឬគណៈមេធាវី បោះបង់ចោលកាតព្វកិច្ចវិជ្ជាជីវៈរបស់ពួកគេឡើយ ។ គណៈមេធាវីត្រូវតែផ្តល់សេវាផ្លូវច្បាប់ស្មើគ្នាដល់ជនទាំងឡាយគ្រប់រូប រួមទាំង ជនដែលជួបប្រទះបញ្ហាលំបាកដោយសាររស់នៅតំបន់ឆ្ងាយៗផង ។

ឧទាហរណ៍:

គណៈមេធាវី មានកាតព្វកិច្ចបង្កើតមជ្ឈមណ្ឌលច្បាប់ដោយបើកចំហនៅទូទាំងប្រទេស ដោយផ្អែកលើចំណាយផ្ទាល់ខ្លួន ដើម្បីដោះស្រាយបញ្ហានៃការបែងចែកមេធាវីមិនស្មើគ្នា និងការប្រមូលផ្តុំនៅក្នុងទីក្រុងភ្នំពេញរបស់ពួកគេ ។

[៣៤] សូមមើល www.lac.org.kh
[៣៥] សូមមើល www.cdpcambodia.org

**២) ករណីយកិច្ចចំពោះអតិថិជនៈ**

មេធាវីត្រូវតែបំពេញតួនាទីដើម្បីជាប្រយោជន៍របស់អតិថិជនដោយសេចក្តីក្លាហាន ស្មោះត្រង់ និងដោយបញ្ចេញឱ្យអស់នូវចំណេះដឹង និងសមត្ថភាពរបស់ខ្លួន ស្របតាមច្បាប់ ។

មេធាវីអាចធ្វើដូច្នេះបាន ដោយ[៣៦] :

ក) ធ្វើការសម្ភាសន៍អតិថិជនប្រកបដោយសេចក្តីព្យាយាមបំផុតអំពីរឿងក្តីនោះ

ខ) ធ្វើការស្រាវជ្រាវអំពីការពិត និងច្បាប់ទៅលើករណីនោះដោយយកចិត្តទុកដាក់

គ) ផ្តល់យោបល់ដល់អតិថិជនអំពីសិទ្ធិ និងកាតព្វកិច្ចផ្លូវច្បាប់ របស់ពួកគេ និង

ឃ) រៀបចំ និងបង្ហាញការទាមទារ/ការពារ សំរាប់អតិថិជននៅពេលជំនុំជំរះ

មុនពេលបំពេញកិច្ចការទាំងអស់នេះ វាជួយដល់ការធ្វើឱ្យទំនាក់ទំនងមានទំនុកចិត្ត និងការចុះហត្ថលេខាលើកិច្ចសន្យាជាលាយលក្ខណ៍អក្សរស្តីពី ថ្លៃចំណាយលើការធ្វើជាតំណាងផ្លូវច្បាប់ (មាត្រា៦៨ នៃលក្ខន្តិកៈមេធាវី[៣៧]) ។

មេធាវីត្រូវតែកសាងជំនឿ និងទំនុកចិត្តជាមួយអតិថិជន ដើម្បីការពារផលប្រយោជន៍របស់អតិថិជនឱ្យអស់ពីសមត្ថភាព ។ ករណីយកិច្ចនៃការរក្សាការសំងាត់ក្នុងវិជ្ជាជីវៈមានចែងយ៉ាងច្បាស់លាស់នៅក្នុងមាត្រា៥៨ នៃលក្ខន្តិកៈមេធាវី មាត្រា៧ នៃក្រមសីលធមិសំរាប់មេធាវី និងនៅក្នុងគោលការណ៍២២ នៃ BPRL ។

| |
|---|
| មាត្រា៥៨ នៃលក្ខន្តិកៈមេធាវី :<br><br>មេធាវី ត្រូវតែរក្សាការសម្ងាត់ជាដាច់ខាត ។ មេធាវី កំណត់តាមសតិសម្បជញ្ញៈរបស់ខ្លួន និងដោយមានការយល់ព្រមពីអតិថិជនផង នូវអ្វីដែលខ្លួនត្រូវលើកឡើង ដើម្បីការពារផលប្រយោជន៍របស់អតិថិជនដែលខ្លួនទទួលបន្ទុក ។<br>មេធាវី ពុំអាចបំពារបំពានលើការសម្ងាត់នៃវិជ្ជាជីវៈបានឡើយ ហើយក៏មិនអាចត្រូវបានបង្ខំឱ្យបំពារបំពានលើការសម្ងាត់នៃវិជ្ជាជីវៈរបស់ខ្លួន ទោះបី នៅមុខតុលាការក៏ដោយ ។<br>ត្រូវទុកជាការសម្ងាត់នៃវិជ្ជាជីវៈ ការពិគ្រោះយោបល់ និងការផ្តល់យោបល់ឯកសារក្រៅផ្លូវការទាំងឡាយ ដែលមេធាវីតាក់តែងឡើងសំរាប់អតិថិជនរបស់ខ្លួន លិខិតស្នាមទាំងឡាយដែលមេធាវី និងអតិថិជនរបស់ខ្លួន ផ្ញើទាក់ទងគ្នា ។ |

[៣៦] សូមមើលមាត្រា២ និងមាត្រា៣ នៃលក្ខន្តិកៈមេធាវីផង ។

[៣៧] សូមមើលមាត្រា២២ I នៃក្រមសីលធមិសំរាប់មេធាវីៈ "កិច្ចព្រមព្រៀងជាមុនមួយ អាចត្រូវបានបញ្ចប់ដោយកំណត់នូវតារាងតម្លៃ ឬវិធីសាស្ត្រនៃការបង្កើតប្រាក់ឈ្នួល"។ ជាអកុសល នៅក្នុងប្រទេសកម្ពុជា គេពុំទាន់ឃើញមាន "លក្ខន្តិកៈស្តីពីតម្លៃឈ្នួលរបស់មេធាវី" ដែលអាចជួយដោះស្រាយបញ្ហាពុករលួយ និងការប្រកួតប្រជែងមិនមានតុល្យភាពក្នុងចំណោមមេធាវីឡើយ ។ ភារកិច្ចមួយក្នុងចំណោមភារកិច្ចដ៏សំខាន់បំផុតនាពេលអនាគត សំរាប់គណៈមេធាវីគឺត្រូវធ្វើពង្រាងច្បាប់ប្រភេទនេះ ។

| |
|---|
| មាត្រា៧ នៃក្រមសីលធម៌សំរាប់មេធាវី :<br>មេធាវី ត្រូវមានកាតព្វកិច្ចរក្សាការសំងាត់ជាដាច់ខាត ។ ការសំងាត់ មិនអាចត្រូវបានបោះបង់ដោយបុគ្គលណាម្នាក់ឡើយ រួមទាំងតុលាការផង ។...<br>នៅពេលដែលមេធាវី ត្រូវឆ្លើយតបចំពោះវិធានការច្បាប់របស់អតិថិជនរបស់ខ្លួន នៅក្នុងក៏រិតចាំបាច់សំរាប់ការការពារអតិថិជននោះ ពុំមានកាតព្វកិច្ចក្នុងការរក្សាការសំងាត់ឡើយ ។ |

**៣) ករណីយកិច្ចចំពោះតុលាការ:**

តួនាទីចំបងរបស់មេធាវី គឺការជួយឱ្យតុលាការសម្រេចបានយុត្តិធម៌ស្របតាមច្បាប់ ។ អាស្រ័យហេតុនេះ មេធាវី មិនត្រូវដឹកនាំតុលាការឱ្យដើរផ្លូវខុស ឬបង្ហាញនូវភស្តុតាងដែលខ្លួនដឹងថាក្លែងក្លាយ ទោះបីជាការធ្វើបែបនេះ អាចជាប្រយោជន៍ដល់អតិថិជនក៏ដោយ ។ ផ្ទុយទៅវិញ មេធាវីពុំត្រូវបង្ហើបប្រាប់តុលាការនូវការពិតទាំងឡាយណាដែលមិនស្ថិតក្នុងផលប្រយោជន៍របស់អតិថិជនឡើយ បើទោះបីជា ការពិតទាំងនេះបង្ហាញនូវពិរុទ្ធភាពរបស់អតិថិជនក៏ដោយ ។ ការបង្ហាញពិរុទ្ធភាពគឺជាភារកិច្ចរបស់ព្រះរាជអាជ្ញា វាមិនមែនជាភារកិច្ចរបស់មេធាវីឡើយ!

## II) សិទ្ធិរបស់មេធាវី:

សិទ្ធិដូចរៀបរាប់តទៅនេះមានចែងនៅក្នុង "គោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី"(BPRL) ។

**១) សិទ្ធិក្នុងការបំពេញមុខងារវិជ្ជាជីវៈដោយគ្មានការជ្រៀតជ្រែក:**

| |
|---|
| ប្រការ១៦ នៃ BPRL:<br>រដ្ឋាភិបាលទាំងឡាយត្រូវធានាថា មេធាវីទាំងអស់ :<br>ក) មានសមត្ថភាពបំពេញមុខងារវិជ្ជាជីវៈគ្រប់ប្រភេទរបស់ខ្លួន ដោយគ្មានការបំភិតបំភ័យ ការយាយី ឬការជ្រៀតជ្រែកមិនសមស្រប<br>ខ) មានសមត្ថភាពធ្វើដំណើរ និងពិគ្រោះយោបល់ជាមួយអតិថិជនរបស់ខ្លួនដោយសេរី ទាំងនៅក្នុងប្រទេសរបស់គេផ្ទាល់ និងនៅក្រៅប្រទេស ។ និង<br>គ) មិនត្រូវរងទុក្ខ ឬទទួលការគំរាមកំហែងដោយការកាត់ទោស ឬទណ្ឌកម្មរដ្ឋបាល សេដ្ឋកិច្ច ឬទណ្ឌកម្មដទៃទៀត ចំពោះសកម្មភាពណាមួយដែលត្រូវបានធ្វើឡើងស្របទៅតាមករណីយកិច្ចបទដ្ឋាន និងក្រមសីលធម៌វិជ្ជាជីវៈដែលត្រូវបាន ទទួលស្គាល់ឡើយ ។ |

ក) ប្រសិនបើ មេធាវីណាម្នាក់ បានទទួលរងនូវអំពើអយុត្តិធម៌ពីសំណាក់ចៅក្រមណាម្នាក់ ពួកគេអាចដាក់ពាក្យបណ្តឹងទៅប្រធានតុលាការ (សូមមើល មាត្រា២៤ IV នៃក្រមសីលធម៌សំរាប់មេធាវី) ទៅប្រធានគណៈមេធាវី ឬទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដោយផ្ទាល់ ដែលអាចធ្វើអន្តរាគមន៍បាន ។ មេធាវី

ថែមទាំងអាចជំទាស់ដល់ចៅក្រមក្នុងការធ្វើសេចក្តីសម្រេចបានទៀតផង ប្រសិនបើ សញ្ញានៃការវិនិច្ឆ័យជាមុន (Prejudice) ឬការបោកបញ្ឆោត ឬការរារាំង (មើលឧទាហរណ៍ មាត្រា២៨ នៃពង្រាងច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណី ខែមិថុនា ឆ្នាំ២០០៣ និងមាត្រា៤៧៦-៤៨៤ នៃពង្រាងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៣) ។ ចៅក្រមអាចបដិសេធនូវការជំទាស់របស់មេធាវី ក៏ប៉ុន្តែ ការជំទាស់នោះ នឹងត្រូវបានរក្សាទុក នៅក្នុងឯកសារដែលនឹងជួយដល់គូភាគី នៅពេលដែលបញ្ហានោះត្រូវបានធ្វើឧទ្ធរណ៍ទៅតុលាការមួយថ្នាក់ទៀត ដោយមានចៅក្រមថ្មី ដែលនឹងពិចារណាលើករណីនោះខុសគ្នាពីចៅក្រមមុន ។

<u>ឧទាហរណ៍នៃការប្រព្រឹត្តិដោយអយុត្តិធម៌:</u>

- មេធាវីត្រូវបានគេសុំប្រាក់ មុនពេលទទួលសិទ្ធិដើម្បីពិនិត្យលើឯកសារនៃរឿងក្តីនោះ
- ចៅក្រមប្រើប្រាស់ចម្លើយសារភាពមួយដែលទទួលបានដោយមធ្យោបាយទណ្ឌកម្ម ថាជាវត្ថុតាងនៃពិរុទ្ធភាព (សូមមើលមាត្រា២៤ III នៃក្រមព្រហ្មទណ្ឌអន្តរកាល)
- ចៅក្រមរំលោភសិទ្ធិណាមួយនៃសិទ្ធិមេធាវីដែលមានរៀបរាប់នៅជំពូកក្រោយ ។

ខ) ការអនុវត្តន៍របស់គណៈមេធាវី ដើម្បីដាក់កំហិតលើការចូលជាសមាជិករបស់ខ្លួន ជ្រៀតជ្រែកដល់សិទ្ធិរបស់មេធាវីក្នុងការអនុវត្តន៍ដោយសេរីនូវវិជ្ជាជីវៈរបស់ពួកគេ (មាត្រា៣៦ I CC) ។

<u>ឧទាហរណ៍ចំពោះការដាក់កំហិតហួសហេតុ:</u>

- មជ្ឈមណ្ឌលបណ្តុះបណ្តាលច្បាប់ដែលចេញនូវ "វិញ្ញាបនបត្រជំនាញវិជ្ជាជីវៈ" ដើម្បីក្លាយជាសមាជិករបស់គណៈមេធាវីនោះមិនបានកំណត់<u>ប្រកបដោយតម្លាភាព</u> នូវលក្ខខណ្ឌដែលត្រូវបំពេញ ដើម្បីឱ្យបានជាប់ការប្រឡងរបស់មេធាវីឡើយ[៣៨] ។ មជ្ឈមណ្ឌល ក៏កំណត់នូវចំនួនមេធាវីជាអតិបរមាដែលត្រូវជ្រើសរើសសំរាប់ការប្រឡងនោះដែរ ។ ប៉ុន្តែ ពុំមានហេតុផលអ្វីសំរាប់ការកំណត់នេះ ប្រសិនបើ យើងគិតដល់ប្រទេសកម្ពុជាដែលមានមេធាវីមិនលើសពី ២០០នាក់ សំរាប់បំរើប្រជាជនកម្ពុជាសរុបចំនួន ១៤លាននាក់ នោះ ។
- គណៈមេធាវី បកស្រាយមាត្រា៣២ ចំនុចទី១ នៃលក្ខន្តិកៈមេធាវី យ៉ាងចង្អៀតចង្អល់បំផុតដោយ តំរូវឱ្យមានការបំរើការវិជ្ជាជីវៈរយៈពេល ពីរឆ្នាំ នៅក្នុងអង្គការរបស់<u>រដ្ឋាភិបាល</u> ។ ជនណាដែលបានបំរើការផ្នែកច្បាប់នៅក្នុង<u>ក្រុមហ៊ុនឯកជន ឬអង្គការក្រៅរដ្ឋាភិបាល</u> ត្រូវបានគេបដិសេធមិនឱ្យចូលសមាជិករបស់គណៈមេធាវី និងមិនអាចប្រកបវិជ្ជាជីវៈជាមេធាវីបាន ។

ការបដិសេធន៍នូវលទ្ធភាពចូលជាសមាជិកនៃគណៈមេធាវី ប៉ះពាល់ដល់ សិទ្ធិសេរីភាពក្នុងការប្រកបវិជ្ជាជីវៈរបស់មេធាវី (មាត្រា៣៦ I CC) ។

ប៉ុន្តែយោងតាម មាត្រា៣៦ I CC សេរីភាពក្នុងការប្រកបវិជ្ជាជីវៈ អាចត្រូវបានដាក់កំហិតក្នុងគោលបំណងមួយដើម្បីធានាដល់ "សមត្ថភាព" ក្នុងការអនុវត្តន៍វិជ្ជាជីវៈ ឬដើម្បីការពារ "តំរូវការរបស់សង្គម" តែប៉ុណ្ណោះ ។ យើងពុំចាំបាច់សង្ស័យឡើយថា សង្គមកម្ពុជាកំពុងត្រូវការមេធាវីឱ្យបានច្រើនតាមដែលខ្លួនអាចធ្វើទៅបាន ។ គេត្រូវការចំណាយ ពេលវេលាច្រើនរហូតដល់ "ចំនួនមេធាវីច្រើនលើសលប់" នឹងលេចឡើងដើម្បីបំរើប្រទេសនេះ[៣៩] ។

---

[៣៨] សូមមើលមាត្រា៩ នៃបទបញ្ជាផ្ទៃក្នុងរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា: "មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ" កំណត់ខ្លឹមសារ ដែល CAPA (វិញ្ញាបនបត្រនៃសម្បទាក្នុងវិជ្ជាជីវៈមេធាវី) ត្រូវយកធ្វើជាមូលដ្ឋាន ព្រមទាំងវិធីសាស្ត្រនៃការប្រឡងផង ។ លោក-អ្នក អាចរកបទបញ្ជាផ្ទៃក្នុងរបស់គណៈមេធាវីនៅលើ: www.ifrance.com/cambodialaw/judicial/jud008g.htm

[៣៩] ពីព្រោះវាករណីនៅក្នុងប្រទេសអាល្លឺម៉ង់ដែលមានមេធាវីប្រមាណ៩០ ០០០ នាក់សំរាប់ប្រជាជន ៨០លាននាក់ ។

ហើយមានតែឧក្រិដ្ឋជន មេធាវីក្ស័យធន និងជនដែលមិនបានទទួលចំនួនពិន្ទុពិសេសនៅក្នុងការប្រឡងជាមេធាវីប៉ុណ្ណោះ ដែលអាចត្រូវបានដាក់កំហិត នៅក្នុងសិទ្ធិសេរីភាពក្នុងការប្រកបវិជ្ជាជីវៈដោយសេរីរបស់ពួកគេ និងត្រូវបដិសេធមិនឱ្យចូលជាសមាជិកគណៈមេធាវី ។

**២) សិទ្ធិទទួលបានការការពារៈ**

មេធាវី មានសិទ្ធិធ្វើការនៅក្នុងបរិយាកាសសុវត្ថិភាពមួយ ដោយគ្មានការភ័យខ្លាចដោយសារការគំរាម-កំហែង និងការបង្ខិតបង្ខំ ។

> ប្រការ១៧ BPRL:
>
> ប្រសិនបើសន្តិសុខរបស់មេធាវីត្រូវបានគំរាមកំហែង ដោយសារការបំពេញមុខងាររបស់ខ្លួន ពួកគេត្រូវទទួលបានការការពារគ្រប់គ្រាន់ពីអាជ្ញាធរ ។

**៣) សិទ្ធិទទួលបានអភ័យឯកសិទ្ធិរដ្ឋប្បវេណី និងព្រហ្មទណ្ឌៈ**

មេធាវី ការពារប្រយោជន៍កូនក្តីរបស់ខ្លួន ដោយប្រើប្រាស់នូវព័ត៌មានរបស់កូនក្តីនៅចំពោះមុខតុលាការ ។ ប្រសិនបើព័ត៌មានទាំងនេះ ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរក្តី មើលទៅពិតប្រាកដ គួរឱ្យទុកចិត្ត និងគួរឱ្យជឿជាក់បាន (ដែលជាក់ស្តែងក្នុងករណីខ្លះ វាមិនពិតប្រាកដ មិនគួរឱ្យទុកចិត្ត និងមិនគួរឱ្យជឿជាក់ នោះទេ) មេធាវី មិនត្រូវបានគេអាចចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌនោះទេ ដូចជា ពីបទការបង្ហាញដោយបន្លំ ។

> ប្រការ២០ BPRL:
>
> មេធាវី ត្រូវមានអភ័យឯកសិទ្ធិរដ្ឋប្បវេណី និងព្រហ្មទណ្ឌសំរាប់សេចក្តីថ្លែង-ការណ៍ ដែលបានធ្វើឡើងដោយសេចក្តីស្មោះត្រង់ នៅក្នុងចម្លើយថាព្រមទទួល ឬមិនព្រមទទួលជាលាយលក្ខណ៍អក្សរ ឬ ផ្ទាល់មាត់នៅក្នុងការបង្ហាញខ្លួនចំពោះមុខតុលាការ សាលាក្តី ឬច្បាប់ ឬអាជ្ញាធររដ្ឋបាលដទៃទៀត ។

ប៉ុន្តែ មេធាវីម្នាក់ មិនដែលត្រូវបានអនុញ្ញាតឱ្យធ្វើការភូតកុហកដោយចេតនា ក្នុងនាមជាកូនក្តីរបស់ខ្លួនដើម្បីឈ្នះក្តីនោះទេ ។

**៤) សិទ្ធិក្នុងការតំណាងកូនក្តីៈ**

មេធាវី **ស្វ័យត** និងជ្រើសរើសកូនក្តីរបស់ខ្លួនបាន**ដោយសេរី** ។ មេធាវីអាចបដិសេធក្នុងការធ្វើជាតំណាងកូនក្តីនៅក្នុងករណីណាមួយក៏បាន ក៏ប៉ុន្តែមេធាវីអាចទទួលធ្វើជាតំណាងកូនក្តីបានដោយសេរី ។ មេធាវី អាចតំណាងកូនក្តីណាម្នាក់ដោយមានការយល់ព្រមពីកូនក្តីនោះ ។ ការបដិសេធន៍ក្នុងការធ្វើជាតំណាងកូនក្តីមានតម្លៃស្មើគ្នានឹងការបដិសេធន៍នូវសិទ្ធិក្នុងការបញ្ចេញមតិនៅចំពោះមុខតុលាការ (មាត្រា៣៩ CC) ។ តុលាការមិនអាចបដិសេធ មេធាវីមិនឱ្យតំណាងកូនក្តីបានទេ ប្រសិនបើមេធាវីនោះធ្វើបែបនេះដោយមានការយល់ព្រមពីកូនក្តីនោះ ។ តុលាការ ត្រូវគោរពសេចក្តីសំរេចចិត្តរបស់កូនក្តី ។ បើមិនដូច្នោះទេ តុលាការអាចជ្រៀតជ្រែកដោយខុសច្បាប់ ចូលក្នុងសិទ្ធិមនុស្សរបស់មេធាវីក្នុងការអនុវត្តន៍វិជ្ជាជីវៈរបស់ពួកគេ (មាត្រា៣៦ I CC) ។

| |
|---|
| ប្រការ១៩ BPRL: |
| ពុំមានតុលាការ ឬអាជ្ញាធររដ្ឋបាលណាមួយ ... ត្រូវបដិសេធមិនទទួលស្គាល់សិទ្ធិរបស់មេធាវី ក្នុងការបង្ហាញខ្លួនចំពោះមុខតុលាការ ឬអាជ្ញាធរនោះ ដើម្បីតំណាងឱ្យកូនក្តីរបស់ខ្លួនឡើយ លុះត្រាតែ មេធាវីនោះពុំមាន លក្ខណៈសម្បត្តិគ្រប់គ្រាន់ស្របតាមច្បាប់ និងការអនុវត្តន៍របស់ជាតិ ... ។ |

**៥) សិទ្ធិក្នុងការទទួលបានកូនក្តី និងព័ត៌មានចាំបាច់សំរាប់ការពារកូនក្តី:**

ប្រការ៥ និង ៧ នៃ "គោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី" បានចែងពីសិទ្ធិរបស់ជនជាប់ចោទដែលត្រូវស្វែងរកជំនួយពីអ្នកការពារក្តី :

| |
|---|
| ប្រការ៥ BPRL:<br>រដ្ឋាភិបាល ត្រូវធានាថា អាជ្ញាធរមានសមត្ថកិច្ចត្រូវជូនដំណឹងជាបន្ទាន់ដល់ជនគ្រប់រូបអំពីសិទ្ធិរបស់ពួកគេ ក្នុងការទទួលបានជំនួយពីមេធាវីតាមការជ្រើស-រើសរបស់ពួកគេ នៅពេលឃាត់ខ្លួន ឬឃុំឃាំង ឬនៅពេលដែលត្រូវបានចោទពីបទល្មើសណាមួយ ។ |
| ប្រការ៧ BPRL:<br>រដ្ឋាភិបាលត្រូវធានាបន្ថែមថា ជនគ្រប់រូបដែលត្រូវឃាត់ខ្លួន ឬឃុំឃាំង ដោយមាន ឬគ្មានការចោទពីបទល្មើសណាមួយ ត្រូវមានលទ្ធភាពជាបន្ទាន់ក្នុងការស្វែងរកមេធាវី ហើយនៅក្នុងករណីណាក៏ដោយមិនត្រូវឱ្យលើសពីរយៈពេល ៤៨ម៉ោង ក្រោយការឃាត់ខ្លួន ឬ ការឃុំឃាំងឡើយ ។ |

មាត្រា១០ នៃក្រមព្រហ្មទណ្ឌអន្តរកាល មានលក្ខណៈស្របគ្នាជាមួយមាត្រា៣៩ CC ដែលផ្តល់ដល់ប្រជាពលរដ្ឋគ្រប់រូបក្នុងការបញ្ចេញមតិនៅចំពោះមុខតុលាការ:

| |
|---|
| មាត្រា១០ នៃក្រមព្រហ្មទណ្ឌអន្តរកាល: ជំនួយផ្នែកច្បាប់ |
| ១- សិទ្ធិពឹងពាក់មេធាវីឬទីប្រឹក្សា ត្រូវបានធានាជូនជនគ្រប់រូបដែលជាប់ចោទ ពីបទមជ្ឈិមឬបទឧក្រិដ្ឋ។<br>២- ទោះបីបទល្មើសនោះធ្ងន់ស្រាលយ៉ាងណាក៏ដោយ គ្មានជនណាម្នាក់ត្រូវជាប់ឃុំឃាំងនៅលើទឹកដីកម្ពុជាលើសពីរយៈពេល ៤៨ម៉ោង ដោយគ្មានបានទទួលជំនួយពីទីប្រឹក្សា ពីមេធាវី ឬពីអ្នកតំណាង ដែលបទប្បញ្ញត្តិនេះបានអនុញ្ញាតឡើយ។ |

### ៦) សិទ្ធិមិនត្រូវសំដែងសមានចិត្តជាមួយកូនក្តី ឬបុព្វហេតុរបស់កូនក្តីៈ

> ប្រការ១៨ BPRL:
>
> មេធាវីមិនត្រូវសំដែងសមានចិត្តជាមួយកូនក្តី ឬបុព្វហេតុរបស់កូនក្តីក្នុងការបំពេញមុខងាររបស់ខ្លួនឡើយ ។

ការងាររបស់មេធាវីសំរាប់កូនក្តីមិនគួរត្រូវបានគេមើលឃើញថា ជាការបង្ហាញថា មេធាវីមានសមានចិត្តជាមួយ ឬយល់ព្រមជាមួយជំនឿ ឬទង្វើរបស់កូនក្តីឡើយ!

### ៧) សិទ្ធិក្នុងការទទួលបានការសំងាត់ផ្នែកវិជ្ជាជីវៈមេធាវីៈ

មេធាវី ក៏ដូចជាវេជ្ជបណ្ឌិតដែរ អាចទទួលបាននូវទំនាក់ទំនងជាសំងាត់ជាមួយនឹងអតិថិជនរបស់ខ្លួន ។ មធ្យោបាយណាមួយដែលប្រែក្លាយការសន្ទនារវាងមេធាវី និងកូនក្តីរបស់គាត់ ឱ្យបើកចំហរ គឺជាមធ្យោបាយដែលផ្ទុយនឹងច្បាប់ ។ ការចំលងឯកសារ ឬការថតសំលេងដោយសំងាត់ គឺជាកម្មវត្ថុនៃការដាក់ទណ្ឌកម្ម ។ គ្មានមេធាវីណា ត្រូវបានគេបង្ខំឱ្យបើកកកាយអំពីការប្រាស្រ័យទាក់ទងរបស់គាត់ជាមួយនឹងកូនក្តីនោះទេ ។

> ប្រការ២២ BPRL:
>
> រដ្ឋាភិបាលត្រូវទទួលស្គាល់ និងគោរពថា រាល់ការប្រាស្រ័យទាក់ទង និងការពិគ្រោះយោបល់រវាងមេធាវី និងកូនក្តីរបស់ពួកគេ នៅក្នុងទំនាក់ទំនងវិជ្ជាជីវៈរបស់ពួកគេគឺជាការសំងាត់ ។

### ៨) សិទ្ធិទទួលបានការអប់រំ និងការបណ្តុះបណ្តាលៈ

> ប្រការ៩ BPRL:
>
> រដ្ឋាភិបាល សមាគមវិជ្ជាជីវៈមេធាវី និងគ្រឹះស្ថានសិក្សា ត្រូវធានាថា មេធាវីមានការអប់រំ និងការបណ្តុះបណ្តាលសមស្រប និងត្រូវឱ្យគេយល់ច្បាស់អំពីឧត្តមគតិ និងករណីយកិច្ចផ្នែកសីលធម៌របស់មេធាវី និងករណីយកិច្ចនៃសិទ្ធិមនុស្ស ព្រមទាំងសេរីភាពជាមូលដ្ឋានដែលទទួលស្គាល់ដោយច្បាប់ជាតិ និងអន្តរជាតិ ។

នៅក្នុងឆ្នាំ២០០២ គណៈមេធាវីកម្ពុជាបានបង្កើត "មជ្ឈមណ្ឌលបណ្តុះបណ្តាលមេធាវី" (LTC) សំរាប់អនុវត្តកម្មវិធីចូលជាសមាជិកគណៈមេធាវីក្នុងការចេញអាជ្ញាប័ណ្ណដល់មេធាវីថ្មីនៅក្នុងប្រទេសកម្ពុជា។ សាលានេះត្រូវបានបើកឡើងជាផ្លូវការនៅចុងខែតុលា ឆ្នាំ២០០២ ដោយមានសិស្សពូកែចំនួន ៦០នាក់ ដែលផ្តោតលើការសរសេរកិច្ចសន្យា ជំនាញក្នុងការទំនាក់ទំនង ការចរចា និងការសម្រុះសម្រួល និងច្បាប់ពាណិជ្ជកម្ម[៤០] ។

### ៩) សិទ្ធិទទួលបានសេរីភាពក្នុងការបញ្ចេញមតិ និងការបង្កើតសមាគមៈ

> ប្រការ២៣ BPRL:
>
> ដូចប្រជាពលរដ្ឋដទៃទៀតដែរ មេធាវី មានសិទ្ធិទទួលបានសេរីភាពក្នុងការបញ្ចេញមតិ ជំនឿ ការបង្កើតសមាគម និងការប្រមូលផ្តុំគ្នា ។ លើសពីនេះទៀត ពួកគេមានសិទ្ធិក្នុងការចូលរួមក្នុងការពិភាក្សាជាសាធារណៈអំពីបញ្ហាទាំងឡាយ ដែលពាក់ព័ន្ធនឹងច្បាប់រដ្ឋបាលនៃវិស័យយុត្តិធម៌ និងការលើកកំពស់ ការពារសិទ្ធិមនុស្ស និងក្នុងការចូលរួម ឬបង្កើតអង្គការក្នុងស្រុក ឬអង្គការអន្តរជាតិ ព្រមទាំងចូលរួមកិច្ចប្រជុំ ដោយគ្មានការទទួលរងនូវការដាក់កំហិតផ្នែកវិជ្ជាជីវៈ ដោយសារ សកម្មភាពស្របច្បាប់ ឬសមាជិកភាពរបស់ ពួកគេនៅក្នុងអង្គការស្របច្បាប់ណាមួយឡើយ ។ ក្នុងការប្រើសិទ្ធិទាំងនេះ មេធាវី ត្រូវរៀបចំខ្លួនឱ្យបានសមស្របតាមច្បាប់ និងបទដ្ឋាន ព្រមទាំងសីលធម៌ដែលគេទទួលស្គាល់ នៅក្នុងវិជ្ជាជីវៈមេធាវីរបស់ខ្លួន ។

មេធាវី អាចចូលរួមនៅក្នុងអង្គការជាតិ (=គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា) និងអង្គការអន្តរជាតិ ដើម្បីបង្កើតជារូបរាង សំរាប់អនាគតនៃវិជ្ជាជីវៈមេធាវី ។

ដូចជា "គណៈមេធាវីអន្តរជាតិ" (IBA) មានមេធាវីចំនួន ១៦០០០នាក់ ព្រមទាំងគណៈមេធាវី និងសមាគមច្បាប់ចំនួន ១៨០[៤១] ។ នៅក្នុងឆ្នាំ ១៩២៧ "សហព័ន្ធមេធាវីអន្តរជាតិ" (UIA) ត្រូវបានបង្កើតឡើងនៅអឺរ៉ុប ដើម្បីបង្កើតទំនាក់ទំនងអន្តរជាតិរវាងមេធាវីទាំងអស់នៅជុំវិញពិភពលោក ។ សព្វថ្ងៃ សហព័ន្ធនេះតំណាងឱ្យមេធាវីជាង ២លាននាក់ និងបានអនុម័តធម្មនុញ្ញជាច្រើនដែលពាក់ព័ន្ធនឹងវិជ្ជាជីវៈច្បាប់ ដែលត្រូវបានគេអនុវត្តនៅទូទាំងពិភពលោក[៤២] ។

នៅពេលដែលមេធាវីចូលរួមជាសមាគម វាជួយឱ្យពួកគេលើកកំពស់ ការពារ និងពង្រឹងសិទ្ធិមនុស្សនៅក្រោមនីតិរដ្ឋ និងដើម្បីរក្សាភាពឯករាជ្យនៃតុលាការ និងវិជ្ជាជីវៈមេធាវីបាន មិនត្រឹមតែនៅក្នុងប្រទេសពួកគេបានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅលើពិភពលោកទៀតផង ។

---

[៤០] សំរាប់ព័ត៌មានលំអិត សូមមើល: www.cba.org/CBA/IDP/NewReport/Cambodia2003.asp

[៤១] អង្គការជាសមាជិករបស់គណៈមេធាវីអន្តរជាតិមាននៅគ្រប់ទ្វីបទាំងអស់ និងរួមមានគណៈមេធាវីអាមេរិក គណៈមេធាវីសហព័ន្ធអាល្លឺម៉ង់ សហព័ន្ធគណៈមេធាវីជប៉ុន សមាគមច្បាប់ហ្ស៊ីមបាវេ និងគណៈមេធាវីប្រទេសម៉ិចស៊ិកូ ។ សំរាប់ព័ត៌មានលំអិត សូមមើល: www.ibanet.org/

[៤២] មើល www.uianet.org

## ? សំនួរសិក្សាទី ៩

មើលមាត្រា៥៤ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។

**មេធាវីដែលបានទទួលតួនាទីក្នុងរាជរដ្ឋាភិបាល ឬទទួលអាណត្តិជាអ្នកតំណាងរាស្ត្រនៃរដ្ឋសភា អាចនៅជាសមាជិកនៃគណៈមេធាវីបាន ប៉ុន្តែត្រូវឈប់ប្រកបវិជ្ជាជីវៈនេះរហូតដល់ចប់តួនាទី ឬអាណត្តិនោះ ។**

ក) តើសិទ្ធិមនុស្សណាមួយ ឬណាខ្លះ ដែលត្រូវបានដាក់កំហិតដោយមាត្រានេះ? ចូររៀបរាប់ពីសិទ្ធិទាំងនោះ និងបញ្ជាក់ឱ្យបានច្បាស់ពីមាត្រាដែលពាក់ព័ន្ធ !

ខ) តើការដាក់កំហិត ដែលហាមឃាត់មិនឱ្យធ្វើជាមេធាវីនៅពេលដែលធ្វើការជាមន្ត្រីរដ្ឋាភិបាលផងដែរនោះ ស្របនឹងរដ្ឋធម្មនុញ្ញ ដែរឬទេ? ផ្តល់ហេតុផលចំពោះចំលើយរបស់អ្នក!

គ) តើការដាក់កំហិត ដែលហាមមិនឱ្យធ្វើជាមេធាវីនៅពេលជាមួយគ្នា ធ្វើការជាសមាជិករដ្ឋសភាផងដែរនោះ ស្របនឹងរដ្ឋធម្មនុញ្ញដែរឬទេ? ចូរផ្តល់ហេតុផលចំពោះចំលើយរបស់អ្នក!

## ? សំនួរសិក្សាទី ១០

មាត្រា២៩ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចែងថា គណៈមេធាវី ត្រូវផ្តល់ថវិកាសំរាប់ជំនួយផ្នែកច្បាប់ដល់ប្រជាជនក្រីក្រ ។ តើអ្នកគិតថា អ្នកណាគួរតែទទួលខុសត្រូវក្នុងបញ្ហាជំនួយផ្នែកច្បាប់នេះ? ចូរផ្តល់ហេតុផលចំពោះចំលើយរបស់អ្នក!

## ? សំនួរសិក្សាទី ១១

លោក ប៉ែនសុន សម័យ ដែលធ្វើជាមេធាវី ត្រូវបានតែងតាំងដោយអនុក្រឹត្យជាមន្ត្រីសាការីតែម្នាក់គត់នៅប្រទេសកម្ពុជា នៅឆ្នាំ ២០០១ ។ គណៈមេធាវី បានដេញគាត់ចេញពីគណៈមេធាវី ។ តើអ្នកគិតថា តើហេតុអ្វីបានជាគាត់ត្រូវគេដេញចេញ?

## ? សំនួរសិក្សាទី ១២

ចូរអានអត្ថបទសង្ខេបដូចខាងក្រោម ដែលដកស្រង់ចេញមកពីសារព័ត៌មាន ផ្សាយថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០០២ ។

**លោក ខៀវ សំផន ដែលជាប្រមុខរដ្ឋ នាសម័យប៉ុលពត បានសុំជំនួយផ្នែកច្បាប់ពីអង្គការសិទ្ធិមនុស្ស "អង្គការក្រុមអ្នកការពារសិទ្ធិនៅកម្ពុជា (CDP) " កាលពីខែកញ្ញា ឆ្នាំ២០០៣ ពីព្រោះ គាត់ត្រូវពាក់ព័ន្ធ**

នឹងការចោទប្រកាន់ពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ ដែលធ្វើដោយតុលាការកាត់ទោសខ្មែរក្រហមនាពេល ខាងមុខ ទោះបីជាមានការតវ៉ាដោយលិខិតបើកចំហរមួយ នៅក្នុងឆ្នាំ២០០១ ថាគាត់គ្មានទោសក៏ដោយ ។

នាយកអង្គការក្រុមអ្នកការពារសិទ្ធិកម្ពុជា លោក សុក សំអឿន បាននិយាយថា ទោះបីជា អង្គការ លើកកំពស់សិទ្ធិដែលត្រូវទទួលបានការផ្តល់មតិយោបល់ និងការសន្មត់ទុកជាមុនថាគ្មានទោស ក៏ដោយ ក៏អង្គការ មិនទាន់បានសំរេចទទួលសំណូមពរនេះនៅឡើយ ហើយបានបញ្ជាក់អំពីហេតុផលចំនួន ៥ ដូចតទៅៈ ក) តុលាការកាត់ទោសខ្មែរក្រហម មិនទាន់ត្រូវបានបង្កើតឡើងនៅឡើយ ខ) អង្គការនេះ ក៏ជាអ្នកគាំទ្រ យ៉ាងខ្លាំងក្លាចំពោះតុលាការកាត់ទោសខ្មែរក្រហម អាចប្រឈមនឹងបញ្ហាទំនាស់ផលប្រយោជន៍ គ) ការចំណាយ សំរាប់ជំនួយផ្នែកច្បាប់នៅក្នុងការកាត់ក្តីដ៏ធំ និងយូរបែបនេះ អាចនឹងខុសពីគំរោងថវិការបស់អង្គការ ឃ) អង្គការសហប្រជាជាតិ ឬរដ្ឋាភិបាលកម្ពុជា ត្រូវទទួលខុសត្រូវចំពោះការផ្តល់នូវជំនួយផ្នែកច្បាប់ដល់ជនជាប់ចោទ ទាំងនោះ នៅក្នុងដំណើរការក្តី និង ង) លោក សុក សំអឿន ផ្ទាល់នឹងប្រហែលជាលំអៀង ព្រោះថា ឪពុក របស់គាត់ក៏ជាជនរងគ្រោះនៅសម័យប៉ុលពតដែរ ។

អង្គការជំនួយផ្នែកច្បាប់សំខាន់មួយទៀត គឺអង្គការជំនួយច្បាប់នៃកម្ពុជា ក៏មិនប្រាកដថានឹងផ្តល់ជំនួយនោះ ដែរ ក្នុងករណី លោក ខៀវ សំផន នឹងមកសុំជំនួយផ្នែកច្បាប់នោះ ។

តើអតីតមេដឹកនាំខ្មែរក្រហម លោក ខៀវ សំផន មានសិទ្ធិនឹងទទួលបានជំនួយផ្នែកច្បាប់ដែរឬទេ?

កុំឆ្លើយត្រឹម "មាន" ឬ "មិនមាន" ប៉ុន្តែ ចូរពន្យល់ទស្សនៈផ្នែកច្បាប់ និងបញ្ជាក់ពីមាត្រានៃ ICCPR ដែលពាក់ព័ន្ធ ។

## ? សំនួរសិក្សាទី ១៣

នៅក្នុងប្រទេសកម្ពុជា ព្រះរាជអាជ្ញា នៅតែធ្វើការយ៉ាងជិតស្និទជាមួយនឹងចៅក្រមស៊ើបអង្កេត នៅក្នុងការប្រមូលភស្តុតាង និងរៀបចំរឿងក្តីព្រហ្មទណ្ឌ ។ ការលាយបញ្ចូលគ្នារវាងមុខងារព្រះរាជអាជ្ញា និងមុខងារតុលាការបែបនេះ បំពានលើច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ (ឆ្នាំ១៩៩៣) និង "គោលការណ៍ណែនាំ របស់ អ.ស.ប ស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា" (ឆ្នាំ១៩៩០) ផងដែរ ។

ក) ចូរលើកពីមាត្រាដែលត្រូវបានបំពានឱ្យបានច្បាស់លាស់!

ខ) តើហេតុអ្វីបានជាអ្នកគិតថា ស្ថាប័នព្រះរាជអាជ្ញាត្រូវតែបំបែកចេញពីតុលាការ?

គ) ដោយការអានច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ (LoCP ឆ្នាំ១៩៩៣) ចូររៀបរាប់ដោយសង្ខេបអំពី សកម្មភាពរបស់ព្រះរាជអាជ្ញាម្នាក់ក្នុងការយករឿងក្តីព្រហ្មទណ្ឌមួយ ទៅកាត់សេចក្តី!

## ? សំនួរសិក្សាទី ១៤

តើក្រឡាបញ្ជី មានភារកិច្ចអ្វីខ្លះ?

# គោលការណ៍នៃការជំនុំជំរះដោយយុត្តិធម៌



## ក) សេចក្តីផ្តើម

ការធ្វើការជំនុំជំរះ "ដោយយុត្តិធម៌" មានន័យថាគោរពសិទ្ធិមនុស្សក្នុងការទទួលបាន**ភាពស្មើគ្នាចំពោះមុខច្បាប់** ( មាត្រា៣១ II ១ CC) ដោយការប្រព្រឹត្តិចំពោះគូភាគីវិវាទទាំងពីរដោយវិធីដូចៗគ្នា ។

នេះមានន័យថា ផ្តល់ឱ្យភាគីទាំងពីរនូវឱកាសដូចគ្នា ដើម្បីបង្ហាញនូវរឿងក្តីរបស់ពួកគេ និងប្រាស្រ័យទាក់ទងជាមួយតួអង្គដទៃទៀតនៅក្នុងនីតិវិធីរឿងក្តីនេះ ប្រកបដោយតម្លាភាព ។

លើសពីនេះទៀត នីតិវិធីជំនុំជំរះ "ដោយយុត្តិធម៌" មានន័យថាគោរពសិទ្ធិរបស់គូភាគីដែល**ត្រូវរួចផុតពីការបង្ខិតបង្ខំ ឬការធ្វើបាប** និងគោរពគំរិតយុត្តិធម៌សំខាន់ៗមួយចំនួន ជាការហាមប្រាមលើការដាក់ទណ្ឌកម្ម ឬការដាក់ទោស ដែលមិនសមាមាត្រ ។

ជាចុងក្រោយ ការជំនុំជំរះ "ដោយយុត្តិធម៌" មានន័យថា ការផ្តល់នូវយុត្តិធម៌មិនលឿនពេក និងមិនយូរពេក ដោយការរៀបចំ**នីតិវិធីដោយគ្មានការយឺតយ៉ាវមិនសមស្រប** ប៉ុន្តែនៅតែមានពេលគ្រប់គ្រាន់ដើម្បីឱ្យគូភាគីទាំងពីររៀបចំ និងបង្ហាញពីបុព្វហេតុរបស់ពួកគេ ។

ដោយពិចារណាលើបញ្ហានេះ របៀបអនុវត្តការកាត់ក្តីនៅប្រទេសកម្ពុជាបច្ចុប្បន្ននៅចំពោះមុខតុលាការរដ្ឋប្បវេណី និងតុលាការព្រហ្មទណ្ឌ នៅតែស្ថិតនៅឆ្ងាយពីភាពយុត្តិធម៌នៅឡើយ ។ ឧទាហរណ៍:

ឯកសារដែលភាគីមួយដាក់ជូនតុលាការជួនកាលមិនត្រូវបានបង្ហើបឱ្យដឹងឡើយ ហើយត្រូវបានបញ្ជូនបន្តទៅឱ្យភាគីម្ខាងទៀត ។

ភស្តុតាងកម្រត្រូវបានលើកឡើង និងពិនិត្យឱ្យបានសមស្របណាស់ ។

មេធាវី មិនមានតួនាទីឋានន្តរស័ក្តិ និងកេរ្តិ៍ឈ្មោះស្មើគ្នានឹងព្រះរាជអាជ្ញា ឬចៅក្រមឡើយ ។

មូលហេតុចំពោះការវិនិច្ឆ័យក្តី កម្រត្រូវបានគេប្រាប់ឱ្យដឹងណាស់ ។

នីតិវិធីព្រហ្មទណ្ឌ នៅតែពឹងផ្អែកយ៉ាងខ្លាំងលើចម្លើយសារភាពរបស់ជនជាប់ចោទនៅឡើយ ហើយចម្លើយសារភាពបែបនេះជារឿយៗ បានមកពីការបង្ខិតបង្ខំ ឬការធ្វើទារុណកម្ម ចំណែកឯការស៊ើបអង្កេតឯករាជ្យ និងហ្មត់ចត់ មិនត្រូវបានធ្វើឡើងដោយនគរបាល ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបអង្កេតដែលនៅក្នុងករណីជាច្រើន មិនខ្វល់ខ្វាយក្នុងការស្វែងរក និងពិនិត្យភស្តុតាង ។

ការកំណត់រយៈពេល ៦ខែ សំរាប់ការឃុំខ្លួនមុនការកាត់ទោសនោះ ជារឿយៗ បានហួសពេលកំណត់ដោយពុំមានការធ្វើយុត្តិកម្ម ។

មានមូលហេតុផ្សេងៗគ្នា សំរាប់គុណវិបត្តិបច្ចុប្បន្ន ក្នុងគោលការណ៍ការកាត់ក្តីដោយយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា: ការសម្លាប់ប្រជាជនកម្ពុជា ដែលបានទទួលការហ្វឹកហ្វឺនផ្នែកច្បាប់ស្ទើរតែទាំងអស់នៅក្នុងរបបប៉ុល ពត បានធ្វើឱ្យប្រទេសនេះបាត់បង់ធនធានមនុស្សភាគច្រើនបំផុត ដែលអាចយល់ និងអនុវត្តគោលការណ៍ទាំងនេះបាន ។ ការរាលដាលនៃអំពើពុករលួយនៅគ្រប់ទីកន្លែង ក្នុងចំណោមមេធាវីទាំងអស់នៃប្រព័ន្ធតុលាការកម្ពុជា បណ្តាលឱ្យមានការមិនគោរពដ៏រាតត្បាតចំពោះបទដ្ឋានត្រឹមត្រូវ ដែលទង្វើនេះត្រូវបានមើលឃើញថាជាឧបសគ្គមួយចំពោះការរៀបចំការកាត់ក្តី "ដ៏រលូន" និង "ដែលមានធនធានគ្រប់គ្រាន់" ។ ម្យ៉ាងវិញទៀត វាគឺជាកេរមរតកនៃគំនិតផ្លូវច្បាប់ ដែលត្រូវបានអនុវត្តក្នុងកំឡុងទសវត្សឆ្នាំ១៩៨០ ដើម្បីដាក់ឱ្យមានចៅក្រម និងព្រះរាជអាជ្ញាដែលមានជំនឿយ៉ាងទូលំទូលាយ និងទទួលស្គាល់ថា នគរបាល និងព្រះរាជអាជ្ញា (ដែលជាអង្គនីតិប្រតិបត្តិ) ត្រូវមានឥទ្ធិពល ជ្រៀតជ្រែកនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ។ យោងតាមទស្សនៈនោះ ដំណើរការនីតិវិធីខ្លួនឯង ត្រូវបានគេមើលឃើញថា ជាមធ្យោបាយមួយដែលគេប្រើដើម្បីបង្ហាញជាសាធារណៈនូវពិរុទ្ធភាពរបស់ជនជាប់ចោទជាជាង ជាមធ្យោបាយមួយដែលគេប្រើដើម្បីស្វែងរកការពិត និងដើម្បីសម្រេចបានយុត្តិធម៌ដោយការពិនិត្យអង្គហេតុ និងច្បាប់មួយជំហានម្តងៗ ។ ជាចុងក្រោយ ការផ្តល់សិទ្ធិ និងឱកាសស្មើគ្នាដល់ភាគីជម្លោះទាំងពីរ ត្រូវបានរារាំងដោយរចនាសម្ព័ន្ធផ្តាច់ការ និងផ្នត់គំនិតនៃសង្គមកម្ពុជា ដែលគាំទ្រលំដាប់ឋានានុក្រមសង្គមដែលមានទំនាក់ទំនងមិនស្មើគ្នារវាង សមាជិកសង្គមដែលរឹងមាំ មានទ្រព្យសម្បត្តិ មានអំណាច និងមានស័ក្តិធំ និងសមាជិកសង្គមដែលទន់ខ្សោយ មិនមានអំណាច និងដែលនៅក្រោមបង្គាប់គេ[៤៣] ។

## ២) តើការជំនុំជំរះ "ដោយយុត្តិធម៌" មានន័យជាសំរាយយ៉ាងដូចម្តេច?

### I) គោលដៅនៃនីតិវិធីៈ ការស្វែងរកដំណោះស្រាយជម្លោះត្រឹមត្រូវមួយ (យុត្តិធម៌)

គេមិនអាចឆ្លើយសំនួរថា តើការជំនុំជំរះ "ដោយយុត្តិធម៌" មានន័យដូចម្តេច ដោយមិនបានឆ្លើយជាមុននូវសំនួរថា "តើការជំនុំជំរះ មានគោលបំណងដូចម្តេច?" បានឡើយ ។

ការជំនុំជំរះ គឺជានីតិវិធីមួយជាអគ្គានុរូបមានន័យថា "ការប្រព្រឹត្តិទៅមួយជំហានម្តងៗ" ដើម្បីសម្រេចគោលដៅ ។ **គោលដៅនៃនីតិវិធីរឿងក្តីតុលាការមួយ (ការជំនុំជំរះ) គឺដើម្បីសម្រេចបានយុត្តិធម៌** ។ យុត្តិធម៌

---

[៤៣] សំរាប់ការអធិប្បាយ និងការវិភាគលំអិត អំពីការខ្វះការគោរពទៅលើគោលការណ៍កាត់ក្តីដោយយុត្តិធម៌នៅប្រទេសកម្ពុជា សូមមើលៈ

- សុក សំអឿន "ឱនភាពនៃការកាត់ក្តីដោយយុត្តិធម៌" ខែកុម្ភៈ ឆ្នាំ២០០០ ទំព័រទី ១២៩-១៤៧
- បាស៊ីល ហ៊ែរណង់ដូ "បញ្ហាដែលកំពុងប្រឈមមុខប្រព័ន្ធច្បាប់កម្ពុជា" ខែកក្កដា ឆ្នាំ១៩៩៨
- ចេសុន បាប័រ "មិនមែនជាមនុស្ស-ទារុណកម្មនៅក្នុងប្រទេសកម្ពុជា" លីកាដូ ខែមិថុនា ឆ្នាំ២០០០

មានន័យថា ដំណោះស្រាយប្រកបដោយយុត្តិធម៌មួយ ចំពោះជម្លោះផ្លូវច្បាប់ក្នុងចំណោមភាគីជម្លោះពីរតាមរយៈសាលក្រម ។

សាលក្រមនេះ អាចសម្រេចបានដោយ**ការស្រាវជ្រាវ ការស្វែងរក និងការពិនិត្យ**ដោយហ្មត់ចត់នូវ**អង្គហេតុ និងអង្គច្បាប់** ហើយបន្ទាប់មកអនុវត្តច្បាប់ដែលបានរកឃើញទៅលើអង្គហេតុ ដែលត្រូវបានរកឃើញដែរ ។ បញ្ហានេះ ត្រូវតែធ្វើឡើងមួយជំហានម្តងៗក្នុងរូបភាពជានីតិវិធីច្បាប់ជាក់លាក់មួយ ។ នោះមានន័យថា ច្បាប់ (វិធាននីតិវិធី) កំណត់នូវជំហាននីមួយៗដែលត្រូវធ្វើឡើង ។ ជំហាននីមួយៗ ត្រូវតែកត់ត្រាដោយប្រុងប្រយ័ត្ន ។ បន្ទាប់ពីជំហាននីមួយៗ ដំណើរការផ្អាកបន្តិចសិន ហើយ**នីតិវិធីក្នុងការសម្រេច** ក៏ត្រូវបានធ្វើឡើងអំពីថា តើត្រូវអនុវត្តជំហានអ្វីបន្ទាប់មកទៀត ឬអំពី**នីតិវិធីក្នុងការទាមទារ ឬការជំទាស់**របស់គូភាគី ។

<u>ឧទាហរណ៍:</u>

- ចុងចោទ ទាមទារស្តាប់សាក្សីមួយដែលជួយសំរាលការចោទប្រកាន់ ។ តុលាការ ត្រូវធ្វើសេចក្តីសំរេចមួយលើការស្នើសុំនេះជាមុនសិន និងបន្ទាប់មកអាចបន្តដំណើរការនីតិវិធីតទៅទៀតបាន ។
- ឬចុងចោទ តវ៉ានឹងចៅក្រមដែលលំអៀង ហើយបន្ទាប់សុំបដិសេធចៅក្រមនោះ ។ តុលាការ ត្រូវបញ្ឈប់ដំណើរការនីតិវិធី ត្រូវពិចារណាលើបណ្តឹង និងសំរេចថា តើចៅក្រមរូបនោះ ត្រូវតែដកចេញពីរឿងក្តីឬទេ?

ការបែងចែកនីតិវិធីចេញជាជំហានតូចៗជាច្រើននេះ ផ្តល់នូវរចនាសម្ព័ន្ធដ៏ច្បាស់លាស់មួយសំរាប់តួអង្គទាំងអស់ និងធានាថាមិនមានជំហានចាំបាច់ណាមួយត្រូវបានលុបចោលឡើយ ។

តួអង្គជាច្រើន រួមចំណែកចំពោះនីតិវិធីនោះ ។

តួអង្គ គឺជាគូភាគីជម្លោះទាំងពីរ មេធាវីរបស់គេ ព្រះរាជអាជ្ញា នគរបាល និងជាចុងក្រោយចៅក្រម និងក្រឡាបញ្ជី ។ ហេតុផលជាមូលដ្ឋាននៃ**ការចូលរួមរបស់តួអង្គផ្សេងៗ ដែលមានតួនាទីខុសៗគ្នានោះ** គឺថា វាបំរើផលប្រយោជន៍នៃការស្វែងរកការពិតទាំងស្រុង ដើម្បីពិនិត្យមើលការពិត និងការជំទាស់ផ្លូវច្បាប់ពីគ្រប់ជ្រុងជ្រោយ និងពីទស្សនៈផ្សេងៗគ្នា ។ ដូចគ្នានឹង ដំណើរការជជែកដេញដោលជាសាធារណៈតាមបែបលទ្ធិ-ប្រជាធិបតេយ្យក្នុងចំណោមបុគ្គលឯកជនដែរ ដំណើរការបែបនេះទំនងជាមានបំណងបង្ហាញការពិតច្រើនជាងរបៀបនៃការរៀបចំនីតិវិធីដែលប្រកាន់ភាគីតែម្ខាង ។ នៅទីបញ្ចប់ ចៅក្រម ត្រូវតែរកដំណោះស្រាយយុត្តិធម៌មួយ សំរាប់គូភាគីដែលមានទំនាស់ផ្លូវច្បាប់នោះត្រូវតែប្រមូលការពិត និងទស្សនៈច្បាប់ពីភាគីទាំងពីរ ។ បន្ទាប់មក ចៅក្រមត្រូវតែថ្លឹងថ្លែងការពិត និងទស្សនៈផ្លូវច្បាប់របស់ភាគីទាំងពីរប្រៀបធៀបគ្នាទៅវិញទៅមក ។ នោះមានន័យថា ចៅក្រមត្រូវតែថ្លឹងថ្លែង ការពិត និងការជំទាស់នានា ហើយធ្វើការវាយតម្លៃថា តើកត្តាអ្វីខ្លះជាគុណប្រយោជន៍នៃភាគីម្ខាង និងតើកត្តាអ្វីខ្លះជាគុណប្រយោជន៍នៃភាគីម្ខាងទៀត?

**នីតិវិធីៈ**

ការប្រមូលអង្គហេតុ និងអង្គច្បាប់
មួយជំហានម្ដងៗពីភាគីវិវាទទាំងពីរ




## II) ធាតុសំខាន់ៗនៃ "ភាពយុត្តិធម៌"[៤៤]:

តើនៅពេលណាទៅ ទើបដំណើរការមួយជំហានម្ដងៗឆ្ពោះទៅរកសាលក្រមមួយ អាចត្រូវបានហៅថា "មានយុត្តិធម៌" ? "យុត្តិធម៌" មានន័យថា "ស្មើគ្នា" ឬ "តាមវិធីដូចគ្នា" ឬ "ដោយមានឱកាសប្រហាក់ប្រហែលគ្នា"

### ១) ឱកាសដូចគ្នាដែលមានឥទ្ធិពលលើដំណើរការធ្វើសេចក្ដីសំរេចៈ

ដំណើរការនៃការធ្វើសេចក្ដីសម្រេចរបស់ចៅក្រមអាចត្រូវបានហៅថា "យុត្តិធម៌" នៅពេលដែលភាគី**វិវាទទាំងពីរមានឱកាស (ស្មើគ្នា) ដែលមានឥទ្ធិពលលើដំណើរការធ្វើសេចក្ដីសំរេច**របស់ចៅក្រម ។ ភាគីទាំងពីរអាចមានឥទ្ធិពលលើការធ្វើសេចក្ដីសម្រេចនេះ ដោយការបង្ហាញព័ត៌មាន អង្គហេតុ ភស្តុតាង និងទស្សនៈផ្លូវច្បាប់ (អំណះអំណាង) ជូនដល់ចៅក្រម ។ ដើម្បីធ្វើដូច្នេះឱ្យបានសមស្រប ភាគីនីមួយៗត្រូវការព័ត៌មានពីចៅក្រម ឬពីភាគីម្ខាងទៀត ហើយជាថ្នូរមកវិញ ភាគីនេះត្រូវតែផ្ដល់ព័ត៌មានរបស់ខ្លួនទៅឱ្យចៅក្រម និងភាគីម្ខាងទៀតដែរ ។

ដូច្នេះ ភាគីទាំងពីរត្រូវតែមានៈ

- **ឱកាស** (ដោយយុត្តិធម៌) ដូចគ្នា **ដើម្បីបង្ហាញពីអង្គហេតុជូនចៅក្រម**
- **សិទ្ធិក្នុងការទទួលបានព័ត៌មានស្មើគ្នាអំពីការពិតដែលពាក់ព័ន្ធទាំងអស់ ។**
  ចៅក្រម ត្រូវតែផ្ដល់ឱ្យភាគីទាំងពីរនូវលទ្ធភាពដូចគ្នាក្នុងការទទួលដឹងពីអង្គហេតុ និងឯកសារនានា ហើយប្រាប់ពួកគេអំពីអង្គហេតុទាំងអស់ មតិយោបល់ អំណះអំណាង និងភស្តុតាង ដែលគេបានទទួលពីភាគីម្ខាងទៀត ឬដែលគេបានលើកឡើងដោយខ្លួនឯង ។
- ឱកាស (យុត្តិធម៌) និងសិទ្ធិដូចគ្នា **ក្នុងការបញ្ចេញមតិ និងសាកសួរពីអង្គហេតុពីភាគីម្ខាងទៀត** ។
  ឧទាហរណ៍ ការសួរកភស្តុតាងដែលបង្ហាញដោយភាគីម្ខាងទៀត ។

[៤៤] អ្នកអាចរកព័ត៌មានសំខាន់ៗអំពី "គោលការណ៍កាត់ក្ដីដោយយុត្តិធម៌" នៅក្នុងការផ្សាយពីទីក្រុងញ៉ូយ៉ក "គណៈកម្មការមេធាវីដើម្បីសិទ្ធិមនុស្ស" ហៅ "អ្វីទៅជាការជំនុំជំរះមួយដោយយុត្តិធម៌" នៅ www.lchr.org/pubs/descriptions/fair_trial.pdf
សំរាប់ព័ត៌មានលំអិត សូមមើលក្នុងសៀវភៅស្ដីពី "គោលការណ៍នៃការកាត់ក្ដីដោយយុត្តិធម៌" របស់អង្គការលើកលែងទោសអន្តរជាតិ នៅក្នុង www.amnesty.org/ailib/intcam/fairtrial/indxftm_a.htm (ចំពោះសិទ្ធិនៅមុនពេលជំនុំជំរះ) និង www.amnesty.org/ailib/intcam/fairtrial/indxftm_b.htm (ចំពោះសិទ្ធិនៅពេលជំនុំជំរះ) ។




**២) សាធារណភាព[៤៥] និងសេរីភាពរួចផុតពីការបង្ខិតបង្ខំ:**





លក្ខខណ្ឌបន្ថែមមួយសំរាប់ភាពយុត្តិធម៌ គឺដំណើរការ ត្រូវតែធ្វើជា**សាធារណៈ** និង**គ្មានការបង្ខិតបង្ខំ** ។ បើ សាធារណភាព ត្រូវបានផ្ដល់ឱ្យ សាធារណជនអាចសង្កេតការណ៍នូវការកាត់ក្ដីនោះបាន ហើយពិនិត្យមើលថា តើភាគីទាំងពីរពិតជាត្រូវបានគេផ្ដល់ឱ្យនូវឱកាសដូចគ្នា ដើម្បីចូលរួមយ៉ាងសកម្មក្នុងដំណើរការនោះពេញលេញឬក៏អត់? លើសពីនេះទៅទៀត ការបង្ខិតបង្ខំចំពោះភាគីមួយនៃភាគីទាំងពីរនេះ ត្រូវតែបំបាត់ឱ្យបាននៅក្នុងដំណើរការនៃការស្វែងរកដំណោះស្រាយ "ដ៏យុត្តិធម៌" មួយដែលតាមលក្ខណៈធម្មជាតិរបស់វា មិនអាចជាដំណោះស្រាយមួយ ដែលផ្អែកលើការពិត និង ព័ត៌មានដែលបានមកពីការបង្ខិតបង្ខំទៅលើភាគីនោះឡើយ (ឧទាហរណ៍ តាមរយៈការធ្វើទារុណកម្ម ឬ ការបំភិតបំភ័យ) ។ ផ្ទុយទៅវិញ លទ្ធផលដែលបានមកពីការបង្ខិតបង្ខំបែបនេះ នឹងផ្ដល់នូវ គុណវិបត្តិដល់ភាគីដែលត្រូវបានគេបង្ខិតបង្ខំ ដែលជាការរំលោភបំពានលើគោលការណ៍នៃឱកាស "ដោយយុត្តិធម៌" ដែលមានន័យថា ការផ្ដល់នូវអត្ថប្រយោជន៍ និងគុណវិបត្តិដោយស្មើភាពគ្នា ។

[៤៥] មើលផងដែរ "គោលការណ៍ធ្វើនៅទីក្រុង ម៉ាឌ្រីត ស្ដីពីទំនាក់ទំនងរវាង ប្រព័ន្ធផ្សព្វផ្សាយ និងឯករាជភាពរបស់តុលាការ": wwwlaw.murdoch.edu.au/icjwa/medind.htm

### ៣) ល្បឿនដោយយុត្តិធម៌នៃនីតិវិធីរឿងក្ដី



ប្រតិទិន



**ល្បឿននៃនីតិវិធីរឿងក្ដីដោយយុត្តិធម៌** ក៏ជាកត្តាដ៏សំខាន់បំផុតមួយដែរដែលត្រូវពិចារណា នៅពេលនិយាយអំពីការរៀបចំនីតិវិធី "ដោយយុត្តិធម៌" នោះ ។ ប្រសិនបើ ជំហានទោលផ្សេងៗគ្នានៃនីតិវិធីដើម្បីស្វែងរកយុត្តិធម៌ ត្រូវបានចាត់ឡើង**លឿនពេក** វាអាចកាត់បន្ថយនូវឱកាសសំរាប់ភាគីជម្លោះមួយ ក្នុងការចូលរួមយ៉ាងសកម្ម និងរួមចំណែកក្នុងដំណើរការនោះ ដូចភាគីម្ខាងទៀត ពីព្រោះភាគីនោះពុំមានពេលវេលាគ្រប់គ្រាន់ ដើម្បីទទួល និងផ្ដល់ និងពិនិត្យមើលព័ត៌មាន ។

ផ្ទុយទៅវិញ ប្រសិនបើនីតិវិធីនោះ**យឺតយូរពេក** ហើយត្រូវបានពន្យារពេលដោយមិនសមហេតុផលនោះ វាក៏អាចទម្លាក់គុណវិបត្តិទៅលើភាគីមួយ ដែលគេរំពឹងថាមិនអាចទទួលបន្ទុកជាឯកតោភាគីនៃស្ថានភាពផ្លូវច្បាប់ដែលមិនទាន់បានដោះស្រាយ ឧទាហរណ៍ ដោយការជាប់ពន្ធនាគារ ហើយរង់ចាំការកាត់ទោសបានឡើយ ។

### ៤) លក្ខខណ្ឌតំរូវនៃ "ភាពយុត្តិធម៌" សំរាប់ចៅក្រម និងការវិនិច្ឆ័យរបស់ចៅក្រមៈ

នីតិវិធីរឿងក្ដីដើម្បីសម្រេចបានសាលក្រមមួយ មិនត្រឹមតែត្រូវ "មានភាពយុត្តិធម៌" ប៉ុណ្ណោះទេ ក៏ប៉ុន្តែតួបុគ្គលជាចៅក្រម និងសាលក្រមផ្ទាល់ ដែលជាលទ្ធផលស្ថាពរនៃនីតិវិធីរឿងក្ដីក៏ត្រូវតែបំពេញលក្ខខណ្ឌតំរូវនៃភាពយុត្តិធម៌ចំពោះភាគីជម្លោះផងដែរ ដើម្បីធានាការការពារស្មើៗគ្នាចំពោះសិទ្ធិរបស់ពួកគេ ។

ក) ចៅក្រមដោយផ្ទាល់ ត្រូវតែ**មិនលំអៀង** ដែលមានន័យថា លំអៀងទៅរកភាគីតែម្ខាង ។

ខ) សាលក្រមមួយនៃតុលាការព្រហ្មទណ្ឌមួយ អាចធ្វើទៅបានតែនៅពេលណាដែលមានភស្ដុតាងចោទប្រកាន់គ្រប់គ្រាន់ទៅលើចុងចោទប៉ុណ្ណោះ ។ ដរាបណាគ្មានភស្ដុតាងគ្រប់គ្រាន់ ដរាបនោះបុគ្គលនោះត្រូវបាន គេចាត់ទុកថាគ្មានទោស ។ ដែលហៅថា "**សច្ចធារណ៍នៃនិរទោស**" គឺជាគោលការណ៍មួយដែលស្ថិតនៅក្រោមនីតិវិធីព្រហ្មទណ្ឌ និងដាក់បន្ទុកភស្ដុតាងទៅលើព្រះរាជអាជ្ញា ។ គោលការណ៍សំខាន់មួយទៀត គេហៅថា "**អត្ថប្រយោជន៍នៃវិមតិសង្ស័យ**" (**"in dubio pro reo"**) ដែលត្រូវបានទៅលើជនជាប់ចោទ ។ គោលការណ៍នេះ មានន័យថា សាក្សីដែលផ្ដល់ឱ្យដោយព្រះរាជអាជ្ញា មិនគួរឱ្យទុកចិត្តបាន ដូច្នេះ ចុងចោទ មិនអាចត្រូវបានកាត់ឱ្យជាប់ទោសទេ ផ្ទុយទៅវិញត្រូវទទួលបានការលើកលែងទោស ។

នៅក្នុងរឿងក្ដីរដ្ឋប្បវេណី បទបញ្ញត្តិច្បាប់ ត្រូវតែថ្លឹងថ្លែងឱ្យមានយុត្តិធម៌ អំពីបន្ទុក**ភស្ដុតាង**រវាងភាគី ។

ឧទាហរណ៍ៈ

ដើមចោទទាមទារឱ្យ ចុងចោទប្រគល់ដីដែលចុងចោទបានកាន់កាប់ឱ្យទៅខ្លួនវិញ ។ បន្ទុកភស្ដុតាងរបស់ដើមចោទ គឺត្រូវបញ្ជាក់ប្រាប់តុលាការថា ខ្លួនគឺជាម្ចាស់ដីស្របច្បាប់ ហើយថាចុងចោទបានកាន់កាប់ដីនេះដោយខុសច្បាប់ ។ ផ្ទុយទៅវិញ ចុងចោទត្រូវបង្ហាញភស្ដុតាងថា ខ្លួនបានទទួលដីនេះត្រឹមត្រូវពីតតិយជនណាម្នាក់ ។

គ) សាលក្រមមួយរបស់តុលាការព្រហ្មទណ្ឌ ត្រូវតែមានតុល្យភាព និងមានភាពយុត្តិធម៌ ។ សាលក្រមនេះមិនត្រូវដាក់បន្ទុកវិសមាមាត្រទៅលើភាគីដែលត្រូវបានកាត់ឱ្យជាប់ទោស ឬករណីយកិច្ចណាដែលមិនអាចបំពេញបានឡើយ ។ ក្នុងន័យនេះ វាអាច មិន"យុត្តិធម៌" ប្រសិនបើសាលក្រមមួយ **ដាក់ទណ្ឌកម្មជាលើកទីពីរ (ពីរដង)**

ចំពោះបទឧក្រិដ្ឋតែមួយ ឬប្រសិនបើនៅពេលក្រោយមក សាលក្រមនេះអនុវត្តច្បាប់ព្រហ្មទណ្ឌថ្មីទៅលើសកម្មភាពដែលកន្លងហួសទៅហើយណាមួយ ដែលមិនអាចផ្តន្ទាទោសបាននៅក្រោមច្បាប់នោះនៅពេលនោះ ។ **ការអនុវត្តច្បាប់បែបប្រតិសកម្មនេះ** នឹងដាក់កំហិតករណីយកិច្ចទៅលើជនជាប់ចោទ ដើម្បីគោរពតាមច្បាប់នេះទោះបីជា ខ្លួនគេមិនបានដឹងអំពីច្បាប់នេះ នៅពេលដែលគេបានធ្វើសកម្មភាពក៏ដោយ (="**ការហាមឃាត់ដល់ការដាក់ទោសប្រតិសកម្ម**") ។

**ឃ)** ជាចុងក្រោយ គូភាគីទាំងពីរ ត្រូវតែមានឱកាសធ្វើការរិះគន់សាលក្រមនោះ ហើយបង្ហាញនូវអង្គហេតុនិងភស្តុតាងថែមទៀតដែលអាចផ្តល់ហេតុផល ដើម្បីកែប្រែសាលក្រមនោះ ។ ដូច្នេះ គូភាគីទាំងពីរត្រូវតែមានសិទ្ធិក្នុងការធ្វើឧទ្ធរណ៍ ។ ដើម្បីអាចឱ្យគូភាគីទាំងពីរធ្វើឧទ្ធរណ៍ដោយប្រសិទ្ធភាព ហេតុផលនៃសាលក្រមត្រូវតែពន្យល់ជាលាយលក្ខណ៍អក្សរ ។

## គោលការណ៍ជាមូលដ្ឋាន ៤ នៃការកាត់ក្តីព្រហ្មទណ្ឌដោយយុត្តិធម៌




## គ) <u>អត្ថបទច្បាប់សំខាន់បំផុតស្តីពី "គោលការណ៍នៃការជំនុំជំរះដោយយុត្តិធម៌"</u>:

អត្ថបទខាងក្រោម បង្ហាញនូវមាត្រាច្បាប់ពាក់ព័ន្ធជាច្រើន ដែលបានបញ្ចូលធាតុនៃការជំនុំជំរះដោយយុត្តិធម៌ ។ ម្យ៉ាងវិញទៀត អត្ថបទនេះ នឹងផ្តល់នូវទិដ្ឋភាពរួមតាមប្រព័ន្ធនៃគោលការណ៍ដ៏សំខាន់បំផុតមួយចំនួន ។

ធាតុនៃការជំនុំជំរះដោយយុត្តិធម៌ដែលបានពោលមកខាងលើ ត្រូវបានអភិវឌ្ឍ និងចងក្រងជាពិសេសសំរាប់នីតិវិធីព្រហ្មទណ្ឌ ពីព្រោះ នីតិវិធីប្រភេទនេះ ជ្រៀតជ្រែកយ៉ាងខ្លាំងទៅលើសិទ្ធិរបស់ភាគីចុងចោទ (សិទ្ធិនៃការធ្វើដំណើរ សេរីភាពនៃការធ្វើសកម្មភាព) ។ ប៉ុន្តែ ជាការពិតណាស់ **គោលការណ៍នៃការជំនុំជំរះដោយយុត្តិធម៌ អនុវត្តផងដែរចំពោះច្បាប់រដ្ឋប្បវេណី និងនីតិវិធីតុលាការរដ្ឋបាល** (មើលមាត្រា១៤ I ២ ICCPR) ។

អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ក៏ដូចជារដ្ឋធម្មនុញ្ញកម្ពុជា (CC) ផ្តល់នូវបទបញ្ញត្តិជាមូលដ្ឋាន ដែលចាំបាច់ដើម្បីធានា និងការពារការរៀបចំការជំនុំជំរះដោយយុត្តិធម៌ ។ បញ្ញត្តិដ៏សំខាន់បំផុត មានចែងនៅក្នុង**មាត្រា៩, ១០ និងជាពិសេសមាត្រា១៤ ICCPR** និង**មាត្រា៣៨ CC** ។

សិទ្ធិជាមូលដ្ឋានក្នុងការធានានូវការរៀបចំការជំនុំជំរះ "ដោយយុត្តិធម៌" (ស្មើភាពគ្នា មានតុល្យភាព) គឺសិទ្ធិក្នុងការទទួលបាន **"សិទ្ធិមានលទ្ធភាពស្មើគ្នាក្នុងការទទួលបានយុត្តិធម៌"** និង **"ភាពស្មើគ្នាចំពោះមុខច្បាប់"** ។ ការធានាជាមូលដ្ឋាននេះ ធ្វើឱ្យប្រាកដថា ភាគីជម្លោះទាំងពីរបានទទួលការគោរព និងការយកចិត្តទុកដាក់ដូចគ្នា ទទួលបានសិទ្ធិដូចគ្នាក្នុងការនិយាយដូចភាគីម្ខាងទៀតដែរ មានសិទ្ធិទទួលព័ត៌មាន និងធ្វើការរិះគន់ដូចគ្នា ។ ម្យ៉ាងវិញទៀត ច្បាប់នេះ ការពារគូភាគីពីចៅក្រមដែលមានភាពលំអៀង អគតិ និងវិធានការទណ្ឌកម្ម សាលក្រម ឬការផ្តន្ទាទោស អតុល្យភាព វិសមាមាត្រ ។

> មាត្រា៣១ II CC:
>
> ប្រជាពលរដ្ឋខ្មែរ មាន<u>ភាពស្មើគ្នាចំពោះមុខច្បាប់</u> មាន<u>សិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នា</u>ទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាព ឯទៀតឡើយ ។
>
> មាត្រា១៤ I ១ ICCPR:
>
> មនុស្សគ្រប់រូប <u>មានសិទ្ធិស្មើៗគ្នានៅចំពោះមុខតុលាការ ឬនៅក្នុងសាលាជំនុំជំរះក្តី</u> ។

បញ្ញត្តិច្បាប់ទាំងអស់ សង្កត់ធ្ងន់លើការប្រព្រឹត្តិដោយយុត្តិធម៌ និងនីតិវិធីយុត្តិធម៌ **ក្នុងដំណាក់កាលមុនការជំនុំជំរះ** ។ ក្នុងកំឡុងពេលនៃដំណាក់កាលដ៏សំខាន់នៃនីតិវិធីនេះ ការងារស៊ើបអង្កេតភាគច្រើន ត្រូវបានធ្វើឡើងដោយនគរបាល ឬព្រះរាជអាជ្ញា ។ ក៏ប៉ុន្តែ ភាគច្រើននៃការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ដូចជាឃុំខ្លួនខុសច្បាប់ ឬការបង្ខិតបង្ខំឱ្យឆ្លើយសារភាព (ទារុណកម្ម ការបំភិតបំភ័យ ការចោទបកមកលើខ្លួនវិញដោយបង្ខំ) ជារឿយៗកើតឡើងនៅក្នុងកំឡុងរយៈពេលនេះ ។ ហេតុដូច្នេះហើយ ភាគីទន់ខ្សោយ (ចុងចោទ) ត្រូវការការការពារពិសេសដោយការផ្តល់សិទ្ធិពិសេសដល់គេ ដើម្បីធានានូវប្រព្រឹត្តកម្មដោយយុត្តិធម៌របស់ខ្លួន ។

មាត្រា៩ ICCPR:

**I-** បុគ្គលគ្រប់រូបមានសិទ្ធិទទួលបាននូវសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន ។ គ្មានបុគ្គលណាម្នាក់ត្រូវគេ ចាប់ចង ឬឃុំឃាំងតាមអំពើចិត្តបានឡើយ ។ គ្មានបុគ្គលណាម្នាក់ត្រូវគេដកហូតសេរីភាពរបស់ខ្លួនបានឡើយ លើកលែងតែក្នុងករណីណាដែលមានហេតុផល និងការអនុវត្តន៍ត្រឹមត្រូវតាមច្បាប់ ។

**II-** ជនដែលត្រូវគេចាប់ខ្លួន ត្រូវតែបានប្រាប់អំពីមូលហេតុនៃការចាប់ខ្លួន និងបទចោទប្រកាន់ចំពោះរូបគេ ឱ្យបានដឹងភ្លាម១ផង ក្នុងរយៈពេលនៃការចាប់ខ្លួន ។

**III-** ជនដែលត្រូវគេចាប់ខ្លួន ឬឃុំខ្លួនពីបទឧក្រិដ្ឋ ត្រូវតែបាននាំខ្លួនភ្លាម១ទៅជួបចៅក្រម ឬភ្នាក់ងារផ្សេងទៀតដែលច្បាប់អនុញ្ញាត ដើម្បីអនុវត្តន៍អំណាច "ច្បាប់" តុលាការ ហើយជននោះ ត្រូវមានសិទ្ធិឱ្យគេជំនុំជំរះទោសខ្លួនក្នុងរយៈពេលមួយដ៏សមគួរ ឬក៏ត្រូវដោះលែង ។ មិនត្រូវឱ្យមានបទបញ្ជាជាទូទៅណាមួយថា ជនដែលរង់ចាំការជំនុំជំរះទោសត្រូវតែដាក់ក្នុងមន្ទីរឃុំឃាំងនោះឡើយ ក៏ប៉ុន្តែការដោះលែងឱ្យនៅក្រៅឃុំ ត្រូវតែមានការធានារ៉ាប់រងថា ជននោះនឹងបង្ហាញមុខសំរាប់ការជំនុំជំរះទោសតាមកាលកំណត់ណាមួយនៃនីតិវិធីរបស់តុលាការ និងត្រូវមានមុខអនុវត្តសេចក្តីសំរេច "សាលក្រម" របស់តុលាការ ។

**VI-** ជនដែលត្រូវគេដកហូតសេរីភាពដោយការចាប់ខ្លួន ឬឃុំខ្លួន ត្រូវតែមានសិទ្ធិឱ្យគេនាំខ្លួនទៅជំនុំជំរះទោសនៅចំពោះមុខតុលាការ ដើម្បីឱ្យតុលាការនោះអាចសំរេចដោយគ្មានការយឺតយ៉ាវទៅលើភាពស្របច្បាប់នៃការឃុំខ្លួនរបស់គេ ហើយតុលាការអាចចេញបញ្ជាឱ្យដោះលែង ប្រសិនបើការឃុំឃាំងនោះ មិនត្រឹមត្រូវតាមច្បាប់ ។

**V-** ជនណាដែលបានរងគ្រោះដោយសារការចាប់ខ្លួន ឬឃុំខ្លួនមិនត្រឹមត្រូវតាមច្បាប់ ត្រូវមានសិទ្ធិពេញទីក្នុងការប្តឹងទាមទារជំងឺចិត្ត (ប្តឹងទៅតុលាការអាជ្ញាធរ ដែលចាប់ចងនេះ សងជម្ងឺចិត្ត) ។

មាត្រា ១០ ICCPR:

**I-** ជនដែលជាប់ឃុំឃាំង មានសិទ្ធិទាមទារឱ្យគេថែរក្សាខ្លួនឱ្យសមតាមបែបបទមនុស្សធម៌ និងឱ្យគេគោរពសេចក្តីថ្លៃថ្នូររបស់ខ្លួនដូមនុស្សឯទៀត១ដែរ ។

**មាត្រា៣៨ CC** ចែងអំពីការធានាអប្បបរមាដែលគួរឱ្យចាប់អារម្មណ៍ និងសំខាន់មួយចំនួន ដែលសូម្បីតែអនុសញ្ញាអន្តរជាតិ ជួនកាលក៏មិនបានអធិប្បាយឱ្យបានពិស្តារដូច្នោះដែរ ។

មាត្រា៣៨ CC:

**I-** ច្បាប់រ៉ាប់រង មិនឱ្យមាន ការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ ។

**II-** ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ។

**III-** ការចោទ ប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

**IV-** ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តកម្មណាមួយ ដែលបន្ថែមទម្ងន់ទណ្ឌកម្មអនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឱ្យធ្វើឡើយ ។ អ្នកដែដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិតត្រូវទទួលទោស តាមច្បាប់។

បទបញ្ញត្តិដែលពិស្តារបំផុតអំពីសិទ្ធិផ្នែកនីតិវិធី ដែលធានានូវប្រព្រឹត្តិកម្មដោយយុត្តិធម៌នៅក្នុងកំឡុងពេល ជំនុំជំរះនោះ មានកំណត់នៅក្នុង**មាត្រា១៤ ICCPR:**

មាត្រា ១៤ ICCPR:

**I-** នៅចំពោះមុខតុលាការ ឬនៅក្នុងសាលាជំនុំជំរះក្តីមនុស្សគ្រប់រូបមានសិទ្ធិស្មើៗគ្នា ។ ក្នុងការសំរេចផ្តន្ទាទោសឧក្រិដ្ឋទៅលើជនណាម្នាក់ និងក្នុងការសំរេចអំពីសិទ្ធិនិងករណីយកិច្ច របស់ជនណាម្នាក់ ក្នុងករណីដែលមានការប្តឹងផ្តល់សាមីខ្លួន ត្រូវមានសិទ្ធិស្មើសុំឱ្យមានការកាត់សេចក្តីឱ្យបានសមរម្យជាសាធារណៈ ។ ការសំរេចក្តីនេះត្រូវរៀបចំ និងដឹកនាំដោយក្រុមជំរះក្តីដែលតែងតាំងឡើងតាមលក្ខណៈច្បាប់ ។ ក្រុមជំរះក្តីនេះ ត្រូវមានសមត្ថភាពគ្រប់គ្រាន់ប្រកបទៅដោយឯករាជភាពពេញលេញ ហើយមិនត្រូវមានការលំអៀងទៅខាងណាឡើយ ។ ក្រុមសារព័ត៌មាន និងសាធារណៈជន អាចត្រូវគេហាមឃាត់មិនឱ្យចូលស្តាប់ ការកាត់ទោសនេះ ប្រសិនបើ គេយល់ថាអាចមានការទំនាស់ដល់សីលធម៌ របៀបរៀបរយសាធារណៈ ឬសន្តិសុខជាតិ នៅក្នុងសង្គមប្រជាធិបតេយ្យ ។ ម្យ៉ាងវិញទៀត ប្រសិនបើគូភាគីនានា ពុំមានឆន្ទៈចង់ឱ្យដឹងឮដល់សាធារណជន ឬក្នុងកាលៈទេសៈណាដែលតុលាការ យល់ឃើញថាការកាត់ទោសនៅចំពោះមុខសាធារណៈជនអាចបណ្តាលឱ្យមានការលំអៀង ប្រាសចាកពីគោលជំហរដែលត្រឹមត្រូវក្នុងការរកយុត្តិធម៌នេះ គេក៏អាចចេញបញ្ញត្តិហាមឃាត់ មិនឱ្យពួកកាសែត ឬសាធារណៈជនចូលស្តាប់ដែរ ។ ប៉ុន្តែក្រោយពីការជុំនុំជំរះរួចសព្វគ្រប់ ហើយលទ្ធផលនៃការវិនិច្ឆ័យរបស់តុលាការ ទោះជាក្នុងប្រការនៃបទឧក្រិដ្ឋឬជាក្តីក្តាំធម្មតាក្តី នឹងត្រូវផ្សាយជាព័ត៌មានជូនសាធារណជន ។ ក្នុងករណីណាដែលមានការជំទាស់ពីសំណាក់អ្នកទោសក្មេងៗ ការផ្សាយជាសាធារណៈនេះ អាចត្រូវហាមឃាត់បានដែរ ។ រីឯការវិនិច្ឆ័យ ទោសស្តីពីជម្លោះក្នុងរឿងអាពាហ៍ពិពាហ៍ ជម្លោះរឿងប្តីប្រពន្ធ ឬជម្លោះក្នុងរឿងដណ្តើមកូនចៅ ការផ្សាយជាសាធារណៈត្រូវហាមជាដាច់ខាត ។

**II-** តាមក្របខ័ណ្ឌច្បាប់ ជនជាប់ចោទពីបទឧក្រិដ្ឋត្រូវគេចាត់ទុកថាជាជនគ្មានកំហុស ដរាបណាបើគ្មានភស្តុងតាងគ្រប់គ្រាន់ ។

មាត្រា១៤ ICCPR (ត):

**III-** ក្នុងករណីនៃការសំរេចវិនិច្ឆ័យទោសឧក្រិដ្ឋ ជនជាប់ចោទគ្រប់ៗរូប មានសិទ្ធិស្មើៗគ្នាក្នុងការទទួលនូវកិច្ចធានាខ្លះៗ ដូចជា:

(ក) ការប្រាប់ឱ្យដឹងខ្លួនភ្លាមពីលក្ខណៈ និងហេតុផលនៃការផ្តន្ទាទោសនេះ ហើយគេត្រូវនិយាយភាសា ដែលសាម៉ីខ្លួនអាចស្តាប់បានគ្រប់គ្រាន់ ។
(ខ) សាម៉ីខ្លួនត្រូវមានពេលវេលា ព្រមទាំងសម្ភារៈគ្រប់គ្រាន់ក្នុងការការពារខ្លួននៅចំពោះមុខច្បាប់ និងដើម្បីទំនាក់ទំនងជាមួយស្មាក្តីដែលខ្លួនបាន ជ្រើសរើស ។
(គ) ការជំនុំជំរះកាត់ទោសត្រូវធ្វើភ្លាមដោយឥតពន្យាពេលយូរ ។
(ឃ) ការជំនុំជំរះកាត់ទោស ត្រូវធ្វើនៅចំពោះមុខសាមីជន ។ សាមីជនអាចឆ្លើយដោះសារដើម្បីការពារខ្លួនដោយខ្លួនឯង ឬអាចរកស្មាក្តីឱ្យជួយការពារ ។ សាមីជន មានសិទ្ធិរើសស្មាក្តីដោយខ្លួនឯង ប្រសិនបើខ្លួនមានប្រាក់គ្រប់គ្រាន់សំរាប់បង់ថ្លៃឈ្នួល ។ ក្នុងករណីណាដែលចាំបាច់តុលាការ ត្រូវតែងតាំងឱ្យស្មាក្តីឱ្យតំណាងជនជាប់ចោទដោយឥតគិតឈ្នួល ប្រសិនបើសាមីជននេះគ្មានមធ្យោបាយ ឬប្រាក់កាសគ្រាប់គ្រាន់ ។
(ង) លទ្ធភាពអាចពិនិត្យ និងសាកសួរដេញដោលទៅលើសាក្សីខាងគូបដិបក្ខ ។ សិទ្ធិស្មើសុំឱ្យមានសាក្សី ដើម្បីជួយឆ្លើយការពារខ្លួន ។ សាក្សីទាំងសង្ខាងគឺសាក្សីប្រឆាំង និងសាក្សីការពារ ត្រូវស្ថិតនៅក្នុងល័ក្ខខ័ណ្ឌច្បាប់ស្មើគ្នា ។
(ច) ត្រូវមានអ្នកបកប្រែភាសាសំរាប់ជួយដោយឥតគិតឈ្នួល ប្រសិនបើសាមីជនមិនចេះស្តាប់ភាសា ដែលប្រើក្នុងការកាត់ក្តីនេះ ។
(ឆ) សិទ្ធិមិនឱ្យនរណាបង្ខិតបង្ខំឱ្យឆ្លើយដាក់កំហុសលើខ្លួនឯង ឬទទួលសារភាពនូវកំហុសដែលមិនត្រឹមត្រូវ ។

**IV-** ចំពោះអ្នកទោសក្មេងៗវិញ ការវិនិច្ឆ័យទោស ត្រូវយោលទៅលើអាយុរបស់សាមីជន ហើយត្រូវផ្អែកទៅលើគោលដៅ នៃការអប់រំកសាងខ្លួន សាមីជនឱ្យបានប្រពៃឡើង ។

**V-** ជនដែលត្រូវគេផ្តន្ទាទោសក្នុងបទឧក្រិដ្ឋមានសិទ្ធិស្មើសុំទៅតុលាការថ្នាក់លើ ឱ្យសើរើពិនិត្យការវិនិច្ឆ័យទោសនេះសាជាថ្មី ។

**VI-** ជនណាម្នាក់ដែលត្រូវគេសំរេចផ្តន្ទាទោសជាបទឧក្រិដ្ឋរួចទៅហើយ ប៉ុន្តែស្រាប់តែត្រូវគេលើកលែងទោសឱ្យវិញ ដោយហេតុថាគេទើបតែរកឃើញភស្តុតាងថ្មីមួយដែលបញ្ជាក់ឱ្យឃើញថាការផ្តន្ទាទោសនោះពុំបានត្រឹមត្រូវដោយគតិយុត្តិធម៌ទេ ជនរងគ្រោះ ដោយអគតិយុត្តិធម៌នេះមានសិទ្ធិប្តឹងទាមទារជម្ងឺចិត្តតាមលក្ខណៈច្បាប់ ។ ប្រសិនបើ មូលហេតុនៃការកាត់ទោស មិនត្រឹមត្រូវនេះបណ្តាលមកអំពីការខំលាក់លៀមភស្តុតាង ពីសំណាក់ជនជាប់ចោទវិញនោះ ការប្តឹងទាមទារជម្ងឺចិត្តចំពោះករណីដូចចែងខាងលើ នឹងត្រូវទុកជាមោឃៈ ។

**VII-** យោលទៅតាមទម្រង់ការច្បាប់ព្រហ្មទណ្ឌនៃប្រទេសនិមួយៗ គេមិនអាចយកជនណាម្នាក់ទៅកាត់ទោសសារជាថ្មី ចំពោះបទល្មើសដែលសាមីជនបានទទួលទណ្ឌកម្ម ឬបានទទួលការលើកលែងទោស រួចទៅហើយទេ ។

មាត្រា ១៥ ICCPR:

១. គ្មានជនណាម្នាក់ត្រូវជាប់ទោសពីបទល្មើសព្រហ្មទណ្ឌឡើយ ចំពោះអំពើ ឬការធ្វេស-ប្រហែសណាមួយដែលពុំមែនជាបទល្មើសព្រហ្មទណ្ឌដែលមាននៅក្រោមច្បាប់ជាតិ ឬ ច្បាប់អន្តរជាតិ នៅខណៈពេលដែលអំពើនោះបានប្រព្រឹត្ត ។ ហើយក៏មិនត្រូវឱ្យមានការដាក់ទោសណាមួយឱ្យធ្ងន់ជាងទោស ដែលបានដាក់កាលពីបទល្មើសព្រហ្មទណ្ឌនោះ បានប្រព្រឹត្តឡើយ ។ ប្រសិនបើ ក្រោយពីការប្រព្រឹត្តបទល្មើស ហើយច្បាប់បានបញ្ញត្តិ ឱ្យមានការដាក់ទោសស្រាលជាងមុន ជនល្មើសត្រូវតែបានទទួលប្រយោជន៍នោះ ។

## ឃ) តើត្រូវធ្វើដូចម្តេចក្នុងករណីមានការរំលោភលើ "គោលការណ៍នៃការជំនុំជំរះដោយយុត្តិធម៌"?:

ចៅក្រម មេធាវីនៃគូភាគីវិវាទទាំងពីរ និងនៅក្នុងករណីព្រហ្មទណ្ឌ ព្រះរាជអាជ្ញាត្រូវតែធានាថាគ្មានការរំលោភ លើគោលការណ៍នៃការជំនុំជំរះដោយយុត្តិធម៌កើតឡើង ។ វាគឺជាភារកិច្ចទទួលខុសត្រូវរបស់ពួកគេដើម្បីធានានូវនីតិវិធីរឿងក្តីដោយយុត្តិធម៌ ។ ដូច្នេះ ពួកគេត្រូវតែឃ្លាំមើលនីតិវិធីនោះដោយយកចិត្តទុកដាក់ ហើយទាមទារនូវសេចក្តីសំរេចចិត្តតាមនីតិវិធីរបស់ចៅក្រម គ្រប់ពេលដែលពួកគេយល់ថា សិទ្ធិរបស់ភាគីមួយមិនត្រូវបានគោរពដោយចៅក្រម ដោយព្រះរាជអាជ្ញា ឬដោយភាគីមួយទៀត ។

ប្រសិនបើចាំបាច់ ការជំនុំជំរះត្រូវផ្អាកមួយភ្លែតដោយតុលាការ ដើម្បីធ្វើសេចក្តីសំរេចអំពីបញ្ហានីតិវិធីបែបនោះ ។ តុលាការ ត្រូវផ្អាកនីតិវិធីផងដែរ នៅពេលដែលគូភាគីសុំពេលវេលាខ្លះ ដើម្បីសំរេចអំពីជំហាននីតិវិធីជាបន្ទាប់ទៀតរបស់ពួកគេ ។

ឧទាហរណ៍:

១០ នាទី មុនពេលចាប់ផ្តើមការជំនុំជំរះ មេធាវីរបស់ចុងចោទដឹងអំពីសាក្សីថ្មីម្នាក់ដែលអាចផ្តល់ភស្តុតាងអំពីនិរទោសនៃកូនក្តីរបស់គាត់ ។ ក្នុងកំឡុងពេលសវនាការ គាត់សំរេចធ្វើសវនាការដោយមានសាក្សីនោះ ។ ចៅក្រមក៏បានសំរេចចិត្តធ្វើសវនាការសាក្សីនោះ ប៉ុន្តែគាត់ត្រូវតែផ្អាកការជំនុំជំរះ ពីព្រោះសាក្សីនោះរស់នៅក្នុងទីក្រុងផ្សេងទៀត ហើយមិនអាចកោះហៅមកភ្លាមៗបាន ។

គូភាគីត្រូវតែធានាថា ការទាមទារនីតិវិធីរបស់ខ្លួនព្រមទាំងការបដិសេធនូវការទាមទារណាមួយ បែបនេះដោយចៅក្រមត្រូវបានកត់ត្រាទុកដោយយកចិត្តទុកដាក់នៅក្នុងកំណត់ហេតុផ្លូវការ (ពិធីសារ) នៃនីតិវិធីរឿងក្តីនោះជាលាយលក្ខណ៍អក្សរ ។ បើមិនដូច្នោះទេ នៅពេលធ្វើបណ្តឹងឧទ្ធរណ៍លើកក្រោយ ពួកគេមិនមានលទ្ធភាពបង្ហាញថា សាលក្រមនេះ មានកំហុសផ្នែកនីតិវិធី ហើយត្រូវការកែប្រែបានឡើយ ។ ហើយសាលាឧទ្ធរណ៍អាចពិនិត្យមើលថា តើកំហុសពិតជាមានមែនឬអត់?

**ភារកិច្ចរបស់ក្រឡាបញ្ជី** គឺត្រូវរក្សាកំណត់ហេតុឱ្យបានល្អ ។



**ការថែរក្សា និងបំពេញ សុំណុំរឿង ឯកសារ**
**និងកំណត់ហេតុជំនុំជំរះបានល្អ**
**សំខាន់សំរាប់**
**ភាពយុត្តិធមិនៃការកាត់ក្តី!**



នៅក្នុងអត្ថបទខាងក្រោមនេះ រៀបរាប់អំពីការរំលោភបំពានជាទូទៅមួយចំនួនលើគោលការណ៍នៃការជំនុំជំរះដោយយុត្តិធមិនៅក្នុងប្រទេសកម្ពុជា និងអំពីប្រតិកម្មមួយចំនួនរបស់គូភាគី ។

### I) ចៅក្រមលំអៀង ស៊ីសំណូក អគតិៈ

ឧទាហរណ៍:

- មេធាវីដឹងថា គេបានឃើញចៅក្រមអង្គុយជាមួយមេធាវីរបស់ភាគីម្ខាងទើបតែមួយថ្ងៃមុនថ្ងៃជំនុំជំរះ ហើយបានហុចស្រោមសំបុត្រឱ្យគ្នាទៅវិញទៅមក (ប្រហែលជាដាក់លុយ) ។
- ចៅក្រម ប្រើពាក្យសម្តីប្រមាថមើលងាយទៅលើភាគីម្ខាងទៀតនៅក្នុងពេលជំនុំជំរះ ឬរំខានដល់ភាគីនេះគ្រប់ពេល ឬពាក្យសម្តីរបស់គាត់បង្ហាញនូវការលំអៀងទៅរកភាគីនោះយ៉ាងច្បាស់ថា ("អ្នកនិយាយពាក្យមិនបានការរហូត") ។
- មេធាវីដឹងថា ចៅក្រមបានរៀបចំសាលក្រម ដែលសរសេររួចជាស្រេចនៅលើតុរបស់គាត់មុនពេលការជំនុំជំរះចប់ ។

គូភាគី មានសិទ្ធិទទួលបានចៅក្រមដែលមិនលំអៀង (មាត្រា១២៨ I, II CC, មាត្រា១៤ I ២ ICCPR) ។

## វិធាននៃដំណោះស្រាយៈ

- នៅក្នុងករណីទាំងអស់ដែលបំពានលើ "គោលការណ៍នៃការជំនុំជំរះដោយយុត្តិធមិ" មេធាវីរបស់ភាគីដែលទទួលរងផលប៉ះពាល់ អាច**បដិសេធចៅក្រមនោះ** ហើយអាចទាមទារឱ្យ**ចៅក្រមម្នាក់ទៀត**សំរេចបាន ។ មេធាវី ត្រូវតែប្តឹងទាមទារនីតិវិធី ។ វាជាសិទ្ធិរបស់ភាគី ដែលត្រូវឱ្យចៅក្រមម្នាក់ទៀត សំរេចអំពីការទាមទារនេះ ។ ការទាមទារ និងការបដិសេធន៍ដែលអាចកើតមានឡើងចំពោះការទាមទារនេះ ត្រូវតែកត់ត្រាទុកក្នុងកំណត់ហេតុ!
- នៅក្នុងនីតិវិធីនៃ**ការធ្វើឧទ្ធរណ៍ជាបន្តបន្ទាប់មកទៀត** មេធាវី អាចទាមទារឱ្យមាន**ការកែប្រែសាលក្រម**ដោយសារមានកំហុសផ្នែកនីតិវិធីដែលថា ការបដិសេធន៍មិនទទួលយកចៅក្រម មិនត្រូវបានសំរេចឱ្យបានសមស្រប ។

## II) ការបដិសេធន៍សិទ្ធិក្នុងការពិនិត្យមើលឯកសាររបស់ភាគីម្ខាងទៀត៖

ឧទាហរណ៍៖

ភាគីមួយដាក់ជូនសេចក្តីថ្លែងការណ៍ និងឯកសារភស្តុតាងរបស់ខ្លួនទៅចៅក្រម ។ ចៅក្រម មិនបានផ្ញើច្បាប់ចម្លងនៃឯកសារទាំងនេះទៅឱ្យមេធាវីនៃភាគីម្ខាងទៀត ។ ប៉ុន្តែ ចៅក្រមបានរក្សាឯកសារទាំងនេះទុកក្នុងសំណុំឯកសារតុលាការរបស់ខ្លួន ។ នៅពេលដែលភាគីម្ខាងទៀសុំមើលឯកសារទាំងនេះ និងសុំច្បាប់ចម្លងនៃឯកសារនេះ ចៅក្រមបដិសេធន៍មិនឱ្យ ។ ចៅក្រមនិយាយថា ប្រការនេះមិនអាចធ្វើទៅបានទេ ពីព្រោះឯកសារទាំងនេះគឺជាឯកសារសំងាត់ "ផ្ទៃក្នុង" តុលាការ ។ ម្យ៉ាងវិញទៀត គាត់និយាយថា តុលាការមិនអាចមានថវិកាគ្រប់គ្រាន់ដើម្បីធ្វើការថតចម្លងបានទេ ដោយសារតែកង្វះខាតមូលនិធិ ។

ភាគីនោះ មានសិទ្ធិទទួលបានឱកាសគ្រប់គ្រាន់សំរាប់ការរៀបចំការជំនុំជំរះ (មាត្រា១៤ III ខ) ICCPR)។ សិទ្ធិនេះ រាប់បញ្ចូលទាំង សិទ្ធិដើម្បីដឹង និងមើលឯកសារ និងសេចក្តីថ្លែងការណ៍ និងភស្តុតាងទាំងអស់ដែលភាគី ម្ខាងទៀតបានដាក់ជូនចៅក្រម ។ ដូច្នេះ ឯកសារទាំងនេះ មិនអាចជាឯកសារ "ផ្ទៃក្នុង" ក្នុងន័យនៃការដាក់កំហិតសំរាប់តែចៅក្រមម្នាក់ឯងអានប៉ុណ្ណោះទេ ។ តាមធម្មតា ភាគីដែលដាក់ជូនឯកសារមានបន្ទុកផ្តល់នូវច្បាប់ចម្លងនៃឯកសារទាំងនេះ ហើយតុលាការបញ្ជូនឯកសារទាំងនេះទៅឱ្យភាគីម្ខាងទៀត ។ យ៉ាងហោចណាស់ តុលាការត្រូវតែឱ្យភាគីម្ខាងទៀតមានឱកាសថតចម្លងឯកសារទាំងនេះ ដោយចេញថវិកាផ្ទាល់ខ្លួន ។

### វិធាននៃដំណោះស្រាយ៖

- ក្នុងករណីមានការរំលោភបំពានលើ "គោលការណ៍នៃការជំនុំជំរះដោយយុត្តិធម៌" មេធាវី គួរតែ**ប្តឹងទាមទារទៅតាមនីតិវិធី ដើម្បីពិនិត្យមើលឯកសារទាំងនោះ** ។ ចៅក្រម គួរតែដាក់**សេចក្តីសំរេចដែលមានបញ្ជាក់ហេតុផលជាលាយលក្ខណ៍អក្សរ** ឱ្យមាននៅក្នុងសំណុំឯកសាររបស់តុលាការ ។
- ប្រសិនបើ ចៅក្រម បដិសេធន៍ មិនចេញសេចក្តីសរេចដែលមានបញ្ជាក់ហេតុផលជាលាយលក្ខណ៍ មេធាវីអាច**ដាក់ពាក្យ បណ្តឹងប្តឹងពីចៅក្រមនេះទៅប្រធានតុលាការ** ពីការប្រព្រឹត្តមិនប្រក្រតីរបស់ចៅក្រម ។
- មេធាវីថែមទាំង អាចផ្ញើច្បាប់ចម្លង**នៃការទាមទារនេះទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម** ដែលទទួលខុសត្រូវលើការត្រួតពិនិត្យការអនុវត្តន៍របស់ចៅក្រម ។
- ប្រសិនបើ ការធ្វើបែបនេះមិនអាចជួយបាន មេធាវីអាច**ប្តឹងជំទាស់ចៅក្រម**ចំពោះការលំអៀង មុនពេលនីតិវិធីជំនុំជំរះចាប់ផ្តើម និងអាចទាមទារឱ្យ**ចៅក្រមផ្សេងទៀតសំរេច** ។
- ជាចុងក្រោយ **ការធ្វើឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមរបស់ចៅក្រមដែលលំអៀងនេះ** អាចផ្អែកលើកំហុសផ្នែកនីតិវិធីនៃការរំលោភសិទ្ធិក្នុងការទទួលព័ត៌មានស្មើគ្នាអំពីសេចក្តីថ្លែងការណ៍ទាំងអស់របស់ភាគីម្ខាងទៀត ។

## III) ការឆ្លើយសារភាពពីពិរុទ្ធភាពរបស់ចុងចោទដែលបានមកពីការធ្វើទារុណកម្ម:

ឧទាហរណ៍:

ក្នុងកំឡុងពេលជំនុំជំរះ ចុងចោទនិយាយថា គាត់ត្រូវបាននគរបាលវាយធ្វើបាបយ៉ាងព្រៃផ្សៃក្នុងកំឡុងពេលនៃការឃុំខ្លួនមុនពេលជំនុំជំរះ ហើយនគរបាលបង្ខំគាត់ដោយប្រើមធ្យោបាយនោះឱ្យឆ្លើយសារភាព ថាគាត់បានប្រព្រឹត្តឧក្រិដ្ឋកម្មមែន ។ គាត់បើកអាវឡើង ហើយបង្ហាញស្នាមជាំថ្មីៗ និងស្នាមដំបៅនៅលើខ្លួនគាត់ ។

ទារុណកម្ម ត្រូវបានហាមឃាត់ដោយគ្មានការលើកលែងណាមួយឡើយ ។ ការធ្វើទារុណកម្មជនណាម្នាក់គឺជាឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុតសំរាប់មនុស្សជាតិ ។ អ្នកធ្វើទារុណកម្មត្រូវតែផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរ (សូមមើលមាត្រា៤-៩ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម) ។ ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម មិនអាចត្រូវបានប្រើប្រាស់ប្រឆាំងទៅលើចុងចោទបានទេ។ គ្មានជនណាម្នាក់ ត្រូវបានគេបង្ខំឱ្យចោទប្រកាន់លើខ្លួនឯង ថាបានប្រព្រឹត្តិបទឧក្រិដ្ឋឡើយ (មាត្រា៣៨ I, III, IV CC មាត្រា៧, ១០ I និងមាត្រា១៤ III ឆ) ICCPR) ។

### វិធាននៃដំណោះស្រាយ:

- ក្នុងករណីមានការបំពានលើ "គោលការណ៍នៃការជំនុំជំរះដោយយុត្តិធម៌" មេធាវីរបស់ចុងចោទ ត្រូវតែដាក់ពាក្យបណ្តឹងទាមទារទៅតាមនីតិវិធីថា **ចម្លើយសារភាពរបស់កូនក្តីរបស់គាត់ ដែលទុកជាភស្តុតាងនោះត្រូវតែ ដកចេញពីនីតិវិធី** ។
- ក្នុងករណីមានវិមតិសង្ស័យអំពីការចោទប្រកាន់លើកូនក្តីរបស់ខ្លួន មេធាវីគួរតែយ៉ាងហោចណាស់ ស្នើសុំផ្អាក ឬលើកពេលជំនុំជំរះ ដើម្បីបានពេលវេលាគ្រប់គ្រាន់សំរាប់ស៊ើបអង្កេត ។
- មេធាវី អាចស្នើសុំបន្ថែមនូវ**ការស៊ើបអង្កេតផ្លូវការ** ទៅលើឧប្បត្តិហេតុនៃការធ្វើទារុណកម្មនោះ ។
- គាត់អាចដាក់ពាក្យ**បណ្តឹងព្រហ្មទណ្ឌ ប្តឹងអំពីមន្ត្រីនគរបាលដែលទទួលខុសត្រូវ** ។
- លើសពីនេះទៀត មេធាវី អាចដាក់ពាក្យបណ្តឹង**ទាមទារសំណងរដ្ឋប្បវេណី**បន្ថែម **អំពីមន្ត្រីនគរបាលទាំងនេះ**ទៅតុលាការរដ្ឋប្បវេណី ទាមទារសំណងជំងឺចិត្ត ។
- បន្ថែមពីលើនេះ មេធាវី អាចធ្វើពាក្យបណ្តឹងមួយទៅ**ក្រសួងមហាផ្ទៃ និងនាយកដ្ឋានពន្ធនាគារ** ដោយស្នើសុំឱ្យពួកគេដាក់ទណ្ឌ**កម្មវិន័យ**ណាមួយ ។

គេក៏អាចចាត់វិធានការទាំងអស់នេះបានផងដែរ ក្នុងករណីជនសង្ស័យ ត្រូវឃុំខ្លួនមុនការជំនុំជំរះ**លើសពី ៦ខែ ដោយគ្មានហេតុផល និងបញ្ជាបន្ថែមរបស់តុលាការ** ។ ក្នុងករណីនេះ សេរីភាពផ្ទាល់ខ្លួនរបស់ជនដែលជាប់ក្នុងមន្ទីរឃុំឃាំង ត្រូវរំលោភបំពានដោយខុសច្បាប់ ដែលទង្វើបែបនេះគឺជាបទឧក្រិដ្ឋមួយ ។

## IV) ពុំមានភស្តុតាងដែលត្រូវលើកឡើងដោយតុលាការ:

ឧទាហរណ៍:

- ក្រឡាបញ្ជី អានតែរបាយការណ៍នគរបាលប៉ុណ្ណោះ ដើម្បីបង្ហាញភស្តុតាងប្រឆាំងចុងចោទ ។ ទាំងមន្ត្រីនគរបាលដែលបានសរសេររបាយការណ៍នេះ ទាំងសាក្សីដែលបានរៀបរាប់នៅក្នុងរបាយការណ៍ ពុំត្រូវបានកោះ

ហៅឱ្យមកបង្ហាញមុខនៅក្នុងតុលាការ ដើម្បីឆ្លើយបំភ្លឺដោយផ្ទាល់ឡើយ ។ ឬពួកគេត្រូវបានកោះហៅ តែមិនបានមកបង្ហាញមុខឡើយ ។

- នៅក្នុងករណីរដ្ឋប្បវេណី ដើមចោទគ្រាន់តែចោទប្រកាន់សំអាងលើអង្គហេតុមួយចំនួនប៉ុណ្ណោះ ប៉ុន្តែមិនបាន ផ្តល់នូវភស្តុតាងណាមួយ ដើម្បីបង្ហាញឡើយ ទោះបីជាអង្គហេតុទាំងនោះ ត្រូវបានជំទាស់ដោយភាគីចុងចោទ ក៏ដោយ ។

គ្មានជនណាម្នាក់ ត្រូវបានកាត់ទោសដោយគ្មានភស្តុតាងគ្រប់គ្រាន់ឡើយ ។ អង្គហេតុដែលមានទំនាស់ ត្រូវតែបង្ហាញភស្តុតាងដោយភាគីដែលបានបង្ហាញអង្គហេតុទាំងនេះ (គោលការណ៍នៃសច្ចធារណ៍នៃនិរទោស, បន្ទុកភស្តុតាង, អត្ថប្រយោជន៍នៃវិមតិសង្ស័យ) ។ ភាគីនីមួយៗមានសិទ្ធិដើម្បីពិនិត្យ និងសាកសួរអំពីភស្តុតាង ចោទប្រកាន់ ដែលត្រូវបានបង្ហាញដោយភាគីម្ខាងទៀត (មាត្រា១៤ II, III ង) ICCPR មាត្រា៣៨ VI និង V CC) ។

## វិធាននៃដំណោះស្រាយៈ

- នៅក្នុងករណីមានការបំពានលើ "គោលការណ៍នៃការជំនុំជំរះដោយយុត្តិធម៌" មេធាវី **ត្រូវតែដាក់ពាក្យបណ្តឹង ទាមទារទៅតាមនីតិវិធី** ដោយស្នើសុំឱ្យតុលាការ**កោះហៅសាក្សី និងមន្ត្រីនគរបាលៈ**
  ក) ដើម្បីមកបង្ហាញមុខ
  ខ) ឆ្លើយបំភ្លឺ និង
  គ) ដើម្បីមកសួរចម្លើយ មិនត្រឹមតែដោយតុលាការ និងព្រះរាជអាជ្ញា ប៉ុណ្ណោះទេ ប៉ុន្តែដោយមេធាវីរបស់ខ្លួន ផងដែរ ។
- ក្នុងករណីដែលពួកគេមិនគោរពតាមការកោះហៅ មេធាវី អាចទាមទារឱ្យចៅក្រមបង្ខំពួកគេឱ្យមកបង្ហាញ មុខ ដោយការគំរាមដាក់ពិន័យលើពួកគេ ឬដឹកជញ្ជូនពួកគេទៅតុលាការទាំងបង្ខំដោយនគរបាលយុត្តិធម៌ ។
- នៅពេលដែលជាចុងក្រោយពួកគេបង្ហាញមុខ មេធាវីមានសិទ្ធិសួរចម្លើយសាក្សីទាំងនេះ និងដើម្បីបញ្ចេញ មតិលើការឆ្លើយបំភ្លឺរបស់ពួកគេដោយគ្មានការរំខានឡើយ ។

## V) អត្ថបទនៃសាលក្រមមិនមានហេតុផលៈ

<u>ឧទាហរណ៍ៈ</u>

ចៅក្រម ចេញសាលក្រមដោយគ្រាន់តែរៀបរាប់ពីលទ្ធផលនៃការជំនុំជំរះ (ការដាក់ទោស ឬការលើក- លែងទោស ឬការច្រានចោលការទាមទារសំណងរដ្ឋប្បវេណី) ។ សាលក្រមនេះ សំអាងទៅលើ "ច្បាប់ដែលជំពាក់ ទាក់ទង" និង "អង្គហេតុ និងភស្តុតាងដែលប្រមូលបាន" តែប៉ុណ្ណោះ ប៉ុន្តែមិនបង្ហាញមួយជំហានម្តងៗថា តើអង្គហេតុមួយណាដែលមិនផ្ទុយគ្នា អង្គហេតុមួយណាដែលផ្ទុយគ្នា ប៉ុន្តែត្រូវបង្ហាញភស្តុតាង ដោយភាគី ម្ខាងនៃគូភាគី និងថាតើមាត្រាច្បាប់ណា ដែលត្រូវបានអនុវត្តទៅលើអង្គហេតុទាំងនេះឡើយ?

សាលក្រមប្រភេទនេះ កាត់ផ្តាច់នូវសិទ្ធិរបស់គូភាគីក្នុងការធ្វើឧទ្ធរណ៍ប្រកបដោយប្រសិទ្ធិភាព ពីព្រោះវាមិនបានផ្តល់នូវឱកាសណាមួយ ដើម្បីធ្វើឱ្យសាលក្រមនេះ អាចប្រឈមមុខជាមួយឧទ្ធរណ៍ណាមួយបានឡើយ (មាត្រា១៤ V ICCPR) ។ វាបើកឱកាសគ្រប់យ៉ាង ឱ្យចៅក្រមលាក់កំបាំងនូវមូលហេតុពិតប្រាកដសំរាប់ចេញសាលក្រមនេះ ។ កង្វះខាតហេតុផល អាចលាក់កំបាំងសេចក្តីសំរេចអត្តនោម័ត និងសេចក្តីសំរេចចិត្តក្រោមឥទ្ធិពលសំណូក ឬអាចក៏អាចលាក់កំបាំងនូវកង្វះខាតចំណេះផ្នែកច្បាប់របស់ចៅក្រមបាន ។

## វិធាននៃដំណោះស្រាយ:

- ក្នុងករណីមានការបំពានលើ "គោលការណ៍នៃការជំនុំជំរះដោយយុត្តិធម៌" មេធាវីរបស់ភាគីទាំងពីរ អាចដាក់**ពាក្យបណ្តឹងទាមទារតាមនីតិវិធី ដោយស្នើសុំនូវការពន្យល់ ជាលាយលក្ខណ៍អក្សរនូវហេតុផលនៃការសំរេចរបស់សាលក្រមនោះ** ក្នុងពេលកំណត់ណាមួយ ។

- ប្រសិនបើចៅក្រម មិនព្រមពន្យល់ហេតុផលជាលាយលក្ខណ៍អក្សរនោះទេ មេធាវីអាចដាក់**ពាក្យបណ្តឹង ប្តឹងចៅក្រមនោះទៅ**
  ក) **ប្រធានតុលាការ** និង
  ខ) **ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម** ។

- ជាចុងក្រោយ **ការធ្វើឧទ្ធរណ៍ប្រឆាំងទៅនឹងសាលក្រមនេះ** អាចផ្អែកលើការពិតដែលថា ការចេញសាលក្រមដោយគ្មានហេតុផល គឺជាកំហុសដ៏ធ្ងន់ធ្ងរមួយ ដែលធ្វើឱ្យសាលក្រមទាំងមូលទៅជា**មោឃៈ** ។ សាលក្រមបែបនេះ ត្រូវបានគេបដិសេធ ហើយប្រកាសថាជាមោឃៈ ។ សាលាឧទ្ធរណ៍ ត្រូវតែផ្ញើនីតិវិធីនោះទៅឱ្យតុលាការថ្នាក់ក្រោមខាងដើមវិញសំរាប់ប្រើក្នុងនីតិវិធីនៃរឿងក្តីថ្មី ពីព្រោះ ការជំនុំជំរះពីមុននៅតែបើកចំហនៅឡើយ ពីព្រោះ វាមិនទាន់បានបិទដោយសាលក្រមដែលសមស្របមួយឡើយ ។

# បញ្ជីត្រួតពិនិត្យអំពីសិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌

| **ការប្រាស្រ័យទាក់ទងដោយយុត្តិធម៌** | **សិទ្ធិពិសេស** | **មាត្រាដែលពាក់ព័ន្ធ** |
|---|---|---|
| សិទ្ធិទទួលព័ត៌មាន<br> | សិទ្ធិស្មើគ្នាដើម្បី :<br>• **ដឹងពីបទចោទប្រកាន់** (ការទាមទាររបស់ដើមចោទនៅក្នុងវិវាទច្បាប់រដ្ឋប្បវេណី)<br>• **ពិនិត្យមើលរាល់ឯកសារទាំងអស់ សំណុំរឿង និងភស្តុតាង** ដែលត្រូវបានបង្កើតប្រឆាំងនឹងភាគីផ្ទាល់។ (សិទ្ធិនេះកើត ចេញពីសិទ្ធិដើម្បី រៀបចំការការពារផ្ទាល់ខ្លួន) | មាត្រា៩ II និងមាត្រា ១៤ III ក) ICCPR<br>មាត្រា ១៤ III ខ) ICCPR |
| សិទ្ធិផ្តល់ព័ត៌មាន<br><br>(នៅក្នុងក្តីព្រហ្មទណ្ឌ គ្មានករណីយកិច្ចត្រូវផ្តល់ព័ត៌មានទេ!<br>សូមមើលខាងក្រោម: សិទ្ធិរក្សាភាពស្ងៀមស្ងាត់ និងសិទ្ធិមិនឱ្យគេបង្ខំឱ្យឆ្លើយសារភាព ឬការចោទមកលើខ្លួនវិញ) | សិទ្ធិស្មើគ្នាដើម្បី :<br>• **និយាយ** (ការនិយាយដែលគ្មានគេនិយាយកាត់ពាក្យចុងក្រោយរបស់ជនជាប់ចោទ)<br>• **បង្ហាញមុខ**<br>• **បង្ហាញភស្តុតាង** (ភស្តុតាងសំរាល ឧទាហរណ៍: ហៅសាក្សីការពារ) | មាត្រា១៤ I ២ ICCPR ("សវនាការ" ដោយយុត្តិធម៌)<br>មាត្រា១៤ ឃ) ICCPR<br>មាត្រា ១៤ III ង) ICCPR |
| សិទ្ធិពិនិត្យព័ត៌មានរបស់ភាគីម្ខាង ទៀត<br> | សិទ្ធិស្មើគ្នាដើម្បី :<br><br>**សាកសួរសាក្សី**អំពីការកាត់ទោស (ឬអំពីភាគីម្ខាងទៀត) | មាត្រា ១៤ III ង) ICCPR |
| សិទ្ធិគាំទ្រការប្រាស្រ័យទាក់ទង<br> | សិទ្ធិស្មើគ្នាដើម្បីរក:<br>• ការបកប្រែ/អ្នកបកប្រែ<br>• មេធាវី (ជំនួយផ្នែកច្បាប់) | មាត្រា ១៤ III ក) ឆ) ICCPR<br>មាត្រា ១៤ III ខ) ឃ) ICCPR |
| **ការប្រាស្រ័យទាក់ទងដោយ សុវត្ថិភាព និងបើកចំហ** | **សិទ្ធិពិសេស** | **មាត្រាដែលពាក់ព័ន្ធ** |
| សិទ្ធិធ្វើការជំនុំជំរះជាសាធារណ:<br> | សិទ្ធិទទួល:<br>• ការជំនុំជំរះសាធារណ:<br>• សាលក្រមសាធារណ: | មាត្រា១៤ I ២ ICCPR<br>មាត្រា១៤ I ៣ ជំរើសទី ២ ICCPR |
| សិទ្ធិមិនត្រូវបានគេបង្ខិតបង្ខំ<br> | សិទ្ធិមិនត្រូវបានគេ :<br>• ធ្វើបាប ធ្វើទារុណកម្ម<br>• បង្ខិតបង្ខំឱ្យឆ្លើយសារភាព ឬការធ្វើពិរុទ្ធកម្មខ្លួនឯង<br>• កាត់ទោសដោយផ្អែកលើ ភស្តុតាងដែលបានពីការធ្វើទារុណកម្ម | មាត្រា៣៨ I, III, IV CC<br>មាត្រា៧,១០ I ICCPR<br>មាត្រា៣៨ IV 1 CC<br>មាត្រា១៤ III ឆ) ICCPR<br>មាត្រា៣៨ V CC |

| **ល្បឿនសមរម្យនៃនីតិវិធី** | **សិទ្ធិពិសេស** | **មាត្រាដែលពាក់ព័ន្ធ** |
|---|---|---|
| សិទ្ធិទទួលការជំនុំជំរះរហ័ស<br>(ការជំនុំជំរះមិនត្រូវយឺតយូរពេកទេ)<br>Calendar<br> | សិទ្ធិ:<br>• **ត្រូវដឹងព័ត៌មានភ្លាមៗ**អំពីបទចោទប្រកាន់<br>• ទទួល**ការពិនិត្យភ្លាមៗ**លើការឃាត់ខ្លួន **ដោយតុលាការ**<br>• ទទួលបាន**សាលក្រម ដោយគ្មានការពន្យាដោយមិនសមស្រប** (ក្នុងករណីដែលមានការកាត់ទោសយុវជន: កាន់តែឆាប់ដែលអាចធ្វើទៅបាន) | មាត្រា៩ II និង<br>មាត្រា១៤ III ក) ICCPR<br>មាត្រា៩ II, III ICCPR<br>មាត្រា១៤ III គ) ICCPR និង<br>មាត្រា១០ II ខ) ICCPR |
| សិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់<br>(ការជំនុំជំរះមិនត្រូវលឿនពេកទេ)<br> | សិទ្ធិក្នុងការ:<br>• **និយាយ** ដោយមិនមានគេនិយាយកាត់<br>="ការជំនុំជំរះ" ដោយយុត្តិធម៌<br>• **រៀបចំការការពារ** និងនិយាយជាមួយមេធាវី | មាត្រា១៤ I ១ ICCPR<br>មាត្រា១៤ III ខ) ICCPR |
| **លក្ខខណ្ឌគំរូវសំរាប់** | **សិទ្ធិពិសេស** | **មាត្រាដែលពាក់ព័ន្ធ** |
| ភាពយុត្តិធម៌របស់ចៅក្រម<br> | សិទ្ធិដើម្បីទទួលបាន:<br>• ចៅក្រម**មិនលំអៀង អនាគតិ មិនស៊ីសំណូក**<br>• **សច្ចធារណ៍នៃនិរទោស** (ដរាបណា មិនមានភស្តុតាង ចៅក្រម ត្រូវតែប្រព្រឹត្តិចំពោះចុងចោទដូចជាអ្នកគ្មានទោស)<br>• **អត្ថប្រយោជន៍នៃវិមតិសង្ស័យ** (បន្ទុកភស្តុតាងត្រូវធ្វើដោយព្រះរាជអាជ្ញា ឬដើមចោទ តែក្នុងករណីដែលមិនមានវិមតិសង្ស័យប៉ុណ្ណោះ ប៉ុន្តែអង្គហេតុទាំងអស់ ត្រូវបង្ហាញដោយភស្តុតាងដែលចៅក្រមអាចកាត់ទោសជនជាប់ចោទបាន)។ | មាត្រា១២៨ I និង II CC<br>មាត្រា១៤ I ២ ICCPR<br>មាត្រា៣៨ VI CC និង<br>មាត្រា១៤ II ICCPR<br>មាត្រា៣៨ V CC |
| ភាពយុត្តិធម៌នៃសាលក្រម<br> | សិទ្ធិមិនត្រូវបាន:<br>• **ដាក់ទោសពីរដង** ចំពោះសកម្មភាពដដែល ពីព្រោះទង្វើបែបនេះ **អាចវិសមាមាត្រ** (=ខ្លាំងក្លាពេក)<br>• ដាក់ទោសចំពោះទង្វើកន្លងទៅហើយ ដែលមិនអាចដាក់ទោសបានដោយច្បាប់ជាធរមាន នៅពេលដែលទង្វើនោះត្រូវបានប្រព្រឹត្ត (**"ការហាមឃាត់ដល់ការដាក់ទោសដែលមានលក្ខណៈប្រតិសកម្ម"**)<br>សិទ្ធិដើម្បី :<br>**ធ្វើបណ្តឹងឧទ្ធរណ៍**ចំពោះសាលក្រម (ករណីនេះ រាប់ទាំងសិទ្ធិទទួលហេតុផលរបស់សាលក្រម: តើអង្គហេតុអ្វីខ្លះដែលចៅក្រមបានទទួលយកជាភស្តុតាង? និងតើចៅក្រមអនុវត្តច្បាប់ណាទៅលើអង្គហេតុទាំងនេះ?) | មាត្រា១៤VII ICCPR<br>មាត្រា១៥ I ICCPR<br>មាត្រា១៥ V ICCPR |

## ? សំនួរសិក្សាទី ១៥

តើចៅក្រមកម្ពុជា ត្រូវបានចងភ្ជាប់ដោយមាត្រានានា នៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ដែរឬទេ?

## ? សំនួរសិក្សាទី ១៦

ទាំងរដ្ឋធម្មនុញ្ញកម្ពុជា និងកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មានចែង មាត្រាជាច្រើនស្តីពី សិទ្ធិមនុស្សដូចៗគ្នា (ដូចជា សេរីភាពក្នុងការបញ្ចេញមតិ មាត្រា១៩ ICCPR និងមាត្រា៤១ CC) ។

ក) ហេតុអ្វីបានជា វានៅតែមានប្រយោជន៍សំរាប់ចៅក្រមកម្ពុជា ដែលត្រូវអនុវត្តមាត្រានៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បន្ថែមលើមាត្រានៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ដូចជា ករណីដែលទាក់ទងនឹងសេរីភាពក្នុងការបញ្ចេញមតិ)?

ខ) តើចៅក្រមកម្ពុជា អាចយកមាត្រា១៤ ICCPR មកធ្វើជាមូលដ្ឋាននៃនីតិវិធីក្នុងការធ្វើសេចក្តីសំរេចបានដែរឬទេ?

## ? សំនួរសិក្សាទី ១៧

មាត្រា៣១ I CC ចែងយ៉ាងច្បាស់អំពី "សេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស" ទោះបីជាសេចក្តីថ្លែងការណ៍នេះ មិនមែនជាអនុសញ្ញាអន្តរជាតិដែលមានអានុភាពចាប់បង្ខំ ក៏ប៉ុន្តែវាគ្រាន់តែជាសេចក្តីថ្លែងការណ៍ ដែលមិនមានអានុភាពចាប់បង្ខំ ។

តើមានប្រយោជន៍អ្វីនៃការសំអាងទៅលើសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស ចំពោះការអនុវត្តន៍មាត្រាសិទ្ធិមនុស្សដែលធ្វើដោយចៅក្រមកម្ពុជានោះ?

## ? សំនួរសិក្សាទី ១៨

តើចៅក្រមកម្ពុជាអាចធ្វើអ្វីបានខ្លះ នៅពេលដែលគាត់គិតថា ច្បាប់ដែលកំពុងតែអនុវត្តនៅក្នុងប្រទេសកម្ពុជា មិនស្របនឹងរដ្ឋធម្មនុញ្ញ (=មិនស្របនឹងមាត្រាសិទ្ធិមនុស្សដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា)?

<u>ឧទាហរណ៍:</u>

ករណីដែលមាត្រានៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ បានបំពានលើមាត្រា៣១ III CC ដែលចែងអំពីសិទ្ធិស្មើភាពគ្នារវាងស្ត្រី និងបុរស ។

## ? សំនួរសិក្សាទី ១៩

ការប្រើប្រាស់សិទ្ធិមនុស្ស អាចត្រូវបានដាក់កំហិតដោយច្បាប់មួយ (មាត្រា២៩ II UDHR) ។

តើចៅក្រមកម្ពុជា ត្រូវសំរេចយ៉ាងដូចម្តេច នៅពេលដែលអាជ្ញាធរបានកំណត់ចេញនូវការដាក់កំហិតមួយ លើការប្រើប្រាស់សិទ្ធិមនុស្ស ប៉ុន្តែពុំមានច្បាប់ណាមួយអនុញ្ញាតឱ្យ មានការដាក់កំហិតនេះឡើយ?

ឧទាហរណ៏:

ក្រសួងព័ត៌មាន ហាមមិនឱ្យប៉ុស្តិ៍វិទ្យុធ្វើការផ្សព្វផ្សាយពីកម្មវិធីនៃវិទ្យុបរទេស ប៉ុន្តែច្បាប់ស្តីពីប្រព័ន្ធផ្សព្វផ្សាយ មិនទាន់មាននៅឡើយទេ ទោះបីជា រដ្ឋធម្មនុញ្ញកម្ពុជាទាមទារឱ្យបង្កើតច្បាប់នេះក៏ដោយ (មាត្រា៤១ II CC) ។

## ? សំនួរសិក្សាទី ២០

យោងតាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ការដាក់កំហិតលើសិទ្ធិមនុស្ស អាចកំណត់ឡើង នៅក្នុងករណី "ចាំបាច់" តែប៉ុណ្ណោះ ។ មានន័យថា ការដាក់កំហិតទាំងឡាយ ជាការដាក់កំហិតស្របច្បាប់ នៅពេលដែលគ្មានវិធានការណាដែលស្រាលជាងការដាក់កំហិតនេះទៀតទេ ("**គោលការណ៏នៃភាពសមាមាត្រ**") ។

តើតុលាការកម្ពុជាអាចកំណត់បានដែរឬទេថា សេចក្តីសំរេចរដ្ឋបាលមួយមិនស្របច្បាប់ ដោយសារអាជ្ញាធរ មិនបានជ្រើសរើសវិធានការដែលស្រាលបំផុតដែលអាចធ្វើទៅបាន ចេញពីបណ្តាវិធានការនានាដែលចែងដោយច្បាប់ ?

ឧទាហរណ៏:

អាជ្ញាធរ ហាមឃាត់ទាំងស្រុងចំពោះបាតុកម្មមួយ ដើម្បីរក្សាសណ្តាប់ធ្នាប់ចរាចរនៅលើដងផ្លូវ ទោះបីជា គេអាចពង្វាងផ្លូវចរាចរជាបណ្តោះអាសន្ន ហើយអាចអនុញ្ញាតឱ្យធ្វើបាតុកម្មក្រោមលក្ខខណ្ឌដែលថា បាតុកម្មនោះត្រូវធ្វើនៅក្នុងរយៈពេលមួយ និងនៅលើផ្លូវមួយជាកំណត់ ក៏ដោយ ។

## ? សំនួរសិក្សាទី ២១

វិវាទការងារ:

កម្មករម្នាក់ ត្រូវបានបណ្តេញចេញដោយនិយោជក ពីព្រោះគាត់ត្រូវបានគេចោទថា មកធ្វើការយឺតជាប្រចាំ ហើយបានយកប្រាក់ពីក្រុមហ៊ុនទៀតផង ។

កម្មកររូបនោះ បដិសេធការចោទប្រកាន់នេះ ជួលមេធាវីម្នាក់ និងធ្វើបណ្តឹងទៅតុលាការ ដើម្បីទាមទារឱ្យគេជួលមកបំរើការងារឡើងវិញ ឬសំណងជំងឺចិត្ត ។

ក) និយោជក ក៏ជួលមេធាវីម្នាក់ដែរ ដែលជាអ្នករៀបចំបណ្តឹងតវ៉ាមួយ និងដាក់ពាក្យសុំថតចំលងឯកសារនៃបណ្តឹងទាមទាររបស់កម្មករនិយោជិក នៅពេលជាមួយគ្នានោះផងដែរ ។

ចៅក្រម ពុំផ្តល់ឯកសារថតចំលងនោះដល់មេធាវីរបស់និយោជកឡើយ ដោយនិយាយថា មេធាវីគ្មានសិទ្ធិត្រួតពិនិត្យលើឯកសារ ពីព្រោះនេះគឺជាកិច្ចការផ្ទៃក្នុង ។

តើសំដីរបស់ចៅក្រម ត្រូវ ឬខុស? ចូរកុំគ្រាន់តែឆ្លើយ "ត្រូវ" ឬ "ខុស" ប៉ុន្តែសូមផ្តល់ការពន្យល់អំពីគំនិតរបស់អ្នកផង!

ខ) និយោជិក បង្ហាញពីមិត្តរួមការងារដែលជាអ្នកដែលអាចបញ្ជាក់ថា និយោជិករូបនោះមិនបានមកធ្វើការយឺត និងមិនបានយកលុយពីក្រុមហ៊ុនឡើយ ។

ចៅក្រមកោះហៅសាក្សីមួយចំនួន មកសម្ភាសន៍ពួកគេនៅក្នុងបន្ទប់របស់គាត់ និងសរសេររបាយ-ការណ៍អំពីពាក្យសំដីរបស់សាក្សីទាំងនោះ ។

តើសកម្មភាពរបស់ចៅក្រមធ្វើបែបនេះ ត្រឹមត្រូវដែរឬទេ? ចូរកុំគ្រាន់តែឆ្លើយ "ត្រូវ" ឬ "ខុស" ប៉ុន្តែសូមផ្តល់ការពន្យល់អំពីគំនិតរបស់អ្នកផង!

## ? សំនួរសិក្សាទី ២២

ករណី:

មន្ត្រីជាន់ខ្ពស់ម្នាក់ ត្រូវបានចោទប្រកាន់ពីបទមនុស្សឃាដ ។ សាក្សីរបស់ព្រះរាជអាជ្ញា មិនចង់ប្រាប់ពីអត្តសញ្ញាណរបស់គាត់ទេ ពីព្រោះគាត់ព្រួយបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់គាត់ ។ យ៉ាងណាមិញ ព្រះរាជអាជ្ញា សុំទៅតុលាការសុំឱ្យបង្ហាញចំលើយអនាមិករបស់សាក្សី ។

ឧបមាថាអ្នកជាចៅក្រម ហើយត្រូវតែធ្វើសេចក្តីសំរេចចិត្តលើការពាក្យសុំរបស់ព្រះរាជាអាជ្ញា ។ តើអ្នកធ្វើការសំរេចយ៉ាងដូចម្តេច? ចូរផ្តល់ហេតុផលចំពោះការសំរេចរបស់អ្នក និងបញ្ជាក់ពីមាត្រានានាដែលពាក់ព័ន្ធ ។

## ? សំនួរសិក្សាទី ២៣

ហេតុអ្វី សវនាការត្រូវធ្វើជាសាធារណៈ?
ចូរពន្យល់ពីចំលើយរបស់អ្នក និងបញ្ជាក់ពីមាត្រានានាដែលពាក់ព័ន្ធ ។

## ? សំនួរសិក្សាទី ២៤

តើមានករណីលើកលែងទៅគោលការណ៍នៃសវនាការជាសាធារណៈនេះដែរឬទេ?
បើសិនជាមាន តើមានអ្វីខ្លះ?

## ? សំនួរសិក្សាទី ២៥

បើក "សៀវភៅស្តីពីតុលាការយុត្តិធម៌" តាមរយៈគេហទំព័ររបស់ "អង្គការលើកលែងទោសអន្តរជាតិ" = www.amnesty.org/alibi/intcam/fairtrial/indxftm_b.htm និងមើលជំពូកទី ១៧.១ នៃ "សៀវភៅស្តីពីតុលាការយុត្តិធម៌" ។

តើមាត្រាណាមួយនៃរដ្ឋធម្មនុញ្ញកម្ពុជា ដែលមានលក្ខណៈដែលប្រហាក់ប្រហែលនឹងបណ្តាមាត្រាដែលចែងនៅក្នុងជំពូកទី ១៧.១ នៃ "សៀវភៅស្តីពីតុលាការយុត្តិធម៌"?

## ? សំនួរសិក្សាទី ២៦

តើចៅក្រមត្រូវធ្វើអ្វីខ្លះ ប្រសិនបើ មានតែភស្តុតាងចោទប្រកាន់មួយគត់បង្ហាញជូនចៅក្រមនោះ គឺជាសំដីសារភាពរបស់ជនជាប់ចោទដែលបានមកពីការវាយដំ និងធ្វើទារុណកម្ម?

សូមផ្តល់ហេតុផលនៃចំលើយរបស់អ្នក និងដកស្រង់មាត្រាច្បាប់នានាដែលពាក់ព័ន្ធ!

## ? សំនួរសិក្សាទី ២៧

តើសិទ្ធិនៅក្នុងការទទួលបានសាលក្រមដែលមានបញ្ជាក់ពីមូលហេតុ មានមូលដ្ឋានលើសិទ្ធិសំខាន់ៗអ្វីខ្លះ របស់ចុងចោទ?

ចូរលើកយកផ្នែកដែលពាក់ព័ន្ធ ដែលមានចែងនៅក្នុងមាត្រា ១៤ ICCPR ។

## ? សំនួរសិក្សាទី ២៨

តើហេតុអ្វីបានជា ចុងចោទត្រូវការដឹងពីមូលហេតុនៅក្នុងសាលក្រម?

## ? សំនួរសិក្សាទី ២៩

តើហេតុអ្វីបានជា វាមានសារៈសំខាន់ចំពោះការដែលព្រះរាជអាជ្ញា ជូនដំណឹងដល់ចុងចោទជាមុនមុនពេលសវនាការ អំពីសាក្សីដែលនឹងត្រូវកោះហៅដោយព្រះរាជាអាជ្ញាឱ្យមកចូលរួមសវនាការ?

## ? សំនួរសិក្សាទី ៣០

ចៅក្រមម្នាក់ អាចបញ្ជាឱ្យឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្នបាន ។

តើហេតុផលតែពីរដែលចៅក្រមសំអាងសំរាប់ការឃុំខ្លួននេះគឺអ្វី?

សូមរៀបរាប់ពីហេតុផលទាំងពីរនោះ និងដកស្រង់នូវមាត្រាដែលពាក់ព័ន្ធ!

## ? សំនួរសិក្សាទី ៣១

តើចៅក្រមត្រូវចេញដីកាអ្វី ក្នុងករណីដែលការឃុំខ្លួនបណ្តោះអាសន្នលើសពីរយៈពេល៦ ខែ?

ចូរដកស្រង់នូវមាត្រានានាដែលពាក់ព័ន្ធ!

## ? សំនួរសិក្សាទី ៣២

តើអ្វីទៅជាបញ្ហាចំពោះ ការឃាត់ខ្លួនជនសង្ស័យ ក្នុងរយៈពេល ៤៨ម៉ោង ដោយនគរបាលយុត្តិធមិ ដោយមិនមានការយល់ព្រមពីតុលាការ ដែលមានចែងនៅក្នុង មាត្រា៤៧ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ និង មាត្រា១៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល?

# ការសង្កេតលើតុលាការ

## ក) មុខងារ:

មុខងារសំខាន់បំផុតមួយក្នុងចំណោមមុខងារសំខាន់ៗទាំងអស់នៃសាធារណជន គឺការត្រួតពិនិត្យសកម្ម-ភាពរបស់តុលាការ ។ អ្វីដែលកើតឡើង "ក្នុងនាមប្រជារាស្ត្រខ្មែរ" មិនត្រូវកើតឡើងនៅពីក្រោយទ្វារដែលបិទជិតនោះទេ ប៉ុន្តែត្រូវកើតឡើងនៅក្នុងពន្លឺភ្លឺច្បាស់នៃចំណាប់អារម្មណ៍របស់សារធារណជន ។ មូលហេតុគឺថា ចៅក្រមត្រូវការការត្រួតពិនិត្យ និងគ្រប់គ្រងខ្លះពីសំណាក់សាធារណជន ប្រសិនបើចៅក្រមចង់អនុវត្តមុខងាររបស់ខ្លួនឱ្យបានល្អ និងប្រកបដោយយុត្តិធម៌ ។ ដូច្នេះ យ៉ាងហោចណាស់ចៅក្រម ត្រូវទទួលខុសត្រូវចំពោះមុខមតិសាធារណជនដែលជាគ្រឿងលើកទឹកចិត្តដ៏មុតមាំមួយ ដើម្បីឱ្យចៅក្រមគោរពតាមវិធាននីតិវិធី ប្រព្រឹត្តិទៅលើភាគីទាំងអស់ប្រកបដោយយុត្តិធម៌ និងចៀសវាងការរំលោភច្បាប់ជាចំហ ។

## ខ) សិទ្ធិរបស់សាធារណជន:

សិទ្ធិក្នុងការអង្កេតទៅលើតុលាការ និង ការបំពេញការងាររបស់តុលាការត្រូវបានធានាចំពោះបុគ្គលគ្រប់រូប ដោយ**ការផ្សព្វផ្សាយជាសាធារណៈនូវការកាត់ក្តី និងការប្រកាសសាលក្រម** ( **មាត្រា ១៤ I ២ និង ៣ ICCPR**) ។ មានតែករណីមួយចំនួនតូចតែប៉ុណ្ណោះ ដែលសាធារណជនមិនត្រូវបានអញ្ជើញឱ្យចូលរួមក្នុងការកាត់ក្តី ដើម្បីការពារផលប្រយោជន៍ដ៏ខ្ពង់ខ្ពស់របស់ភាគីនានា ឬសាក្សី[៤៦] ។ ដើម្បីឱ្យសាធារណជន អាចអនុវត្តសិទ្ធិរបស់ខ្លួនប្រកបដោយប្រសិទ្ធិភាព គេចាំបាច់ត្រូវធានានូវលក្ខខណ្ឌជាមូលដ្ឋានមួយចំនួន ដូចតទៅ :

- **ពុំមាននរណាម្នាក់ចាំបាច់នូវការអញ្ជើញ ឬការអនុញ្ញាតពិសេសណាមួយ** ដើម្បីចូលរួមក្នុងការកាត់ក្តីរបស់តុលាការ និងស្តាប់រឿងក្តីរបស់តុលាការឡើយ ។ ជាងនេះទៅទៀត គេមិនចាំបាច់មានមុខងារពិសេសណាមួយ ដូចជា មានមុខងារជានិស្សិតច្បាប់ ឬជាសមាជិកនៃក្រុមស្រាវជ្រាវណាមួយដើម្បីចូលរួមនោះទេ ។ ភាពគ្រាន់តែជាសមាជិកដ៏សាមញ្ញរបស់សាធារណជន គឺគ្រប់គ្រាន់រួចទៅហើយក្នុងការផ្តល់សិទ្ធិដល់មនុស្សគ្រប់រូប ដើម្បីចូលរួមសាលតុលាការ និងការកាត់ក្តី ។ ពុំមាននរណាម្នាក់ដែលចង់ចូលរួមក្នុងការកាត់ក្តីត្រូវតែបង្ហាញអំពីអត្តសញ្ញាណរបស់ខ្លួន ឬ បង្ហាញលិខិតឆ្លងដែនដល់តុលាការ ឬ ក្រឡាបញ្ជីឡើយ **លុះត្រាតែបុគ្គលនោះពាក់ព័ន្ធនឹងរឿងក្តីដោយផ្ទាល់ និង/ឬ គាត់អាចត្រូវបានកោះហៅឱ្យធ្វើជាសាក្សី មកធ្វើកសិណសាក្សីជាផ្លូវការ** ។ ប្រការនេះជាការសំខាន់ណាស់ ពីព្រោះពុំមាននរណាម្នាក់ ត្រូវបានរារាំងមិនឱ្យអនុវត្តនូវសិទ្ធិរបស់ខ្លួនក្នុងការចូលរួមជាសាធារណៈ ដោយសារលក្ខខណ្ឌបែបនេះឡើយ ។
- លើសពីនេះតុលាការនីមួយៗត្រូវធានាថា សាធារណជនមានកន្លែងធំគ្រប់គ្រាន់ដើម្បីចូលរួមក្នុងការកាត់ក្តី ។ ប្រសិនបើគ្មានកន្លែងធំគ្រប់គ្រាន់ ឬ មានកន្លែងតូចចង្អៀត សាធារណជននឹងត្រូវបង្ខំឱ្យស្ថិតនៅក្រៅ

---

[៤៦] សេចក្តីលំអិតបន្ថែមស្តីពីការផ្សព្វផ្សាយជាសាធារណៈនូវការកាត់ក្តីអាចទទួលបានពី "សៀវភៅស្តីពីការកាត់ក្តីដោយយុត្តិធម៌" របស់អង្គការលើកលែងទោសអន្តរជាតិ (មើលលេខយោងទី ៤៤) សេចក្តីណែនាំអំពីការកាត់ក្តីប្រកបដោយយុត្តិធម៌របស់គណៈកម្មាធិការមេធាវីដើម្បីសិទ្ធិមនុស្ស (Lawyers' Human Rights Committee) និងតាមរយៈការស្រាវជ្រាវគេហទំព័រ www.bayefsky.com សំរាប់យុត្តាធិការដែលមានចែងនៅក្នុងមាត្រា ១៤ I ២ និង ៣ ICCPR ។

តុលាការដោយខុសច្បាប់ ។ នៅក្នុងក្តីមួយចំនួនដែលទាក់ទាញចំណាប់អារម្មណ៍សាធារណជនយ៉ាងច្រើន គេរឹតតែចាំបាច់រៀបចំការកាត់ក្តីនៅក្នុងសាលដ៏ធំ ឬនៅទីវាលដែលមានទំហំធំ ដើម្បីឱ្យមនុស្សមួយហ្វូងធំអាចចូលរួមបាន ។

- តុលាការក៏ត្រូវតែធានាថា សាធារណជនត្រូវបាន**ជូនដំណឹងសមស្របជាមុនអំពី ថាតើការកាត់ក្តីណាមួយនឹងត្រូវធ្វើឡើង**នៅពេលណា និងចៅក្រមណាមួយដែលជាអ្នកកាត់ក្តី ។ កិច្ចការនេះអាចធ្វើឡើងតាមរយៈការបិទផ្សាយជាសាធារណៈនូវកាលវិភាគនៅក្នុងច្រកចូលសាល ឬ បិទនៅលើទ្វារនៃសាលតុលាការដែលបញ្ជាក់អំពីអ្វីដែលនឹងកើតមានឡើង នៅពេលណា និងនៅកន្លែងណា ។ យ៉ាងហោចណាស់ តុលាការត្រូវផ្តល់ព័ត៌មានទាំងឡាយអំពីអង្គហេតុទាំងនេះដោយមិនគិតថ្លៃដល់មនុស្ស ដែលចាប់អារម្មណ៍ចង់ចូលរួម ។
- **នីតិវិធីកាត់ក្តីដោយផ្ទាល់មាត់**របស់តុលាការ មានចែងនៅក្នុងក្រមនីតិវិធី ។ ការនេះធានាថា សាធារណជនពិតជាអាចតាមដានរឿងក្តីបាន។ ដូច្នេះ រាល់ព័ត៌មានដែលពាក់ព័ន្ធទាំងអស់ ត្រូវតែផ្លាស់ប្តូរដោយផ្ទាល់មាត់ ដើម្បីឱ្យសាធារណជន អាចតាមដាននីតិវិធីបាន ។ ប្រសិនបើ ព្រះរាជាអាជ្ញា ចៅក្រម និងក្រឡាបញ្ជីគ្រាន់តែខ្សឹប ឬនិយាយតិចៗដែលពុំមានអ្នកចូលរួមណាម្នាក់អាចយល់បាន ឬប្រសិនបើពួកគេគ្រាន់តែផ្លាស់ប្តូរនូវឯកសារជាលាយលក្ខណ៍អក្សរ មានន័យថា ពួកគេកាត់ផ្តាច់សិទ្ធិរបស់សាធារណជនក្នុងការត្រួតពិនិត្យនីតិវិធី ដូច្នេះអ្នកចូលរួមគ្រប់រូបមានសិទ្ធិទាមទារឱ្យចៅក្រម ព្រះរាជអាជ្ញា ក្រឡាបបញ្ជីនិយាយឱ្យបានលឺ ដើម្បីឱ្យខ្លួនអាចស្តាប់ និងយល់បាន ។

## គ) ការត្រួតពិនិត្យឯកសារ

សាធារណជន មានសិទ្ធិតាមដាននីតិវិធីកាត់ក្តីផ្ទាល់មាត់ប៉ុណ្ណោះ ។ សាធារណជន ពុំមានសិទ្ធិពិនិត្យមើលរាល់ឯកសារពាក់ព័ន្ធទាំងអស់បានទេ ។ **ការពិនិត្យមើលឯកសារ និងសំនុំឯកសារ គឺជាបុព្វសិទ្ធិរបស់ភាគីជំលោះ និងមេធាវីរបស់ពួកគេ** ។ ខណៈដែលសាធារណជន ជាពិសេសប្រព័ន្ធផ្សព្វផ្សាយ អាចមានសិទ្ធិទទួលបានអត្ថបទពេញលេញនៃសាលក្រមជាលាយលក្ខណ៍អក្សរ ដែលជាសិទ្ធិក្នុងការបញ្ចេញមតិ ដែលរួមមានសិទ្ធិអាចទទួលបានព័ត៌មានដោយសេរី ។ ប៉ុន្តែបើសិន អ្នកសង្កេតទៅលើតុលាការ ចង់មើលឯកសារផ្សេងៗ ពួកគេត្រូវសួរភាគីជំលោះ និងមេធាវីរបស់ភាគី ថាតើពួកគេ មានបំណងអនុញ្ញាតឱ្យខ្លួនពិនិត្យមើលសំណុំឯកសាររបស់ពួកគេដែរឬទេ ។ ជាធម្មតា ភាគីជំលោះ ត្រូវមានសំណុំឯកសារពេញលេញដែលមិនត្រឹមតែមានឯកសាររបស់ខ្លួនផ្ទាល់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានឯកសារដែលបង្ហាញនៅក្នុងការកាត់ក្តីដោយភាគីម្ខាងទៀត ។ យ៉ាងហោចណាស់ ភាគីជំលោះម្ខាង នឹងមានបំណងចែករំលែកព័ត៌មាន ជាមួយអ្នកសង្កេតការណ៍នៅតុលាការ ។ ជាធម្មតាប្រការនេះ គឺធ្វើឡើងដោយសារភាគីម្ខាងគិតថា ខ្លួនត្រូវបានភាគីម្ខាងទៀតប្រព្រឹត្តិដាក់យ៉ាងអយុត្តិធម៌ ឬដោយតុលាការ ដូច្នេះហើយ ខ្លួនចាំបាច់នូវការគាំទ្រខ្លះពីសាធារណ-ជន ។ ដូច្នេះ វាជាការប្រសើរ**ដែលត្រូវទាក់ទងមេធាវីនៃភាគីជំលោះទាំងពីរ ហើយប្រាប់អំពីគោលបំណងចង់បាន ព័ត៌មាន** ។

## ឃ) ការកត់ត្រាអំពីការជំនុំជំរះ

ជាធម្មតា ច្បាប់នីតិវិធី មិនអនុញ្ញាតឱ្យមានការថតជាខ្សែវីដេអូ ឬខ្សែអាត់ ឬថតរូបនូវសវនាការរបស់តុលាការឡើយ ពីព្រោះ សវនាការទាំងនេះ មិនគួរត្រូវបំប្លែងធ្វើជាឆាកល្ខោនដែលធ្វើឱ្យតួអង្គកាត់ក្ដីបាត់បង់នូវការផ្ដោតអារម្មណ៍ ទៅលើមុខងារផ្នែកច្បាប់របស់ខ្លួនឡើយ ។

ដូច្នេះ អ្នកសង្កេតលើតុលាការ **ត្រូវធ្វើកំណត់ហេតុឱ្យបានច្បាស់លាស់** ដើម្បីប្រមូលទិន្នន័យដែលពាក់ព័ន្ធ ។ ដើម្បីគាំទ្រភារកិច្ចនេះ និងដើម្បីបានរចនាសម្ព័ន្ធច្បាស់លាស់ និងដែលមានរបៀបរៀបរយសមរម្យនៃរបាយការណ៍នៃការសង្កេត យើងសូមផ្ដល់អនុសាសន៍ឱ្យអនុវត្តតាម**បញ្ជីត្រួតពិនិត្យ** ដូចនៅក្នុងឧទាហរណ៍ដែលមាននៅក្នុងទំព័រខាងក្រោមនេះ ។ បញ្ជីត្រួតពិនិត្យនេះ ធ្វើឱ្យប្រាកដថា អ្នកសង្កេតការណ៍ មិនសង្កត់ធ្ងន់លើចំណុចខ្សោយនៃនីតិវិធីរឿងក្ដីនីមួយៗទេ និងមិនភ្លេចចំណុចនៃប្រយោជន៍ ដែលអាចពាក់ព័ន្ធដល់ភាពយុត្តិធម៌នៃការជំនុំជំរះឡើយ ។

លើសពីនេះទៀត វាធានានូវលក្ខណៈវិជ្ជាជីវៈ និងនៅពេលក្រោយមក ធ្វើឱ្យមានភាពងាយស្រួលច្រើនដើម្បី ប្រើប្រាស់របាយការណ៍បែបនេះជាភស្តុតាងប្រឆាំងនឹងចៅក្រមដែលមិនយុត្តិធម៌ទៀតផង ។ ជាពិសេសនៅពេលដែលមានពាក្យប្ដឹងជិតចិត្ត ឬពាក្យបណ្ដឹងទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬប្រធានតុលាការត្រូវពឹងផ្អែកលើរបាយការណ៍បែបនោះ វាជាការសំខាន់ដើម្បីធ្វើឱ្យវាមានភាពច្បាស់លាស់ មានរបៀបរៀបរយល្អ និងមានខ្លឹមសារ ។

# បញ្ជីត្រួតពិនិត្យជាមូលដ្ឋានសម្រាប់របាយការណ៍នៃការអង្កេតលើតុលាការ

| តុលាការ | ករណី | សេចក្ដីសម្រេច | សវនាការ | មតិយោបល់ |
|---|---|---|---|---|
| ឈ្មោះរបស់តុលាការ: ...<br>ឈ្មោះរបស់ក្រុម/អង្គចៅក្រម: ...<br>ឈ្មោះរបស់ចៅក្រម: ...<br>ឈ្មោះរបស់ក្រឡាបញ្ជី: ... | ឈ្មោះរបស់គូភាគី: ...<br>ឈ្មោះរបស់មេធាវីរបស់ភាគី: ...<br>ប្រធានបទនៃពាក្យបណ្ដឹង: ...<br>លេខសំណុំរឿង: ...<br>កាលបរិច្ឆេទសវនាការ: ... | ខ្លឹមសារនៃសេចក្ដីសម្រេច: ...<br>កាលបរិច្ឆេទនៃសេចក្ដីសម្រេច: ... | លំនាំនៃសវនាការ..................<br>សេចក្ដីផ្ដើមនៃរបាយការណ៍........<br>ការលើកបង្ហាញភស្តុតាង........... | សន្និដ្ឋាន<br>ចុងក្រោយ:...<br>ចំណុចសំខាន់នៃម តិ រិះគន់: ...<br>អនុសាសន៍: ... |
| • **សមត្ថកិច្ចរបស់តុលាការ:**<br>ឧទាហរណ៍:<br>តុលាការយោធា មិនអាចជំនុំជំរះ ជនស៊ីវិលបានទេ ។ តុលាការខេត្ត មិនអាចសម្រេចហួសពីយុត្តាធិការកំណត់នៅក្នុងតំបន់របស់ខ្លួនបានទេ។<br>• **សម្ភារៈតុលាការនិងការរៀបចំទូទៅ**<br>តើមានឧបសគ្គសម្រាប់ការចូលរួម ឬ/និងការត្រួតពិនិត្យរបស់សាធារណជន ដែរឬទេ?<br>• **បន្ទប់តុលាការ:**<br>តើមានលំហគ្រប់គ្រាន់សំរាប់សាធារណជន ដែរឬទេ?<br>• **ស្នូរសម្លេងនៅក្នុងបន្ទប់តុលាការ:**<br>តើសម្លេងតួអង្គនីមួយៗក្នុងការជំនុំជំរះ ឮល្មមអ្នកស្ដាប់អាចយល់បាន? តើប្រដាប់បំពងសម្លេងចាំបាច់ ដែរឬទេ?<br>• **ការដាក់កំហិតលើការចូលស្ដាប់**<br>ស្នើសុំឱ្យបង្ហាញអត្តសញ្ញាណ ផ្ដល់ការអនុញ្ញាត ឬការអញ្ជើញ? (ការហាមមិនឱ្យចូលស្ដាប់សំរាប់តែសមាជិកសារព័ត៌មានដែលមានការទទួលស្គាល់ ឬអ្នកដែលមានជំនាញពិសេស) ការឆែក-ឆេររាងកាយ ឬថតពីសកម្មភាពភ្ញៀវ? | • **វត្តមានរបស់គូភាគី :**<br>ក្នុងរឿងក្ដីព្រហ្មទណ្ឌ: ជាទូទៅជនជាប់ចោទ មិនអាចត្រូវបានដាក់ទោសដោយកំបាំងមុខនោះទេ!<br>នៅក្នុងរឿងក្ដីរដ្ឋប្បវេណី: អវត្តមានអាចអត់ឱនបាន ប៉ុន្តែលុះត្រាតែចុងចោទទទួលបានព័ត៌មានសមស្របអំពីកាលបរិច្ឆេទសវនាការ និងផលវិបាកនៃអវត្តមាន។<br>• **ការតំណាងដោយមេធាវី**<br>ភាពចាំបាច់នៃការតំណាងនៅក្នុងរឿងក្ដីព្រហ្មទណ្ឌ ។<br>តើតុលាការបានជូនព័ត៌មានអំពីសិទ្ធិទទួលបានមេធាវីម្នាក់ដល់ជនជាប់ចោទហើយឬនៅ (ជំនួយផ្នែកច្បាប់)?<br>• **ការទាមទាររបស់គូភាគី**<br>នៅក្នុងករណីរដ្ឋប្បវេណី: តើគូភាគីចង់បានអ្វីពីតុលាការ? តើតុលាការដោះស្រាយគ្រប់ពាក្យបណ្ដឹង ឬទេ ឬក៏តុលាការ មិនអើពើចំពោះបណ្ដឹងមួយចំនួនដែលបានបង្ហាញចេញមក ដោយកាត់ផ្ដាច់សិទ្ធិនៃឧបាស្រ័យតុលាការ? | • **ការប្រកាសសាលក្រមជា សាធារណៈ :**<br>តើសាលក្រម ត្រូវបានប្រកាសជាសាធារណៈ ដែរឬទេ?<br>តើអត្ថបទI ទាំងមូលអាចរកបានឬទេ?<br>• **ហេតុផលនៃសាលក្រម:**<br>តើចៅក្រម ផ្ដល់ហេតុផលច្បាស់សម្រាប់សាលក្រម ឬទេ?<br>តើសាលក្រមលាយលក្ខណ៍អក្សរផ្ដល់ហេតុផលដូចម្ដេចខ្លះ?<br>តើហេតុផលដែលផ្ដល់ឱ្យគ្រប់គ្រាន់ដើម្បីបំពេញមុខងាររបស់ខ្លួនបានឬទេ?<br>• **ភាពយុត្តិធម៌នៃសេចក្ដីសំរេច:**<br>- ការដាក់ទោសមិនសមាមាត្រ?<br>- ការដាក់ទោសពីរដង ចំពោះបទល្មើសដដែល?<br>- ការអនុវត្តន៍ច្បាប់ថ្មីបែបប្រតិសកម្ម?<br>• **ធម្មនុញ្ញភាពនៃសេចក្ដីសម្រេច:**<br>ឧទាហរណ៍:<br>– ការដាក់ពន្ធនាគារដោយសារមិនអាចសងបំណុលបាន (អាចធ្វើទៅបាន ស្របតាមច្បាប់ស្ដីពីការដាក់ពន្ធនាគារ បង្ខំរូបកាយ) រំលោភមាត្រា១១ ICCPR<br>- ដីកាលែងលះ: (តែមួយគត់) ប្រពន្ធដែលលែងលះហើយ ត្រូវនៅ "មេម៉ាយ" ចំនួន ៣០០ថ្ងៃ ក្រោយការលែងលះ ។ ករណីនេះរំលោភសមធម៌រវាង បុរស និងស្ត្រី (មាត្រា៣១ II និង ៤៥ II និង III CC)<br>• **ឱកាសដើម្បីធ្វើឧទ្ធរណ៍ជំទាស់នឹងសេចក្ដីសម្រេច:**<br>តើមានព័ត៌មានគ្រប់គ្រាន់ស្ដីពីសិទ្ធិប្ដឹងឧទ្ធរណ៍ ដែរឬទេ? | • **ឱកាសស្មើគ្នាក្នុងការនិយាយស្ដី:**<br>តើមានឱកាសស្មើគ្នាសម្រាប់ភាគីទាំងពីរក្នុងការនិយាយ ឬទេ?<br>• **ពេលវេលាគ្រប់គ្រាន់ ដើម្បីរៀបចំទំរង់នីតិវិធី:**<br>តើតុលាការគ្រប់គ្រងទំរង់នៃការសុំផ្អាក ឬលើកពេលសវនាការដូចម្ដេចខ្លះ?<br>• **ឱកាសរបស់ភាគី ដើម្បីពិនិត្យសាក្សី:**<br>តើតុលាការគ្រប់គ្រងលើសំនួររបស់ភាគីបដិបក្ខចំពោះសាក្សីដូចម្ដេច?<br>• **ការទទួលយកភស្តុតាងបានមកដោយខុសច្បាប់:**<br>តើតុលាការទទួលយកចម្លើយ សារភាពដែលទទួលបានដោយការធ្វើទារុណកម្មឬទេ? តើតុលាការមានប្រតិកម្មយ៉ាងណាលើការចោទប្រកាន់សមហេតុផលរបស់ចុងចោទឬទេ?<br>• **ការយកចិត្តទុកដាក់ពេញលេញរបស់តុលាការចំពោះគូភាគី:**<br>ឧ.តើចៅក្រមសំរានលក់ ជជែកគ្នាជាមួយក្រឡាបញ្ជី លើកទូរស័ព្ទដៃរបស់ពួកគេ ដែលធ្វើឱ្យរំខាននីតិវិធី ដែរឬទេ ។ល។?<br>• **សច្ចធារណ៍នៃនិរទោសៈ**<br>តើតុលាការបង្ហាញការលំអៀងនៅក្នុងសំនួររបស់ខ្លួនឬទេ?<br>តើតុលាការបង្ហាញការលំអៀងក្នុងការបើកសវនាការ ដោយធ្វើជាគុណប្រយោជន៍ ឬគុណវិបត្តិចំពោះ ភាគីមួយនៃភាគីទាំងពីរ ដែរឬទេ? តើចៅក្រមប្រើពាក្យសម្ដីគួរឱ្យស្អប់ខ្ពើម ដែរឬទេ? តើតុលាការ បានរៀបចំអត្ថបទសាលក្រមរួចហើយនៅលើតុរបស់ខ្លួន ដែរឬទេ? | |

# របៀបសរសេរសាលក្រម

## ក) មុខងាររបស់សាលក្រមៈ

ដោយវាជាលទ្ធផលចុងក្រោយនៃនីតិវិធីច្បាប់មួយ សាលក្រមត្រូវផ្តល់នូវដំណោះស្រាយទំនាស់មួយប្រកបដោយតុល្យភាព ។ សាលក្រមមួយដែលល្អវិសេស អាចធ្វើឱ្យភាគីទំនាស់ទាំងសងខាងរស់នៅដោយស្ងប់ចិត្តទាំងអស់គ្នា ។

ដើម្បីសម្រេចគោលបំណងនេះ វាជាការចាំបាច់ដែលចៅក្រមត្រូវចេញ**ដីកាអនុវត្តសាល**ក្រមច្បាស់លាស់មួយ ដោយណែនាំភាគីទាំងពីរឱ្យអនុវត្តតាម ។

លើសពីនេះទៀត សាលក្រមត្រូវតែធ្វើឱ្យគេជឿបានថា តើវាអាចបំពេញមុខងារបង្កើតសន្តិភាពរបស់ខ្លួនបានល្អដែរឬអត់?

ដើម្បីសម្រេចគោលបំណងនេះ ចៅក្រម ចាំបាច់ត្រូវបញ្ចូលការរិះរក**ហេតុផល** ដែលត្រូវពិចារណាឱ្យបានត្រឹមត្រូវទៅក្នុងសាលក្រម ដែលបង្ហាញភាគីទាំងពីរថា ស្ថានភាពរបស់ពួកគេ ត្រូវបានពិចារណាយ៉ាងល្អិតល្អន់ ។ ចៅក្រមត្រូវតែបង្ហាញភាគីទាំងពីរដោយ លំអិតថា **អង្គហេតុ** និងទស្សនៈច្បាប់នានាដែលពួកគេបានទទួលត្រូវបានធ្វើការពិចារណា និងត្រូវបានថ្លឹងថ្លែង យ៉ាងសមស្រប ។

នៅទីបញ្ចប់ សាលក្រមត្រូវតែបង្ហាញឱ្យបានជាក់លាក់ថា តើ**មាត្រាច្បាប់**ណាខ្លះ ត្រូវបានយកមកអនុវត្តចំពោះអង្គហេតុនៃរឿងក្តីនោះ? ប្រការខាងលើនេះមានសារៈសំខាន់ ដើម្បីធ្វើឱ្យគូភាគីបានយល់អំពីច្បាប់ និងរៀនសូត្រពីសាលក្រមនូវការប្រព្រឹត្តឱ្យបានត្រឹមត្រូវទៅតាមច្បាប់ ។ ម្យ៉ាងវិញទៀត វាផ្តល់ឱកាសឱ្យពួកគេដើម្បីពិនិត្យសាលក្រម ក្នុងករណីមានកំហុសផ្សេងៗ ដូចជា ការធ្វេសប្រហែស ឬការយល់ខុសលើអង្គហេតុ ឬកំហុសផ្លូវច្បាប់ផ្សេងៗ ដើម្បីរៀបចំបណ្តឹងឧទ្ធរណ៍មួយដែលអាចមាននៅពេលខាងមុខ ដោយផ្អែកលើកំហុសទាំងនេះ ។

ចៅក្រមដែលសរសេរសាលក្រម ត្រូវតែពិចារណាជានិច្ចថា អត្ថបទដែលខ្លួនចងក្រងនេះត្រូវបានអានដោយ**អ្នកទទួលផ្សេងៗ** ។ ដោយពិចារណាលើប្រការនេះ អត្ថបទនោះត្រូវតែ **សរសេរឱ្យអ្នកទទួលទាំងអស់នេះអាចយល់បាន** ហើយត្រូវតែមានព័ត៌មានដែលចាំបាច់សម្រាប់ពួកគេៈ

- **គូភាគី**ខ្លួនគេដែលមិនមែនជាគណៈវិនិច្ឆ័យ ត្រូវការ**សេចក្តីណែនាំដែលងាយស្រួលអាន**មួយអំពីអ្វីដែលច្បាប់បានចែង និងអំពីអ្វីដែលច្បាប់តម្រូវឱ្យពួកគេធ្វើ ។ គូភាគីក៏ត្រូវការដឹងផងដែរថា តើចៅក្រមបានស្តាប់ដោយយកចិត្តទុកដាក់ ចំពោះតួនាទីរបស់ភាគី ដែរឬទេ?
- **មេធាវី**របស់គូភាគីត្រូវការដឹងឱ្យបានច្បាស់លាស់ថា តើសាលក្រមនោះផ្អែកលើមូលបទច្បាប់ដូចម្តេច? ចំណុចនេះ តម្រូវឱ្យចៅក្រម**ដកស្រង់ឱ្យបានជាក់លាក់នូវមាត្រាច្បាប់** ដែលខ្លួនបានអនុវត្តទៅលើរឿងក្តីនោះ។ ដើម្បីពន្យល់អំពីការត្រិះរិះពិចារណាហេតុផលផ្លូវច្បាប់ ចៅក្រមអាចបញ្ចូល**ពាក្យបច្ចេកទេសច្បាប់**បាន ពីព្រោះ មេធាវីក្នុងនាមជាគណៈវិនិច្ឆ័យដែលបានទទួលការបណ្តុះបណ្តាល អាចយល់បានងាយអំពីហេតុផលទាំងនោះ ។

- នៅក្នុងករណីដែលភាគីធ្វើបណ្តឹងឧទ្ធរណ៍ **តុលាការដែលទទួលពាក្យបណ្តឹងខ្ពស់ជាង** ដែលត្រូវពិនិត្យពិច័យសាលក្រម ត្រូវការដឹងថា តើអង្គហេតុទាំងអស់ត្រូវបានប្រមូលដោយសមស្របហើយឬនៅ និងថាតើភស្តុតាងទាំងអស់ត្រូវបានប្រមូលស្របទៅតាមច្បាប់ដែរឬទេ? លើសពីនេះទៅទៀត សាលក្រមគួរតែបញ្ចូលផងដែរនូវ**សេចក្តីសង្ខេបខ្លីមួយអំពីនីតិវិធី** ឬគួរមានអមមកជាមួយនូវកំណត់ហេតុនៃនីតិវិធីរឿងក្តីភ្ជាប់មកជាមួយផង ។

## ខ) តម្រូវការផ្លូវច្បាប់ជាមូលដ្ឋានពាក់ព័ន្ធនឹងសាលក្រម:

### I) ពេលវេលា ការបោះពុម្ពផ្សាយ ហេតុផល:

មាត្រា១៤ ICCPR ដែលបានកំណត់អំពី គោលការណ៍ជាមូលដ្ឋាននៃការជំនុំជំរះដោយយុត្តិធម៌នោះតម្រូវថា សាលក្រមត្រូវតែ:

- ធ្វើភ្លាមនៅក្នុង**រយៈពេលសមស្រប** បន្ទាប់ពីការជំនុំជំរះបានបញ្ចប់ (មាត្រា ១៤ III គ ICCPR)
- ប្រកាស **ជាសាធារណៈ** (មាត្រា១៤ I ៣ ICCPR)
- បង្ហាញ**ហេតុផល**ជាមូលដ្ឋាននៃសេចក្តីសម្រេច ដើម្បីធានាសិទ្ធិប្តឹងឧទ្ធរណ៍ប្រកបដោយប្រសិទ្ធភាព (មាត្រា១៤ V ICCPR)

### II) តម្រូវការផ្លូវច្បាប់ចំពោះខ្លឹមសារនៃសាលក្រមមួយ:

បញ្ញត្តិច្បាប់មួយចំនួនអធិប្បាយអំពីខ្លឹមសារអប្បបរមាប៉ុន្មានដែលត្រូវបញ្ចូលទៅក្នុងសាលក្រម ប្រសិនបើសាលក្រមនឹងបំពេញមុខងារដូចពោលខាងលើរបស់ខ្លួន :

> មាត្រា ១៨៣ ក្រមនីតិវិធីព្រហ្មទណ្ឌ
>
> សាលក្រមទាំងឡាយត្រូវមានពីរផ្នែក: ផ្នែកខាងលក្ខណៈសម្បត្តិ និងផ្នែកសាលក្រមសុទ្ធសាធ ។
>
> I) ផ្នែកខាងលក្ខណៈសម្បត្តិ ដែលសរសេរនៅក្បាលសាលក្រមត្រូវមាន: គោត្តនាម និងនាម វិជ្ជាជីវៈ ទីលំនៅ និងតួនាទីនៃគូភាគី គោត្តនាម និងនាមរបស់មេធាវី ឬអ្នកការពារបទចោទប្រកាន់ និងសំណូមពររបស់គូក្តីប្រសិនបើមាន សុំសេចក្តីរំលឹកអំពីនីតិវិធី ដែលបានប្រព្រឹត្ត ដោយមានចុះនិទ្ទេសនូវអំពើ និងកិច្ចធំៗ ព្រមទាំងឧប្បត្តិហេតុនានា ដែលតុលាការបានសម្រេចហើយ ។ លក្ខណៈសម្បត្តិនេះ ក៏ត្រូវផងដែរនូវសំនួរ និង ចម្លើយដែលបានធ្វើនៅពេលសវនាការ ។
>
> II) ផ្នែកខាងសាលក្រមសុទ្ធសាធ ត្រូវចែកចេញជាពីរផ្នែកទៅទៀតគឺ: ផ្នែកខាងសំអាងហេតុ និងផ្នែកខាងសេចក្តីសម្រេច ។
>
> ក) សំអាងហេតុ គឺយោបល់ទាំងឡាយដែលកំណត់ចេញសេចក្តីសម្រេចរបស់តុលាការ ។
>
> ខ) សេចក្តីសម្រេច បញ្ជាក់ពីវិធានការទាំងឡាយដែលចាំបាច់ ឬការផ្តន្ទាទោសដែលតុលាការបានសម្រេច ។

មាត្រា ១៨៤ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ:

សាលក្រមណាក៏ដោយ ត្រូវមានសំអាងហេតុគ្រប់ចំណុចសំខាន់ៗ នៃបទចោទប្រកាន់ និង គ្រប់ចំណុចនៃពាក្យសុំរបស់គូភាគី ។ សំអាងហេតុត្រូវតែច្បាស់លាស់ មានន័យថា បញ្ជាក់ឱ្យប្រាកដនូវគំនិតរបស់ចៅក្រម ដោយឥតនាំឱ្យមានការភ័ន្តច្រឡំ ឬសេចក្តីផ្ទុយគ្នានោះឡើយ ។

សេចក្តីសម្រេចដែលជាផ្នែកសំខាន់បំផុតនៃសាលក្រម ក៏ត្រូវតែសរសេរឱ្យច្បាស់លាស់ ដូចសំអាងហេតុដែរ ។ នៅក្នុងសេចក្តីសម្រេច ត្រូវចុះអត្ថបទច្បាប់ទាំងឡាយដែលការសម្រេចត្រូវផ្អែកលើ ។

មាត្រា២៦ I ១ នៃព្រហ្មទណ្ឌអន្តរកាលៈ

គ្រប់សាលក្រមព្រហ្មទណ្ឌត្រូវប្រកាស "ក្នុងនាមប្រជាជាតិកម្ពុជា" សាលក្រមត្រូវចង្អុលអំពើដែលចោទប្រកាន់លើជនជាប់ចោទ ចង្អុលសាក្សី ឬភស្តុតាងដែលចាត់ទុកជាត្រឹមត្រូវ ហើយដែលមានចែងមូលហេតុច្បាស់លាស់ក្នុងការផ្តន្ទាទោស ។

មាត្រា ១៨៩ នៃពង្រាងច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណី និង ប្រការ៣៨ នៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល (សំរាប់វិវាទការងាររួម) ចែងអំពីកំរិតអប្បបរមាសំរាប់ខ្លឹមសារនៃសាលក្រម ឬសេចក្តីបង្គាប់របស់អាជ្ញាកណ្តាលៈ

មាត្រា ១៨៩ ពង្រាងច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីៈ

I) សាលក្រមជាលាយលក្ខណ៍អក្សរត្រូវបញ្ចូលបញ្ហាអង្គច្បាប់ដូចខាងក្រោមៈ
- ក) តុលាការ
- ខ) កាលបរិច្ឆេទដែលសេចក្តីសំអាងជាពាក្យសម្តីត្រូវបានបញ្ចប់
- គ) ឈ្មោះ និងអាស័យដ្ឋានរបស់គូភាគី និងអ្នកតំណាងរបស់គេ
- ឃ) អង្គហេតុ និងបញ្ហាអង្គច្បាប់ក្នុងទំនាស់
- ង) សំអាងហេតុចំពោះសេចក្តីសម្រេច
- ច) អត្ថបទមេ និងសន្និដ្ឋានរបស់សាលក្រម

II) ឯកសាររាយការណ៍អំពីអង្គហេតុ និងបញ្ហាអង្គច្បាប់ក្នុងទំនាស់ត្រូវផ្អែកលើ និងរាប់បញ្ចូលនូវ សេចក្តីសង្ខេបនៃសេចក្តីថ្លែងការណ៍របស់គូភាគី ។

III) សាលក្រមជាលាយលក្ខណ៍អក្សរ ត្រូវចុះហត្ថលេខាដោយចៅក្រម ដែលចេញសាលក្រមនោះ ។

មាត្រា១៨៩ នៃពង្រាងក្រមនីតិវិធីរដ្ឋប្បវេណី (ត):

IV) ប្រសិនបើ កាលៈទេសៈរារាំងចៅក្រមដែលជាសមាជិកនៃក្រុមចៅក្រម មិនឱ្យចុះហត្ថលេខាលើសាលក្រមជាលាយលក្ខណ៍អក្សរនោះបាន ចៅក្រមផ្សេងទៀតត្រូវចុះហត្ថលេខា លើសាលក្រមនោះ ហើយចង្អុលហេតុផលអំពីអវត្តមានរបស់ចៅក្រមម្នាក់ៗ ដែលត្រូវចុះ ហត្ថលេខាលើសាលក្រមនោះ ។

មាត្រា ៣៨ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលៈ

សេចក្តីបង្គាប់របស់អាជ្ញាកណ្តាលត្រូវមានៈ

ក) ឈ្មោះរបស់អាជ្ញាកណ្តាលទាំងបីនាក់
ខ) ឈ្មោះ ទីលំនៅ និងអាសនៈ ឬលំនៅដ្ឋានពិតប្រាកដរបស់ភាគី
គ) សេចក្តីសង្ខេបនៃនីតិវិធី
ឃ) ពិពណ៌នាអំពីការទាមទារ និងពិពណ៌នាអំពីការទាមទារតប ប្រសិនបើមាន
ង) ហេតុផលចំពោះសេចក្តីសម្រេចដែលបានផ្តល់ឱ្យនៅក្នុងសេចក្តីបង្គាប់ ដែលឯកសារសំអាងពាក់ព័ន្ធនឹងបទបញ្ញត្តិដែលមានចែងក្នុងច្បាប់ការងារ អាចយកមកអនុវត្តបាន វាអនុវត្តនូវបទបញ្ជា ឬកិច្ចព្រមព្រៀងការងាររួម ឬកិច្ចសន្យាការងារជាឯកបុគ្គល
ច) សេចក្តីសម្រេចរបស់ក្រុមអាជ្ញាកណ្តាល
ឆ) កាលបរិច្ឆេទចេញសេចក្តីបង្គាប់ ។

## គ) **រចនាសម្ព័ន្ធជាមូលដ្ឋាននៃសាលក្រមជាលាយលក្ខណ៍អក្សរ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលត្រូវបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា ដើម្បីដោះស្រាយជម្លោះការងាររួម បានរៀបចំបែបបទដែលមានប្រយោជន៍បំផុតសំរាប់ការសរសេរសេចក្តីបង្គាប់របស់អាជ្ញាកណ្តាល ។ ដោយសេចក្តីបង្គាប់មួយមានទ្រង់ទ្រាយដូចគ្នានឹងសាលក្រមនោះ បែបបទនៃសេចក្តីបង្គាប់នេះអាចជាឧបករណ៍មួយដ៏មានប្រយោជន៍សំរាប់ជនគ្រប់រូបដែលត្រូវសរសេរសាលក្រម ឬ ដែលចង់ឃើញនូវអ្វីដែលជាខ្លឹមសារអប្បបរមានៃសាលក្រម ។ គេហទំព័ររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តា[៨៧] ផ្តល់នូវអត្ថបទជាច្រើនស្តីពីសេចក្តីបង្គាប់ដែលត្រូវបានពិចារណារកហេតុផល និងដែលសរសេរជាលាយលក្ខណ៍អក្សរជាភាសាខ្មែរ និងភាសាអង់គ្លេស ដែលអាចធ្វើជាគំរូសំរាប់ការសរសេរសាលក្រម ។

[៨៧] www.arbitrationcouncil.org

ផ្នែកសំខាន់ៗរបស់សាលក្រមៈ

- ចំណងជើងនៃរឿងក្ដី
- ដីកាអនុវត្តសាលក្រម
- សេចក្ដីសង្ខេបនៃសេចក្ដីថ្លែងការណ៍របស់គូភាគី
- លទ្ធផលនៃអង្គហេតុ
- ហេតុផលចំពោះសេចក្ដីសម្រេច
- ព័ត៌មានអំពីសិទ្ធិប្ដឹងឧទ្ធរណ៍

## I) ចំណងជើងនៃរឿងក្ដីៈ

ផ្នែកដែលនៅលើក្បាលនៃសាលក្រមនេះមានព័ត៌មានលំអិតអំពីគូភាគី មេធាវីរបស់ពួកគេ និងប្រធានបទនៃការទាមទារ ។ វាមានជាបន្ថែមទៀតនូវលេខសំណុំរឿង ឈ្មោះរបស់ចៅក្រមដែលធ្វើសេចក្ដីសម្រេច ឬឈ្មោះនៃក្រុមតុលាការដែលធ្វើសេចក្ដីសម្រេច និងពាក្យមួយឃ្លាថាៈ "ក្នុងនាមប្រជារាស្ដ្រខ្មែរ - សាលក្រម " ។

<u>ឧទាហរណ៍</u>ៈ

លេខសំណុំរឿង :….

**ក្នុងនាមប្រជារាស្ដ្រខ្មែរ**

**~ សាលក្រម~**

ក្នុងរឿងក្ដីរបស់

ភាគី ក -ដើមបណ្ដឹង-

(ឈ្មោះ អាស័យដ្ឋាន ។ល។)

តំណាងដោយ :

មេធាវី ហ

(ឈ្មោះ អាស័យដ្ឋាន)

ប្ដឹង

ភាគី ខ -ចុងចំលើយ-

(ឈ្មោះ អាស័យដ្ឋាន ។ល។)

តំណាងដោយៈ

មេធាវី ឡ

(ឈ្មោះ អាស័យដ្ឋាន)

**អំពីការទាមទារសំណងការខូចខាត**

ចៅក្រមៈ ...(ឈ្មោះ) នៃតុលាការខេត្ត-ក្រុង ...(ឈ្មោះ) បានសំរេចដូចតទៅៈ

## II) ដីកាអនុវត្តសាលក្រមៈ

ផ្នែកនេះនៃសាលក្រមបង្កើតនូវសេចក្ដីសម្រេចដែលចៅក្រមបានធ្វើ ។ វាប្រាប់គូភាគីឱ្យបានដឹងយ៉ាងច្បាស់លាស់អំពីអ្វីដែលតុលាការបញ្ជាឱ្យពួកគេធ្វើ និងវិធីដែលសេចក្ដីសម្រេចនោះត្រូវអនុវត្ត ។ បញ្ជាដែលតុលាការចេញឱ្យនេះត្រូវតែអាចអនុវត្តបាន នេះមានន័យថា វាត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់ **ដោយកំណត់ឈ្មោះគូភាគីឱ្យច្បាស់លាស់ ករណីយកិច្ចរបស់ពួកគេ ពេលកំណត់ ចំនួនទឹកប្រាក់ អត្រាការប្រាក់ដែលត្រូវសង** ។ល។ វាត្រូវតែច្បាស់លាស់សំរាប់តុលាការអនុវត្តច្បាប់ ឬទីភ្នាក់ងារអនុវត្តច្បាប់ផ្សេងៗ (ដូចជា មន្ត្រីនគរបាលយុត្តិធម៌) ដោយមិនចាំបាច់ពិភាក្សាជាបន្ថែមថា តើគូភាគីមានកាតព្វកិច្ចអ្វីខ្លះទៅតាមសេចក្ដីសំរេចនោះឡើយ? ការបង្កើតដីកាអនុវត្តសាលក្រមណាមួយដែលមិនច្បាស់លាស់ អាចជំរុញឱ្យគូភាគីចាប់ផ្ដើមនូវជម្លោះថ្មីមួយទៀតអំពីការអនុវត្តន៍ និងខ្លឹមសារនៃសេចក្ដីសម្រេច ។

<u>ឧទាហរណ៍</u> :

"ភាគីចុងចោទ ត្រូវបានតុលាការបញ្ជាឱ្យបង់ប្រាក់ចំនួន ១.០០០.០០០រៀល ទៅឱ្យភាគីដើមចោទ រួមទាំងអត្រាការប្រាក់ ១០ភាគរយ បន្ថែមលើចំនួនខាងលើ គិតចាប់តាំងពីថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០០៣ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីបានទទួលសាលក្រមនេះជាផ្លូវការ ។

លើសពីនេះទៀត ភាគីចុងចោទត្រូវ ទទួលបន្ទុកលើថ្លៃចំណាយនៃនីតិវិធីរឿងក្ដី ដោយរាប់បញ្ចូលទាំងថ្លៃចំណាយលើមេធាវីរបស់ដើមចោទផង ។"

អត្ថបទបែបនេះ មិនបន្សល់ទុកនូវមន្ទិលសង្ស័យអំពីអ្វីដែលត្រូវធ្វើពិតប្រាកដឡើយ ចំណែកឧទាហរណ៍នៃបញ្ជាតុលាការដូចខាងក្រោមនេះ អាចមានភាពស្រពិចស្រពិលខ្លាំងពេក និងមិនអាចអនុវត្តបានឡើយៈ

"ភាគី "ក" ត្រូវបង់ការសងជំងឺចិត្តគ្រប់គ្រាន់ដល់ភាគី "ខ" ចំពោះការខូចខាតដែលភាគី "ក"បានបង្កឡើងឱ្យបានឆាប់តាមដែលភាគី "ក" អាចមានប្រាក់សងគ្រប់" ។

ការសរសេរបែបនេះ បានបើកឱកាសឱ្យមានសំនួរជាច្រើនៈ តើការសងជំងឺចិត "គ្រប់គ្រាន់" ប៉ុន្មាន ? តើបញ្ជានេះ គ្របដណ្ដប់លើ "ការខូចខាត " អ្វីខ្លះ? តើភាគី "ក" ត្រូវបង់ប្រាក់នៅពេលណា ?

## III) អង្គហេតុៈ

សាលក្រម គឺជាលទ្ធផលនៃការអនុវត្តន៍ច្បាប់ចំពោះអង្គហេតុ ។ ចៅក្រមប្រមូលអង្គហេតុពីគូភាគីទាំងពីរនៅក្នុងនីតិវិធីរឿងក្ដីដោយយុត្តិធម៌មួយ ។ ដូច្នេះ នៅពេលចាប់ផ្ដើមនៃសាលក្រម ត្រូវតែមាន**សេចក្ដីសង្ខេបនៃរឿងក្ដីនោះដូចដែលគូភាគីបានបង្ហាញ** ។

ប្រសិនបើមានអង្គហេតុដែលមានទំនាស់ ចៅក្រមត្រូវតែលើកយកភស្តុតាងមកបង្ហាញ និងត្រូវកំណត់ថា តើអង្គហេតុមួយណា ដែលខ្លួនយល់ថាអាចបង្ហាញបានដោយភស្តុតាងនេះ និងអង្គហេតុមួយណាដែលមិនអាចបង្ហាញបាន? ផ្នែកនេះនៃសាលក្រមហៅថា **លទ្ធផលនៃអង្គហេតុ** ។ វាក៏រាប់បញ្ចូលផងដែរនូវការជ្រើសរើសយកអង្គហេតុទាំងឡាយ ដែលតុលាការយល់ថាមានការចាំបាច់ ដើម្បីយកធ្វើជាមូលដ្ឋាននៃសេចក្ដីសំរេច ។

ជាចុងក្រោយ ចៅក្រមអនុវត្តនូវអត្ថបទច្បាប់សមស្របមួយជំហានម្តងៗ ទៅលើអង្គហេតុទាំងនេះ ដោយពិនិត្យមើលដោយ ប្រុងប្រយ័ត្នថា តើអង្គហេតុដែលត្រូវបានផ្តល់ឱ្យនោះបំពេញលក្ខខណ្ឌច្បាប់ដែលបង្កើតឡើងដោយច្បាប់នេះដែរឬអត់?

### ១) សេចក្តីសង្ខេបនៃរឿងក្តីដែលលើកបង្ហាញដោយគូភាគីៈ

ចៅក្រម ត្រូវតែចង្អុលបង្ហាញឱ្យបានច្បាស់នៅក្នុងសាលក្រមអំពីអង្គហេតុណាដែលខ្លួនបានយកធ្វើជាមូលដ្ឋាននៃសេចក្តីសម្រេច ពីព្រោះថា **"វាមិនទាន់គ្រប់គ្រាន់ទេដែលយុត្តិធម៌ត្រូវបានផ្តល់ឱ្យនោះ ប៉ុន្តែគេក៏ត្រូវតែមើលឃើញថាយុត្តិធម៌ត្រូវបានផ្តល់ឱ្យផង"** ។ នេះមានន័យថា គូភាគីនៃទំនាស់មួយត្រូវតែមើលឃើញសាលក្រមនោះ ថាជាដំណោះស្រាយដ៏យុត្តិធម៌ និងត្រឹមត្រូវចំពោះទំនាស់របស់ពួកគេ ។ ពួកគេនឹងទទួលយកសាលក្រម ប្រសិនបើ ពួកគេពិតជាអាចមើលឃើញថា ចៅក្រមបានកត់សំគាល់នូវរាល់សំដីរបស់ពួកគេ ដោយយកចិត្តទុកដាក់។

ដូច្នេះ ត្រូវតែមានសេចក្តីសង្ខេបដ៏ខ្លីមួយស្តីពីសំដីរបស់គូភាគីដែលបង្ហាញអំពី **អង្គហេតុ ភស្តុតាង** និង **ទស្សនៈផ្លូវច្បាប់** ដែលផ្តល់ឱ្យដោយគូភាគី ។ ដើម្បីធ្វើឱ្យអត្ថបទនោះមានភាពច្បាស់លាស់ គួរតែមានការបែងចែករវាងអង្គហេតុដែលភាគីទាំងពីរបានព្រមព្រៀងគ្នា និងអ្វីដែលជាបញ្ហាជំលោះ ។ ជាចុងក្រោយ សេចក្តីសង្ខេបនោះ គួរតែបញ្ជាក់ផងដែរ នូវអ្វីដែលជា**ការទាមទារ**ពិតប្រាកដរបស់ភាគីនីមួយៗ ។




ការធ្វើការបែងចែកភាពខុសគ្នាទាំងនេះផ្តល់នូវវចនាសម្ព័ន្ធ និងទិដ្ឋភាពរួមកាន់តែច្បាស់ថែមទៀត ។ វាធ្វើឱ្យមានភាពងាយ យល់ភ្លាមៗថា តើបញ្ហា និងជម្លោះស្ថិតនៅកន្លែងណានៅក្នុងរឿងក្តីជាក់លាក់មួយ?

ឧទាហរណ៍:

**១. អង្គហេតុដែលត្រូវបានព្រមព្រៀងគ្នាដោយភាគីទាំងពីរ**

ដើមចោទ "ក" ជាម្ចាស់កម្មសិទ្ធិផ្ទះលេខ ... នៅក្នុង ... ចុងចោទ "ខ" បានជួលផ្ទះនេះដោយផ្អែកលើកិច្ចសន្យាជួលផ្ទះមួយជាមួយ "ក" ចុះថ្ងៃទី... ខែ... ឆ្នាំ... ផ្ទះនេះត្រូវបានប្រគល់ជូនលោក "ខ" នៅថ្ងៃទី... ខែ... ឆ្នាំ... ភាគីទាំងពីរបានព្រមព្រៀងគ្នាថា ផ្ទះនេះស្ថិតក្នុងស្ថានភាពល្អនៅកាលបរិច្ឆេទនោះ ។ កិច្ចសន្យាជួលផុតកំណត់ នៅថ្ងៃទី... ខែ... ឆ្នាំ... "ខ" បានប្រគល់ផ្ទះនោះទៅឱ្យ "ក" វិញ បន្ទាប់ពីកិច្ចសន្យាជួលនេះបានចប់ ។

**២. គោលជំហររបស់ភាគី "ក"**

ក) ការចោទប្រកាន់**ដោយភាគី "ក"**:

"ក" ចោទថា "ខ" បានប្រគល់ផ្ទះឱ្យខ្លួនវិញក្នុងស្ថានភាពមិនល្អ ពីព្រោះ "ខ" បានបង្កការខូចខាតដោយការធ្វេសប្រហែស ដោយទុកឱ្យអាងទឹកហៀរចោលនៅពេលដែលខ្លួនមិននៅផ្ទះ នៅថ្ងៃ... ខែ... ឆ្នាំ... ។ "ក" និយាយថា ការខូចខាតនេះត្រូវការចំណាយ ៥០០ ដុល្លារ ដើម្បីជួសជុល ។

ខ) **ទស្សនៈផ្លូវច្បាប់របស់ "ក"**:

"ក" គិតថា ខ្លួនមានសិទ្ធិយោងតាមមាត្រា... នៃច្បាប់រដ្ឋប្បវេណី ក្នុងការទទួលសំណងជំងឺចិត្តដែល "ខ" ត្រូវសង ដោយសារការបង្កការខូចខាត ដោយធ្វេសប្រហែសមកលើទ្រព្យសម្បត្តិរបស់ខ្លួន ។

**៣. ការទាមទាររបស់ "ក"**:

ការទាមទាររបស់ "ក":

សាលក្រមតុលាការមួយដែលបញ្ជាឱ្យ "ខ" សងប្រាក់ ៥០០ ដុល្លារដល់ "ក" ក្នុងរយៈពេល ១០ថ្ងៃ ក្រោយពីបានទទួលសាលក្រមនេះ រាប់បញ្ចូលទាំងការប្រាក់ ១០ភាគរយ គិតចាប់តាំងពី ថ្ងៃទី... ហើយបញ្ជាឱ្យ "ខ" ទទួលបន្ទុកលើថ្លៃចំណាយលើនីតិវិធីរឿងក្តីទាំង អស់រួមទាំងថ្លៃចំណាយលើមេធាវីរបស់ "ក" ផង ។

**៤. ការទាមទារតបរបស់ "ខ"**:

ការទាមទាររបស់ "ខ":

ឱ្យតុលាការបដិសេធចោលទាំងស្រុងនូវការទាមទាររបស់ "ក" ហើយបញ្ជាឱ្យ "ក" ទទួលរ៉ាប់រងរាល់ចំណាយទាំងអស់លើនីតិវិធីរឿងក្តី រាប់បញ្ចូលទាំងថ្លៃចំណាយលើមេធាវីរបស់ "ខ" ផង ។

**៥. គោលជំហររបស់ "ខ"**:

ក) ការចោទ**ដោយ "ខ"**:

"ខ" យល់ព្រមថា ផ្ទះនោះមានការខូចខាតមែន ។ ប៉ុន្តែ "ខ" និយាយថា គាត់មិនទទួលខុសត្រូវលើការខូចខាតនោះទេ ពីព្រោះនៅថ្ងៃហេតុការណ៍ខាងលើ គាត់មិនបាននៅផ្ទះ ហើយមិនបានប្រើអាងទឹកនោះឡើយ ប៉ុន្តែមានភ្លៀងធ្លាក់យ៉ាងខ្លាំងបណ្តាលឱ្យទឹកជន់លិចផ្ទះទាំងមូល ។ លើសពីនេះ គាត់បាននិយាយថា ការខូចខាតនៅផ្ទះនោះ អាចជួលជុលបានយ៉ាងងាយដោយត្រូវចំណាយត្រឹមតែ ១៥០ ដុល្លារ ប៉ុណ្ណោះ ។

ខ) **ទស្សនៈផ្លូវច្បាប់របស់ "ខ"**:

"ខ" យល់ថា "ក" គ្មានសិទ្ធិទាមទារប្រាក់ ៥០០ដុល្លារ ពីគាត់ឡើយ ពីព្រោះច្បាប់មិនអនុញ្ញាតឱ្យ "ក" តំរូវឱ្យគាត់ទទួលខុសត្រូវចំពោះការខូចខាតដែលបង្កឡើងដោយកម្លាំងដែលមិនអាចគ្រប់គ្រងបាន ក្នុងករណីនេះដោយសារទឹកភ្លៀងជន់លិចឡើយ ។

**២) ការស្វែងរកអង្គហេតុ:**

ផ្នែកនេះនៃសាលក្រម ត្រូវតែបង្ហាញអំពីអង្គហេតុដែលចៅក្រមយកធ្វើជាមូលដ្ឋាននៃសេចក្ដីសំរេច ។ សាលក្រម ត្រូវតែផ្ដល់នូវហេតុផលដ៏ខ្លីមួយថា តើហេតុអ្វីបានជាអង្គហេតុនៅក្នុងទំនាស់ ត្រូវបានចាត់ទុកថាជាអង្គហេតុដែលចៅក្រម ត្រូវបង្ហាញទៅតាមការថ្លឹងថ្លែងលើភស្ដុតាងដែលពាក់ព័ន្ធ?

ឧទាហរណ៍:

ការខូចខាតចំពោះទឹកនៅក្នុងផ្ទះនោះ ត្រូវបានបង្កឡើងដោយ "ខ" ប៉ុន្ដែការជួសជុលការខូចខាតនេះ មានតម្លៃត្រឹមតែ ១៥០ដុល្លារ ប៉ុណ្ណោះ ។

តុលាការ ប្រមូលបានអង្គហេតុនេះពីការសាកសួរអ្នកជិតខាងរបស់ "ខ" ដែលបានធ្វើជាកសិណសាក្សីថា ក្នុងកំឡុងពេលជួល ពុំមានភ្លៀងធ្លាក់នៅកន្លែងនោះទាល់តែសោះ ។ ពុំមានហេតុផលណាមួយដែលមិនត្រូវជឿអ្នកជិតខាងទាំងនេះទេ ។ ពួកគេ បានធ្វើជាកសិណសាក្សីបង្ហាញអង្គហេតុដូចៗគ្នា ដាច់ដោយឡែកពីគ្នា ហើយមិនបានបង្ហាញនូវសមានចិត្ត ឬអាកប្បកិរិយាជាអវិជ្ជមានចំពោះ "ខ" ឡើយ ។

ម្យ៉ាងវិញទៀត របាយការណ៍សាធារណៈ បានបញ្ជាក់បន្ថែមនូវសក្ដិភាពនេះ ។ លើសពីនេះទៀត តុលាការ បានត្រួតពិនិត្យផ្ទះរបស់ "ក" និងអ្នកជិតខាងរបស់គាត់ ដោយរកឃើញថា ផ្ទះរបស់អ្នកជិតខាង មិនបង្ហាញនូវសញ្ញាណាមួយនៃការខូចខាតដោយសារទឹកភ្លៀងជន់លិចឡើយ ទោះបីជា ផ្ទះទាំងនោះស្ថិតនៅជិតផ្ទះរបស់ "ក" ហើយអាចនឹងទទួលរងការខូចខាតដូចគ្នា ក្នុងករណីមានទឹកជំនន់ ក៏ដោយ ។ ជាចុងក្រោយ ស្នាមទឹក មានសភាពស្អាតល្អដូចជាទឹកម៉ាស៊ីន ហើយមិនកខ្វក់ដូចទឹកកខ្វក់ ដែលហូរចូលមកពីក្រៅជន់លិចផ្ទះនោះឡើយ ។ ដោយផ្ទះនោះ មិនមានការខូចខាតនៅពេលដែលជួលទៅឱ្យ "ខ" ប៉ុន្ដែមានការខូចខាតនៅពេលដែល "ខ" បានចាកចេញនោះ បញ្ហាទាំងអស់នេះសបញ្ជាក់យ៉ាងច្បាស់ថា ការខូចខាតនេះត្រូវបានបង្កឡើងដោយ "ខ" ដែលបានបណ្ដោយឱ្យទឹកអាងហូរហៀរចោល ។

ប៉ុន្ដែការសាកសួរអ្នកជំនាញខាងបំពង់ទឹក និងឯកសារផ្សេងគ្នាពីរទៀតនៃតម្លៃដាក់ស្នើសំរាប់ការជួសជុលដែល "ខ" បានដាក់ជូន បង្ហាញថា វាមានតម្លៃត្រឹមតែ ១៥០ដុល្លារ ប៉ុណ្ណោះ ក្នុងការជួសជុលការខូចខាតនោះ ។

## IV) ហេតុផលចំពោះសេចក្ដីសំរេច:

គ្រប់ភាគី មានសិទ្ធិទទួលសាលក្រមមួយដែលបង្ហាញនូវហេតុផល ។ សាលក្រមមួយដែលគ្មានហេតុផលនឹងធ្វើឱ្យមានការលំបាកក្នុងការរៀបចំបណ្ដឹងឧទ្ធរណ៍ ដែលមានមូលដ្ឋានត្រឹមត្រូវប្រឆាំងនឹងសាលក្រមនោះ ។ ដូច្នេះ សិទ្ធិប្ដឹងឧទ្ធរណ៍ (មាត្រា ១៤ V ICCPR) រាប់បញ្ចូលទាំងសិទ្ធិដើម្បីដឹងអំពីហេតុផលនៃសាលក្រមផង ។ ករណីយកិច្ចដើម្បីផ្ដល់ហេតុផលចំពោះសាលក្រម ក៏ធ្វើឱ្យមានការពិបាកដល់ចៅក្រមក្នុងការលាក់កំបាំងនូវទឹកចិត្តពិតរបស់ខ្លួនសំរាប់ការធ្វើសាលក្រម ដែលមិនស្ថិតក្រោមឥទ្ធិពលនៃអង្គច្បាប់ និងអង្គហេតុ ប៉ុន្ដែច្រើនតែស្ថិតក្រោមឥទ្ធិពលសំណូករបស់ភាគីម្ខាងដែលសូកប៉ាន់ចៅក្រម ឬដោយសារ តែចៅក្រមមិនមានចំណេះដឹងផ្នែកច្បាប់គ្រប់គ្រាន់ ។

ការផ្ដល់ហេតុផលនៃសាលក្រមមួយ ត្រូវតែធ្វើឱ្យគូភាគីជឿជាក់ថា ស្ថានភាពរបស់ពួកគេត្រូវបានពិចារណាយ៉ាងពេញលេញ ។ វាត្រូវតែបង្ហាញនូវមូលហេតុដែលអង្គហេតុមួយចំនួនដែលគូភាគីផ្ដល់ឱ្យត្រូវបានចាត់ទុកថាមានសារៈសំខាន់ និងមូលហេតុមួយចំនួនទៀត ដែលមិនត្រូវបានចាត់ទុកថាមានសារៈសំខាន់ ។ លើសពីនេះទៀត ហេតុផលនៃសាលក្រមត្រូវតែបង្ហាញនូវការអនុវត្តន៍បញ្ញត្តិច្បាប់ ពាក់ព័ន្ធមួយជំហានម្ដងៗ មួយមាត្រាម្ដងៗ និងមួយពាក្យម្ដងៗ ។

**កំណត់សំគាល់: វាមិនមែនជាការផ្តល់ហេតុផលដែលគ្រប់គ្រាន់ឡើយ ដោយគ្រាន់តែប្រើឃ្លាថា "ដោយបានឃើញអង្គហេតុ និងអង្គច្បាប់ តុលាការសំរេច..." ។**

ដូច្នេះ ហេតុផលនៃសាលក្រមមួយត្រូវតែពន្យល់ឱ្យបានពិស្តារ ហើយត្រូវតែអាចធ្វើឱ្យអ្នកអានដទៃទៀតអនុវត្តតាមគំនិតនីមួយៗនៃការសន្និដ្ឋានរបស់ចៅក្រម :

ឧទាហរណ៍:

- " ចុងចោទត្រូវតែសងថ្លៃខូចខាតដល់ដើមចោទ ។ យោងតាមមាត្រា... នៃច្បាប់រដ្ឋប្បវេណី ជនណាដែលរំលោភដោយក្តីធ្វេសប្រហែស លើអចលនទ្រព្យរបស់អ្នកដទៃដោយខុសច្បាប់ ហើយបណ្តាលឱ្យមានការខូចខាត ត្រូវបង់ប្រាក់សងជំងឺចិត្តចំពោះការខូចខាតនេះ ។

  នៅក្នុងករណីដែលបានលើកឡើងខាងលើ ចុងចោទ ខ បានជួលផ្ទះដែលស្ថិតក្នុងស្ថានភាពល្អរបស់ ក ប៉ុន្តែពេលប្រគល់ផ្ទះមកឱ្យ ក វិញ ស្រាប់តែមានការខូចខាតដែលបណ្តាលមកពីទឹកហៀរ ។ ការខូចខាតនេះត្រូវបានបង្ក ឡើងដោយ ខ ដែលមានការធ្វេសប្រហែសទុកឱ្យទឹកហូរហៀរចេញពីអាងទឹក ។ ការខូចខាតដែលបណ្តាលមកពីទឹកហៀរ មិនមែនបណ្តាលមកពីភ្លៀងខ្លាំង ឬមកពីទឹកជោរជន់នោះទេ តែវាបណ្តាលមកពីទង្វើរបស់ ខ ដែលត្រូវប្រើប្រាស់ទ្រព្យសម្បត្តិរបស់ ក ឱ្យបានសមស្រប ។ ដូច្នេះ ដោយសារទង្វើធ្វេសប្រហែសរបស់ ខ ផ្ទះរបស់ ក ត្រូវធ្វើការជួសជុលដោយចំណាយទឹកប្រាក់ចំនួន ១៥០ដុល្លារ ។

- "ចុងចោទត្រូវតែសងថ្លៃខូចខាតដល់ដើមចោទ ។ យោងតាមមាត្រា... នៃច្បាប់រដ្ឋប្បវេណី ជនណាដែលរំលោភដោយក្តីធ្វេសប្រហែស លើអចលនទ្រព្យរបស់អ្នកដទៃដោយខុសច្បាប់ ហើយបណ្តាលឱ្យមានការខូចខាត ត្រូវបង់ប្រាក់សងជំងឺចិត្តចំពោះការខូចខាតនេះ ។

  នៅក្នុងករណីជាក់លាក់មួយ ចុងចោទបានបើករថយន្តរបស់ខ្លួនលឿនពេក ។ គាត់បានរំលោភលើការកំណត់ល្បឿនដែលកំណត់ដោយមាត្រា... នៃច្បាប់ចរាចរណ៍ ។ ដោយបើកលឿនដូច្នេះ គាត់មិនអាចបញ្ឈប់រថយន្តរបស់គាត់បានទាន់ពេល ហើយក៏បានបុកដើមចោទដោយអចេតនា នៅពេលដែលដើមចោទកំពុងឆ្លងថ្នល់ ។ ករណីនេះបានកើតឡើងដោយខុសច្បាប់ ដោយហេតុថា ពុំមានហេតុផលណាមួយនៃហេតុផលទាំងឡាយ ដែលមានចែងនៅក្នុងមាត្រា... នៃក្រមរដ្ឋប្បវេណី ដែលអាចបង្ហាញថា អាកប្បកិរិយារបស់ចុងចោទត្រឹមត្រូវឡើយ ។ ជាលទ្ធផលនៃឧបទ្ទវហេតុនេះ ដើមចោទត្រូវទទួល ការព្យាបាលចំនួន ពីរថ្ងៃ នៅឯមន្ទីរពេទ្យ និងពីរថ្ងៃទៀតនៅគេហដ្ឋាន ដើម្បីបានជាសះស្បើយ ។ ដូច្នេះ ចុងចោទ បង្កការខូចខាតផ្នែកហិរញ្ញវត្ថុដោយសេចក្តីធ្វេសប្រហែស ដែលកើនដល់ចំនួនសរុបមានតម្លៃស្មើនឹងថ្ងៃធ្វើការចំនួន បួនថ្ងៃ បូកនឹងថ្លៃចំណាយលើការព្យាបាលចាំបាច់ផ្សេងៗទៀត ។ យោងតាមមាត្រា... ក្រមរដ្ឋប្បវេណី ការខូចខាតទាំងឡាយដែលត្រូវសងដោយអ្នកប្រព្រឹត្ត មិនត្រឹមតែរាប់បញ្ចូលថ្លៃចំណាយលើការព្យាបាលសុខភាពផ្លូវកាយប៉ុណ្ណោះទេ ក៏ប៉ុន្តែ ថែមទាំងការខាតបង់ផ្នែកហិរញ្ញវត្ថុដែលបង្កដោយផ្ទាល់ដោយទង្វើបំផ្លិចបំផ្លាញទៀតផង ។"

## V) ព័ត៌មានអំពីសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍:

ដោយសិទ្ធិប្តឹងឧទ្ធរណ៍អាចនឹងមិនមានតម្លៃ ប្រសិនបើគូភាគីជំលោះមិនដឹងអំពីសិទ្ធិនេះនោះ សាលក្រមគួរតែបញ្ចូលផងដែរ នូវព័ត៌មានសំរាប់ហេតុផលយុត្តិធម៌អំពីពេលវេលា មធ្យោបាយ និងទីកន្លែង ដែលគូភាគី

អាចដាក់ពាក្យប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមនេះ ។ យ៉ាងហោចណាស់ គូភាគីដែលមិនត្រូវបានតំណាងតាមផ្លូវច្បាប់ដោយមេធាវីណាម្នាក់នោះត្រូវការដឹងអំពីសិទ្ធិប្តឹងឧទ្ធរណ៍របស់ខ្លួន ។ ព័ត៌មាននេះ ត្រូវតែនិយាយឱ្យច្បាស់លាស់អំពីទីកន្លែងដែលពួកគេត្រូវដាក់បណ្តឹងឧទ្ធរណ៍ អំពីគតិយុត្តិណាខ្លះដែលគេត្រូវគោរព និងពេលវេលាកំណត់បែបណាដែលគេត្រូវរក្សា ។

ដូច្នេះ យើងខ្ញុំសូមសំណូមពរឱ្យភ្ជាប់មកជាមួយនូវព័ត៌មានដ៏ខ្លីដូចខាងក្រោមនេះនៅខាងចុងសាលក្រមនីមួយៗ :

<u>ឧទាហរណ៍</u> :

"ភាគីទាំងពីរ មានសិទ្ធិដាក់ពាក្យប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមនេះក្នុងរយៈពេល ១៤ថ្ងៃ បន្ទាប់ពីពួកគេ បានទទួលអត្ថបទសាលក្រមជាលាយលក្ខណ៍អក្សរនេះដោយមានការបញ្ជាក់ជាផ្លូវការ ។ ការទាមទារប្តឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយអាចផ្ញើទៅតុលាការដែលចេញសាលក្រមក៏បាន ឬផ្ញើទៅសាលាឧទ្ធរណ៍ដោយផ្ទាល់ក៏បាន ។ បណ្តឹងឧទ្ធរណ៍ត្រូវរៀបរាប់ហេតុផលនៃការជំទាស់ចំពោះសាលក្រមនោះ" ។

## ? សំនួរសិក្សាទី ៣៣

ករណីៈ

ភាគី ក ទាមទារប្រាក់ចំនួន ១០០ ដុល្លារអាមេរិក ពីភាគី ខ នៅចំពោះមុខតុលាការ ។ ក និយាយថាគាត់បានផ្តល់កំចីនៃចំនួនលុយនេះឱ្យទៅ ខ ។

ខ បដិសេធការទាមទារនេះ និងនិយាយថា លុយនេះមិនដែលត្រូវបានឱ្យមកគាត់ទេ ។

ក ធ្វើឯកសារមួយស្តីពីកំចីដែល ខ បានចុះហត្ថលេខា ឱ្យទៅតុលាការ ។ វាមិនច្បាស់ទេថាតើឯកសារនេះជាឯកសារពិតប្រាកដ ឬក្លែងក្លាយ? ដូច្នេះ ចៅក្រមហៅសាក្សី គ មកដើម្បីសាកសួរព័ត៌មានលើស្ថានភាពកំចីបន្ថែមទៀត ។ ចៅក្រម បដិសេធការទាមទាររបស់ ក ។

ចូរបង្កើតនូវមូលហេតុនៃសាលក្រមរបស់ចៅក្រមដោយសង្ខេប!

## ? សំនួរសិក្សាទី ៣៤

សាលក្រមដែលយុត្តិធម៌មួយ ត្រូវតែផ្តល់នូវហេតុផល ។

តើហេតុផលអ្វីខ្លះដែលត្រូវលើកឡើងដើម្បីផ្តល់នូវការពន្យល់គ្រប់ជ្រុងជ្រោយនៅក្នុងសាលក្រម?

# សំនួរប្រលងបញ្ចប់វគ្គ

## ? សំនួរសិក្ខាទី ១

តើប្រជាពលរដ្ឋកម្ពុជា មានសិទ្ធិទទួលបាននូវការត្រួតពិនិត្យដោយតុលាការ លើសេចក្តីសំរេចរដ្ឋបាល ដែរឬទេ?

ចូរដកស្រង់នូវបញ្ញត្តិច្បាប់ជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធ ។

## ? សំនួរសិក្ខាទី ២

ក្នុងការជំនុំជំរះរឿងក្តីមួយ តើការដែលមានអង្គជំនុំជំរះដែលមានចៅក្រម ៣រូប មានអត្ថប្រយោជន៏អ្វីជាជាងអង្គជំនុំជំរះដែលមានចៅក្រមតែ ១រូប?

## ? សំនួរសិក្ខាទី ៣

តើហេតុអ្វីបានជា ដំណើរការនីតិវិធីទាំងអស់ដែលត្រូវកត់ត្រាចូលក្នុងកំណត់ហេតុពិធីសារ ហើយនិងឯកសារទាំងអស់ដែលត្រូវរក្សាទុកក្នុងសុំណុំរឿងឱ្យបានត្រឹមត្រូវនោះ មានសារៈសំខាន់ម្លេះ?

## ? សំនួរសិក្ខាទី ៤

ការអនុវត្តន៏ការងាររបស់ចៅក្រម ១រូប ត្រូវបានត្រួតពិនិត្យដោយតួអង្គជាច្រើន ។

រៀបរាប់ឈ្មោះតួអង្គទាំងនោះយ៉ាងហោចណាស់ឱ្យបាន ៥ និងពិពណ៌នាអំពីរបៀបដែលពួកគេធ្វើការត្រួតពិនិត្យទៅលើចៅក្រម ។

## ? សំនួរសិក្ខាទី ៥

តើហេតុអ្វីសាលក្រមត្រូវតែផ្តល់ហេតុផល?

## ? សំនួរសិក្ខាទី ៦

ល្បឿនស្មើគ្នានៅក្នុងការកាត់ក្តីមួយ មានន័យថា ការកាត់ក្តីនោះ មិនត្រូវប្រព្រឹត្តទៅ យឺតពេក ហើយក៏កុំ លឿនពេកដែរ ។

រៀបរាប់:

ក) បទបញ្ញត្តិមួយ ដែលធានាថា ដំណើរការនីតិវិធីមួយលឿន និង

ខ) បទបញ្ញត្តិមួយ ដែលធានាថា ដំណើរការនីតិវិធីមួយមិនលឿនពេក

## ? សំនួរសិក្សាទី ៧

នៅក្នុងដំណើរការរឿងក្ដីព្រហ្មទណ្ឌ ជនជាប់ចោទនិយាយថា គាត់បានផ្ដល់ចំលើយសារភាពរបស់គាត់ក៏ព្រោះតែ គាត់ត្រូវធ្វើទារុណកម្មដោយប៉ូលិស ។

តើមេធាវីការពារក្ដីអាចធ្វើអ្វីបានខ្លះ? រៀបរាប់នូវមធ្យោបាយនានាទាំងអស់ដែលអាចធ្វើទៅបាន!

## ? សំនួរសិក្សាទី ៨

ចៅក្រម បានសាកសួរសាក្សីម្នាក់នៅក្នុងបន្ទប់របស់គាត់ ។ ជនជាប់ចោទ និងមេធាវីការពារក្ដី មិនត្រូវបានអនុញ្ញាតឱ្យចូលរួមស្ដាប់ការសួរដេញដោលនោះទេ ។

តើចៅក្រមរូបនេះ បានបំពានទៅលើសិទ្ធិណាមួយរបស់ជនជាប់ចោទ?

ចូរដកស្រង់នូវបទបញ្ញត្តិនានាដែលពាក់ព័ន្ធ!

## ? សំនួរសិក្សាទី ៩

ដើម្បីឱ្យកាន់តែមានឯករាជភាព តើគេគួរកែប្រែ សមាសភាពនៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមយ៉ាងណាឱ្យកាន់តែប្រសើរ? ផ្ដល់ហេតុផលចំពោះសំណើរបស់អ្នក ។

## ? សំនួរសិក្សាទី ១០

តើ "គោលការណ៍នៃការត្រួតពិនិត្យ និងធ្វើឱ្យមានតុល្យភាព" មានន័យយ៉ាងដូចម្ដេច?

តើហេតុអ្វីបានជា គោលការណ៍នេះត្រូវបានគេបង្កើតឡើង?

## ? សំនួរសិក្សាទី ១១

តើអំណាចនីតិបញ្ញត្តិ និងអំណាចតុលាការ ធ្វើការត្រួតពិនិត្យគ្នាទៅវិញទៅមក យ៉ាងដូចម្ដេចខ្លះ?

## ? សំនួរសិក្សាទី ១២

តើអ្វីខ្លះទៅជាមុខងារសំខាន់ៗរបស់គណៈមេធាវី?

# ដំណោះស្រាយ

## សំនួរសិក្សាទី ១

*ចូរមើលក្រាហ្វិកស្តីពីទំនាក់ទំនងរវាងតុលាការ និងអំណាចផ្សេងៗទៀត (មើលទំព័រទី ៥) ។*

*តាមក្រាហ្វិកនេះ អំណាចនីតិប្រតិបត្តិ មានឥទ្ធិពលលើការតែងតាំងចៅក្រមដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។*

*ក) តើករណីនេះស្របនឹងគោលការណ៍នៃការបែងចែកអំណាចដែរឬទេ?*

ទេ, វាមិនសមស្របទេ ពីព្រោះ តុលាការត្រូវតែឯករាជ្យ (មាត្រា១២៨ I CC) ។ នេះមានន័យថា តុលាការ មិនត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់អង្គនីតិប្រតិបត្តិឡើយ ។ ម្យ៉ាងវិញទៀត ឥទ្ធិពលរបស់ក្រសួងយុត្តិធម៌ទៅលើឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មិនខ្លាំងពេកទេ ពីព្រោះវាមានសំលេងឆ្នោតតែមួយប៉ុណ្ណោះ ក្នុងចំណោមប្រាំបួនសម្លេង។ ដូច្នេះ យោងតាម "គោលការណ៍នៃការត្រួតពិនិត្យ និងធ្វើឱ្យមានតុល្យភាព" ឥទ្ធិពលដ៏តិចតួចបែបនេះ អាចអត់ឱនឱ្យបាន ។

*ខ) តើឥទ្ធិពលនៃអង្គនីតិប្រតិបត្តិដែលបានបញ្ជាក់ខាងលើ មានគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះ?*

តាមពិត មានគុណវិបត្តិអាក្រក់តែមួយប៉ុណ្ណោះ ពីព្រោះ អង្គនីតិប្រតិបត្តិធ្វើការគ្រប់គ្រងទៅលើតុលាការ ហើយវាធ្វើឱ្យប៉ះពាល់ដល់ឯករាជភាពរបស់តុលាការ ដោយសារតែអង្គនីតិប្រតិបត្តិអាចមានលទ្ធភាពសម្រេចចិត្ត ក្នុងចំណោមកិច្ចការផ្សេងទៀត លើការតែងតាំង ការតំឡើងឋានៈ និងការដាក់ទណ្ឌកម្ម ។

គុណសម្បត្តិដ៏តិចតួចបំផុតដែលគេអាចមើលឃើញ គឺថា ក្រសួងយុត្តិធម៌មានសិទ្ធិផ្តួចផ្តើមគំនិត និងបញ្ចេញមតិលើការតាក់តែងច្បាប់ ដែលពាក់ព័ន្ធនឹងប្រព័ន្ធតុលាការ ។ ដូច្នេះ ការចូលរួមជាមួយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចផ្តល់នូវចក្ខុវិស័យដ៏ជិតដិតដល់ក្រសួងយុត្តិធម៌ទៅលើប្រព័ន្ធតុលាការ និងបញ្ហានានារបស់ប្រព័ន្ធនេះ ហើយក្រសួងក្នុងនាមជាស្ថាប័នជំនាញ អាចដាក់ឱ្យប្រើប្រាស់ជំនាញ បច្ចេកទេសមួយចំនួន ។

## សំនួរសិក្សាទី ២

*ហេតុអ្វីបានជាសាលក្រមកម្ពុជាទាំងអស់ មានឃ្លាផ្តើមថា "តាងនាមប្រជារាស្ត្រខ្មែរ"?*

*ចូរផ្តល់នូវហេតុផលចំពោះចំលើយរបស់អ្នក និងដកស្រង់នូវមាត្រានានាដែលពាក់ព័ន្ធ ពីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។*

ចំណងជើងនេះត្រូវបានប្រើ ពីព្រោះអំណាចទាំងអស់នៅក្នុងរដ្ឋ - រាប់បញ្ចូលទាំងអំណាចតុលាការ - បានមកពីប្រជាជនកម្ពុជា (មាត្រា៥១ III ១, ២ CC) ។ ដូច្នេះ មាត្រា១២៩ I CC កំណត់ថា រាល់ការជំនុំជំរះរបស់តុលាការទាំងអស់ ត្រូវធ្វើឡើងក្នុងនាមប្រជារាស្ត្រខ្មែរ ។

## សំនួរសិក្សាទី ៣

*តើចាំបាច់បង្កើតឱ្យមានតុលាការរដ្ឋបាលនៅប្រទេសកម្ពុជាដែរឬទេ?*

*ចូរផ្តល់ហេតុផលចំពោះចំលើយរបស់អ្នក និងដកស្រង់នូវមាត្រាដែលពាក់ព័ន្ធ ពីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។*

រដ្ឋធម្មនុញ្ញកម្ពុជាចែងថា សកម្មភាពរដ្ឋបាលទាំងអស់ ត្រូវត្រួតពិនិត្យដោយតុលាការ (មាត្រា៣៩ និង ១២៨ III CC) ហើយច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពនៃសាលាជំរះក្តី មិនបដិសេធឱ្យបានច្បាស់លាស់ ចំពោះការដាក់បញ្ចូលនូវករណីរដ្ឋបាល ទៅក្នុងសមត្ថកិច្ចរបស់តុលាការទូទៅ (តុលាការខេត្ត-ក្រុង) ឡើយ (មាត្រា៦ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពនៃសាលាជំរះក្តី) ។

ដូច្នេះ តុលាការកម្ពុជាទូទៅ មានសមត្ថកិច្ចរួចជាស្រេចក្នុងការដោះស្រាយពាក្យបណ្តឹងអំពីការរំលោភសិទ្ធិដោយរដ្ឋបាល ។ ដូច្នេះ ការបង្កើតតុលាការរដ្ឋបាលមួយ មិនពិតជាចាំបាច់ ដើម្បីផ្តល់នូវការគ្រប់គ្រងលើផ្នែករដ្ឋបាល និងដើម្បីបំពេញតំរូវការរដ្ឋធម្មនុញ្ញឡើយ ។ ប៉ុន្តែ យើងអាចផ្តល់អនុសាសន៍ថា គេគួរតែមានតុលាការជំនាញសំរាប់កិច្ចការរដ្ឋបាល ព្រោះថា ជាទូទៅ តុលាការមិនប្រសប់លើគ្រប់ជំនាញនោះទេ ។ ម្យ៉ាងទៀត តុលាការមានបន្ទុកការងារដ៏ធ្ងន់រួចទៅហើយ ជាមួយករណីព្រហ្មទណ្ឌ និងរដ្ឋប្បវេណី ដែលតុលាការមានបទពិសោធន៍ ក្នុងការដោះស្រាយ ។

## សំនួរសិក្សាទី ៤

*ចូរមើលមាត្រា៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (ច្បាប់ SCM) ហើយធ្វើការប្រៀបធៀបជាមួយមាត្រា៧ថ្មី នៃពង្រាងច្បាប់ស្តីពីវិសោធនកម្មលើច្បាប់ SCM (មើលឧបសម្ព័ន្ធ) ។*

*តើអ្នកគិតថា អ្វីជាគោលបំណងនៃវិសោធនកម្មដែលស្នើមកនោះ?*

មាត្រា៧ថ្មី នៃពង្រាងវិសោធនកម្មច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានគោលបំណង **ធ្វើឱ្យឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានឯករាជភាពពីក្រសួងយុត្តិធម៌** ។ យោងតាមពង្រាងវិសោធនកម្មនេះ ក្រសួង មិនអាចសំរេចលើការកោះប្រជុំឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងលើប្រធានបទដែលត្រូវពិភាក្សាបានតទៅទៀតឡើយ ។ ផ្ទុយទៅវិញ បច្ចុប្បន្ននេះ វាអាស្រ័យលើឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាអ្នកកោះប្រជុំ និងសំរេចលើប្រធានបទដែលត្រូវពិភាក្សាទៅតាមសំណើរបស់សមាជិក បីនាក់យ៉ាងតិច ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក៏ត្រូវបានពង្រឹងផងដែរ ដោយការបង្កើតអគ្គលេខាធិការផ្ទាល់ខ្លួនមួយ ដែលត្រូវបានបោះឆ្នោតជ្រើសរើសក្នុងចំណោមចៅក្រមដែលមិនមែនជាសមាជិករបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ ដូច្នេះ ជាមួយការងាររដ្ឋបាល ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មិនពឹងផ្អែកលើការគាំទ្ររបស់ក្រសួងយុត្តិធម៌ទៀតទេ ។

## សំនួរសិក្សាទី ៥

*ចូរចាត់ប្រភេទឱ្យមុខងារនៃបុគ្គលដែលមានរៀបរាប់ខាងក្រោម ចូលក្នុង:*

*<u>អំណាចនីតិបញ្ញត្តិ:</u> តើគាត់កំពុង ធ្វើការជំរុញ និងអនុវត្តច្បាប់?*

*<u>អំណាចតុលាការ:</u> តើគាត់កំពុងតែធ្វើការត្រួតពិនិត្យការអនុវត្តន៍ច្បាប់លើរឿងក្តីណាមួយ ដែរឬទេ?*

*<u>អំណាចនីតិប្រតិបត្តិ:</u> តើគាត់កំពុងធ្វើការអនុម័តវិធានច្បាប់ដែលមានលក្ខណៈចាប់បង្ខំ ដែរឬទេ?*

១- ជំនួយការក្រឡាបញ្ជី = មុខងារ**ផ្នែកនីតិប្រតិបត្តិ**ដែលជួយគាំទ្រតុលាការ
២- អគ្គលេខាធិការសភាជាតិ = មុខងារ**ផ្នែកនីតិប្រតិបត្តិ**ដែលជួយគាំទ្រផ្នែកនីតិបញ្ញត្តិ
៣- ព្រះរាជអាជ្ញា = មុខងារ**ផ្នែកតុលាការ**
៤- ប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់ = ទាំង មុខងារ**ផ្នែកនីតិប្រតិបត្តិ** និង**នីតិបញ្ញត្តិ**
៥- ប្រធានគណៈមេធាវី = មុខងារឯករាជ្យដែលជួយគាំទ្រ**ផ្នែកតុលាការ**
៦- នាយក "វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ" = មុខងារ**ឯកជន** អង្គការក្រៅរដ្ឋាភិបាល
៧- ប្រធានពន្ធនាគារ = មុខងារ**ផ្នែកនីតិបញ្ញត្តិ**
៨- ចៅក្រមស៊ើបអង្កេត = មុខងារ**ផ្នែកតុលាការ**
៩- ប្រធានក្រុមប្រឹក្សាអ្នកច្បាប់ = មុខងារ**នីតិប្រតិបត្តិ** ក្រុមប្រឹក្សាអ្នកច្បាប់ គឺជាផ្នែកមួយនៃរដ្ឋាភិបាល
១០- អធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច ដែលដោះស្រាយវិវាទការងារ = មុខងារ**ផ្នែកនីតិប្រតិបត្តិ**
១១- ប្រធានសមាគមម្ចាស់រោងចក្រកាត់ដេរ = **ឯកជន** សមាគមក្រៅរដ្ឋាភិបាល

**កំណត់សំគាល់:**

- **ក្រឡាបញ្ជី** គឺជាផ្នែកនៃស្ថាប័នតុលាការ ហើយនិង **អគ្គលេខាធិការនៃរដ្ឋសភា** គឺជាផ្នែកមួយនៃអង្គនីតិបញ្ញត្តិ ប៉ុន្តែ ពួកគេមាន**មុខងារប្រតិបត្តិ**តែប៉ុណ្ណោះ ដើម្បីគាំទ្រស្ថាប័នទាំងនេះ ពីព្រោះ ក្រឡាបញ្ជីសំរេចលើរឿងក្តីផ្សេងៗ និងអគ្គលេខាធិការនៃរដ្ឋសភាមិនធ្វើច្បាប់ដោយខ្លួនឯងឡើយ ។
- **សមាគមរោងចក្រកាត់ដេរ** ឬ **វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ** <u>មិនមែន</u>ជាផ្នែកមួយរបស់អង្គនីតិប្រតិបត្តិទេ ។ ពួកគេ មិនមែនជាអ្នកអនុវត្តច្បាប់ទេ ។ ពួកគេគ្រាន់តែជាសមាគមឯកជនក្រៅពីស្ថាប័នរដ្ឋ តែប៉ុណ្ណោះ (= អង្គការក្រៅរដ្ឋាភិបាល) ។
- **ប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់** មានមុខងារពីរ: ម្យ៉ាង គាត់គឺជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ហើយអាចអនុម័តបទបញ្ញត្តិរបស់ឃុំ-សង្កាត់ ។ ម្យ៉ាងទៀត គេមានភារកិច្ចអនុវត្តសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។
- **ក្រុមប្រឹក្សាអ្នកច្បាប់** គឺជាផ្នែកមួយនៃរដ្ឋាភិបាល (នីតិប្រតិបត្តិ!) ផ្តល់ឱវាទផ្នែកច្បាប់ដល់រដ្ឋាភិបាល ។

## សំនួរសិក្សាទី ៦

*តើក្រុមប្រឹក្សាធម្មនុញ្ញមានមុខងារសំខាន់ៗអ្វីខ្លះ?*
*ចូរដកស្រង់នូវមាត្រានានាដែលពាក់ព័ន្ធ ។*

ដូចមានចែងនៅក្នុងបញ្ញត្តិទូទៅ មាត្រា១៣៦ I CC ភារកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ គឺដើម្បីការពារការគោរពរដ្ឋធម្មនុញ្ញ និងដើម្បីបកស្រាយរដ្ឋធម្មនុញ្ញ ។

ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញបំពេញភារកិច្ច ដោយ :

១) ពិនិត្យមើលធម្មនុញ្ញភាពនៃច្បាប់ដែលធ្វើពង្រាងរួច និងច្បាប់ដែលត្រូវបានប្រកាសឱ្យប្រើប្រាស់ មាត្រា១៤០ I និង ១៤១ I, II CC និងមាត្រា១៧, ១៨ I ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ (LoOFCC)
២) ពិនិត្យធម្មនុញ្ញភាពនៃច្បាប់រៀបចំអង្គការ មាត្រា១៤០ II CC និងមាត្រា១៦ LoOFCC

៣) ពិនិត្យមើលធម្មនុញ្ញភាពនៃអំពើណាមួយរបស់អាជ្ញាធរ និងស្ថាប័នរដ្ឋនានា មាត្រា១៩ I LoOFCC តាមការស្នើសុំរបស់ប្រជាពលរដ្ឋម្នាក់ៗ ។
៤) ធ្វើការសេចក្តីសំរេចចិត្តលើករណីបោះឆ្នោតដែលមានការប្រកួតប្រជែង មាត្រា១៣៦ II CC និងមាត្រា ២៥ LoOFCC
៥) សវនាការជាមួយព្រះមហាក្សត្រអំពីសំណើទាំងអស់ ដើម្បីធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ មាត្រា១៤៣ CC
៦) ធ្វើសេចក្តីសំរេចពីមោឃភាពលើច្បាប់ដែលផ្ទុយទៅនឹងអធិបតេយ្យភាពរបស់ព្រះរាជាណាចក្រកម្ពុជា និងដែលត្រូវបានអនុម័តដោយរដ្ឋសភារួចហើយ ( មាត្រា៩២ ប្រយោគទី ២ CC) ។

## សំនួរសិក្សាទី ៧

*សមាជិកសភាចំនួន ១ ភាគ ១០ ស្នើទៅក្រុមប្រឹក្សាធម្មនុញ្ញ ឱ្យធ្វើការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ដែលពាក់ព័ន្ធនឹងសេរីភាពក្នុងការបញ្ចេញមតិ ។*

*ក) ក្នុងនាមជាសមាជិកមួយរូបនៃក្រុមប្រឹក្សាធម្មនុញ្ញ តើអ្នកនឹងធ្វើការបកស្រាយលើពាក្យថា "សេរីភាពក្នុងការបញ្ចេញមតិ" យ៉ាងដូចម្តេច ?*
*ចូរឱ្យនិយមន័យនៃពាក្យនេះ ។*

សេរីភាពនៃការបញ្ចេញមតិ ដែលមានចែងនៅក្នុងមាត្រា៤១ ប្រយោគទី ១ CC មាត្រា១៩ I, II ICCPR និងមាត្រា១៩ UDHR គឺជាសេរីភាពក្នុង**ការស្វែងរក ទទួល ផ្ទេរ និងលទ្ធភាពបានទទួលព័ត៌មានតាមរយៈបណ្តាញផ្សព្វផ្សាយគ្រប់ប្រភេទ ដូចជា ពាក្យសម្តី សារព័ត៌មានបោះពុម្ព អ៊ិនធើណិត វិទ្យុ ឬទូរទស្សន៍** ។ គេអាចដាក់លំហិតលើសេរីភាពនេះ តែសំរាប់គោលបំណង ដើម្បីការពារសិទ្ធិរបស់បុគ្គលដទៃប៉ុណ្ណោះ (ឧ. សិទ្ធិរបស់គេ ដើម្បីរក្សាកេរ្តិ៍ឈ្មោះពីការបង្ខូចកេរ្តិ៍), សីលធម៌ (ឧ. ការរក្សាប្រពៃណីល្អ ដូចជាការគោរពចាស់ព្រឹទ្ធាចារ្យ), សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខជាតិ (ឧ. ការបោះពុម្ពផ្សាយការណ៍សំងាត់ផ្នែកយោធាដែលការពារឯកភាពជាតិ) ។

*ខ) ប្រសិនណា សមាជិកសភាមិនយល់ស្របនឹងសេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ តើសមាជិកសភាទាំងនោះ អាចប្តឹងតបនឹងសេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែរឬទេ?*
*ចូរផ្តល់ហេតុផលសំរាប់ចំលើយរបស់អ្នក និងដកស្រង់នូវមាត្រានានាដែលពាក់ព័ន្ធ ។*

ពួកគេមិនអាចតវ៉ាចំពោះសេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ ពីព្រោះសេចក្តីសំរេចរបស់ស្ថាប័ននេះ គឺជាសេចក្តីសំរេច**ចុងក្រោយបិទផ្លូវតវ៉ា** ( មាត្រា ១៤២ II CC និងមាត្រា ២៣ និង ៣៤ IV សំរាប់សេចក្តីសំរេចលើបញ្ហាបោះឆ្នោត) LoOFCC ។ ក្រុមប្រឹក្សាធម្មនុញ្ញ គឺជាស្ថាប័នខ្ពស់បំផុត ដែលត្រូវបកស្រាយរដ្ឋធម្មនុញ្ញ ។ ពុំមានតុលាការថ្នាក់ណានៅលើក្រុមប្រឹក្សាធម្មនុញ្ញទៀតទេ ។ ការបញ្ចប់កិច្ចពិភាក្សាមួយ ដែលមានសេចក្តីសំរេចចុងក្រោយ បង្កើតសន្តិសុខផ្លូវច្បាប់មួយ ដែលប្រជាជនអាចជឿទុកចិត្តបាន ។ បើមិនដូច្នោះទេ វាអាចនឹងមានកិច្ចពិភាក្សាដែលគ្មានទីបញ្ចប់ និងជាចំហ ដែលបណ្តាលឱ្យមានអសន្តិសុខ និងកង្វះខាតការតំរង់ទិស ។

## សំនួរសិក្សាទី ៨

*ចូរអានបណ្តាមាត្រាដូចខាងក្រោម នៃពង្រាងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញានៃព្រះរាជាណាចក្រកម្ពុជា (ខែមីនា ឆ្នាំ ២០០៣):*

មាត្រា ១៦:

អាចនឹងត្រូវបានអនុញ្ញាតិឱ្យប្រលងជ្រើសរើសជានិស្សិតចៅក្រម ដែលត្រូវប្រព្រឹត្តទៅជាធម្មតា នៅសាលាភូមិន្ទចៅក្រម នូវបេក្ខភាពជានិស្សិត ឬមន្ត្រីរាជការក្របខ័ណ្ឌ ដែលបានបំពេញលក្ខខណ្ឌ ដូចខាងក្រោមនេះ:

១- ត្រូវមានសញ្ជាតិខ្មែរ

២- មានអាយុ ៣០ឆ្នាំ យ៉ាងច្រើន គិតមកដល់ថ្ងៃប្រលង

៣- ត្រូវមានបរិញ្ញាប័ត្រច្បាប់

៤- មិនដែលធ្លាប់ជាប់ទោសមជ្ឈឹម ឬឧក្រិដ្ឋ

៥- ត្រូវមានកាយសម្បទាគ្រប់គ្រាន់អាចបំពេញការងារបាន

ចំពោះបេក្ខភាពជាមន្ត្រីក្របខ័ណ្ឌ ដែលលក្ខខណ្ឌខាងលើអាចប្រលងជ្រើសរើសជាចៅក្រមបាន ប៉ុន្តែ ត្រូវមានអាយុមិនលើសពី ៣៨ឆ្នាំ គិតមកទល់នឹងថ្ងៃប្រលង ។

មាត្រា ៣៣:

ការតម្លើងថ្នាក់របស់ចៅក្រមត្រូវផ្អែកលើមូលដ្ឋាន :

- គោរពវិន័យការងារបានត្រឹមត្រូវ
- សំរេចភារកិច្ចបានល្អ
- មានកិរិយាមាយាទ និងសីលធម៌ មិនធ្វើឱ្យប៉ះពាល់ដល់កិត្តិយសនៃអង្គចៅក្រម
- ឆ្លងកាត់ការបណ្តុះបណ្តាលរយៈពេលវែងនៅសាកលវិទ្យាល័យ ឬនៅមហាវិទ្យាល័យ ឬនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលមុខវិជ្ជាជីវៈ
- ធ្វើការនៅតំបន់ដាច់ស្រយាល តំបន់ប៉ះពាល់ដល់សុខភាព ឬ គ្រោះថ្នាក់ ។

មាត្រា ៩៤:

មុននឹងចូលបំពេញការងារ ចៅក្រម ត្រូវធ្វើសច្ចាប្រណិធានតាមព្រះពុទ្ធសាសនានៅព្រះវិហារ ព្រះកែវមរកត ។

សម្បថត្រូវធ្វើទៅតាមការណែនាំ និងតាមរូបមន្តរបស់ប្រធានពិធីការ ក្រោមការចាត់ចែងរបស់ក្រសួងព្រះបរមរាជវាំង ។

*ក) មាត្រា១៦ នៃពង្រាងច្បាប់ រៀបរាប់អំពីលក្ខខណ្ឌដើម្បីក្លាយជាចៅក្រម ។*
*តើអ្នកយល់ស្របនឹងលក្ខខណ្ឌទាំងអស់នោះដែរឬទេ?*
*ចូរផ្តល់ហេតុផលចំពោះចំលើយរបស់អ្នក ។*

ការកំណត់អាយុ នៅក្នុងចំណុចទី ២ នៃបទបញ្ជានេះ អាចត្រូវបានមើលឃើញថា ជាការរើសអើងចំពោះមនុស្សចាស់ និងបទពិសោធន៍របស់ពួកគេ ។ ប៉ុន្តែ អាចមានហេតុផលល្អសំរាប់ការជ្រើសរើសចៅក្រមដែលមានអាយុមិនលើសពី ៣០ឆ្នាំ: ពួកគេមិនសូវមានការអនុវត្តន៍ និងបទពិសោធន៍ ជាមួយតំណែងដែលមានឥទ្ធិពល

ខ្លាំង និងពុករលួយ ។ លើសពីនេះទៀត ពួកគេមានចិត្តទូលំទូលាយច្រើន មិនសូវជឿលើអាជ្ញាធរ និងមិនសូវទទួលរងផលប៉ះពាល់ខ្លាំងដោយការភ័យរន្ធត់ ដោយសម័យប៉ុល ពត ។ ដោយពិចារណាទៅលើបញ្ហានេះ យើងមិនអាចយល់បានច្បាស់ថា តើហេតុអ្វីបានជាមន្ត្រីរាជការត្រូវបានផ្តល់ឱ្យនូវការកំណត់អាយុខ្ពស់ផ្សេងពីនេះ (មើលមាត្រា១៦ ប្រយោគចុងក្រោយ) ។

តំរូវការសំរាប់ **សមត្ថភាពរាងកាយ** នៅក្នុងចំណុចទី ៥ មិនមែនជាការរើសអើងចំពោះជនពិការទេ ពីព្រោះ វាគ្រាន់តែតំរូវថា ចៅក្រមត្រូវតែមានសមត្ថភាពបំពេញការងាររបស់ខ្លួន (អានអត្ថបទ, ស្តាប់, សរសេរ, ចូលរួមការប្រជុំរបស់តុលាការ) ។ ឧទាហរណ៍ ជនពិការដែលមាន ជើង ឬដៃតែម្ខាង ឬដែលមានភ្នែកតែម្ខាង មិនត្រូវបាន បដិសេធឡើយ ពីព្រោះពួកគេនៅតែអាចបំពេញភារកិច្ចទាំងនេះបាន ។

លក្ខខណ្ឌ (ចំណុចទី ៤) ដែលថាគ្មានជនណាដែលត្រូវដាក់ទោស ឬកាត់ទោសឱ្យ**ជាប់ពន្ធនាគារ** ពីបទឧក្រិដ្ឋ ឬបទល្មើសមជ្ឈិម អាចក្លាយជាចៅក្រមបានទេ លក្ខខណ្ឌអាចទទួលយកបាន ដោយសារតែចំណុចនេះមិនត្រឹមតែគ្របដណ្តប់ទៅលើជនណាដែលបានរំលោភច្បាប់ដោយចេតនាប្រហែសតែប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងករណីធ្ងន់ធ្ងរ នៃការរំលោភច្បាប់ទៀតផង ។

*ខ) ចូរមើលមាត្រា៣៣ នៃពង្រាងច្បាប់ដដែល ។*

*តើអ្នកយល់ស្របនឹងលក្ខខណ្ឌទាំងអស់ក្នុងការតម្លើងស័ក្តិ និងឋានន្តរស័ក្តិដែរឬទេ?*

*ចូរផ្តល់ហេតុផលចំពោះចំលើយរបស់អ្នក ។*

លក្ខខណ្ឌបីដំបូង មានលក្ខណៈ**ស្រពិចស្រពិលយ៉ាងខ្លាំង** អាស្រ័យហេតុនេះ វាមានការលំបាកដើម្បីធ្វើការវាយតម្លៃ ដោយគ្មានការបំភ្លឺបន្ថែមណាស់ ។

តើ "កិរិយាមារយាទល្អ" និង "ការបំពេញការងារល្អ" មានន័យ ជាពិស្តារដូចម្តេចដែរ? កង្វះភាពច្បាស់លាស់នេះ អាចបើកឱកាសសំរាប់ការវាយតម្លៃ និងការតំឡើង ឋានៈបែបអត្តនោម័ត មានលក្ខណៈពឹងផ្អែកលើលក្ខខណ្ឌទាំងនេះ ។

លក្ខខណ្ឌដែលថា **ការសិក្សារៀនសូត្ររយៈពេលយូរនៅសាកលវិទ្យាល័យ"ណាមួយ"** ឬក៏នៅមជ្ឈមណ្ឌល **"បណ្តុះបណ្តាល វិជ្ជាជីវៈ"** អាចលើកកំពស់ឱកាសនៃការតំឡើងឋានៈ ហើយគួរតែលុបចោល ។ វាជាការល្អ ដើម្បីលើកទឹកចិត្តដល់ការសិក្សាបន្ថែម និងដើម្បីទទួលបានចំណេះដឹងបន្ថែម ប៉ុន្តែការសិក្សានេះគួរតែទាក់ទងទៅនឹងចំណេះដឹងផ្នែកច្បាប់ ឬយ៉ាងហោចណាស់ចំណេះដឹងដែលពាក់ព័ន្ធនឹងភារកិច្ចរបស់ចៅក្រម ។

ការឱ្យរង្វាន់ដល់**ការងារនៅតំបន់ជនបទ ឬតំបន់ដែលមានការប៉ះពាល់ដល់សុខភាព** ដោយការផ្តល់ឱកាសនៃការតំឡើងឋានៈ មិនបង្កឱ្យបញ្ហាអ្វីទេ ។ វាលើកទឹកចិត្តដល់ចៅក្រមឱ្យទៅធ្វើការនៅកន្លែងដែលគេត្រូវការ ។ ជាការពិត ពួកគេត្រូវតែមានចំណេះដឹងផ្នែកច្បាប់គ្រប់គ្រាន់ ។ ឯការពិតដែលថា ពួកគេប្រថុយគ្រោះថ្នាក់សំរាប់ការតំឡើងឋានៈ គួរមានតែមួយប៉ុណ្ណោះក្នុងចំណោមកត្តាជាច្រើន ។

*គ) មើលមាត្រា៩៤ នៃពង្រាងច្បាប់ដដែល ។*

*តើបទបញ្ញត្តិនេះ ស្របជាមួយនឹង "សេចក្តីថ្លែងការណ៍នាទីក្រុងប៉េកាំងស្តីពីគោលការណ៍ឯករាជភាពនៃតុលាការ" (ឆ្នាំ ១៩៩៥) ដែរឬទេ?*

*ចូរដកស្រង់មាត្រាមួយនៃសេចក្តីថ្លែងការណ៍នាទីក្រុងប៉េកាំង ។*

លក្ខខណ្ឌដែលថា មុនពេលចូលកាន់តំណែង ចៅក្រមត្រូវតែសច្ចាប្រណិធានទៅចំពោះព្រះភ័ក្ត្រព្រះពុទ្ធ គឺជា **ការរើសអើងផ្អែកសាសនា** ។ លក្ខខណ្ឌបែបនេះអាចបដិសេធ ជាឧទាហរណ៍ ចំពោះប្រជាពលរដ្ឋខ្មែរដែលជាជនជាតិចាម (ឥស្លាម) ឬគ្រិស្តបរិស័ទ មិនឱ្យធ្វើជាចៅក្រមនៅក្នុងប្រទេសកម្ពុជា ពីព្រោះពួកគេមិនអាចធ្វើសច្ចាប្រណិធាន ចំពោះព្រះពុទ្ធបានទេ ប៉ុន្តែពួកគេអាចធ្វើសច្ចាប្រណិធានចំពោះសាសនារបស់គេផ្ទាល់បាន ។ **មាត្រា៨ នៃសេចក្តីថ្លែងការណ៍ក្រុងប៉េកាំង** គោរពសិទ្ធិសេរីភាពសាសនារបស់ចៅក្រម យ៉ាងច្បាស់លាស់ ហើយមាត្រា១៣ នៃសេចក្តីថ្លែងការណ៍ក្រុងប៉េកាំង បដិសេធយ៉ាងច្បាស់លាស់ចំពោះការរើសអើងផ្អែកសាសនាក្នុងដំណើរការនៃការតែងតាំងចៅក្រម ។

## សំនួរសិក្សាទី ៩

*មើលមាត្រា៥៤ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។*

**មេធាវីដែលបានទទួលតួនាទីក្នុងរាជរដ្ឋាភិបាល ឬទទួលអាណត្តិជាអ្នកតំណាងរាស្ត្រនៃរដ្ឋសភា អាចនៅជាសមាជិកនៃគណៈមេធាវីបាន ប៉ុន្តែត្រូវឈប់ប្រកបវិជ្ជាជីវៈនេះរហូតដល់ចប់តួនាទី ឬអាណត្តិនោះ ។**

*ក) តើសិទ្ធិមនុស្សណាមួយ ឬណាខ្លះ ដែលត្រូវបានដាក់កំហិតដោយមាត្រានេះ? ចូររៀបរាប់ពីសិទ្ធិទាំងនោះ និងបញ្ជាក់ឱ្យបានច្បាស់ពីមាត្រាដែលពាក់ព័ន្ធ !*

១) សេរីភាពក្នុងការប្រកបវិជ្ជាជីវៈ មាត្រា៣៦ I CC ។ ក្នុងករណីនេះ សិទ្ធិសេរីភាពក្នុងការប្រកបវិជ្ជាជីវៈនេះ គឺជាសិទ្ធិមនុស្សពិសេស ។ សិទ្ធិមនុស្សពិសេស តែងតែមានប្រៀបជានិច្ច!

២) ប៉ុន្តែ ប្រសិនបើ អ្នកមិនអាចរកឃើញសិទ្ធិមនុស្សពិសេសទេនោះ វាតែងតែត្រឹមត្រូវជានិច្ច ដើម្បីប្រើសិទ្ធិមនុស្សទូទៅ ធ្វើជាសំអាងសំរាប់សេរីភាពផ្ទាល់ខ្លួន (មាត្រា៣២ I CC) ។

*ខ) តើការដាក់កំហិត ដែលហាមឃាត់មិនឱ្យធ្វើជាមេធាវីនៅពេលដែលធ្វើការជាមន្ត្រីរដ្ឋាភិបាលផងដែរនោះ ស្របនឹងរដ្ឋធម្មនុញ្ញ ដែរឬទេ? ផ្តល់ហេតុផលចំពោះចំលើយរបស់អ្នក!*

ការដាក់កំរិតនេះ **គឺស្របតាមរដ្ឋធម្មនុញ្ញ** ។

មេធាវីមិនត្រឹមតែបំរើផលប្រយោជន៍ឱ្យកូនក្តីរបស់ខ្លួនប៉ុណ្ណោះ ក៏ប៉ុន្តែថែមទាំងត្រូវតែបំរើភាពយុត្តិធម៌ជាលក្ខណៈឯករាជ្យ ដោយការរួមចំណែកដើម្បីសម្រេចលទ្ធផលស្របច្បាប់ មិនមែនលទ្ធផលមិនស្របច្បាប់ទេ ។ ការធ្វើជាមេធាវីម្នាក់ដែលបំរើការនៅតុលាការ និងនៅពេលតំណាលគ្នានេះ ធ្វើជាមន្ត្រីរដ្ឋាភិបាលដែលផ្អែកមួយនៃអង្គនីតិប្រតិបត្តិ អាចរំលោភបំពានលើគោលការណ៍នៃការបែងចែកអំណាច (**មាត្រា៥១ IV CC**) ។

បើពិចារណាលើករណីមួយ ដែលមេធាវីម្នាក់តំណាងកូនក្តីនៅក្នុងបញ្ហាពន្ធដារ ហើយមេធាវីនោះ គឺជាបុគ្គលិកបំរើការក្នុងនាយកដ្ឋានពន្ធដាររបស់រដ្ឋដែរនោះ ទំនាស់ផលប្រយោជន៍ អាចកើតឡើងយ៉ាងឆាប់រហ័ស ។ តើមេធាវីគួរគោរពនរណា? សំណើរបស់កូនក្តី ដើម្បីសន្សំលុយដែលត្រូវបង់ពន្ធ ឬរបស់ចៅហ្វាយនាយ (រដ្ឋាភិបាល) របស់ខ្លួន ដើម្បីប្រមូលពន្ធឱ្យបានច្រើនកាន់តែល្អ?

ការដាក់កំហិតនេះនៅក្នុងមាត្រា៥៤ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី មិនរំលោភបំពានលើសេរីភាពនៃការប្រកបវិជ្ជាជីវៈនៅក្នុងមាត្រា៣៦ I CC ពីព្រោះវាបំរើ "សេចក្តីត្រូវការរបស់សង្គម" ដើម្បីជៀសវាងទំនាស់ផលប្រយោជន៍ ដែលអាចបង្កើតអំពើពុករលួយ និងខ្សែរនិយម ។

លើសពីនេះទៀត មាត្រា១២០ CC បំភ្លឺថា តំណែងមួយនៅក្នុងរដ្ឋាភិបាលមិនអាចត្រូវគ្នាជាមួយតំណែងនៅក្នុងសេវាសាធារណៈទេ ។ នៅក្នុងន័យទូលំទូលាយជាងនេះ មេធាវីបំរើការនៅក្នុង "សេវាសាធារណៈ" ខណៈដែលលើសពីនេះទៀតបំរើយុត្តិធម៌ ហើយតាមរយៈយុត្តិធម៌នោះ បំរើសាធារណជនផងដែរ ។

*គ) តើការដាក់កំហិត ដែលហាមមិនឱ្យធ្វើជាមេធាវី នៅពេលជាមួយគ្នា ធ្វើការជាសមាជិករដ្ឋសភាផងដែរនោះ ស្របទឹងរដ្ឋធម្មនុញ្ញដែរឬទេ? ចូរផ្តល់ហេតុផលចំពោះចំលើយរបស់អ្នក!*

ការដាក់កំរិតនេះ **មិនស្របតាមរដ្ឋធម្មនុញ្ញទេ** ។

នៅក្នុងករណីនេះ ការរំលោភលើគោលការណ៍នៃការបែងចែកអំណាច មាត្រា៥១ IV CC ក៏អាចពិចារណាបានផងដែរ ពីព្រោះ ករណីយកិច្ចរបស់មេធាវីដើម្បីធ្វើជាភ្នាក់ងារយុត្តិធម៌ឯករាជ្យ ហើយតាមរយៈករណីយកិច្ចនោះបំរើការឱ្យតុលាការ អាចមានការភ័ន្តច្រឡំជាមួយករណីយកិច្ចរបស់សមាជិកនៃអង្គនីតិបញ្ញត្តិ ។ ប៉ុន្តែ ទំនាស់ផលប្រយោជន៍ពិតប្រាកដដូចនៅក្នុងសំនួរ ២៥ មិនអាចកើតឡើងបានទេ ពីព្រោះអ្នកធ្វើច្បាប់មិនមានករណីយកិច្ច ដើម្បីគោរពតាមមាគ៌ារបស់គណបក្សនយោបាយណាមួយឡើយ តែគ្រាន់តែសម្រេចចិត្តស្របទៅតាមមនសិការរបស់ខ្លួនតែប៉ុណ្ណោះ ។ នេះគឺជា "**អាណត្តិសេរី**" នៅក្នុងមាត្រា៧៧ II CC ។ ពលរដ្ឋគ្រប់រូប មិនថា អ្នកជំនួញ វេជ្ជបណ្ឌិត មន្ត្រីរាជការ ។ល។ ឬមេធាវី មានមនសិការផ្ទាល់ខ្លួន អាស្រ័យហេតុនេះ ពួកគេអាចក្លាយជាអ្នកធ្វើច្បាប់បាន ។ ប្រសិនបើមានការតំណាងនៃវិជ្ជាជីវៈនៅក្នុងសភាជាតិកាន់តែចំរុះគ្នាច្រើន វាកាន់តែប្រសើរសំរាប់ការតំណាងនូវសេចក្តីត្រូវការផ្សេងៗចំរុះគ្នារបស់ប្រជាពលរដ្ឋ ។ (សូមមើលមាត្រា៧៧ I CC) ។

## សំនួរសិក្សាទី ១០

*មាត្រា២៩ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចែងថា គណៈមេធាវី ត្រូវផ្តល់ថវិកាសំរាប់ជំនួយផ្នែកច្បាប់ដល់ប្រជាជនក្រីក្រ ។ តើអ្នកគិតថា អ្នកណាគួរតែទទួលខុសត្រូវក្នុងបញ្ហាជំនួយផ្នែកច្បាប់នេះ?*
*ចូរផ្តល់ហេតុផលចំពោះចំលើយរបស់អ្នក!*

ជាការពិតណាស់ មេធាវីគួរតែធានាថា បុគ្គលគ្រប់រូបមានលទ្ធភាពបានទទួលសេវាផ្លូវច្បាប់ ។ ពួកគេគួរតែចូលរួមនៅក្នុង**កម្មវិធីជំនួយផ្នែកច្បាប់**នានា ។ នេះគឺជាផ្នែកមួយនៃកាតព្វកិច្ចក្នុងវិជ្ជាជីវៈរបស់ពួកគេ ក្នុងការបំរើដល់ភាពយុត្តិធម៌ ។

ប៉ុន្តែ **ជំនួយផ្នែកច្បាប់មិនមែនជារឿងសប្បុរសធម៌ទេ តែវាជាសិទ្ធិមនុស្សជាមូលដ្ឋាន** ។ ម្យ៉ាងវិញទៀត វាគឺជាកាតព្វកិច្ចរបស់រដ្ឋនីមួយៗ ដើម្បីធានាថា ប្រជាពលរដ្ឋគ្រប់រូបរបស់ខ្លួនអាចប្រើសិទ្ធិមនុស្សគ្រប់យ៉ាងរបស់ខ្លួនបាន (សូមមើលផងដែរនូវមាត្រា៣ BPRL) ។ មាត្រា២ II ពាក់ព័ន្ធជាមួយមាត្រា១៤ III ចំណុច (ឃ) ប្រយោគទី៣ និងមាត្រា២៦ I ICCPR ចែងថា បុគ្គលគ្រប់រូបមាន សិទ្ធិទទួលបានការ**ការពារផ្លូវច្បាប់ស្មើៗគ្នា** ដោយគ្មានការរើសអើង ហើយរដ្ឋមានករណីយកិច្ចផ្តល់ប្រសិទ្ធិភាពចំពោះសិទ្ធិនេះ ។ ម្យ៉ាងវិញទៀត អ្នកក្រីក្រទទួលបានការការពារផ្លូវច្បាប់ដូចអ្នកមានដែរ ។ រដ្ឋត្រូវតែធានាថា ប្រជាជនទាំងនេះត្រូវបានតំណាងដោយមេធាវីនៅចំពោះមុខតុលាការ ។ ប្រសិនបើអ្នកក្រីក្រមិនអាចមានប្រាក់សំរាប់បង់ថ្លៃមេធាវី រដ្ឋត្រូវតែផ្តល់មូលនិធិ ដើម្បីចេញថ្លៃសេវារបស់មេធាវី ។

## សំនួរសិក្សាទី ១១

*លោក ប៉ែន សុនសម័យ ដែលធ្វើជាមេធាវី ត្រូវបានតែងតាំងដោយអនុក្រឹត្យជាមន្ត្រីសាការី តែម្នាក់គត់នៅប្រទេសកម្ពុជា នៅឆ្នាំ ២០០១ ។ គណៈមេធាវី បានដេញគាត់ចេញពីគណៈមេធាវី ។*

*តើអ្នកគិតថា តើហេតុអ្វីបានជាគាត់ត្រូវគេដេញចេញ?*

សារការី គឺជាអ្នកជំនាញផ្នែកច្បាប់ ដែលទទួលខុសត្រូវលើការធ្វើពង្រាង និងប្រថាប់ត្រាផ្លូវការលើឯកសារច្បាប់ទាំងអស់ ។ អាស្រ័យហេតុនេះ សារការីបំពេញ**មុខងារសាធារណៈ** ។ ប៉ុន្តែ មាត្រា៥៣ នៃលក្ខន្តិកៈមេធាវីចែងថា វិជ្ជាជីវៈផ្លូវច្បាប់មិនត្រូវឱ្យស្របជាមួយការបំពេញមុខងារសាធារណៈឡើយ ។ លោក ប៉ែន សុនសម័យ ត្រូវបានបណ្តេញចេញពីគណៈមេធាវីដោយសំអាងហេតុនៃ មាត្រា៥៣ នៃលក្ខន្តិកៈមេធាវី ដើម្បីរារាំងមិនឱ្យមានទំនាស់ផលប្រយោជន៍របស់សាធារណជន ដែលនឹងអាចកើតឡើងបាននៅពេលអនាគត ម្យ៉ាងវិញទៀត ផលប្រយោជន៍ឯកជនរបស់កូនក្តី ។

## សំនួរសិក្សាទី ១២

*តើអតីតមេដឹកនាំខ្មែរក្រហម លោក ខៀវ សំផន មានសិទ្ធិនឹងទទួលបានជំនួយផ្នែកច្បាប់ដែរឬទេ?*

*កុំឆ្លើយត្រឹម "មាន" ឬ "មិនមាន" ប៉ុន្តែ ចូរពន្យល់ទស្សនៈផ្នែកច្បាប់ និងបញ្ជាក់ពីមាត្រានៃ ICCPR ដែលពាក់ព័ន្ធ ។*

តាមមាត្រា**១៤ III (ឃ) ប្រយោគទី ៣ ICCPR** ប្រទេសកម្ពុជា ត្រូវផ្តល់ឱ្យ លោក ខៀវ សំផន នូវជំនួយជាមេធាវីការពារក្តីព្រហ្មទណ្ឌមួយ ដោយឥតគិតថ្លៃ សំរាប់ការកាត់ក្តីនៅឯតុលាការក្នុងស្រុករបស់កម្ពុជា នៅក្រោមលក្ខខណ្ឌ **២:**

ក) **នៅពេលដែលការជួយទ្រទ្រង់បែបនោះ មានលក្ខណៈចាំបាច់ចំពោះប្រយោជន៍នៃដំណើរការរបស់តុលាការ** និង (លើសពីនេះទៅទៀត)

ខ) **នៅពេលដែលគាត់មិនអាចលៃលកបង់ថ្លៃសេវាបែបនោះ ដោយថវិកាផ្ទាល់ខ្លួនរបស់គាត់បាន ។**

ដូច្នេះ នៅក្នុងករណីនេះ:

លក្ខខណ្ឌ ក) (ភាពចាំបាច់នៃការការពារធ្វើឡើងដោយមេធាវីម្នាក់) ហាក់ដូចជាត្រូវបានបំពេញ ព្រោះរឿងក្តីដែលស៊ាំញ៉ាំ និងមានការចោទប្រកាន់ខ្លាំងក្លាបែបនេះ គេមិនអាចសង្ឃឹមថា ជនជាប់ចោទណាមួយ ការពារខ្លួនដោយខ្លួនឯង ដោយពុំមានប្រឹក្សានោះទេ ។

ប៉ុន្តែ លក្ខខណ្ឌ ខ) (កង្វះខាតមធ្យោបាយថវិកា) ហាក់ដូចជាមិនច្បាស់លាស់សោះ ។ តើអ្វីទៅជាស្ថានភាពហិរញ្ញវត្ថុរបស់លោក ខៀវ សំផន? តើគាត់អាចមានលទ្ធភាព ជួលមេធាវីម្នាក់បានដែរឬទេ? (ប្រហែលតើគាត់អាចជា ម្ចាស់ភាគហ៊ុននៃក្រុមហ៊ុនលក់ត្បូងមួយនៅទីក្រុង ប៉ៃលិន ដែរឬទេ?)

## សំនួរសិក្សាទី ១៣

*នៅក្នុងប្រទេសកម្ពុជា ព្រះរាជអាជ្ញា នៅតែធ្វើការយ៉ាងជិតស្និតជាមួយនឹងចៅក្រមស៊ើបអង្កេតនៅក្នុងការប្រមូលភស្តុតាង និងរៀបចំរឿងក្តីព្រហ្មទណ្ឌ ។ ការលាយបញ្ចូលគ្នារវាងមុខងារព្រះរាជអាជ្ញា និងមុខងារតុលាការបែបនេះ បំពានលើច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ (ឆ្នាំ១៩៩៣) និង "គោលការណ៍ណែនាំរបស់ អ.ស.ប ស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា" (ឆ្នាំ១៩៩០) ផងដែរ ។*

*ក) ចូរលើកពីមាត្រាដែលត្រូវបានបំពានឱ្យបានច្បាស់លាស់!*

មាត្រា៩៨ I និង II នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ (១៩៩៣)

ប្រការ១០ នៃ "គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពី តួនាទីរបស់ព្រះរាជាអាជ្ញា" (ឆ្នាំ១៩៩០) និង

មាត្រា២ ប្រយោគទី ២ និង ៣ ក្រមព្រហ្មទណ្ឌអន្តរកាល ។

*ខ) តើហេតុអ្វីបានជាអ្នកគិតថា ស្ថាប័នព្រះរាជអាជ្ញាត្រូវតែបំបែកចេញពីតុលាការ?*

ព្រះរាជអាជ្ញា ត្រូវតែបំបែកចេញពីតុលាការជាដាច់ខាត ពីព្រោះព្រះរាជអាជ្ញា និងចៅក្រម ដើរតួនាទីជាមូលដ្ឋាន ផ្សេង១ពីគ្នាៈ

ព្រះរាជអាជ្ញាកសាងសំណុំរឿងប្រឆាំងនឹងជនជាប់ចោទ ហើយបង្ហាញសំណុំរឿងនោះដោយមានបំណងចង់ឱ្យមានការកាត់ទោស ។

ផ្ទុយទៅវិញ ចៅក្រមត្រូវ "រកការពិត" មិនថាការពិតនោះគាំទ្រព្រះរាជអាជ្ញា ឬក៏អត់ឡើយ ។ ចៅក្រមត្រូវតែកាត់សេចក្តីប្រកបដោយយុត្តិធម៌ ដោយស្តាប់គូភាគីទាំងសងខាងដោយស្មារតីអព្យាក្រិត្យ ទាំងខាងព្រះរាជអាជ្ញា និងភាគីរបស់ចុងចោទ ។

ដើម្បីបញ្ជាក់ឱ្យបានច្បាស់នូវភាពខុសគ្នាជាមូលដ្ឋាននេះ នៅក្នុងប្រទេសប្រជាធិបតេយ្យសេរីភាគច្រើន ព្រះរាជអាជ្ញាត្រូវបានចាត់ទុកថា ជាផ្នែកឯករាជ្យមួយនៃផ្នែកនីតិប្រតិបត្តិ ចំណែកឯចៅក្រមគឺជាសមាជិករបស់ផ្នែកតុលាការយ៉ាងច្បាស់លាស់ ។

*គ) ដោយការអានច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ (LoCP ឆ្នាំ១៩៩៣) ចូររៀបរាប់ដោយសង្ខេបអំពីសកម្មភាពរបស់ព្រះរាជអាជ្ញាម្នាក់ក្នុងការយករឿងក្តីព្រហ្មទណ្ឌមួយ ទៅកាត់សេចក្តី!*

ព្រះរាជអាជ្ញា ទទួលពាក្យបណ្តឹងពី
**នគរបាល ជនរងគ្រោះ ទីភ្នាក់ងាររដ្ឋាភិបាល**
**ឬតុលាការ**
មាត្រា៥៦ I និងមាត្រា៩ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ

↓

ព្រះរាជអាជ្ញា ស៊ើបអង្កេតឧក្រិដ្ឋកម្ម មាត្រា៥៥ I ១ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ១៩៩៣ ដោយ

- **ពិនិត្យភស្តុតាង**ដែលប្រមូលដោយនគរបាល មាត្រា៦៣ I ១ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ
- **សួរចម្លើយជនសង្ស័យ**នៅចំពោះមុខមេធាវី និង**សម្ភាសន៍សាក្សី** មាត្រា៦២ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ

↓

សេចក្តីសំរេចចោទប្រកាន់ ឬមិនចោទប្រកាន់ ( មាត្រា៦៣ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ)

បើកសវនាការដោយផ្ទាល់ចំពោះមុខតុលាការ ក្នុងករណីបទល្មើសមជ្ឈិមជាក់ស្តែង ដែលមានទោស ជាប់ពន្ធនាគារក្រោម១ ឆ្នាំ មាត្រា៦៧ និង៦១ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ

គ្មានវិធានការ ពីព្រោះគ្មានភស្តុតាង គ្រប់គ្រាន់

↓

**ក្នុងករណីផ្សេងទៀតទាំងអស់:**
ព្រះរាជអាជ្ញា បញ្ជូនសុំណុំរឿង ជាមួយនឹងការចោទប្រកាន់ដំបូង ទៅចៅក្រមស៊ើបអង្កេត
មាត្រា៦១ ប្រយោគទី ៥ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ
( ប្រសិនបើជនសង្ស័យត្រូវបានចាប់ខ្លួនៈ ត្រូវបញ្ជូនសុំណុំរឿងក្នុងរយៈពេល **៤៨ម៉ោង**នៃការចាប់ខ្លួន )

↓

ព្រះរាជអាជ្ញា បញ្ចប់ការចោទប្រកាន់
(ក្នុងរយៈពេល ៣ថ្ងៃ ចាប់ពីថ្ងៃទទួលសុំណុំរឿង
ពីចៅក្រមស៊ើបអង្កេតវិញ)

↓

**ការជំនុំជំរះ**

## សំនួរសិក្សាទី ១៤

*តើក្រឡាបញ្ជី មានភារកិច្ចអ្វីខ្លះ?*

ក្រឡាបញ្ជី មានភារកិច្ច ដូចតទៅ:

១) ជួយដល់ចៅក្រម និងព្រះរាជអាជ្ញានៅក្នុងសវនាការ និងការស៊ើបអង្កេត
២) រក្សាសំណុំឯកសាររឿងក្តី និងសៀវភៅកំណត់ត្រាព្រហ្មទណ្ឌ
៣) ពិនិត្យមើលវត្តមាន និងអត្តសញ្ញាណរបស់គូភាគី និងសាក្សី
៤) អានប្រាប់ពីបទបញ្ជាតុលាការ
៥) រាយការណ៍ជូនចៅក្រមអំពីវត្តមាន ឬអវត្តមានរបស់គូភាគី ឬសាក្សី
៦) អានឱ្យឮៗនូវសេចក្តីថ្លែងការណ៍របស់សាក្សីអវត្តមាន និង
៧) ធ្វើកំណត់ហេតុនៃការជំនុំជំរះ មាត្រា១២៦ និង១២៧ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ (ពាក្យសំដីរបស់សាក្សី និងជនជាប់ចោទ បណ្តឹងជិតចិត្តចៅក្រម និងសំអាងហេតុនៃការទទួលយក ឬការបដិសេធន៍លើការជំទាស់) ។

## សំនួរសិក្សាទី ១៥

*តើចៅក្រមកម្ពុជា ត្រូវចងភ្ជាប់ដោយមាត្រានានានៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែរឬទេ?*

**ចាស់/បាទ** ។ តុលាការកម្ពុជា ត្រូវបានចងភ្ជាប់ដោយមាត្រានានានៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។

តុលាការកម្ពុជា ត្រូវតែគោរព និងអនុវត្តច្បាប់កម្ពុជា ។ **ច្បាប់គ្រឹះ**នៃប្រទេសកម្ពុជា គឺ**រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា** ដែលមានរួមបញ្ចូលនូវមាត្រាទាំងឡាយ ដែលការពារសិទ្ធិមនុស្សរបស់បុគ្គលគ្រប់រូប ។

បន្ថែមពីនេះ កម្ពុជាបានចុះហត្ថលេខា និងផ្តល់សច្ចាប័នលើ "**កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ**" **(ICCPR)** ដែលជាអនុសញ្ញាមួយសំខាន់ជាងគេ ក្នុងចំណោមអនុសញ្ញាស្តីពីសិទ្ធិមនុស្សទាំងអស់ ។ ដោយសារតែ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញានេះ អនុសញ្ញានេះក៏**មានប្រសិទ្ធិភាព និងមានឋានានុក្រមដូចគ្នា នឹងច្បាប់ធម្មតាដទៃទៀតរបស់ប្រទេសកម្ពុជាដែរ** ។ ដូច្នេះ យើងក៏អាចហៅអនុសញ្ញានេះបានថា "ច្បាប់កម្ពុជា ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ" ផងដែរ ។ ដូច្នេះ តុលាការកម្ពុជា មិនត្រឹមតែគោរពរដ្ឋធម្មនុញ្ញនៃប្រទេសរបស់ខ្លួនប៉ុណ្ណោះទេ តែត្រូវគោរពកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយថែមទៀតផង ។ តុលាការត្រូវតែគោរព និងអនុវត្តកតិកាសញ្ញានេះ ឱ្យដូចគ្នានឹងការគោរព និងអនុវត្តច្បាប់កម្ពុជាដទៃទៀតដែរ ទោះបីជាមានឈ្មោះថាជា "អនុសញ្ញាអន្តរជាតិ" ដែលអាចបណ្តាលឱ្យ មានការភាន់ច្រឡំថា មិនមែនជាបទបញ្ញត្តិ របស់ប្រទេសកម្ពុជាក៏ដោយ ។

## សំនួរសិក្សាទី ១៦

*ទាំងរដ្ឋធម្មនុញ្ញកម្ពុជា និងកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មានចែង មាត្រាជាច្រើនស្តីពី សិទ្ធិមនុស្សដូចៗគ្នា (ដូចជា សេរីភាពក្នុងការបញ្ចេញមតិ មាត្រា១៩ ICCPR និងមាត្រា៤១ CC) ។*

*ក) ហេតុអ្វីបានជា វានៅតែមានប្រយោជន៏សំរាប់ចៅក្រមកម្ពុជា ដែលត្រូវអនុវត្តមាត្រានៃកតិកាសញ្ញា អន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បន្ថែមលើមាត្រានៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ដូចជា ករណីដែលទាក់ទងនឹងសេរីភាពក្នុងការបញ្ចេញមតិ)?*

វានៅតែមានប្រយោជន៍សំរាប់តុលាការកម្ពុជានៅក្នុងការអនុវត្តន៍ជាបន្ថែមនូវ កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដើម្បីបំពេញភាពខ្វះចន្លោះនៃច្បាប់ និងដើម្បីប្រើប្រាស់ជាឧបករណ៏សំរាប់ធ្វើការ បកស្រាយ ។

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មានចែងអំពីសិទ្ធិមនុស្សជាច្រើន។ ភាគច្រើន នៃសិទ្ធិទាំងនេះ គឺដូចគ្នាទៅនឹងសិទ្ធិទាំងឡាយដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។ ប៉ុន្តែ ក្នុងករណីភាគច្រើន ការឱ្យនិយមន័យ វិសាលភាព និងលទ្ធភាពនៃការដាក់កំហិតណាមួយទៅលើសិទ្ធិទាំងនេះ នៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មានភាពលំអិតជាង ។

ដូច្នេះ តុលាការកម្ពុជា មិនត្រឹមតែយកកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មកអនុវត្តៈ

- **ដើម្បីបំពេញនូវកង្វះខាតណាមួយនៃសិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះទេ**
- តែថែមទាំង **ប្រើជាឧបករណ៏ដើម្បីបកស្រាយពីសិទ្ធិមនុស្សដូចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញទៀតផង** ។ ចំនុចនេះ ត្រូវបានយកមកចែងយ៉ាងច្បាស់ នៅក្នុងមាត្រា ៣១ CC ផងដែរ។ បានគូសបញ្ជាក់យ៉ាងច្បាស់ថា ប្រព័ន្ធច្បាប់កម្ពុជា ត្រូវតែស្របគ្នាជាមួយនិយាមការច្បាប់អន្តរជាតិ ដូចដែលមានចែងក្នុងកតិកាសញ្ញា អន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយជាឧទាហរណ៏ស្រាប់ ។

  នេះមានន័យថា មាត្រាទាំងឡាយស្តីពីសិទ្ធិមនុស្សដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ត្រូវតែមើលឃើញ និងបកស្រាយ ឱ្យស្របនឹងស្មារតីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។ ឧទាហរណ៏ មាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អាចពន្យល់យ៉ាងច្បាស់ពីអ្វីដែលហៅ ថា "សេរីភាពខាងការបញ្ចេញមតិ" ដែលមានន័យពិស្តារ និងពីអ្វីដែលជាទំហំពិតប្រាកដនៃសេរីភាពនេះ ។ ដូច្នេះ កង្វះខាតនៃការរៀបរាប់ឱ្យបានពិស្តារនៃសិទ្ធិ នេះនៅក្នុងមាត្រា ៤១ I នៃរដ្ឋធម្មនុញ្ញកម្ពុជា មិនមែនជាឧបសគ្គទៀតទេ ។ ឧទាហរណ៏ សេរីភាពខាងការបញ្ចេញមតិ ក៏មានរួមបញ្ចូលផងដែរនូវសិទ្ធិ ទទួលបានព័តិមានដោយសេរី និងសិទ្ធិទទួលបានព័តិមានពីបរទេសដោយសេរី ហើយថែមទាំងគ្របដណ្តប់ លើការផ្លាស់ប្តូរព័តិមានគ្នាតាមគ្រប់មធ្យោបាយទំនាក់ទំនងទាំងអស់ (អ៊ិនធឺណិត វិទ្យុ... ។ល។)

*ខ) តើចៅក្រមកម្ពុជា អាចយកមាត្រា១៤ ICCPR មកធ្វើជាមូលដ្ឋាននៃនីតិវិធីក្នុងការធ្វើសេចក្តីសំរេច បានដែរ ឬទេ?*

**ចាស់/បាទ ធ្វើបាន** ។ តុលាការកម្ពុជាត្រូវតែដំណើរការនីតិវិធី ឱ្យស្របតាមគោលការណ៍នៃការកាត់ក្តីដោយយុត្តិធម៌ ដូចដែលមានចែងជាពិសេសនៅក្នុងមាត្រា១៤ ICCPR ។

ដោយមាត្រា ៣៩, ៣៨ VIII និងមាត្រា ១២៨ CC មានភាពមិនច្បាស់លាស់ មិនបានចែងលំអិតពីសិទ្ធិរបស់ប្រជាពលរដ្ឋនៅក្នុងការកាត់ក្តីមួយប្រកបទៅដោយយុត្តិធម៌ ដូចបញ្ញត្តិនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ជាពិសេសមាត្រា ១៤ ICCPR ដែលចែងអំពីចំណាត់ការរឿងក្តី និងការកាត់ក្តីប្រកបទៅដោយយុត្តិធម៌ ដែលមានសារៈសំខាន់សម្រាប់តុលាការកម្ពុជាយកមកបំពេញកង្វះចន្លោះ យកមកធ្វើការស្រាយបំភ្លឺ និងយកមកប្រើប្រាស់ជាឧបករណ៍ក្នុងការបកស្រាយ ។ បទបញ្ញត្តិនេះ ក៏អាចយកមកប្រើដើម្បីត្រួតពិនិត្យមើលថាតើបញ្ញត្តិនៅក្នុងច្បាប់កម្ពុជា ដូចជា ក្រមនីតិវិធីព្រហ្មទណ្ឌ ឬច្បាប់ព្រហ្មទណ្ឌអន្តរកាល មានភាពគ្រប់គ្រាន់ សំរាប់ការពារសិទ្ធិរបស់ចុងចម្លើយដែរឬទេ ។ ក្នុងពេលដែលក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌថ្មី មិនទាន់បានអនុម័តនៅឡើយនោះ តុលាការត្រូវស្វែងរកគោលការណ៍នៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដើម្បីធានាថាចំណាត់ការរបស់ខ្លួនបានបំពេញនូវបទដ្ឋានអន្តរជាតិ ដូចដែលមានចែងនៅក្នុងមាត្រា៣១ នៃ រដ្ឋធម្មនុញ្ញកម្ពុជា ។ ឧទាហរណ៍ នីតិវិធីស្តីពីសាលក្រមកំបាំងមុខ ត្រូវអនុវត្តនៅក្នុងស្មារតីដូចបានការពារសិទ្ធិរបស់ចុងចម្លើយដែលមានវត្តមានដែរ (មាត្រា ១៤ ICCPR) ។

(ឧទាហរណ៍ កិច្ចព្រមព្រៀងរបស់អង្គការសហប្រជាជាតិស្តីពី តុលាការកាត់ទោសខ្មែរក្រហម ក៏បានចែងយ៉ាងលំអិតផងដែរថា ក្នុងករណីដែលនីតិវិធីនៅក្នុងច្បាប់កម្ពុជាមានភាពចន្លោះប្រហោង ឬមានវិវាទជាមួយនឹងបទដ្ឋានអន្តរជាតិ នោះចៅក្រមជំនុំជំរះ អាចស្វែងរកគោលការណ៍នៅក្នុងបញ្ញត្តិ ដែលបានអនុម័តក្នុងក៏រិតអន្តរជាតិ ។ នេះសបញ្ជាក់ឱ្យឃើញថា ភាគីទាំងពីរនៅក្នុងកិច្ចព្រមព្រៀងរបស់អង្គការសហប្រជាជាតិ បានគិតយ៉ាងច្បាស់ថា ច្បាប់នីតិវិធីរបស់កម្ពុជាបច្ចុប្បន្ន អាចមានភាពមិនច្បាស់លាស់ ឬមិនបានបំពេញក៏រិតស្តង់ដារអន្តរជាតិ ។

## សំនួរសិក្សាទី ១៧

*មាត្រា៣១ I CC ចែងយ៉ាងច្បាស់អំពី "សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស" ទោះបីជាសេចក្តីថ្លែងការណ៍នេះ មិនមែនជាអនុសញ្ញាអន្តរជាតិដែលមានអានុភាពចាប់បង្ខំ ក៏ប៉ុន្តែវាជាសេចក្តីថ្លែងការណ៍ដែលមិនមានអានុភាពចាប់បង្ខំ ។*

*តើមានប្រយោជន៍អ្វីនៃការសំអាងទៅលើសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស ចំពោះការអនុវត្តន៍មាត្រាសិទ្ធិមនុស្សដែលធ្វើដោយចៅក្រមកម្ពុជានោះ?*

តុលាការកម្ពុជា អាចអនុវត្ត "សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស" ដូចជា**ឧបករណ៍មួយជំនួយនៅក្នុងការបកស្រាយ** ។

ទោះបីជា សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស គ្រាន់តែជាសេចក្តីថ្លែងការណ៍ ហើយមិនមែនជា "អនុសញ្ញា" ដែលមានអានុភាពចាប់បង្ខំក៏ដោយ ក៏សេចក្តីថ្លែងការណ៍នេះ ត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងមាត្រា៣១ I CC ។ អាស្រ័យហេតុនេះ គោលការណ៍ណែនាំសំរាប់ធ្វើការបកស្រាយលើបណ្តាមាត្រាច្បាប់កម្ពុជាទាំងឡាយពីសិទ្ធិមនុស្ស ក៏អាចរកឃើញនៅក្នុងសេចក្តីថ្លែងការណ៍នេះដែរ ។ ឧទាហរណ៍ **មាត្រា ៣១ III CC**

ដែលចែងថា ការអនុវត្តន៍សិទ្ធិសេរីភាព ត្រូវតែស្របនឹងច្បាប់ អាចត្រូវបានបកស្រាយតាមមាត្រា២៩ **UDHR** ដែលចែងថា **សេរីភាព អាចត្រូវបានកំណត់ព្រំដែនដោយច្បាប់មួយ** ( មិនមែនដោយបទបញ្ជានោះទេ) ។

## សំនួរសិក្សាទី ១៨

*តើចៅក្រមកម្ពុជាអាចធ្វើអ្វីបានខ្លះ នៅពេលដែលគាត់គិតថា ច្បាប់ដែលកំពុងតែអនុវត្តនៅក្នុងប្រទេសកម្ពុជា មិនស្របនឹងរដ្ឋធម្មនុញ្ញ (= មិនស្របនឹងមាត្រាសិទ្ធិមនុស្សដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា)?*

*ឧទាហរណ៍:*

*ករណីដែលមាត្រានៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ បានបំពានលើមាត្រា៣១ III CC ដែលចែងអំពីសិទ្ធិស្មើភាពគ្នារវាងស្ត្រី និងបុរស ។*

តុលាការកម្ពុជា **អាចអនុវត្តបានតែច្បាប់ដែលស្របនឹងរដ្ឋធម្មនុញ្ញ** តែប៉ុណ្ណោះ!

ក្នុងករណីដែលតុលាការ បានអនុវត្តច្បាប់កម្ពុជាណាមួយ ដែលមិនស្របជាមួយនឹងរដ្ឋធម្មនុញ្ញកម្ពុជា នោះតុលាការ មានករណីយកិច្ចត្រូវតែបញ្ឈប់នីតិវិធីរបស់ខ្លួន ហើយបញ្ជូនច្បាប់នេះ**ទៅក្រុមប្រឹក្សាធម្មនុញ្ញតាមរយៈតុលាការកំពូល** ដើម្បីធ្វើការត្រួតពិនិត្យ (**មាត្រា១៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ**) ។ ប្រសិនបើ ច្បាប់ណាមួយ រំលោភសិទ្ធិមនុស្សដូចដែលមានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ច្បាប់នោះ មានលក្ខណៈអធម្មនុញ្ញភាព ដែលតុលាការមិនអាចយកមកអនុវត្តបានឡើយ ។

## សំនួរសិក្សាទី ១៩

*ការប្រើប្រាស់សិទ្ធិមនុស្ស អាចត្រូវបានដាក់កំហិតដោយច្បាប់មួយ ( មាត្រា២៩ II UDHR) ។*

*តើចៅក្រមកម្ពុជា ត្រូវសំរេចយ៉ាងដូចម្តេច នៅពេលដែលអាជ្ញាធរបានកំណត់ចេញនូវការដាក់កំហិតមួយលើការប្រើប្រាស់សិទ្ធិមនុស្ស ប៉ុន្តែពុំមានច្បាប់ណាមួយអនុញ្ញាតឱ្យមានការដាក់ កំហិត នេះឡើយ?*

*ឧទាហរណ៍:*

*ក្រសួងព័ត៌មាន ហាមមិនឱ្យប៉ុស្តិ៍វិទ្យុធ្វើការផ្សព្វផ្សាយពីកម្មវិធីនៃវិទ្យុបរទេស ប៉ុន្តែច្បាប់ស្តីពីប្រព័ន្ធផ្សព្វផ្សាយ មិនទាន់មាននៅឡើយទេ ទោះបីជា រដ្ឋធម្មនុញ្ញកម្ពុជាទាមទារឱ្យបង្កើតច្បាប់នេះក៏ដោយ ( មាត្រា៤១ II CC) ។*

តុលាការកម្ពុជា **មិនអាចអនុម័តការដាក់កំហិតលើសិទ្ធិមនុស្សណាមួយ ដោយពុំមានការអនុវត្តន៍ឱ្យមានការដាក់កំហិតបែបនោះដោយច្បាប់ឡើយ** ។

ប្រសិនបើ ការដាក់កំហិតលើសិទ្ធិមនុស្ស មិនបានផ្អែកលើច្បាប់កម្ពុជាទេ តុលាការត្រូវតែហ៊ានសំរេចថា ការដាក់កំហិតបែបនេះ មិនមានប្រសិទ្ធិភាព ព្រមទាំងផ្ទុយនឹងរដ្ឋធម្មនុញ្ញកម្ពុជាទៀតផង ។ ឧទាហរណ៍ ដរាបណាច្បាប់មួយស្តីពីប្រព័ន្ធឃោសនា ដែលរដ្ឋធម្មនុញ្ញតម្រូវឱ្យមាន ប៉ុន្តែមិនទាន់មាននៅឡើយ ដូច្នេះគ្មានការដាក់កំហិតណាមួយលើប្រព័ន្ធឃោសនា អាចត្រូវបានកំណត់ដោយអាជ្ញាធរនោះទេ ។ តុលាការ ត្រូវតែសំរេចសេចក្តីថា ការដាក់កំហិតបែបនេះ គឺផ្ទុយទៅនឹងច្បាប់ ពីព្រោះការហាមឃាត់នេះ បានរំលោភលើច្បាប់គ្រឹះ (= រដ្ឋធម្មនុញ្ញ

កម្ពុជា) ។ ការដាក់កំហិតណាមួយលើប្រព័ន្ធឃោសនា អាចធ្វើទៅបាន តែដោយផ្អែកទៅលើច្បាប់សារព័ត៌មាន ឬ ក្រមព្រហ្មទណ្ឌប៉ុណ្ណោះ ។

## សំនួរសិក្សាទី ២០

*យោងតាមកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ការដាក់កំហិតលើសិទ្ធិមនុស្ស អាចកំណត់ឡើង នៅក្នុងករណី "ចាំបាច់" តែប៉ុណ្ណោះ ។ មានន័យថា ការដាក់កំហិតទាំងឡាយ ជាការដាក់កំហិតស្របច្បាប់ នៅពេលដែលគ្មានវិធានការណាដែលស្រាលជាងការដាក់កំហិតនេះទៀតទេ (**"គោលការណ៍នៃភាពសមាមាត្រ"**) ។*

*តើតុលាការកម្ពុជាអាចកំណត់បានដែរឬទេថា សេចក្តីសំរេចរដ្ឋបាលមួយមិនស្របច្បាប់ ដោយសារអាជ្ញាធរ មិនបានជ្រើសរើសវិធានការដែលស្រាលបំផុតដែលអាចធ្វើទៅបាន ចេញពីបណ្តាវិធានការនានា ដែលចែងដោយច្បាប់ ?*

*<u>ឧទាហរណ៍</u>:*

*អាជ្ញាធរ ហាមឃាត់ទាំងស្រុងចំពោះបាតុកម្មមួយ ដើម្បីរក្សាសណ្តាប់ធ្នាប់ចរាចរនៅលើដងផ្លូវ ទោះបីជាគេអាចពង្វាងផ្លូវចរាចរជាបណ្តោះអាសន្ន ហើយអាចអនុញ្ញាតឱ្យធ្វើបាតុកម្មក្រោមលក្ខខណ្ឌដែលថាបាតុកម្មនោះត្រូវធ្វើនៅក្នុងរយៈពេលមួយ និងនៅលើផ្លូវមួយជាកំណត់ ក៏ដោយ ។*

តុលាការកម្ពុជា **អាចអនុម័ត ឬបញ្ញត្តិ បានតែការដាក់កំហិតលើសិទ្ធិមនុស្ស ដែលមានលក្ខណៈចាំបាច់ (សមាមាត្រ) តែប៉ុណ្ណោះ ។**

គ្រប់មាត្រាសិទ្ធិមនុស្ស នៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ តែងតែបញ្ជាក់ថា ការដាក់កំហិតលើសិទ្ធិមនុស្ស មានលក្ខណៈត្រឹមត្រូវតាមច្បាប់ លុះត្រាតែការហាមឃាត់នោះ "ចាំបាច់ខានមិនបាន" ដើម្បីការពារសិទ្ធិមនុស្សមួយផ្សេងទៀត ។ ដូច្នេះ តុលាការកម្ពុជា អាចមិនយល់ព្រមចំពោះការដាក់កំហិតណាដែលធ្វើឡើង ដោយអាជ្ញាធរដោយរំលោភទៅលើគោលការណ៍នៃភាពសមាមាត្រនោះឡើយ ។ ទន្ទឹមនឹងនេះ តុលាការកម្ពុជា ត្រូវតែគោរព "គោលការណ៍នៃភាពសមាមាត្រ" នេះ នៅពេលដែលខ្លួនសំរេចធ្វើការដាក់ទណ្ឌកម្មដោយផ្ទាល់ ។

ឧទាហរណ៍ តុលាការកម្ពុជាមួយ មិនអាចចាត់ទុកការហាមឃាត់ដោយផ្អែករដ្ឋបាលមួយលើការធ្វើបាតុកម្មថា ជាការត្រឹមត្រូវតាមច្បាប់ទេ ដរាបណានៅមានវិធានការស្រាលជាងការហាមឃាត់ទាំងស្រុង ដើម្បីទប់ទល់នឹងការបង្កគ្រោះថ្នាក់ដែលកើតចេញពីបាតុកម្មសាធារណៈនេះ ។ តុលាការកម្ពុជា ក៏ត្រូវតែពិនិត្យមើលពីភាពចាំបាច់នៃការហាមឃាត់ ឧទាហរណ៍ តុលាការផ្ទាល់ អនុវត្តតាមមាត្រា១០ V នៃច្បាប់សារព័ត៌មាន ហើយតុលាការត្រូវជ្រើសរើសការដាក់ទណ្ឌកម្មដ៏សមស្របមួយ ។ ឧទាហរណ៍ តុលាការត្រូវតែធ្វើឱ្យប្រាកដថា ទោសពិន័យក្នុងរឿងបរិហាកេរ្តិ៍មិនធ្ងន់ធ្ងរពេកទេ ចំពោះក្រុមហ៊ុនសារព័ត៌មានមួយដែលត្រូវបិទទ្វារទាំងស្រុងនោះ ។ ចំពោះករណីនេះ វាមិនមែនជាការដាក់កំហិតមួយដែលសមស្រម និងចាំបាច់ មកលើសេរីភាពខាងការបញ្ចេញមតិ នោះទេ ។

## សំនួរសិក្សាទី ២១

*វិវាទការងារ:*

*កម្មករម្នាក់ ត្រូវបានបណ្តេញចេញដោយនិយោជក ពីព្រោះគាត់ត្រូវបានគេចោទថា មកធ្វើការយឺតជាប្រចាំ ហើយបានយកប្រាក់ពីក្រុមហ៊ុនទៀតផង ។*

*កម្មកររូបនោះ បដិសេធការចោទប្រកាន់នេះ ដោយគាត់បានជួលមេធាវីម្នាក់ និងធ្វើបណ្តឹងទៅតុលាការ ដើម្បីទាមទារឱ្យគេជួលមកបំរើការងារឡើងវិញ ឬសំណងជំងឺចិត្ត ។*

*ក) និយោជក ក៏ជួលមេធាវីម្នាក់ដែរ ដែលជាអ្នករៀបចំបណ្តឹងតវ៉ាមួយ និងដាក់ពាក្យសុំថតចំលងឯកសារនៃបណ្តឹងទាមទាររបស់កម្មករនិយោជិក នៅពេលជាមួយគ្នានោះផងដែរ ។*

*ចៅក្រម ពុំផ្តល់ឯកសារថតចំលងនោះដល់មេធាវីរបស់និយោជកឡើយ ដោយនិយាយថា មេធាវីគ្មានសិទ្ធិត្រួតពិនិត្យលើឯកសារ ពីព្រោះនេះគឺជាកិច្ចការផ្ទៃក្នុង ។*

*តើសំដីរបស់ចៅក្រម ត្រូវ ឬខុស? ចូរកុំគ្រាន់តែឆ្លើយ "ត្រូវ" ឬ "ខុស" ប៉ុន្តែសូមផ្តល់ការពន្យល់អំពីគំនិតរបស់អ្នកផង!*

សំដីរបស់ចៅក្រម គឺខុស ។

ចៅក្រម ត្រូវផ្តល់ឱ្យមេធាវីរបស់និយោជកនូវសិទ្ធិ ដើម្បីពិនិត្យមើលសំណុំឯកសារតុលាការ ពីព្រោះឯកសារទាំងនេះមិនមែនជា "កិច្ចការផ្ទៃក្នុង" ទេ ។

មេធាវី គឺជាតំណាងស្របច្បាប់របស់ភាគី អាស្រ័យហេតុនេះ គេមិនត្រឹមតែមានសិទ្ធិ (មាត្រា១៤ ចំណុចទី ៣ (ខ) ICCPR មាត្រា៧ ចំណុចទី ១ និងមាត្រា១៧ II នៃក្រមព្រហ្មទណ្ឌអន្តរកាល និងមាត្រា២១ នៃគោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី - BPRL) ប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំង មានកាតព្វកិច្ចតាមកិច្ចសន្យា ដើម្បីការពារយ៉ាងពេញលេញនូវផលប្រយោជន៍នៃកូនក្តីរបស់គេ ។ មេធាវី ថែមទាំងអាចចាត់ទុកថារំលោភលើករណីយកិច្ចនៃកិច្ចសន្យារបស់ខ្លួនទៀតផង ប្រសិនបើ គាត់មិនបានពិនិត្យសំណុំឯកសារទេនោះ ។

មេធាវីអាចរៀបចំសំណុំរឿងបានត្រឹមត្រូវ និងការពារផលប្រយោជន៍នៃកូនក្តីរបស់ខ្លួនបាន លុះត្រាតែគេមានព័ត៌មានគ្រប់គ្រាន់ ។ ដូច្នេះ មេធាវីក៏មានសិទ្ធិថតចម្លងសំណុំរឿងទាំងនេះដោយគិតលើថ្លៃចំណាយនៃកូនក្តីរបស់ខ្លួនផងដែរ។ ចំពោះហេតុផលនេះ តុលាការនីមួយៗគួរតែមានម៉ាស៊ីនថតចម្លងមួយគ្រឿងសំរាប់មេធាវីចំលងឯកសារឬ - ប្រសិនបើគ្មានម៉ាស៊ីនទេនោះ - អនុញ្ញាតឱ្យមេធាវីយកសំណុំរឿងទៅការិយាល័យរបស់គេ ដើម្បីធ្វើការថតចម្លងនៅទីនោះ ។ ពេលវេលាទ្បេងទាត់សំរាប់ការយកសំណុំរឿងមកឱ្យវិញ ត្រូវមានចំនួន បីថ្ងៃ។

គេអាចប្រើប្រាស់សិទ្ធិ ដើម្បីពិនិត្យសំណុំរឿងក្នុងកំឡុងនីតិវិធីទាំងមូល មិនត្រឹមតែក្នុងរយៈពេលដ៏ខ្លីមុនសវនាការប៉ុណ្ណោះទេ ។ ក្នុងកំឡុងពេលសវនាការ អាចមានសំណុំរឿងថ្មីបន្ថែមទៀត ដូចជាសក្ខីភាពរបស់សាក្សី ឬរបាយការណ៍ដែលដាក់ជូនដោយអ្នកជំនាញ ។ មេធាវីត្រូវស្វែងរកព័ត៌មានថ្មីៗសំរាប់ខ្លួនគេ ហើយត្រូវតែពិនិត្យជាបន្តលើសំណុំរឿង ដើម្បីតំណាងកូនក្តីរបស់ខ្លួនឱ្យបានល្អ ។

សិទ្ធិ ដើម្បីពិនិត្យសំណុំរឿងគ្របដណ្តប់លើឯកសារទាំងអស់នៅក្នុងសំណុំរឿង ។ តុលាការមិនមានសិទ្ធិដើម្បីបដិសេធឯកសារមួយចំនួន ហើយដាក់កំហិតសិទ្ធិដើម្បីពិនិត្យសំណុំរឿងរបស់មេធាវីឡើយ ។

តតីយជនដែលគូភាគីមិនបានតែងតាំងជាអ្នកតំណាងផ្លូវការ មិនមានសិទ្ធិត្រួតពិនិត្យសំណុំរឿងទេ ។

*ខ) និយោជិក បង្ហាញពីមិត្តរួមការងារដែលជាអ្នកដែលអាចបញ្ជាក់ថា និយោជិករូបនោះមិនបានមកធ្វើការយឺត និងមិនបានយកលុយពីក្រុមហ៊ុនឡើយ ។*

*ចៅក្រមកោះហៅសាក្សីមួយចំនួន មកសម្ភាសន៍ពួកគេនៅក្នុងបន្ទប់របស់គាត់ និងសរសេររបាយការណ៍អំពីពាក្យសំដីរបស់សាក្សីទាំងនោះ ។*

*តើសកម្មភាពរបស់ចៅក្រមធ្វើបែបនេះ ត្រឹមត្រូវដែរឬទេ? ចូរកុំគ្រាន់តែឆ្លើយ "ត្រូវ" ឬ "ខុស" ប៉ុន្តែសូមផ្តល់ការពន្យល់អំពីគំនិតរបស់អ្នកផង!*

ទង្វើរបស់ចៅក្រម មិនត្រឹមត្រូវទេ ។

ការមិនរាប់បញ្ចូលគូភាគី និងសាធារណជន ខណៈដែលកំពុងធ្វើសវនាការនូវសក្ខីភាពរបស់សាក្សី គឺជាការរំលោភលើគោលការណ៍នៃ "ការជំនុំជំរះដោយយុត្តិធម៌" មាត្រា១៤ ចំណុចទី ៣ (ង) និង (ឃ) ICCPR ហើយសំរាប់ករណីព្រហ្មទណ្ឌៈ មាត្រា២៤ ចំណុចទី ១ ច្បាប់ព្រហ្មទណ្ឌអន្តរកាល) ។ វាគឺជាលក្ខខណ្ឌកំណត់ជាមុនមួយសំរាប់ការលើកឡើងនូវភស្តុតាងដែលថា គេគួរតែផ្តល់ឱ្យគូភាគី នូវលទ្ធភាព ដើម្បីបង្ហាញមុខក្នុងកំឡុងពេលជំនុំជំរះ ។ សិទ្ធិដើម្បីពិនិត្យមើលសាក្សីធ្វើឱ្យភាគីទាំងពីរមានលទ្ធភាព ពិនិត្យដោយខ្លួនគេនូវភាពអាចទុកចិត្តបាន និងភាពគួរជឿបានរបស់សាក្សី ។ ពួកគេអាចសង្កេត និងវិនិច្ឆ័យនូវកាយវិការ និងទំនាក់ទំនងមិនមែនពាក្យសម្តីរបស់សាក្សីបានតែនៅពេលដែលគេឃើញមនុស្សដោយផ្ទាល់ប៉ុណ្ណោះ ។ មេធាវីទាំងពីរ (ឬនៅក្នុងករណីព្រហ្មទណ្ឌៈ ផ្នែកដោះបន្ទុក និងផ្នែកដាក់បន្ទុក) ត្រូវតែបានទទួលសេចក្តីជូនដំណឹងគ្រប់គ្រាន់ជាមុនអំពីការពិនិត្យលើសាក្សី ដើម្បីរៀបចំសំនួររបស់ខ្លួនឱ្យបានល្អ ។

ការធ្វើសម្ភាសន៍ជាមួយសាក្សីអាចធ្វើទៅបាន ដោយគ្មានវត្តមានរបស់អ្នកតំណាងរបស់គូភាគីទាំងពីរបានតែនៅពេលណាដែលមានការយល់ព្រមប៉ុណ្ណោះ និង**នៅក្នុងករណីលើកលែង** ឧទាហរណ៍ សាក្សីរស់នៅឯបរទេស ហើយអាចពិនិត្យបានដោយចៅក្រមរងតែម្នាក់ប៉ុណ្ណោះ ។

## សំនួរសិក្សាទី ២២

*ករណី:*

*មន្ត្រីជាន់ខ្ពស់ម្នាក់ ត្រូវបានចោទប្រកាន់ពីបទមនុស្សឃាដ ។ សាក្សីរបស់ព្រះរាជអាជ្ញា មិនចង់ប្រាប់ពីអត្តសញ្ញាណរបស់គាត់ទេ ពីព្រោះគាត់ព្រួយបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់គាត់ ។ យ៉ាងណាមិញ ព្រះរាជអាជ្ញាសុំទៅតុលាការសុំឱ្យបង្ហាញចំលើយអនាមិករបស់សាក្សី ។*

*ឧបមាថាអ្នកជាចៅក្រម ហើយត្រូវតែធ្វើសេចក្តីសំរេចចិត្តលើការពាក្យសុំរបស់ព្រះរាជាអាជ្ញា ។ តើអ្នកធ្វើការសំរេចយ៉ាងដូចម្តេច? ចូរផ្តល់ហេតុផលចំពោះការសំរេចរបស់អ្នក និងបញ្ជាក់ពីមាត្រានានាដែលពាក់ព័ន្ធ ។*

ជាទូទៅ ការប្រើប្រាស់សក្ខីភាពបានមកពីសាក្សីអនាមិក រំលោភសិទ្ធិរបស់គូភាគី ក្នុងការពិនិត្យបុគ្គលិកលក្ខណៈរបស់សាក្សី មាត្រា១៤ ចំណុចទី៣ (ង) ICCPR ។ ការប្រើប្រាស់សក្ខីភាពអនាមិកធ្វើឱ្យការជំនុំជំរះទាំងមូលមិនមានភាពយុត្តិធម៌ ។ ដូច្នេះ គេត្រូវតែមានការកំណត់តឹងរឹងលើការប្រើប្រាស់សក្ខីភាពអនាមិក ។

នៅក្នុងករណីខាងលើ ការភ័យខ្លាចបែបអត្តនោម័តនៃសាក្សីនៃការសងសឹកក្រៅច្បាប់តែម្យ៉ាងដោយគ្មានការចង្អុលណាមួយថា គេ ឬសាច់ញាតិរបស់គេពិតជានឹងមានគ្រោះថ្នាក់នៅពេលអនាគតនោះ មិនអាចដកហូតនូវសិទ្ធិរបស់គូភាគី ដើម្បីបង្ហាញមុខក្នុងកំឡុងពេលពិនិត្យលើសាក្សី និងដើម្បីស្គាល់អត្តសញ្ញាណរបស់សាក្សីបានឡើយ ។ សាក្សីត្រូវតែបង្ហាញថា ការភ័យខ្លាចរបស់ខ្លួន គឺសមហេតុផល ឧទាហរណ៍ គេអាចផ្តល់នូវខ្សែអាត់សម្លេងទូរស័ព្ទ ដែលក្នុងនោះជនជាប់ចោទបានគំរាមកំហែង ដើម្បីសម្លាប់គេជាដើម ។

នៅក្នុងករណីរបស់យើង ចៅក្រមត្រូវតែបដិសេធនូវការអនុវត្តន៍របស់ព្រះរាជអាជ្ញា ។

## **សំនួរសិក្សាទី ២៣**

*ហេតុអ្វី សវនាការត្រូវធ្វើជាសាធារណៈ?*
*ចូរពន្យល់ពីចំលើយរបស់អ្នក និងបញ្ជាក់ពីមាត្រានានាដែលពាក់ព័ន្ធ ។*

សវនាការត្រូវតែរៀបចំឡើងជាសាធារណៈ រាប់បញ្ចូលទាំងសារព័ត៌មាន ដើម្បីចាត់ទុកថាជាការជំនុំជំរះដោយយុត្តិធម៌ មាត្រា១០ និង ១១ ចំណុចទី ១ UDHR មាត្រា១៤ ចំណុចទី ១ ប្រយោគទី ២ ICCPR មាត្រា១២៨ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ (១៩៩៣) ។

**សរុបមមក សវនាការជាសធារណៈត្រូវធានា**

- ការត្រួតពិនិត្យជាសាធារណៈ
- ការការពារពីភាពអត្តនោម័តរបស់តុលាការ
- ព័ត៌មានដល់សាធារណជនអំពីរបៀបធ្វើសេចក្តីសំរេច
- ការការពារនូវទំនុកចិត្តរបស់សាធារណជនលើប្រព័ន្ធយុត្តិធម៌

គេមិនអាចចាត់ទុកសវនាការមួយថាមានលក្ខណៈសាធារណៈបានទេ ប្រសិនបើ មានតែប្រភេទមនុស្សជាក់លាក់ណាមួយត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងសវនាការនោះ ។

## **សំនួរសិក្សាទី ២៤**

*តើមានករណីលើកលែងទៅគោលការណ៍នៃសវនាការជាសាធារណៈនេះដែរឬទេ?*
*បើសិនជាមាន តើមានអ្វីខ្លះ?*

លទ្ធភាពបានចូលស្តាប់សវនាការរបស់សាធារណជន អាចត្រូវបានដាក់កំហិតនៅក្នុងកាលៈទេសៈដែលត្រូវបានកំណត់មួយចំនួនតូច ។

មាត្រា១៤ ចំណុចទី ១ ប្រយោគទី ៣ ICCPR កំណត់និយមន័យនៃករណីលើកលែង ដូចខាងក្រោមនេះ សំរាប់សវនាការជាសាធារណៈមួយៈ

- "ផ្នែកសីលធម៌" (ឧ. ករណីដែលពាក់ព័ន្ធនឹងបទល្មើសផ្លូវភេទ)
- "សណ្តាប់ធ្នាប់សាធារណៈ" (ឧ. ដើម្បីរក្សាសណ្តាប់ធ្នាប់នៅក្នុងតុលាការ)
- "សន្តិសុខជាតិ" (ឧ. ករណីដែលពាក់ព័ន្ធនឹងកិច្ចការសម្ងាត់ផ្នែកយោធា ដែលការពារដល់ប្រទេសជាតិ ឬបូរណភាពទឹកដីរបស់ប្រទេសពីការគំរាមកំហែងផ្នែកយោធា ឬការញុះញង់ដើម្បីផ្តួលរំលំរដ្ឋាភិបាល)

- "ផលប្រយោជន៍នៃជីវិតឯកជនរបស់គូភាគី" (ឧ. ការលែងលះគ្នា បទល្មើសប្តឹងទៅលើអនីតិជន)
- "កាលៈទេសៈដែលភាពសាធារណៈ អាចធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌" (ឧ. សាធារណជនមានជំនឿលើពិរុទ្ធភាពនៃជនណាម្នាក់ ហើយសារព័ត៌មាន ព្យាយាមជះឥទ្ធិពលទៅលើចៅក្រម ដោយការសរសេរអត្ថបទបរិហារកេរ្តិ៍)

មាត្រា១២៩ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ (ឆ្នាំ១៩៩៣) ចែងអំពី "សណ្តាប់ធ្នាប់សាធារណៈ" និង "ប្រពៃណីល្អ" ។ "ប្រពៃណីល្អ" គឺជាពាក្យមួយដែលមិនច្បាស់លាស់ ហើយត្រូវតែធ្វើការបកស្រាយឱ្យបានច្បាស់ ដោយឆ្លុះបញ្ចាំងជាមួយនឹងមាត្រា១៤ ចំណុចទី ១ ICCPR ។

## សំនួរសិក្សាទី ២៥

*បើក "សៀវភៅស្តីពីតុលាការយុត្តិធម៌" តាមរយៈគេហទំព័ររបស់ "អង្គការលើកលែងទោសអន្តរជាតិ" = www.amnesty.org/alibi/intcam/fairtrial/indxftm_b.htm និងមើលជំពូកទី ១៧.១ នៃ "សៀវភៅស្តីពីតុលាការយុត្តិធម៌" ។*

*តើមាត្រាណាមួយនៃរដ្ឋធម្មនុញ្ញកម្ពុជា ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងបណ្តាមាត្រាដែលចែងនៅក្នុងជំពូកទី ១៧.១ នៃ "សៀវភៅស្តីពីតុលាការយុត្តិធម៌"?*

មាត្រា៣៨ V CC ចែងថាៈ "ការទទួលសារភាព ដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ" ។

## សំនួរសិក្សាទី ២៦

*តើចៅក្រមត្រូវធ្វើអ្វីខ្លះ ប្រសិនបើ មានតែភស្តុតាងចោទប្រកាន់មួយគត់បង្ហាញជូនចៅក្រមនោះ គឺជាសំដីសារភាពរបស់ជនជាប់ចោទដែលបានមកពីការវាយដំ និងធ្វើទារុណកម្ម?*

*សូមផ្តល់ហេតុផលនៃចំលើយរបស់អ្នក និងដកស្រង់មាត្រាច្បាប់នានាដែលពាក់ព័ន្ធ!*

ប្រសិនបើ ចៅក្រម **មិនអាចទទួលបាននូវភស្តុតាងណាមួយទេ** គាត់ត្រូវតែសំរេចធ្វើការលើកលែងការចោទប្រកាន់ចំពោះជនជាប់ចោទ ។ ការស្វែងរកភស្តុតាង គឺជាបន្ទុករបស់**ព្រះរាជអាជ្ញា** (មាត្រា៣៨ VI CC និងមាត្រា១៤ II ICCPR) ហើយ**ចំលើយសារភាពដែលបានពីការធ្វើទារុណកម្ម មិនអាចយកមកធ្វើជាភស្តុតាងបានឡើយ** (មាត្រា ២៤ III ២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា៣៨ CC) ។

## សំនួរសិក្សាទី ២៧

*តើសិទ្ធិនៅក្នុងការទទួលបានសាលក្រមដែលមានបញ្ជាក់ពីមូលហេតុ មានមូលដ្ឋានលើសិទ្ធិសំខាន់ៗ អ្វីខ្លះរបស់ចុងចោទ?*

*ចូរលើកយកផ្នែកដែលពាក់ព័ន្ធ ដែលមានចែងនៅក្នុងមាត្រា ១៤ICCPR ។*

សិទ្ធិក្នុងការដឹងអំពីហេតុផលរបស់សាលក្រមមួយ កើតចេញមកពីសិទ្ធិក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រម ។ សិទ្ធិនេះ មានចែងនៅក្នុងមាត្រា១៤ V ICCPR ។

## សំនួរសិក្សាទី ២៨

*តើហេតុអ្វីបានជា ចុងចោទត្រូវការដឹងពីមូលហេតុនៅក្នុងសាលក្រម?*

ប្រសិនបើចុងចោទ មិនដឹងអំពីហេតុផលរបស់សាលក្រមទេនោះ គេមិនអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនប្រកបដោយប្រសិទ្ធិភាព ដើម្បីប្តឹងឧទ្ធរណ៍ចំពោះសាលក្រមនោះបានឡើយ ។ ប្រសិនបើ គាត់មិនដឹងថាតើសាលក្រមនោះ ផ្អែកលើការវាយតម្លៃលើអង្គហេតុ និងទស្សនៈផ្លូវច្បាប់ ដូចម្តេចទេនោះ គេមិនអាចយល់បានថាថាតើអង្គហេតុត្រូវបានគេមិនអើពើ ឬតើមានកំហុសផ្លូវច្បាប់ ឬក៏អត់ឡើយ? ដូច្នេះ គាត់មិនអាចធ្វើការទិតៀនសាលក្រមនោះប្រកបដោយប្រសិទ្ធិភាព និងចង្អុលបង្ហាញពីកំហុសបែបនោះនៅក្នុងបណ្តឹងឧទ្ធរណ៍បានឡើយ ។

## សំនួរសិក្សាទី ២៩

*តើហេតុអ្វីបានជា វាមានសារៈសំខាន់ចំពោះការដែលព្រះរាជអាជ្ញា ជូនដំណឹងដល់ចុងចោទជាមុនមុនពេលសវនាការ អំពីសាក្សីដែលនឹងត្រូវកោះហៅដោយព្រះរាជាអាជ្ញាឱ្យមកចូលរួមសវនាការ?*

ប្រសិនបើចុងចោទ មិនត្រូវបានផ្តល់ព័តិមានទាន់ពេលអំពីសាក្សី ដែលត្រូវធ្វើជាកសិណប្រឆាំងលើរូបគេនោះ គេមិនមានឱកាសប្រកបដោយយុត្តិធមិ ដើម្បីរៀបចំខ្លួនសំរាប់ការពិនិត្យសាក្សីនេះ ក្នុងពេលជំនុំជំរះ ឬដើម្បីប្រមូលព័តិមានដែលអាចធ្វើឱ្យភាពគួរជឿបានរបស់សាក្សីចុះខ្សោយឡើយ ។ ប្រការនេះរំលោភលើសិទ្ធិដែលមាត្រា១៤ ចំណុច (ខ) និង (ង) ICCPR បានផ្តល់ឱ្យចុងចោទ (ពេលវេលា និងឱកាសគ្រប់គ្រាន់ដើម្បីរៀបចំការការពារខ្លួន និង សិទ្ធិដើម្បីសាកសួរសាក្សីខាងការចោទ និងតែងតាំងសាក្សីការពារ) ។

## សំនួរសិក្សាទី ៣០

*ចៅក្រមម្នាក់ អាចបញ្ជាឱ្យឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្នបាន ។*
*តើហេតុផលតែពីរដែលចៅក្រមសំអាងសំរាប់ការឃុំខ្លួននេះគឺអ្វី?*
*សូមរៀបរាប់ពីហេតុផលទាំងពីរនោះ និងដកស្រង់នូវមាត្រាដែលពាក់ព័ន្ធ!*

ជនសង្ស័យ អាចត្រូវចាប់ខ្លួន និងឃុំខ្លួន នៅក្នុងពន្ធនាគារបាន តែត្រូវស្ថិតនៅក្រោមលក្ខខណ្ឌមួយចំនួនតូចដូចខាងក្រោម (**មាត្រា១៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល**):

- ប្រថុយនឹងការគេចខ្លួន
- មិនបង្ហាញខ្លួនតាមការកោះហៅ

} ការសន្មត់ទុកជាមុនថាមានគ្រោះថ្នាក់ទាំងនេះ ត្រូវតែមាន**សំអាងច្បាស់លាស់មួយចំនួន** ដូចជាជននោះគ្មានការងារធ្វើពិតប្រាកដ គ្មានគ្រួសារ ឬគ្មានទីលំនៅអចិន្ត្រៃយ៍ច្បាស់លាស់ ។

- មានហេតុផលគ្រាប់គ្រាន់ដែលគួរអោយជឿថា ជនជាប់ចោទ នឹងធ្វើការគំរាមកំហែងដល់សាក្សី ឬដល់ការស៊ើបអង្កេត ។

**មាត្រា៩ III ២ ICCPR** ចែងយ៉ាងច្បាស់ថា គ្មានជនណាម្នាក់ **ត្រូវបានឃុំខ្លួនដោយសារតែរឿងសាមញ្ញធម្មតា** ដើម្បីរង់ចាំរហូតដល់មានសវនាការមួយនោះទេ។

## សំនួរសិក្សាទី ៣១

*តើចៅក្រមត្រូវចេញដីកាអ្វី ក្នុងករណីដែលការឃុំខ្លួនបណ្តោះអាសន្នលើសពីរយៈពេល៦ ខែ? ចូរដកស្រង់នូវមាត្រានានាដែលពាក់ព័ន្ធ!*

មាត្រា២២ I ១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចែងច្បាស់ថា ក្នុងករណីដែលមានការរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិរបស់ជនជាប់ចោទ ដោយឃុំខ្លួនជនជាប់ចោទលើសរយៈពេលកំណត់៦ខែ (មើលមាត្រា១៤ IV ១ និងមាត្រា២១ I នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល) ជនជាប់ចោទ**ត្រូវបានដោះលែងភ្លាម** ។

លើសពីនេះ មន្ត្រីដែលទទួលខុសត្រូវក្នុងការរំលោភបំពាន នេះត្រូវតែផ្តន្ទាទោស (សូមមើលមាត្រា ២២ II និងមាត្រា៥៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល) ពី ១ឆ្នាំ ទៅ ២ឆ្នាំ ។

លើសពីនេះទៅទៀត មាត្រា៩ V ICCPR ចែងថា ជនណាដែលត្រូវឃុំខ្លួនដោយខុសច្បាប់ មានសិទ្ធិប្តឹងទាមទារសំណង ។

បណ្តាមាត្រាដ៏តឹងរឹងទាំងនេះ ការពារនូវសិទ្ធិដ៏មានតំលៃនៃសេរីភាពរបស់បុគ្គល (មាត្រា៩ I ១ ICCPR និងមាត្រា ៣២ I ជំរើសទី ២ CC) ។

## សំនួរសិក្សាទី ៣២

*តើអ្វីទៅជាបញ្ហាចំពោះ ការឃាត់ខ្លួនជនសង្ស័យ ក្នុងរយៈពេល ៤៨ម៉ោង ដោយនគរបាលយុត្តិធម៌ ដោយ**មិនមានការយល់ព្រមពីតុលាការ** ដែលមានចែងនៅក្នុង មាត្រា៤៧ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ និង មាត្រា១៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល?*

ក្នុងរយៈពេលនេះ គ្មានការត្រួតពិនិត្យពីមេធាវី ពីសមាជិកគ្រួសារ ឬពីវេជ្ជបណ្ឌិតឡើយ ដូច្នេះមិនដឹងថាតើពិរុទ្ធជនត្រូវបានថែរក្សាបានល្អដែរឬទេ ឬក៏សិទ្ធិរបស់ពិរុទ្ធជនត្រូវបានគេបំពាន? ក្នុងរយៈពេលដ៏វែងដែលគ្មានការត្រួតពិនិត្យដោយតុលាការបែបនេះ បង្កឱ្យមានភយន្តរាយកំរិតខ្ពស់ ក្នុងការទទួលរងនូវទារុណកម្ម ។ តាមធម្មតា មន្ត្រីនគរបាល មានទំនោរគាបសង្កត់ជនសង្ស័យក្នុងរយៈពេលនេះ ដើម្បីយកចំលើយសារភាព និងបង្ខំឱ្យទទួលថាខ្លួនជាអ្នកប្រព្រឹត្តបទល្មើស ហើយម្យ៉ាងទៀតប្រព្រឹត្តអំពើមិនគប្បីមកលើជនសង្ស័យ រហូតដល់ជនសង្ស័យ ចុះហត្ថលេខាលើចំលើយសារភាពនោះ ។

## សំនួរសិក្សាទី ៣៣

*ករណី:*

*ភាគី ក ទាមទារប្រាក់ចំនួន ១០០ដុល្លារអាមេរិក ពីភាគី ខ នៅចំពោះមុខតុលាការ ។ ក និយាយថាគាត់បានផ្តល់កំចីនៃចំនួនលុយនេះឱ្យទៅ ខ ។*

*ខ បដិសេធការទាមទារនេះ និងនិយាយថា លុយនេះមិនដែលត្រូវបានឱ្យមកគាត់ទេ ។*

*ក ធ្វើឯកសារមួយស្តីពីកំចីដែល ខ បានចុះហត្ថលេខា ឱ្យទៅតុលាការ ។ វាមិនច្បាស់ទេថា តើឯកសារនេះជាឯកសារពិតប្រាកដ ឬក្លែងក្លាយ? ដូច្នេះ ចៅក្រមហៅសាក្សី គ មកដើម្បីសាកសួរព័ត៌មានលើស្ថានភាពកំចីបន្ថែមទៀត ។ ចៅក្រម បដិសេធការទាមទាររបស់ ក ។*

*ចូរបង្កើតនូវមូលហេតុនៃសាលក្រមរបស់ចៅក្រមដោយសង្ខេប!*

ការសរសេរមូលហេតុ អាចមានសេចក្តីដូចតទៅ:

"យោងតាមមាត្រាច្បាប់រដ្ឋប្បវេណី... ក អាចទាមទារសំណងចំពោះប្រាក់កម្ចីពី ខ បាន តែក្នុងករណីដែលគាត់បានឱ្យ ខ ខ្ចីប្រាក់ និងនៅក្នុងករណីដែលដល់ពេលកំណត់ត្រូវសងតែប៉ុណ្ណោះ ។

**ក្នុងនាមជាដើមបណ្តឹង** ក ទទួលបន្ទុក**បង្ហាញភស្តុតាង**ថា លក្ខខណ្ឌទាំងពីរនេះ ត្រូវបានបំពេញ ។

តុលាការបដិសេធការទាមទាររបស់ ក ពីព្រោះ គាត់មិនអាចបង្ហាញថា លក្ខខណ្ឌទី ១ (ការឱ្យ ខ ខ្ចីប្រាក់) ត្រូវបានបំពេញ ។

ទោះបីជា ក បានដាក់ជូននូវឯកសារប្រាក់កម្ចី ដែលបង្ហាញពីហត្ថលេខាក៏ដោយ ក៏តុលាការមិនជឿថាហត្ថលេខានេះធ្វើឡើងដោយ ខ ដែលបដិសេធមិនទទួលស្គាល់ហត្ថលេខានេះឡើយ ។ តុលាការ បានស្តាប់ សាក្សី គ ដែល ក បាននាំមកបង្ហាញ ដើម្បីធ្វើជាសក្ខីភាពសំរាប់ការចោទប្រកាន់របស់គាត់ ។ ប៉ុន្តែ ចម្លើយដែលសាក្សី គ បានផ្តល់ឱ្យតុលាការ មិនគ្រប់គ្រាន់ដើម្បីធ្វើឱ្យតុលាការអាចជឿបានទេ ។ ផ្ទុយទៅវិញ វាបានលេចឡើងថា គ មានផលប្រយោជន៍ផ្ទាល់ខ្លួននៅក្នុងកិច្ចការនេះ ដោយសារ ក ខ្លួនឯង បានជំពាក់ប្រាក់ គ ដែរ ។ ម្យ៉ាងវិញទៀត គ អាចបញ្ជាក់ត្រឹមតែថា គាត់បានឮ ក និង ខ និយាយគ្នា អំពីលទ្ធភាពនៃប្រាក់កម្ចីមួយ ប៉ុន្តែ គ មិនបានឃើញ ខ ចុះហត្ថលេខាលើឯកសារមួយ ព្រមទាំងមិនអាចផ្តល់ព័ត៌មានលំអិតថែមទៀតបានឡើយ ។"

## សំនួរសិក្សាទី ៣៤

*សាលក្រមដែលយុត្តិធម៌មួយ ត្រូវតែផ្តល់នូវហេតុផល ។*
*តើហេតុផលអ្វីខ្លះដែលត្រូវលើកឡើងដើម្បីផ្តល់នូវការពន្យល់គ្រប់ជ្រុងជ្រោយនៅក្នុងសាលក្រម?*

ហេតុផលនៃសាលក្រមមួយត្រូវតែបង្ហាញនូវអ្វីដែលជាការចោទប្រកាន់ និងអ្វីជាការទាមទាររបស់គូភាគី ដូច្នេះ ហេតុផល ត្រូវតែបង្ហាញនូវអង្គហេតុ ដែលចៅក្រមចាត់ទុកមិនមានវិវាទ និងមានភស្តុតាងគ្រប់គ្រាន់ ។ វាត្រូវតែបង្ហាញអំពីមូលហេតុដែលចៅក្រមគិតថា មានភស្តុតាងគ្រប់គ្រាន់ ឬមិនមាន ។ លើសពីនេះទៀត ហេតុផល ត្រូវតែបង្ហាញឱ្យបានច្បាស់លាស់អំពីមាត្រាច្បាប់ណា ដែលចៅក្រមបានយកធ្វើជាមូលដ្ឋានសំរាប់សេចក្តីសំរេចចិត្ត និងអំពីថាតើហេតុអ្វីបានជាចៅក្រមយល់ថា អង្គហេតុដែលផ្តល់ឱ្យនោះ បំពេញលក្ខខណ្ឌទាំងឡាយនៃមាត្រានេះ?

# ដំណោះស្រាយនៃសំនួរប្រលងបញ្ចប់វគ្គ

## សំនួរសិក្សាទី ១

*តើប្រជាពលរដ្ឋកម្ពុជា មានសិទ្ធិទទួលបាននូវការត្រួតពិនិត្យដោយតុលាការ លើសេចក្តីសំរេចរដ្ឋបាលដែរឬទេ?*

*ចូរដកស្រង់នូវបញ្ញត្តិច្បាប់ជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធ ។*

ចាស់/បាទ ប្រជាពលរដ្ឋកម្ពុជា មានសិទ្ធិទទួលបាននូវការត្រួតពិនិត្យផ្នែកតុលាការទៅលើសេចក្តីសំរេចរដ្ឋបាល (មាត្រា៣២ ប្រយោគទី ២ មាត្រា ១២៨ III CC និងមាត្រា២ III ក) ICCPR) ។

## សំនួរសិក្សាទី ២

*ក្នុងការជំនុំជំរះរឿងក្តីមួយ តើការដែលមានអង្គជំនុំជំរះដែលមានចៅក្រម ៣រូប មានអត្ថប្រយោជន៍អ្វីជាជាងអង្គជំនុំជំរះដែលមានចៅក្រមតែ ១រូប?*

អត្ថប្រយោជន៍គឺថា វាមានការពិបាកច្រើន និងចំណាយប្រាក់ច្រើន ក្នុងការផ្តល់សំណូលដល់ចៅក្រម ៣នាក់ ជាជាងចៅក្រមតែម្នាក់ ។ លើសពីនេះទៀត ក្រុមចៅក្រមប្រមូលផ្តុំចំណេះដឹងច្រើនជាងចៅក្រមតែម្នាក់។ ដោយចៅក្រមត្រួតពិនិត្យគ្នាទៅវិញទៅមក វាកាន់តែធ្វើឱ្យពួកគេម្នាក់ៗ មានការពិបាក ដើម្បីមានចេតនាមិនអើពើចំពោះអង្គហេតុ និងអង្គច្បាប់ ។

## សំនួរសិក្សាទី ៣

*តើហេតុអ្វីបានជា ដំណើរការនីតិវិធីទាំងអស់ដែលត្រូវកត់ត្រាចូលក្នុងកំណត់ហេតុពិធីសារ ហើយនិងឯកសារទាំងអស់ដែលត្រូវរក្សាទុកក្នុងសុំណុំរឿងឱ្យបានត្រឹមត្រូវនោះ មានសារៈសំខាន់ម្ល៉េះ?*

មានតែសំណុំរឿង និងពិធីសារនីតិវិធីរឿងក្តីដែលត្រូវបានរក្សាទុកយ៉ាងល្អប៉ុណ្ណោះទេ ទើបអាចឱ្យតុលាការថ្នាក់ខ្ពស់ ពិនិត្យមើលសេចក្តីសំរេចរបស់តុលាការថ្នាក់ទាប សំរាប់កំហុសផ្នែកនីតិវិធី និងកំហុសផ្សេងទៀតបាន ។ ការរក្សាទុកសំណុំរឿង និងពិធីសារ ក៏ធ្វើឱ្យចៅក្រមពិបាកធ្វើមិនដឹងមិនឮចំពោះអង្គច្បាប់ អង្គហេតុ និងរៀបចំការជំនុំជំរះ ដោយអយុត្តិធម៌ ។

## សំនួរសិក្សាទី ៤

*ការអនុវត្តនីការងាររបស់ចៅក្រម ១រូប ត្រូវបានត្រួតពិនិត្យដោយតួអង្គជាច្រើន ។*

*រៀបរាប់ឈ្មោះតួអង្គទាំងនោះយ៉ាងហោចណាស់ឱ្យបាន ៥ និង ពិពណ៌នាអំពីរបៀបដែលពួកគេធ្វើការត្រួតពិនិត្យទៅលើចៅក្រម ។*

- **គូភាគី និងមេធាវីរបស់ពួកគេ** អាចបដិសេធចំពោះចៅក្រមដែលលំអៀងបាន
- **តុលាការថ្នាក់ខ្ពស់ជាង** អាចបដិសេធចំពោះសាលក្រមបាន
- **ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម** អាចដាក់ទណ្ឌកម្មលើចៅក្រមដែលរំលោភក្រមសីលធម៌បាន
- **សារព័ត៌មានសេរី និងបណ្ដាញផ្សព្វផ្សាយ** អាចសង្កេតការណ៍ រិះគន់ និងអធិប្បាយអំពីទង្វើរបស់ចៅក្រមបាន
- **ប្រធានតុលាការ** អាចណែនាំចៅក្រមឱ្យគោរពតាមក្រមសីលធម៌បាន
- **ព្រះរាជអាជ្ញា** អាចចោទប្រកាន់ចៅក្រមពីការរំលោភបំពានក្រមព្រហ្មទណ្ឌបាន
- **ចៅក្រមដែលជាសហការីនៃក្រុមចៅក្រម** អាចបោះឆ្នោតប្រឆាំងនឹងសំណើសុំរបស់ចៅក្រមណាមួយ

## សំនួរសិក្សាទី ៥

*តើហេតុអ្វីសាលក្រមត្រូវតែផ្ដល់ហេតុផល?*

**សិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍** (មាត្រា១៤ V ICCPR) មិនអាចត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធិភាពដោយមិនបានដឹងអំពីហេតុផលនៃសាលក្រមឡើយ ពីព្រោះគេមិនអាចចង្អុលបង្ហាញនូវការយល់ខុសលើអង្គហេតុ ឬកំហុសផ្នែកនីតិវិធី ឬកំហុសផ្នែកច្បាប់ធម្មតា នៅក្នុងសាលក្រមនោះ ។ ការមិនផ្ដល់ហេតុផលសំរាប់សាលក្រមក៏ធ្វើឱ្យចៅក្រមងាយស្រួលលាក់នូវការពន្យល់ហេតុផលពិតសំរាប់ការធ្វើសេចក្ដីសំរេចនោះ (ដូចជា ការខ្វះចំណេះដឹងផ្នែកច្បាប់ ឬការមានអគតិ និងលំអៀង) ។

## សំនួរសិក្សាទី ៦

*ល្បឿនស្មើគ្នានៅក្នុងការកាត់ក្ដីមួយ មានន័យថា ការកាត់ក្ដីនោះ មិនត្រូវប្រព្រឹត្តទៅ យឺតពេក ហើយក៏កុំលឿនពេកដែរ ។*

*រៀបរាប់:*

*ក) បទបញ្ញត្តិមួយ ដែលធានាថា ដំណើរការនីតិវិធីមួយលឿន:*

មនុស្សគ្រប់រូបដែលត្រូវបានចាប់ខ្លួន មានសិទ្ធិទទួលព័ត៌មាន**ភ្លាមៗ**អំពីការចោទប្រកាន់ (មាត្រា៩ II និង១៤ III ក) ICCPR) និងមានការត្រួតពិនិត្យផ្នែកតុលាការ**ភ្លាមៗ** លើភាពស្របច្បាប់នៃការចាប់ខ្លួន ។ សាលក្រមចុងក្រោយ ត្រូវតែចេញឱ្យ**ដោយគ្មានការពន្យារដែលមិនសមស្រប** (មាត្រា ១៤ III គ) CC និងមាត្រា១០ II ខ) ICCPR) ។

*ខ) បទបញ្ញត្តិមួយ ដែលធានាថា ដំណើរការនីតិវិធីមួយមិនលឿនពេក:*

ចុងចោទគ្រប់រូប មានសិទ្ធិទទួលបាន**ពេលវេលាគ្រប់គ្រាន់ ដើម្បីរៀបចំការការពារ**របស់ខ្លួន (មាត្រា១៤ III ខ) ICCPR) និងមានសិទ្ធិក្នុងការ**និយាយដោយគ្មានការរំខាន** (មាត្រា១៤ I ១ ICCPR) ។

## សំនួរសិក្សាទី ៧

*នៅក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ ជនជាប់ចោទនិយាយថា គាត់បានផ្តល់ចំលើយសារភាពរបស់គាត់ ក៏ព្រោះតែ គាត់ត្រូវធ្វើទារុណកម្មដោយប៉ូលីស ។*

*តើមេធាវីការពារក្តីអាចធ្វើអ្វីបានខ្លះ? រៀបរាប់នូវមធ្យោបាយនានាទាំងអស់ដែលអាចធ្វើទៅបាន!*

មេធាវីអាចៈ

- **ប្តឹងទាមទារផ្នែកនីតិវិធីថា ការទទួលសារភាពនេះមិនត្រូវបានរាប់បញ្ចូលក្នុងការជំនុំជំរះទេ ពីព្រោះវាមិនអាចទុកថា ជាភស្តុតាងនៃពិរុទ្ធភាពទេ** ( មាត្រា៣៨ V CC) និង/ឬ
- **ប្តឹងទាមទារផ្នែកនីតិវិធី ដើម្បីផ្អាកការជំនុំជំរះ** ដើម្បីផ្តល់ពេលវេលាឱ្យមេធាវីស៊ើបអង្កេតលើការទាមទាររបស់កូនក្តីរបស់គាត់ និង/ឬ
- **ធ្វើបណ្តឹងទៅតុលាការរដ្ឋប្បវេណី** អំពីការខូចខាតប្រឆាំងនឹងនគរបាល និង/ឬ
- **រៀបចំការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌទៅព្រះរាជអាជ្ញា** ប្តឹងនគរបាល និង/ឬ
- **រៀបចំពាក្យបណ្តឹងទៅនាយកដ្ឋាននគរបាល** ឱ្យដាក់ទណ្ឌកម្មផ្នែកវិន័យលើនគរបាល ។

## សំនួរសិក្សាទី ៨

*ចៅក្រម បានសាកសួរសាក្សីម្នាក់នៅក្នុងបន្ទប់របស់គាត់ ។ ជនជាប់ចោទ និងមេធាវីការពារក្តី មិនត្រូវបានអនុញ្ញាតឱ្យចូលរួមស្តាប់ការសួរដេញដោលនោះទេ ។*

*តើចៅក្រមរូបនេះ បានបំពានទៅលើសិទ្ធិណាមួយរបស់ជនជាប់ចោទ?*

*ចូរដកស្រង់នូវបទបញ្ញត្តិនានាដែលពាក់ព័ន្ធ!*

ការសាកសួរសាក្សី គឺជាផ្នែកដ៏សំខាន់បំផុតនៃការជំនុំជំរះនីមួយៗ ។ ដោយធ្វើការសាកសួរនេះនៅក្រៅបន្ទប់តុលាការ ដោយកំបាំងមុខចុងចោទ ចៅក្រម បានបំពានលើ**សិទ្ធិ**របស់ចុងចោទ **ដើម្បីបង្ហាញមុខក្នុងកំឡុងពេលជំនុំជំរះ** ( មាត្រា១៤ III ឃ) ប្រយោគទី ១ ICCPR) និងរំលោភបំពានផងដែរលើសិទ្ធិរបស់ចុងចោទ **ក្នុងការសាកសួរសាក្សី** ( មាត្រា១៤ III ង) ICCPR) ។

## សំនួរសិក្សាទី ៩

*ដើម្បីឱ្យកាន់តែមានឯករាជភាព តើគេគួរកែប្រែ សមាសភាពនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមយ៉ាងណាឱ្យកាន់តែប្រសើរ? ផ្តល់ហេតុផលចំពោះសំណើរបស់អ្នក ។*

បច្ចុប្បន្ន សមាសភាពរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មិនធានាភាពឯករាជ្យគ្រប់គ្រាន់នៃស្ថាប័ននេះទេ ពីព្រោះ មានតែសមាជិកភាគតិចប៉ុណ្ណោះដែលត្រូវបានជ្រើសតាំងដោយចៅក្រម ។ សមាជិកទាំងអស់ដទៃទៀតគឺជាសមាជិកដោយផ្ទាល់របស់ស្ថាប័ននីតិប្រតិបត្តិ (ក្រសួងយុត្តិធម៌) ឬគ្រាន់តែជាសមាជិកដែលមានឋានន្តរស័ក្តិខ្ពស់របស់តុលាការ ដែលត្រូវបានតែងតាំងដោយស្ថាប័ននីតិប្រតិបត្តិកាលពីអតីតកាលតែប៉ុណ្ណោះ ។

ដើម្បីធ្វើឱ្យឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកាន់តែមានឯករាជ្យភាព **គេគួរតែបង្កើនសមាសភាពរបស់ក្រុមប្រឹក្សានេះ** ដោយបញ្ចូល**សមាជិកនៃគណៈមេធាវី សមាជិកសង្គមស៊ីវិល** (អង្គការក្រៅរដ្ឋាភិបាល ដូចជា អង្គការ ជំនួយផ្នែកច្បាប់កម្ពុជា ។ល។) ឬ**សមាជិកសភាជាតិ**ពីគណបក្សផ្សេងៗ ឬ**សាស្ត្រាចារ្យច្បាប់** ។

## សំនួរសិក្សាទី ១០

*តើ "គោលការណ៍នៃការត្រួតពិនិត្យ និងតុល្យភាព" មានន័យយ៉ាងដូចម្ដេច?*
*តើហេតុអ្វីបានជា គោលការណ៍នេះត្រូវបានគេបង្កើតឡើង?*

គោលការណ៍នេះមានន័យថា អំណាចរបស់រដ្ឋមួយមិនត្រឹមតែត្រូវបែងចែកប៉ុណ្ណោះទេ ប៉ុន្តែ អំណាចទាំងនេះក៏ត្រូវ**ការត្រួតពិនិត្យ និងតុល្យភាព**រវាងគ្នាទៅវិញទៅមក ។ ហេតុផល គឺថាអំណាចទាំងអស់នេះត្រូវបានបែងចែក ដោយមនុស្សជាតិ ហើយ**មនុស្សជាតិខ្លួនឯងមិនមានភាពសុក្រិត្យទេ** ប៉ុន្តែ បង្កើតកំហុសទៀតផង ហើយត្រូវការការត្រួតពិនិត្យ ដើម្បីការពារពួកគេពីការរំលោភអំណាចរបស់ពួកគេផង ។

## សំនួរសិក្សាទី ១១

*តើអំណាចនីតិបញ្ញត្តិ និងអំណាចតុលាការ ធ្វើការត្រួតពិនិត្យគ្នាទៅវិញទៅមក យ៉ាងដូចម្ដេចខ្លះ?*

តុលាការ អាចពិនិត្យមើលធម្មនុញ្ញភាពនៃច្បាប់ទាំងឡាយដែលត្រូវបានអនុម័តដោយរដ្ឋសភា ដោយការបង្ហាញច្បាប់ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ (មាត្រា១៤០ និងមាត្រា១៤១ CC) ។ លើសពីនេះទៅទៀត តុលាការព្រហ្មទណ្ឌ អាចដាក់ទណ្ឌកម្មដល់សមាជិកសភាចំពោះទង្វើឧក្រិដ្ឋនៅពេលដែលអភ័យឯកសិទ្ធិសភារបស់គេត្រូវបានដកហូត ។

## សំនួរសិក្សាទី ១២

*តើអ្វីខ្លះទៅជាមុខងារសំខាន់ៗរបស់គណៈមេធាវី?*

គណៈមេធាវី តំណាងផលប្រយោជន៍នៃការប្រកបវិជ្ជាជីវៈមេធាវីជាសាធារណៈ ដោយធ្វើការបញ្ចុះ-បញ្ចូលសំរាប់ច្បាប់ថ្មីស្ដីពីលក្ខន្តិកៈមេធាវី ឬសំរាប់ការធ្វើវិសោធនកម្មចំពោះច្បាប់នេះ ឬដោយផ្ដល់មតិយោបល់លើពង្រាងច្បាប់ដែលពាក់ព័ន្ធនឹងវិធាននីតិវិធី ។ល។

លើសពីនេះទៀត គណៈមេធាវី ក្នុងនាមជាស្ថាប័នឯករាជ្យ ទទួលខុសត្រូវលើការត្រួតពិនិត្យសមាជិករបស់ខ្លួន និងដាក់ទណ្ឌកម្មលើពួកគេ ក្នុងករណីមានការរំលោភបំពានក្រមសីលធម៌ ។

ជាចុងក្រោយ គណៈមេធាវី រៀបចំប្រព័ន្ធជំនួយផ្នែកច្បាប់ ដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុពីរដ្ឋាភិបាល និងរៀបចំវគ្គបណ្ដុះបណ្ដាល ដើម្បីលើកកំពស់ចំណេះដឹងផ្នែកច្បាប់នៃសមាជិកគណៈមេធាវីស្ដីពីច្បាប់ថ្មីៗ និងប្រធានបទច្បាប់ ។

# ឧបសម្ព័ន្ធ

## ក) បទបញ្ញត្តិអន្តរជាតិ

### សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស (ថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ១៩៤៨)

**មាត្រា ៨:**

ជនណាក៏ដោយ ត្រូវមានសិទ្ធិរកដំណោះស្រាយជាក់ស្តែងមួយដ៏មានប្រសិទ្ធិភាពនៅតុលាការជាតិមានសមត្ថកិច្ច ចំពោះប្រព្រឹត្តកម្មទាំងឡាយ ដែលរំលោភសិទ្ធិជាមូលដ្ឋាន ដែលរដ្ឋធម្មនុញ្ញ ឬច្បាប់បានទទួលស្គាល់ដល់គេ រួចហើយ ។

**មាត្រា ១០:**

ជនណាក៏ដោយ ត្រូវមានសិទ្ធិស្មើៗគ្នាពេញលេញ ក្នុងការសុំឱ្យតុលាការ ឯករាជ្យ និងឥតលំអៀងមួយ ពិនិត្យពិច័យសេចក្តីឱ្យការណ៍របស់ខ្លួន ដោយគតិយុត្តិធម៌ និងជាសាធារណៈ ក្នុងការកំណត់សិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន ហើយនិងការចោទប្រកាន់ជាបទព្រហ្មទណ្ឌណាមួយ មកលើគេ ។

**មាត្រា ១១:**

១. ជនណាក៏ដោយ ដែលជាប់ចោទអំពីបទមជ្ឈឹម ត្រូវបានសន្មតថា ជាអ្នកឥតទោសពៃរ៍ រហូតដល់ពេលដែលតុលាការរកឃើញ ហើយផ្តន្ទាទោសតាមច្បាប់នៅក្នុងការជំនុំជំរះក្តីជាសាធារណៈមួយ ដោយមានការផ្តល់នូវការធានា ជាចាំបាច់គ្រប់យ៉ាង សំរាប់ការពារខ្លួនដល់អ្នកជាប់ចោទនោះ ។

២. គ្មានជនណាម្នាក់ ត្រូវគេកាត់ទោស ដោយសំអាងលើប្រព្រឹត្តិកម្ម ឬការភ្លេចភ្លាំងទាំងឡាយណា ដែលមិនមែនជាការប្រព្រឹត្តល្មើសខាងច្បាប់ព្រហ្មទណ្ឌឡើយ យោងទៅតាមច្បាប់ជាតិ ឬអន្តរជាតិ ក្នុងពេលដែលអំពើ និងការភ្លេចភ្លាំងទាំងនោះកើតឡើង ។ ដូចគ្នានេះដែរ មិនត្រូវដាក់ទោសទណ្ឌចំពោះបទល្មើសណាមួយ ឱ្យធ្ងន់ជាងទោស ដែលគេបានអនុវត្តនៅពេលដែលមានការប្រព្រឹត្តល្មើសនឹងច្បាប់ព្រហ្មទណ្ឌនោះឡើយ ។

**មាត្រា ១៩:**

មនុស្សគ្រប់រូប មានសិទ្ធិ និងសេរីភាពក្នុងការកាន់មតិ និងក្នុងការសំដែងគំនិត ឬវិញ្ញត្តិ ។ សិទ្ធិនេះ នឹងបណ្តាលឱ្យមានជាចាំបាច់នូវសេរីភាពក្នុងការប្រកាន់ និងពញ្ចេញមតិដោយគ្មានការជ្រៀតជ្រែក និងបារម្ភភិតភ័យ ដោយសារ មតិរបស់ខ្លួន និងសេរីភាពក្នុងការស្វែងរក ការទទួល និងការផ្សព្វផ្សាយទូទៅ ដោយឥតគិតព្រំដែនអ្វីឡើយ នូវព័ត៌មាន ព្រមទាំងគំនិតអ្វីផ្សេងៗ តាមមធ្យោបាយវិញ្ញត្តិបែបណាក៏ដោយ ។

**មាត្រា ២៩:**

១. បុគ្គលម្នាក់ៗមានករណីយកិច្ចចំពោះសហគមន៍ ដែលជាកន្លែងតែមួយគត់ ដែលអាចបង្កើតនូវការរីកចំរើន ពេញបរិបូរណ៍ និងដោយសេរី នូវបុគ្គលិកលក្ខណៈរបស់ខ្លួន។

២. ក្នុងការអនុវត្តន៍សិទ្ធិសេរីភាពរបស់ខ្លួន មនុស្សគ្រប់រូប ត្រូវស្ថិតក្នុងការកំណត់ទាំងឡាយណា ដែលច្បាប់បានកំណត់ក្នុងគោលបំណងឱ្យមានការទទួលស្គាល់ និងគោរពដល់សិទ្ធិ និងសេរីភាពទាំងឡាយរបស់អ្នកដទៃ និងដើម្បីឆ្លើយតបនឹងការតម្រូវយ៉ាងត្រឹមត្រូវអំពីសីលធម៌ របៀបរៀបរយសាធារណៈ និងនៃសុខុមាលភាពទូទៅ នៅក្នុងសង្គមប្រជាធិបតេយ្យតែប៉ុណ្ណោះ ។

៣. ក្នុងករណីណាក៏ដោយ សិទ្ធិ និងសេរីភាពទាំងនោះ មិនអាចយកទៅប្រើប្រាស់ផ្ទុយនឹងគោលការណ៍ របស់សហប្រជាជាតិឡើយ។

## កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៦៦)

### មាត្រា ២:

១. ភាគីនីមួយៗនៃកតិកាសញ្ញានេះ ត្រូវគោរពនិងធានាជូនប្រជាពលរដ្ឋគ្រប់ៗរូប ដែលនៅក្រោមអំណាចច្បាប់ គេគ្រប់គ្រង នូវសិទ្ធិទាំងឡាយដែលគេបានទទួលស្គាល់នៅក្នុងកតិការសញ្ញានេះ ដោយឥតប្រកាន់ភាពខុសគ្នារវាង ពូជសាសន៍ ពណ៌សំបុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិក្នុងវិស័យ ឯទៀតៗ ជាតិកំណើត វណ្ណៈ ឬឋានៈឡើយ ។

២. ចំពោះប្រការ ឬចំណុចណាដែលនីតិបញ្ញត្តិចាស់ពុំទាន់បានចូលជាធរមាន រដ្ឋនីមួយៗត្រូវតែជ្រើសរើសយក វិធានការណ៍ដ៏ចាំបាច់ស្របទៅតាមនីតិវិធីនៃរដ្ឋធម្មនុញ្ញរបស់ខ្លួន និងស្របទៅតាមបញ្ញត្តិទាំងឡាយ នៃកតិកាសញ្ញានេះ ដើម្បីចងក្រងឱ្យចេញជានីតិបញ្ញត្តិថ្មីៗ ដែលមានប្រសិទ្ធិភាពក្នុងការគោរពសិទ្ធិទាំងឡាយដែលគេបានចែងក្នុងកតិកាសញ្ញានេះ ។

៣. រដ្ឋជាភាគីនីមួយៗមានភារកិច្ចៈ

ក) ត្រូវធានាថា បើមានការរំលោភលើសិទ្ធិ ឬសេរីភាពរបស់ប្រជាជនណាម្នាក់ រដ្ឋមានភារកិច្ចរកវិធីដោះស្រាយបញ្ហានេះ ឱ្យបានស័ក្កសិទ្ធិ ទោះបីការរំលោភនេះ បានប្រព្រឹត្តឡើងដោយភ្នាក់ងារដែលបំពេញបេសកកម្មជាផ្លូវការក៏ដោយ ។

ខ) ត្រូវធានាថាជនរងគ្រោះដោយអំពើរំលោភលើសិទ្ធិ និងសេរីភាពត្រូវមានសិទ្ធិប្តឹងទាមទាររកយុត្តិធម៌ ។ ការរកយុត្តិធម៌ក្នុងករណីនេះ ត្រូវធ្វើឡើងដោយតុលាការមានសមត្ថកិច្ច ឬដោយអាជ្ញាធរនានាក្នុងផ្នែករដ្ឋបាល ឬផ្នែកច្បាប់ ឬដោយក្រសួងមានសមត្ថកិច្ចឯទៀត ដែលក្រសួងយុត្តិធម៌ បានចាត់តាំង ។

គ) ដើម្បីធានាយុត្តិធម៌ជូនប្រជារាស្ត្រ អាជ្ញាធរមានសមត្ថកិច្ច ត្រូវបំពេញបេសកកម្មឱ្យបានហ្មឺងម៉ាត់ ទៅតាមការចាត់តាំងរបស់ក្រសួង ។

### មាត្រា ៧:

គ្មានអ្នកណាម្នាក់ ត្រូវទទួលទារុណកម្ម ឬការធ្វើបាបយ៉ាងសាហាវឃោរឃៅ អមនុស្សធម៌ ឬយ៉ាងថោកទាបឡើយ ។ ជាពិសេស គ្មានអ្នកណាម្នាក់ ត្រូវគេយកទៅធ្វើការពិសោធន៍ខាងវេជ្ជសាស្ត្រ ឬវិទ្យាសាស្ត្រ ដោយគ្មានការយល់ព្រមដោយសេរីអំពីសាមីខ្លួនឡើយ ។

### មាត្រា ៩:

១. បុគ្គលគ្រប់រូបមានសិទ្ធិទទួលបាននូវសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន ។ គ្មានបុគ្គលណាម្នាក់ ត្រូវគេចាប់ចង ឬឃុំឃាំងតាមអំពើចិត្តបានឡើយ ។ គ្មានបុគ្គលណាម្នាក់ ត្រូវគេដកហូតសេរីភាពរបស់ខ្លួនបានឡើយ លើកលែងតែក្នុងណាដែលមានហេតុផល និងការអនុវត្តត្រឹមត្រូវតាមច្បាប់ ។

២. ជនដែលត្រូវគេចាប់ខ្លួន ត្រូវតែបានប្រាប់អំពីមូលហេតុនៃការចាប់ខ្លួន និងបទចោទចំពោះរូបគេឱ្យបានដឹងភ្លាមៗផងក្នុងរយៈពេលនៃការចាប់ខ្លួន ។

៣. ជនដែលត្រូវគេចាប់ខ្លួន ឬឃុំខ្លួនពីបទឧក្រិដ្ឋ ត្រូវតែបាននាំខ្លួនភ្លាមៗទៅជួបចៅក្រម ឬភ្នាក់ងារផ្សេងទៀតដែលច្បាប់អនុញ្ញាត ដើម្បីអនុវត្តនីអំណាច "ច្បាប់" តុលាការ ហើយជននោះ ត្រូវមានសិទ្ធិឱ្យ គេជំនុំជំរះទោសខ្លួនក្នុងរយៈពេលមួយដ៏សមគួរ ឬក៏ត្រូវដោះលែង ។ មិនត្រូវឱ្យមានបទបញ្ជាជាទូទៅ ណាមួយថាជនដែលរង់ចាំការជំនុំជំរះទោស ត្រូវតែដាក់ក្នុងមន្ទីរឃុំឃាំងនោះឡើយ ក៏ប៉ុន្តែការដោះលែងឱ្យនៅក្រៅឃុំ ត្រូវតែមានការធានារ៉ាប់រងថាជននោះនឹងបង្ហាញមុខសំរាប់ការជំនុំជំរះទោសតាមកាលកំណត់ណាមួយនៃនីតិវិធីរបស់តុលាការ និងត្រូវមានមុខអនុវត្តសេចក្តីសំរេច "សាលក្រម" របស់តុលាការ ។

៤. ជនដែលត្រូវគេដកហូតសេរីភាពដោយការចាប់ខ្លួន ឬឃុំខ្លួន ត្រូវតែមានសិទ្ធិឱ្យគេនាំខ្លួនទៅជំនុំជំរះទោសនៅចំពោះមុខតុលាការ ដើម្បីឱ្យតុលាការនោះអាចសំរេចដោយគ្មានការយឺតយ៉ាវ ទៅលើភាពស្របច្បាប់នៃការឃុំខ្លួនរបស់គេ ហើយតុលាការអាចចេញបញ្ជាឱ្យដោះលែង ប្រសិនបើការឃុំឃាំងនោះ មិនត្រឹមត្រូវតាមច្បាប់ ។

៥. ជនណាដែលបានរងគ្រោះដោយសារការចាប់ខ្លួន ឬឃុំខ្លួនមិនត្រឹមត្រូវតាមច្បាប់ ត្រូវមានសិទ្ធិពេញទី ក្នុងការប្តឹងទាមទារសំណងជំងឺចិត្ត (ប្តឹងទៅតុលាការអាជ្ញាធរ ដែលចាប់ចងនេះសងជម្ងឺចិត្ត) ។

**មាត្រា ១០:**

១. ជនដែលជាប់ឃុំឃាំង មានសិទ្ធិទាមទារឱ្យគេថែរក្សាខ្លួនឱ្យសមតាមបែបបទមនុស្សធម៌ និងឱ្យគេ គោរពសេចក្តីថ្លៃថ្នូររបស់ខ្លួន ដូចមនុស្សឯទៀតៗដែរ ។

២.ក) ក្រៅអំពីកាលៈទេសៈដ៏ចាំបាច់ខ្លះៗនោះ ជនជាប់ចោទត្រូវគេដាក់ឱ្យនៅដោយឡែកពីអ្នកទោសដែលតុលាការ បានកាត់ទោសរួចហើយ ។ ជនជំពូកនេះមានសិទ្ធិ ឱ្យគេថែរក្សាខ្លួនឱ្យសមស្រប ទៅតាមលក្ខណៈនៃមនុស្សដែលគ្មានទោស ។

ខ) ក្មេងអាយុក្រោម ១៨ ឆ្នាំ ដែលជាប់ចោទ ត្រូវគេដាក់ឱ្យនៅដោយឡែកពីមនុស្សពេញវ័យ ហើយត្រូវនាំយកទៅវិនិច្ឆ័យទោសឱ្យបានឆាប់បំផុតតាមលទ្ធភាពដែលអាចធ្វើទៅបាន ។

គ) ពន្ធនាគារ ត្រូវមានរបៀបគ្រប់គ្រងអ្នកទោស ដោយយោលទៅតាមគោលដៅសំខាន់ៗ ដូចជា ការកែទម្រង់ក្នុងវិស័យអត្តចរិត និងរបៀបរស់នៅក្នុងសង្គម ។ រីឯអ្នកទោសក្មេងៗវិញ ត្រូវដាក់ឱ្យនៅដោយឡែកពីមនុស្សពេញវ័យ ហើយត្រូវទទួលការគ្រប់គ្រងឱ្យសមស្របទៅតាមអាយុ និងស្ថានភាព ច្បាប់របស់ខ្លួន ។

**មាត្រា ១១:**

គ្មានជនណាម្នាក់ ត្រូវជាប់ពន្ធនាគារ "គុក" ដោយសារតែខ្លួនពុំអាចបំពេញតាមកាតព្វកិច្ចនៃកិច្ចសន្យា របស់ខ្លួនបានឡើយ ។

**មាត្រា ១៤:**

១. នៅចំពោះមុខតុលាការ ឬនៅក្នុងសាលាជំនុំជំរះក្តី មនុស្សគ្រប់រូបមានសិទ្ធិស្មើៗគ្នា ។ ក្នុងការសំរេចផ្តន្ទាទោសឧក្រិដ្ឋទៅលើជនណាម្នាក់ និងក្នុងការសំរេចអំពីសិទ្ធិ និងករណីយកិច្ច របស់ជនណាម្នាក់ ក្នុងករណីដែលមានការប្តឹងផ្តល់សាមីខ្លួន ត្រូវមានសិទ្ធិស្នើសុំឱ្យមានការកាត់សេចក្តីឱ្យបានសមរម្យជាសាធារណៈ ។ ការសំរេចក្តី នេះត្រូវរៀបចំ និងដឹកនាំដោយក្រុមជំរះក្តី ដែលតែងតាំងឡើងតាមលក្ខណៈច្បាប់ ។ ក្រុមជំរះក្តីនេះ ត្រូវមានសមត្ថភាពគ្រប់គ្រាន់ ប្រកបទៅដោយឯករាជភាពពេញលេញ ហើយមិនត្រូវមានការលំអៀងទៅខាងណាឡើយ ។ ក្រុមសារព័ត៌មាន និងសាធារណៈជន អាចត្រូវគេហាមឃាត់មិនឱ្យចូលស្តាប់ការកាត់ទោសនេះ ប្រសិនបើ គេយល់ថាអាចមានការទំនាស់ដល់សីលធម៌ របៀបរៀបរយសាធារណៈ ឬសន្តិសុខជាតិ នៅក្នុងសង្គមប្រជាធិបតេយ្យ ។ ម្យ៉ាងវិញទៀត ប្រសិនបើ គូភាគីនានា ពុំមានឆន្ទៈចង់ឱ្យដឹងឮដល់សាធារណជន ឬក្នុងកាលៈទេសៈណាដែលតុលាការយល់ឃើញ ថាការកាត់ទោសនៅចំពោះមុខសាធារណជន អាចបណ្តាលឱ្យមានការលំអៀងប្រាសចាកពីគោលជំហរ ដែលត្រឹមត្រូវក្នុងការរកយុត្តិធម៌នេះ គេក៏អាចចេញបញ្ញត្តិហាមឃាត់មិនឱ្យពួកកាសែត ឬសាធារណជន ចូលស្តាប់ដែរ ។ ប៉ុន្តែក្រោយពីការជុំនុំជំរះរួចសព្វគ្រប់ហើយ លទ្ធផលនៃការវិនិច្ឆ័យរបស់តុលាការ ទោះជាក្នុងប្រការនៃបទឧក្រិដ្ឋ ឬជាក្តីក្តាំធម្មតាក្តី នឹងត្រូវផ្សាយជាព័ត៌មានជូនសាធារណជន ។ ក្នុងករណីណាដែលមានការជំទាស់ ពីសំណាក់អ្នកទោសក្មេងៗ ការផ្សាយជាសាធារណៈនេះ អាចត្រូវហាមឃាត់បានដែរ ។ រីឯការវិនិច្ឆ័យទោសស្តីពីជម្លោះក្នុងរឿងអាពាហ៍ពិពាហ៍ ជម្លោះរឿងប្តីប្រពន្ធ ឬជម្លោះក្នុងរឿងដណ្តើមកូនចៅ ការផ្សាយជាសាធារណៈ ត្រូវហាមជាដាច់ខាត។

២. តាមក្របខ័ណ្ឌច្បាប់ ជនជាប់ចោទពីបទឧក្រិដ្ឋត្រូវគេចាត់ទុកថាជាជនគ្មានកំហុស ដរាបណាបើគ្មាន ភស្តុតាងគ្រប់គ្រាន់ (ពេលណាគេរកឃើញភស្តុតាងគ្រប់គ្រាន់អំពីអំពើឧក្រិដ្ឋនេះ ទើបគេអាចដាក់កំហុសជនជាប់ចោទនេះបាន) ។

៣. ក្នុងករណីនៃការសំរេចវិនិច្ឆ័យទោសឧក្រិដ្ឋ ជនជាប់ចោទគ្រប់ៗរូប មានសិទ្ធិស្មើៗគ្នាក្នុងការទទួលនូវកិច្ចធានាខ្លះៗដូចជា:

ក) ការប្រាប់ឱ្យដឹងខ្លួនភ្លាមពីលក្ខណៈ និងហេតុផលនៃការផ្តន្ទាទោសនេះ ហើយគេត្រូវនិយាយភាសា ដែលសាមីខ្លួនអាចស្តាប់បានគ្រប់គ្រាន់ ។

ខ) សាមីខ្លួនត្រូវមានពេលវេលា ព្រមទាំងសម្ភារៈគ្រប់គ្រាន់ ក្នុងការការពារខ្លួននៅចំពោះមុខច្បាប់ ឧទាហរណ៍ដូចជាការស្រាវជ្រាវរកស្មាក្តី ( អ្នកចេះដឹងខាងច្បាប់) ឱ្យធ្វើជាតំណាងខ្លួនជាដើម ។

គ) ការជំនុំជំរះកាត់ទោសត្រូវធ្វើភ្លាមដោយឥតពន្យាពេលយូរ ។

ឃ) ការជំនុំជំរះកាត់ទោស ត្រូវធ្វើនៅចំពោះមុខសាមីជន ។ សាមីជន អាចឆ្លើយដោះសារដើម្បីការពារខ្លួនដោយខ្លួនឯង ឬអាចរកស្មាក្តីឱ្យជួយការពារ ។ សាមីជន មានសិទ្ធិរើសស្មាក្តីដោយខ្លួនឯង ប្រសិនបើខ្លួនមានប្រាក់គ្រប់គ្រាន់សំរាប់បង់ថ្លៃឈ្នួល ។ ក្នុងករណីណាដែលចាំបាច់ តុលាការត្រូវតែងតាំងឱ្យស្មាក្តី ឱ្យតំណាងជនជាប់ចោទ ដោយឥតគិតឈ្នួល ប្រសិនបើ សាមីជននេះ គ្មានមធ្យោបាយ ឬប្រាក់កាសគ្រាប់គ្រាន់ ។

ង) លទ្ធភាពអាចពិនិត្យនិងសាកសួរដេញដោលទៅលើសាក្សីខាងគូបដិបក្ខ ។ សិទ្ធិស្នើសុំឱ្យមានសាក្សី ដើម្បីជួយឆ្លើយការពារខ្លួន ។ សាក្សីទាំងសង្ខាងគឺសាក្សីប្រឆាំង និងសាក្សីការពារ ត្រូវស្ថិតនៅក្នុងលក្ខខណ្ឌច្បាប់ស្មើគ្នា ។

ច) ត្រូវមានអ្នកបកប្រែភាសា សំរាប់ជួយដោយឥតគិតឈ្នួល ប្រសិនបើសាមីជនមិនចេះស្តាប់ភាសា ដែលប្រើក្នុងការកាត់ក្តីនេះ ។

ឆ) សិទ្ធិមិនឱ្យនរណាបង្ខិតបង្ខំឱ្យឆ្លើយដាក់កំហុសលើខ្លួនឯង ឬទទួលសារភាពនូវកំហុសដែលមិនត្រឹមត្រូវ ។

៤. ចំពោះអ្នកទោសក្មេងៗវិញ ការវិនិច្ឆ័យទោសត្រូវយោលទៅលើអាយុរបស់សាមីជន ហើយត្រូវផ្អែកទៅលើគោលដៅនៃការអប់រំកសាងខ្លួនសាមីជនឱ្យបានប្រពៃឡើង ។

៥. ជនដែលត្រូវគេផ្តន្ទាទោសក្នុងបទឧក្រិដ្ឋមានសិទ្ធិស្នើសុំទៅតុលាការថ្នាក់លើ ឱ្យសើរើ ពិនិត្យ ការវិនិច្ឆ័យទោសនេះសាជាថ្មី ។

៦. ជនណាម្នាក់ដែលត្រូវគេសំរេចផ្តន្ទាទោសជាបទឧក្រិដ្ឋរួចទៅហើយ ប៉ុន្តែស្រាប់តែត្រូវគេលើកលែងទោសឱ្យវិញ ដោយហេតុថាគេទើបតែរកឃើញភស្តុតាងថ្មីមួយ ដែលបញ្ជាក់ឱ្យឃើញថាការផ្តន្ទាទោសនោះ ពុំបានត្រឹមត្រូវដោយគតិយុត្តិធម៌ទេ ជនរងគ្រោះដោយអគតិយុត្តិធម៌នេះ មានសិទ្ធិប្តឹងទាមទារជម្ងឺចិត្តតាមលក្ខណៈច្បាប់ ។ ប្រសិនបើ មូលហេតុនៃការកាត់ទោស មិនត្រឹមត្រូវនេះ បណ្តាលមកអំពីការខំលាក់លៀមភស្តុតាងពីសំណាក់ជនជាប់ចោទវិញនោះ ការប្តឹងទាមទារជម្ងឺចិត្ត ចំពោះករណីដូចចែងខាងលើ នឹងត្រូវទុកជាមោឃៈ ។

៧. យោលទៅតាមទម្រង់ការច្បាប់ព្រហ្មទណ្ឌនៃប្រទេសនិមួយៗ គេមិនអាចយកជនណាម្នាក់ទៅ កាត់ទោសសារជាថ្មី ចំពោះបទល្មើសដែលសាមីជនបានទទួលទណ្ឌកម្ម ឬបានទទួលការលើកលែងទោស រួចទៅហើយទេ ។

**មាត្រា ១៥:**

១. គ្មានជនណាម្នាក់ ត្រូវជាប់ទោសពីបទល្មើសព្រហ្មទណ្ឌឡើយ ចំពោះអំពើ ឬការធ្វេសប្រហែសណាមួយដែលពុំមែនជាបទល្មើសព្រហ្មទណ្ឌ ដែលមាននៅក្រោមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ នៅខណៈពេលដែលអំពើនោះបានប្រព្រឹត្ត ។ ហើយក៏មិនត្រូវឱ្យមានការដាក់ទោសណាមួយឱ្យធ្ងន់ជាងទោស ដែលបានដាក់កាលពីបទល្មើសព្រហ្មទណ្ឌនោះបានប្រព្រឹត្តឡើយ ។ ប្រសិនបើ ក្រោយពីការប្រព្រឹត្តបទល្មើស ហើយច្បាប់បានបញ្ញត្តិឱ្យមានការដាក់ទោសស្រាលជាងមុន ជនល្មើសត្រូវតែបានទទួលប្រយោជន៍នោះ ។

២. នៅក្នុងមាត្រានេះ ពុំមានចំណុចណាមួយនឹងធ្វើឱ្យការជំនុំជំរះ និងការផ្តន្ទាទោសដល់ជនណាមួយ មានភាពលំអៀងប្រាស់ចាកភាពយុត្តិធម៌ចំពោះអំពើ ឬការធ្វេសប្រហែសណាមួយ ដែលនៅក្នុងពេលប្រព្រឹត្តនោះ វាជាបទព្រហ្មទណ្ឌដោយយោងតាមគោលការណ៍ច្បាប់ជាទូទៅ ដែលសហគមន៍ជាតិនានាបានទទួលស្គាល់ឡើយ ។

**មាត្រា ១៩:**

១. ជនគ្រប់រូបមានសិទ្ធិប្រកាន់យកមតិយោបល់ដោយគ្មានការជ្រៀតជ្រែក " ដោយសេរី " ។

២. ជនគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការបញ្ចេញយោបល់ ។ សិទ្ធិនេះ ត្រូវរាប់ទាំងសេរីភាពក្នុងការស្វែងរក ព័ត៌មានទទួលពតិមាន និងផ្សព្វផ្សាយពតិមាន និងគំនិតសព្វបែបយ៉ាង ដោយមិនគិតពីព្រំដែនឡើយ ទាំងតាម ផ្ទាល់មាត់ក្តី, តាមការសរសេរ ឬបោះពុម្ពក្តី, តាមទំរង់សិល្បៈក្តី ឬតាមរយៈចរន្តផ្សាយពតិមានដទៃៗទៀតក្តី ។

៣. ការអនុវត្តន៍សិទ្ធិដែលបានចែងក្នុងវគ្គទី ២ ខាងលើនេះ ត្រូវប្រទះនិងការទទួលខុសត្រូវនិង កាតព្វកិច្ចខ្លះៗ ។ ជួនកាលវាអាចជួបប្រទះ និងការកំរិតលក្ខខណ្ឌ និងបទបញ្ជាផ្សេងៗ ដែលច្បាប់បានបញ្ញត្តិ ជាចាំបាច់ដើម្បីៈ

ក) គោរពសិទ្ធិ និងកិត្តិនាមអ្នកដទៃ

ខ) ការពារសន្តិសុខជាតិ របៀបរៀបរយសាធារណៈ ព្រមទាំងសុខុមាលភាព និងសីលធម៌សាធារណៈ ។

**មាត្រា ២៦ៈ**

នៅចំពោះមុខច្បាប់ មនុស្សគ្រប់ៗរូបមានសិទ្ធិស្មើៗគ្នា ហើយក៏មានសិទ្ធិទទួលកិច្ចការពារអំពីច្បាប់ យ៉ាងស្មើគ្នាដោយឥតប្រកាន់ពូជសាសន៍ ឬពិណសំបុរឡើយ ។ ក្នុងករណីនេះ ច្បាប់ហាមមិនឱ្យមានការប្រកាន់ពូជសាសន៍ ហើយច្បាប់ធានាជូនបុគ្គលគ្រប់រូបនូវបញ្ញត្តិ ការពារយ៉ាងស័ក្តិសិទ្ធិ កុំឱ្យមាន ការប្រកាន់ទៅលើពូជសាសន៍ ពិណសំបុរ ភេទ សាសនា ភាសា ជំហរនយោបាយ មតិនានា កំណើតជាតិ ឬសង្គម ឋានៈ វណ្ណៈ ឬអ្វីផ្សេងៗទៀតឡើយ ។

## **អនុសញ្ញាប្រឆាំងនឹងទារុណកម្ម** (ថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ១៩៨៤)

**មាត្រា ៤ៈ**

១. រដ្ឋជាភាគីនីមួយៗត្រូវធានាថា អំពើទារុណកម្មទាំងអស់ គឺជាអំពើផ្ទុយច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន។ ចំពោះការប៉ុនប៉ងធ្វើទារុណកម្ម និងអំពើរបស់បុគ្គលណាដែលបានចាត់ទុកជាការសមគំនិត ឬការចូលរួមក្នុងការធ្វើទារុណកម្ម ក៏ត្រូវចាត់ទុកថាជាការខុសច្បាប់ដែរ ។

២. រដ្ឋជាភាគីនីមួយៗត្រូវផ្តន្ទាទោសអំពើខុសច្បាប់ទាំងនេះ តាមបញ្ញត្តិសមស្របទៅតាមទម្ងន់ទោសរបស់ខ្លួន ។

**មាត្រា ៥ៈ**

១. បើសិនជាមានការចាំបាច់ក្នុងការចាត់តាំងនូវដែនអំណាចច្បាប់របស់ខ្លួន ទៅលើអំពើខុសច្បាប់ ទាំងឡាយដែលមានចែងនៅក្នុងមាត្រា ៤ រដ្ឋជាគូភាគីនីមួយៗត្រូវប្រកាន់យកវិធានការតាមបែប ដូចខាងក្រោមនេះៈ

ក) នៅពេលណាដែលអំពើខុសច្បាប់ ត្រូវបានប្រព្រឹត្តឡើងនៅលើទីកន្លែងណាមួយនៃទឹកដីដែល ស្ថិតនៅក្រោមអំណាចច្បាប់របស់ខ្លួន ឬនៅលើនាវា ឬយន្តហោះដែលបានចុះបញ្ជីការ នៅក្នុងរដ្ឋនោះ...

ខ) នៅពេលណាដែលជនជាប់ចោទ (ថាបានប្រព្រឹត្តខុសច្បាប់) មានសញ្ជាតិជាពលរដ្ឋរបស់ប្រទេសនោះ ...

គ) ពេលណាដែលអ្នករងគ្រោះមានសញ្ជាតិជាពលរដ្ឋរបស់ប្រទេសនោះ និងពេលណាដែលប្រទេស នោះយល់ឃើញថាជាការសមស្រប ។

២. រដ្ឋជាភាគីនីមួយៗត្រូវប្រកាន់យកផងដែរនូវវិធានការបែបនេះ បើសិនជាចាំបាច់ ដើម្បីចាត់តាំងនូវដែនអំណាចច្បាប់របស់ខ្លួនទៅលើអំពើខុសច្បាប់បែបនេះ នៅក្នុងករណីដែលជនជាប់ចោទ (ថាបាន ប្រព្រឹត្តអំពើខុសច្បាប់) នោះ ស្ថិតនៅក្នុង (ទីកន្លែងណាមួយនៃ) ទឹកដីដែលនៅក្រោមអំណាចច្បាប់របស់ខ្លួន ហើយដោយអនុលោមតាមមាត្រា ៨ រដ្ឋមិនចាប់បញ្ជូនជននោះចេញពីប្រទេស អោយទៅ ប្រទេស ដែលមានចែងនៅក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះឡើយ ។

៣. អនុសញ្ញានេះមិនផាត់ចេញនូវបញ្ញត្តិព្រហ្មទណ្ឌទាំងឡាយ ដែលគេអនុវត្តតាមលំនាំច្បាប់ក្នុង ប្រទេសនោះឡើយ ។

**មាត្រា ៦ៈ**

១. ក្រោយពីបានពិនិត្យព័ត៌មានដែលមាន ហើយបានឃើញថាស្ថានភាពទាំងឡាយ មានការអះអាង បញ្ជាក់គ្រប់គ្រាន់ហើយ រដ្ឋជាភាគីទាំងឡាយណា ដែលមានជនដែលត្រូវគេចោទថាបានប្រព្រឹត្តនូវ អំពើខុសច្បាប់ ដូចមានចែងនៅក្នុងមាត្រា ៤ ត្រូវនាំមនុស្សនោះទៅឃុំខ្លួន ឬក៏ត្រូវចាត់វិធានការផ្លូវច្បាប់ផ្សេងទៀត ដើម្បីធានាវត្តមានរបស់មនុស្សនេះ (គឺកុំឱ្យជននេះរត់គេចខ្លួនបាត់)។ ការឃាត់ខ្លួន និងរាល់វិធានការផ្លូវច្បាប់ផ្សេងទៀត ត្រូវអនុវត្តតាមច្បាប់របស់ប្រទេសនោះ ប៉ុន្តែអាចធ្វើយ៉ាងនេះបាន តែក្នុងមួយរយៈពេលណាដែលចាំបាច់សំរាប់រៀបចំនីតិវិធីព្រហ្មទណ្ឌ ឬនីតិវិធីដើម្បីបញ្ជូនជននេះចេញក្រៅប្រទេស តែប៉ុណ្ណោះ ។

២. រដ្ឋ (ដែលមានកើតហេតុ) នេះ ត្រូវចាត់ចែងជាបន្ទាន់ឱ្យមានការស៊ើបអង្កេតការណ៍ជាបឋម មួយភ្លាម ។
៣. បុគ្គលណាដែលត្រូវបានជាប់ឃុំតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ នឹងត្រូវបានទទួលកិច្ចឧបត្ថម្ភជាបន្ទាន់ ក្នុងការទាក់ទងជាមួយតំណាងដ៏សមស្របនៃប្រទេសដែលខ្លួនមានសញ្ជាតិ ហើយដែលនៅទីជិតជាងគេបំផុត ឬបើសិនជាបុគ្គលនោះជាមនុស្សអត់សញ្ជាតិ (ត្រូវទាក់ទង) ជាមួយតំណាង នៃប្រទេសណាដែលខ្លួនតែងតែស្នាក់នៅ ។
៤. នៅពេលដែលរដ្ឋមួយបានឃាត់ខ្លួនបុគ្គលណាម្នាក់ ដោយអនុលោមទៅតាមមាត្រានេះ រដ្ឋនោះត្រូវជូនដំណឹងជាលាយល័ក្ខអក្សរភ្លាមទៅដល់រដ្ឋទាំងឡាយ ដែលមានចែងនៅក្នុងមាត្រា ៥ កថាខ័ណ្ឌ ១ ស្តីពីការដែលបុគ្គលនោះ ត្រូវឃាត់ខ្លួន ហើយនឹងស្តីពីហេតុផលដែលនាំឱ្យមានការឃាត់ខ្លួន។ រដ្ឋដែលបានចាត់ចែងការអង្កេតជាបឋម ដូចមានលើកឡើងនៅក្នុងកថាខ័ណ្ឌ ២ នៃមាត្រានេះ ត្រូវធ្វើរបាយការណ៍ជាបន្ទាន់ជូនដល់រដ្ឋទាំងឡាយដែលបានចែងមកនេះ ស្តីពីការរកឃើញរបស់ខ្លួន ហើយត្រូវបញ្ជាក់ថាតើខ្លួនចង់ប្រើអំណាចច្បាប់របស់ខ្លួន ឬមិនចង់ ។

**មាត្រា ៧:**

១. រដ្ឋជាភាគីណាដែលបានរកឃើញជនជាប់ចោទ (ថាបានប្រព្រឹត្តអំពើខុសច្បាប់ណាមួយ) ដូចមានចែងនៅក្នុងមាត្រា ៤ នៅក្នុងទឹកដី (ដែលស្ថិតនៅ) ក្រោមអំណាចច្បាប់របស់ខ្លួននោះ ហើយតាមករណីក្នុងមាត្រា ៥ បើសិនជា (រដ្ឋនេះ) មិនចាប់បញ្ជូនមនុស្សនោះចេញពីប្រទេសខ្លួនទេ (រដ្ឋនេះ) ត្រូវតែបញ្ជូនករណីនេះទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីធ្វើការចោទប្រកាន់ (តាមច្បាប់)។
២. អាជ្ញាធរទាំងនេះត្រូវធ្វើសេចក្តីសំរេចដូចគ្នាទៅនឹងរបៀបដែលខ្លួនបានប្រកាន់យក នៅក្នុងករណីនៃអំពើខុសច្បាប់ដ៏ធ្ងន់ធ្ងរ ដែលតែងតែកើតមានជាធម្មតានៅក្នុងច្បាប់នៃប្រទេសនោះ។ នៅក្នុងករណីទាំងឡាយដែលមាត្រា ៥ កថាខ័ណ្ឌ ២ បានលើកឡើងនោះ កំរិតនៃភស្តុតាងដែលចាំបាច់ដើម្បីឱ្យមានការចោទប្រកាន់ និងការផ្តន្ទាទោសនោះ មិនត្រូវឱ្យមានភាពតឹងរឹងតិចជាងកំរិតដែលគេតម្រូវនៅក្នុង ដែលមាត្រា ៥ កថាខ័ណ្ឌ ១ បានលើកឡើងនោះទេ។
៣. បុគ្គលទាំងឡាយណាដែលជាប់ចោទដោយអំពើខុសច្បាប់ណាមួយ ដែលមានចែងនៅក្នុងមាត្រា ៤ នេះ នឹងត្រូវមានការធានាថា នឹងទទួលបាននូវការពិនិត្យដោះស្រាយដោយយុត្តិធម៌ នៅគ្រប់ដំណាក់កាលនៃការជំនុំជំរះ ។

**មាត្រា ៨:**

១. អំពើខុសច្បាប់ដែលមានចែងនៅក្នុងមាត្រា ៤ ត្រូវចាត់ជាអំពើខុសច្បាប់ដែលអាចចាប់បញ្ជូន ចេញក្រៅប្រទេសបាន ហើយដែលអាចបញ្ចូលទៅក្នុងសន្ធិសញ្ញា (ស្តីពីការចាប់បញ្ជូនចេញក្រៅប្រទេស) ដែលមានរវាងរដ្ឋជាភាគីទាំងឡាយរួចមកហើយនោះ។ រដ្ឋជាភាគីទាំងឡាយសន្យាថា នឹងបញ្ចូលអំពើខុសច្បាប់ទាំងនេះ ដោយទុកជាអំពើខុសច្បាប់ដែលអាចចាប់បញ្ជូនចេញក្រៅប្រទេសបាន ទៅក្នុងរាល់សន្ធិសញ្ញាស្តីពីការចាប់បញ្ជូនចេញក្រៅប្រទេស ដែលរដ្ឋទាំងនេះនឹងព្រមព្រៀងជាមួយគ្នា។
២. បើសិនជារដ្ឋជាភាគីបានកំណត់ថា ការចាប់បញ្ជូនចេញក្រៅប្រទេស ត្រូវឈរលើមូលដ្ឋាននៃសន្ធិសញ្ញានោះហើយ (រដ្ឋនេះ) បានទទួលសំណូមពរពីរដ្ឋជាភាគីមួយទៀតដែលខ្លួនមិនមានសន្ធិសញ្ញា (ស្តីពីការចាប់បញ្ជូនចេញក្រៅប្រទេស) ជាមួយនោះ រដ្ឋនោះអាចចាត់អនុសញ្ញានេះ ជាមូលដ្ឋានច្បាប់ដើម្បីចាប់បញ្ជូនចេញក្រៅប្រទេសនូវអំពើខុសច្បាប់ប្រភេទនេះ។ ការចាប់បញ្ជូនចេញ ក៏ត្រូវគោរពតាមលក្ខខណ្ឌនានារបស់ច្បាប់នៃរដ្ឋដែលបានទទួលសំណូមពរនោះផងដែរ ។
៣. រដ្ឋជាភាគីទាំងឡាយណាដែលមិនយក (អត្ថិភាពនៃ) សន្ធិសញ្ញានេះធ្វើជាលក្ខខណ្ឌ នៃការចាប់បញ្ជូនចេញក្រៅប្រទេសទេនោះ ត្រូវទទួលស្គាល់ថាអំពើខុសច្បាប់ប្រភេទនេះ ជាអំពើខុសច្បាប់ដែលអាចចាប់បញ្ជូនចេញក្រៅប្រទេសបាន ដោយគោរពតាមលក្ខខណ្ឌនានានៃច្បាប់របស់រដ្ឋដែលបានទទួលសំណូមពរនោះផងដែរ ។
៤. ដើម្បីបំរើទិសដៅច្បាប់ រវាងរដ្ឋជាភាគីទាំងឡាយស្តីពីការចាប់បញ្ជូនចេញក្រៅប្រទេស ដោយគោរព អំពើខុសច្បាប់ប្រភេទនេះមិនគ្រាន់តែចាត់ទុកថាត្រូវបានប្រព្រឹត្តឡើងនៅលើទីកន្លែង ដែលមាន កើតហេតុប៉ុណ្ណោះទេ ប៉ុន្តែត្រូវចាត់ទុកថាដូចជាបានប្រព្រឹត្តទៅលើទឹកដីនៃប្រទេស ដែលត្រូវចាត់តាំងដែនអំណាចច្បាប់របស់ខ្លួនតាមលំនាំមាត្រា ៥ កថាខ័ណ្ឌ ១ ផងដែរ។

**មាត្រា ៩:**

១. រដ្ឋជាភាគីទាំងឡាយត្រូវផ្តល់ឱ្យគ្នាទៅវិញទៅមក នូវវិធានការជួយឧបត្ថម្ភឱ្យបានធំធេងបំផុត ក្នុងការចោទប្រកាន់ទោសព្រហ្មទណ្ឌ ដែលទាក់ទិនទៅនឹងអំពើខុសច្បាប់ណាមួយ ដូចមានចែងនៅក្នុងមាត្រា ៤ ដោយរួមទាំងការផ្តល់ឱ្យនូវភស្តុតាងចាំបាច់ទាំងអស់ ដែលខ្លួនមានសំរាប់ជាប្រយោជន៍ដល់ការចោទប្រកាន់ទោសនេះ។

២. រដ្ឋជាភាគីទាំងឡាយ ត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ ឱ្យបានសមស្របទៅនឹងសន្ធិសញ្ញាទាំងឡាយ ស្តីពីការជួយឧបត្ថម្ភគ្នាទៅវិញទៅមកខាងវិស័យតុលាការ ដែលអាចកើតមានរវាងគ្នានឹងគ្នានោះ ។

## សេចក្តីថ្លែងការណ៍ក្រុងប៉េកាំង (ថ្ងៃទី ១៩ ខែសីហា ឆ្នាំ ១៩៩៥)

**មាត្រា ២:**

សេចក្តីប្រកាសជាសលកស្តីពីសិទ្ធិមនុស្ស (មាត្រា ១០) និងកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (មាត្រា ១៤ I) ប្រកាសថា ជនគ្រប់រូប គួរតែមានសិទ្ធិទទួលបាននូវសវនាការមួយដែលយុត្តិធម៌ និងជាសាធារណៈ ដែលដំណើរការដោយតុលាការមួយ មានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង និងត្រូវបង្កើតឡើងដោយច្បាប់ ។

**មាត្រា ៨:**

ដើម្បីពង្រីក និងពង្រឹង ករណីយកិច្ច របស់ខ្លួន ក្នុងនាមជាសមាជិកនៃវិស័យតុលាការ ចៅក្រម ក៏ដូចជាប្រជាពលរដ្ឋដទៃទៀតដែរ មានសិទ្ធិទទួលបាននូវសេរីភាពក្នុងការបញ្ចេញមតិ ខាងជំនឿ ក្នុងការបង្កើតសមាគម និងក្នុងការជួបប្រជុំ ។

**មាត្រា ១៣:**

នៅក្នុងការជ្រើសរើសចៅក្រម មិនត្រូវមានការរើសអើងនឹងមនុស្ស ដោយប្រកាន់ជាតិសាសន៍ ពណ៌សំបុរ ភេទ សាសនា គំនិតនយោបាយ ឬគំនិតផ្សេងទៀត ជាតិកំណើត ឬដើមកំណើតសង្គម ស្ថានភាពផ្ទាល់ខ្លួន ទំនោរ ភេទ ទ្រព្យសម្បត្តិកំណើត ឬស្ថានភាព លើកលែងតែថា វាជាតំរូវការមួយ ដែលថាបេក្ខជនម្នាក់សំរាប់មុខងារក្នុងវិស័យតុលាការ ត្រូវតែជាជនជាតិដើមនៃប្រទេសនោះ តំរូវការនោះមិនត្រូវបានចាត់ទុកថាមានលក្ខណៈរើសអើងទេ ។

## គោលការណ៍ជាមូលដ្ឋានស្តីពី តួនាទីរបស់មេធាវី (ឆ្នាំ១៩៩០)

**មាត្រា ៣:**

រដ្ឋាភិបាល ត្រូវធានាឱ្យមានការផ្តល់នូវថវិកាគ្រប់គ្រាន់ និងធនធានដទៃទៀត នៃសេវាផ្នែកច្បាប់ ដល់ជនក្រីក្រ និងក្នុងករណីចាំបាច់ ឱ្យដល់អ្នកដែលទន់ខ្សោយ ។ សមាគមវិជ្ជាជីវៈមេធាវី ត្រូវសហការចំពោះការរៀបចំ និងផ្តល់សេវាមធ្យោបាយ និងធនធានដទៃទៀត ។

**មាត្រា ២២:**

រដ្ឋាភិបាលត្រូវទទួលស្គាល់ និងគោរពថា រាល់ការប្រាស្រ័យទាក់ទង និងការពិគ្រោះយោបល់រវាងមេធាវី និងកូនក្តីរបស់ពួកគេ នៅក្នុងទំនាក់ទំនងវិជ្ជាជីវៈ របស់ពួកគេគឺជាការសំងាត់ ។

## ២) ច្បាប់ និងបទបញ្ញត្តិកម្ពុជា

### រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ ១៩៩៣)

**មាត្រា ៣១៖**

ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ នៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស សិទ្ធិនារី និងកតិកាសញ្ញា ព្រមទាំង អនុសញ្ញាទាំងឡាយ ទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។

ប្រជាពលរដ្ឋខ្មែរ មានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥត ប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួន របស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃ ឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌកំណត់ក្នុងច្បាប់ ។

**មាត្រា ៣២៖**

ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន ។

ទោសប្រហារជីវិត មិនត្រូវឱ្យមាន ឡើយ ។

**មាត្រា ៣៤៖**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ឆ្នាំ មានសិទ្ធិបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរ ទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំង ជាតំណាងរាស្ត្រ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ៤០ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិក ព្រឹទ្ធសភា ។

បទបញ្ញត្តិបន្ថយ សិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត ត្រូវចែងក្នុងច្បាប់ បោះឆ្នោត ។

**មាត្រា ៣៨៖**

ច្បាប់រ៉ាប់រង មិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ ។

ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវ តាមបញ្ញត្តិច្បាប់ ។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តកម្មណាមួយ ដែលបន្ថែមទម្ងន់ទណ្ឌកម្មអនុវត្តចំពោះ ជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនអោយធ្វើឡើយ ។ អ្នកដៃដល់ អ្នករួមប្រព្រឹត្ត និងអ្នកផ្សំគំនិត ត្រូវទទួលទោសតាមច្បាប់ ។

ការទទួលសារភាព ដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃ ពិរុទ្ធភាពទេ ។

វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

ជនគ្រប់រូប មានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។

**មាត្រា ៣៩:**

ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាត ជាសមត្ថកិច្ចរបស់តុលាការ ។

**មាត្រា ៤១:**

ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយ មិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសអ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់ សាធារណៈ និងសន្តិសុខជាតិបានឡើយ ។

របបសារព័ត៌មាន ត្រូវរៀបចំឡើងដោយច្បាប់ ។

**មាត្រា ៤៥:**

ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទ ត្រូវបំបាត់ចោល ។

ការធ្វើអាជីវកម្មលើការងាររបស់ស្ត្រីត្រូវហាមឃាត់ ។

បុរស និងស្ត្រី មានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ ។

អាពាហ៍ពិពាហ៍ត្រូវធ្វើតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយប្រពន្ធ មួយ ។

**មាត្រា ៥១:**

ព្រះរាជាណាចក្រកម្ពុជា អនុវត្តរបបនយោបាយ ប្រជាធិបតេយ្យ សេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនា នៃប្រទេសជាតិខ្លួន ។

អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួន តាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី ។

អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។

**មាត្រា ៨២:**

រដ្ឋសភាបើកសម័យប្រជុំដំបូង ៦០ថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។ មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង សំរេចអំពីសុពលភាព នៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើស ដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានរដ្ឋសភា និងសមាជិកទាំងអស់ នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើន ពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

តំណាងរាស្ត្រទាំងអស់ ត្រូវធ្វើសច្ចាប្រណិធាន មុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធ៥ ។

**មាត្រា ៩២:**

ការអនុម័តទាំងឡាយរបស់រដ្ឋសភា ដែលផ្ទុយនឹងគោលការណ៍រក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំអោយប៉ះពាល់ដល់ ឯកភាពនយោបាយ ឬការគ្រប់គ្រងរដ្ឋបាល របស់ប្រទេសជាតិ នឹងត្រូវចាត់ទុកជាអាសាសូន្យ ។

ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ ជាអង្គការតែមួយគត់ ដែលមានសមត្ថកិច្ចសំរេចពីមោឃភាពនេះ ។

**មាត្រា ១២៦:**

សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាល ត្រូវទទួលទណ្ឌកម្ម ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលខ្លួនបានប្រព្រឹត្ត ក្នុងការបំពេញការងាររបស់ខ្លួន ។

ក្នុងករណីនេះ និងក្នុងករណីធ្វើខុសជាទម្ងន់ ក្នុងការបំពេញការងាររបស់ខ្លួន រដ្ឋសភាអាចសំរេចប្តឹងទៅតុលាការមានសមត្ថកិច្ច ។

រដ្ឋសភាសំរេចក្នុងរឿងនេះ ដោយវិធីបោះឆ្នោតជាសំងាត់ តាមមតិភាគច្រើនដាច់ខាត នៃសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ១២៨:**

អំណាចតុលាការជាអំណាចឯករាជ្យ ។

អំណាចតុលាការ ធានារក្សាអនាគត និងការពារសិទ្ធិសេរីភាព របស់ប្រជាពលរដ្ឋ ។

អំណាចតុលាការ គ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ។

អំណាចនេះ ត្រូវប្រគល់អោយតុលាការកំពូល និងសាលាជំរះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ ។

**មាត្រា ១២៩:**

ការជំរះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន ។

មានតែចៅក្រមទេ ដែលមានសិទ្ធិជំរះក្តី ។ ចៅក្រមត្រូវបំពេញភារកិច្ចនេះ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន ។

**មាត្រា ១៣០:**

គ្មានអង្គការណាមួយ នៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិ អាចទទួលអំណាចតុលាការ អ្វីបានឡើយ ។

**មាត្រា ១៣១:**

មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ។

**មាត្រា ១៣២:**

ព្រះមហាក្សត្រ ទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ ។

**មាត្រា ១៣៣:**

ចៅក្រមមិនអាច ត្រូវគេដកពីមុខងារបានទេ ។ ប៉ុន្តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សំរេចដាក់វិន័យលើចៅក្រមដែលបានប្រព្រឹត្តខុស ។

**មាត្រា ១៣៤:**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នឹងត្រូវបង្កើតដោយច្បាប់រៀបចំអង្គការមួយ ដែលនឹងកំណត់សមាសភាព និងមុខងារ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ស្ថិតក្រោមព្រះរាជាធិបតីភាព នៃព្រះមហាក្សត្រ ។ ព្រះមហាក្សត្រ ព្រះអង្គទ្រង់អាចចាត់តាំងព្រះរាជតំណាងម្នាក់ របស់ព្រះអង្គ អោយធ្វើជាអធិតី នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រមនេះ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រ អំពីការតែងតាំងអង្គចៅក្រម និងព្រះរាជអាជ្ញាអមសាលាជំរះក្តីទាំងអស់ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងមុខការដាក់វិន័យចំពោះចៅក្រម និងព្រះរាជអាជ្ញា ត្រូវប្រជុំ ក្រោមអធិបតីនៃប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អាស្រ័យដោយករណីទាក់ទងនឹងចៅក្រម ឬព្រះរាជអាជ្ញា ។

**មាត្រា ១៣៥:**

លក្ខន្តិកៈនៃអង្គចៅក្រម និងព្រះរាជអាជ្ញា និងការរៀបចំអង្គការតុលាការ នឹងត្រូវកំណត់ក្នុងច្បាប់ដោយឡែកពីគ្នា។

**មាត្រា ១៣៦:**

ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចធានាការពារ ការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ។

ក្រុមប្រឹក្សាធម្មនុញ្ញ មានសិទ្ធិពិនិត្យ និងសំរេចអំពីករណីវិវាទកម្ម ទាក់ទងនឹងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ និងការបោះឆ្នោតព្រឹទ្ធសភា ។

**មាត្រា ១៣៧:**

ក្រុមប្រឹក្សាធម្មនុញ្ញ មានសមាជិកប្រាំបួនរូប ដែលទទួលអាណត្តិប្រាំបួនឆ្នាំ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួនមួយភាគបី ត្រូវផ្លាស់ថ្មីក្នុងរយៈពេលបីឆ្នាំម្តង បីឆ្នាំម្តង។ សមាជិកបីរូប ត្រូវតែងតាំងដោយព្រះមហាក្សត្រ បីរូបត្រូវជ្រើសរើសតាំងដោយរដ្ឋសភា ហើយ បីរូបទៀត ត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

ប្រធាន ត្រូវបានជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ។ ប្រធាន មានសម្លេងឧត្តមានុភាព ក្នុងករណីបែកសម្លេងជាពីរស្មើគ្នា។

**មាត្រា ១៣៨:**

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវជ្រើសរើសក្នុងចំណោមឥស្សរជន ដែលមានសញ្ញាប័ត្រ ចាប់ពីឧត្តមសិក្សាទៅខាងច្បាប់ ខាងរដ្ឋបាល ខាងការទូត ឬខាងសេដ្ឋកិច្ច ហើយមានពិសោធន៍ច្រើន ក្នុងការងារ។

**មាត្រា ១៣៩:**

មុខងារសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានវិសមិតភាពនឹងមុខងារសមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា សមាជិករដ្ឋាភិបាល ចៅក្រមក្នុងតំណែង ការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ ប្រធាន ឬអនុប្រធានគណបក្សនយោបាយ ប្រធាន ឬអនុប្រធានសហជីព ។

**មាត្រា ១៤០:**

ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា តំណាងរាស្ត្រចំនួនមួយភាគដប់ ប្រធានព្រឹទ្ធសភា ឬសមាជិកព្រឹទ្ធសភាចំនួនមួយភាគដប់ អាចបញ្ជូនសេចក្តីព្រាងច្បាប់ ទៅឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងសេចក្តីព្រាងច្បាប់នោះត្រូវបានប្រកាសឱ្យប្រើ ។

បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងត្រូវបានប្រកាសឱ្យប្រើ ។ ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសំរេចក្នុងរយៈពេលសាមសិប (៣០) ថ្ងៃយ៉ាងយូរថាតើច្បាប់ និងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងបទបញ្ជាផ្ទៃក្នុងខាងលើ ស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ១៤១:**

ក្រោយពីច្បាប់ណាមួយ ត្រូវបានប្រកាសឱ្យប្រើ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រីសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន តំណាងរាស្ត្រមួយភាគដប់ ឬតុលាការ អាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ ។

ប្រជារាស្ត្រ មានសិទ្ធិប្តឹងអំពីធម្មនុញ្ញភាពនៃច្បាប់បាន តាមរយៈតំណាងរាស្ត្រ ឬប្រធានរដ្ឋសភា ឬសមាជិកព្រឹទ្ធសភា ឬប្រធានព្រឹទ្ធសភា ដូចមាន ចែងក្នុងវាក្យខ័ណ្ឌខាងលើ ។

**មាត្រា ១៤២:**

បទបញ្ញត្តិក្នុងមាត្រាណាមួយ ដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា មិនស្របនឹង រដ្ឋធម្មនុញ្ញ មិនអាចយកទៅប្រកាសអោយប្រើ ឬយកទៅអនុវត្តបានឡើយ។
សេចក្តីប្រកាសរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសំរេចបិទផ្លូវតវ៉ា។

**មាត្រា ១៤៣:**

ព្រះមហាក្សត្រ ទ្រង់ពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះសេចក្តីស្នើទាំងឡាយដែលសុំធ្វើវិសោធនកម្មលើ រដ្ឋធម្មនុញ្ញ។

**មាត្រា ១៤៤:**

ច្បាប់រៀបចំអង្គការមួយ នឹងកំណត់ការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាធម្មនុញ្ញ ។

**មាត្រា ១៥០:**

រដ្ឋធម្មនុញ្ញនេះជាច្បាប់កំពូល នៃព្រះរាជាណាចក្រកម្ពុជា។

ច្បាប់ និងសេចក្តីសំរេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត។

**មាត្រា ១៥១:**

ការផ្តើមគំនិតសើរើ ឬការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ជាសិទ្ធិរបស់ ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភា តាមសេចក្តីស្នើរបស់តំណាងរាស្ត្រ មួយភាគបួន នៃចំនួនសមាជិករដ្ឋសភាទាំងមូល។
ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវធ្វើឡើងដោយច្បាប់រដ្ឋធម្មនុញ្ញមួយ ដែលអនុម័តដោយរដ្ឋសភា តាមមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល។

## **ច្បាប់ព្រហ្មទណ្ឌអន្តរកាល** (ថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ១៩៩២)

**មាត្រា ២: មុខងារនៃតុលាការ**

សមាសភាពនៃក្រុមចៅក្រមមាន ចៅក្រម និងរដ្ឋអាជ្ញា។ មានតែចៅក្រមទេដែលមានអំណាចសំរេចសេចក្តី។ រដ្ឋអាជ្ញា មានបន្ទុកខាងបណ្តឹងអាជ្ញាព្រហ្មទណ្ឌ ដែលមានតែរដ្ឋអាជ្ញាទេដែលមានអំណាចធ្វើកិច្ចការហ្នឹង។ រដ្ឋអាជ្ញា ជាអ្នករៀបចំសំណុំពាក្យចោទប្រកាន់ សំរាប់ដាក់ជូនតុលាការជំនុំជំរះ និងដាក់ជូនអង្គប្រជុំផ្សេងៗទៀត ដែលមានចែងនៅក្នុងបទប្បញ្ញត្តិនេះ។ ម្យ៉ាងវិញទៀត អគ្គរដ្ឋអាជ្ញាជាអ្នកលើកយកសំណុំពាក្យចោទប្រកាន់ ដាក់ជូនតុលាការកំពូលក្នុងផលប្រយោជន៍ខាងផ្លូវច្បាប់ ពិនិត្យមើលនូវភាព ពេញលក្ខណៈច្បាប់នៃបណ្តឹងចោទទាំងឡាយរបស់រដ្ឋអាជ្ញាខេត្ត ចាត់ចែង និងណែនាំកិច្ចការរបស់រដ្ឋអាជ្ញា។

**មាត្រា ៧: មេធាវី និងទីប្រឹក្សា**

១. មេធាវីទាំងឡាយ នឹងត្រូវអនុញ្ញាតឱ្យបង្កើតជាអង្គការមេធាវី ដែលមានរូបភាពជាសមាគមមួយ ដោយមានអំណាចខាងវិន័យ និងបទបញ្ជាទៅលើសមាជិកខ្លួនទាំងអស់។ អង្គការមេធាវី មិនត្រូវទទួលការបង្គាប់បញ្ជាជាដាច់ខាត ពីគណបក្សនយោបាយណាមួយ ពីសំណាក់អំណាចនីតិប្បញ្ញត្តិណាមួយ ឬពីអំណាចនីតិប្រតិបត្តិណាមួយ ដែលនៅក្រោមឱវាទនៃភាគីកម្ពុជាណាមួយ ក្នុងកិច្ចព្រមព្រៀងប៉ារីស។

ក្នុងរយៈពេលអន្តរកាល ជនដែលអាចធ្វើជាមេធាវីបាន គឺជនទាំងឡាយណាដែលយ៉ាងហោចណាស់មាន សញ្ញាប័ត្រស្មើនឹងបរិញ្ញាបត្រនីតិសាស្ត្រ ឬមានការពិសោធប្រាំឆ្នាំក្នុងវិស័យច្បាប់ ឬវិស័យតុលាការ ប្រកបដោយកិរិតខ្ពស់ទទួលខុសត្រូវក្នុងកិច្ចការបាន។

២. ដោយចំនួនមេធាវីមានតិចតួចពេកនៅប្រទេសកម្ពុជា ក្នុងរយៈពេលអន្តរកាលនេះ ជនកម្ពុជាគ្រប់រូប ដែលមានសញ្ញាប័ត្រមធ្យមសិក្សា អាចតំណាងជនជាប់ចោទនៅចំពោះមុខតុលាការបាន លើកលែងណាដែល អ្នកនោះគ្មានឋានន្តរសក្តិជាអ្នករដ្ឋការក្នុងបណ្តាថ្នាក់ដឹកនាំ ជាអ្នកជាប់ឆ្នោតក្នុងរចនាសម្ព័ន្ធរដ្ឋបាលដែលមានសព្វថ្ងៃ ឬក្នុងគណៈបក្សនយោបាយដែលគេទទួលស្គាល់ទាំងឡាយ ។ លើសពីនោះទៀត ជនជាប់ចោទអាចពឹងពាក់សមាជិកគ្រួសារខ្លួនអោយធ្វើជាជំនួយការពារខ្លួនបាន ទោះបីមានកំរិតសិក្សាថ្នាក់ណាក៏ដោយ ។

៣. នៅចំពោះមុខតុលាការ អ្នកតំណាងជនជាប់ចោទមានសិទ្ធិដូចជាមេធាវីដែរ ក្នុងការជូនដំណឹងពីឯកសារ ក្នុងការធ្វើលិខិតនីតិវិធី ឬក្នុងការជជែកការពារជនជាប់ចោទ ។ ក្នុងបទប្បញ្ញត្តិនេះ ពាក្យថា "ទីប្រឹក្សា" មានន័យមិនខុសពីពាក្យមេធាវី ឬអ្នកតំណាងគ្រប់ប្រភេទរបស់ជនជាប់ចោទឡើយ ។

៤. មេធាវីបរទេសអាចជជែកការពារចំពោះតុលាការកម្ពុជា ក្នុងកាលៈទេសៈណាដែលគេអាចបង្ហាញភស្តុតាងថា គេបានចុះឈ្មោះក្នុងអង្គការមេធាវីមួយ ឬក៏គេបានសេចក្តីអនុញ្ញាតជាផ្លូវការឱ្យជជែក ការពារនៅក្នុងប្រទេសរបស់គេ ។ រចនាសម្ព័ន្ធរដ្ឋបាលដែលមានសព្វថ្ងៃ សន្យាថានឹងជួយសំរួលក្នុងការផ្តល់ទិដ្ឋាការចូល ដល់មេធាវីដែលមកបំពេញការងារនៅក្នុងប្រទេសកម្ពុជា ។

### មាត្រា ១៣: ការចាប់ខ្លួន និងការឃុំខ្លួន

១. គ្មានជនណាម្នាក់ត្រូវបានគេឃុំខ្លួនលើសពី ៤៨ម៉ោង ដោយមិនបានបញ្ជូនទៅចៅក្រម តាមរយៈបណ្តឹងរបស់រដ្ឋអាជ្ញាឡើយ ។ ក្នុងករណីណាដែលពុំអាចគោរពតាមថិរវេលានេះបាន ដោយសារស្ថានភាពនៃការដឹកជញ្ជូនក្នុងតំបន់នីមួយៗនោះ គេអាចបន្តបន្ថែមបាននូវពេលវេលាចាំបាច់សំរាប់តែដឹកនាំអ្នកជាប់ឃុំឃាំងនេះ ទៅជូនចៅក្រមតាមមធ្យោបាយយ៉ាងឆាប់ដែលអាចធ្វើបាន ។

២-.រដ្ឋអាជ្ញាសុំអោយចៅក្រមចោទប្រកាន់ ព្រមទាំង ជាយថាហេតុ ឃុំខ្លួនជនជាប់សង្ស័យ ក្រោយពី បានពិនិត្យសំណុំរឿងពីនគរបាល ដោយរៀបរៀងដីកាសន្និដ្ឋានមួយ ទុកជាសេចក្តីផ្តើមចោទ យោងតាមអង្គហេតុជាក់ស្តែង និងដែលកំណត់បទល្មើសតាមច្បាប់ឱ្យស្របទៅតាមបទប្បញ្ញត្តិព្រហ្មទណ្ឌនេះ ។

៣. ក្នុងខណៈនោះ ដោយផ្អែកលើសេចក្តីសំរេចដែលមានចែងមូលហេតុ ចៅក្រមអាចសំរេចថា:

- ត្រូវចោទប្រកាន់ជនជាប់សង្ស័យ ដោយឱ្យឃុំឃាំង ឬមិនឱ្យឃុំឃាំង
- ឱ្យដោះលែងជនជាប់សង្ស័យ ដោយចាត់ទុកថាភស្តុតាងនៃពិរុទ្ធភាពមិនគ្រប់គ្រាន់
- សំរេចឱ្យបន្តការស៊ើបអង្កេត ដោយមិនប្រាប់ឈ្មោះជនជាប់សង្ស័យ ។

៤. ក្នុងរយៈពេលយ៉ាងច្រើន ៤៨ម៉ោងដូចគ្នានេះ ក្រោយការចាប់ខ្លួន ហើយជាយថាហេតុត្រូវបានពន្យារ ថេរវេលាចាំបាច់ក្នុងការដឹកនាំ ដូចបានចែងនៅវគ្គទី ១ ទីប្រឹក្សាត្រូវបានទទួលសំណុំរឿង ដែលទាក់ទងក្នុងការចោទប្រកាន់ចំពោះជនជាប់សង្ស័យ ។

### មាត្រា ១៧: សិទ្ធិពិនិត្យសំណុំរឿង

១. ប្រសិនបើចៅក្រមសំរេចថា ចាំបាច់ត្រូវស៊ើបអង្កេតបន្ថែមទៀត តាមលំដាប់លំដោយនៃការស៊ើបអង្កេតនេះ ទីប្រឹក្សារបស់ជនជាប់ចោទត្រូវតែបានទទួលដំណឹងជាបន្ទាន់ អំពីភស្តុតាងថ្មីៗទៀត ប្រឆាំងនឹងកូនក្តីរបស់ខ្លួន ។

២. ទីប្រឹក្សា មានសិទ្ធិពិនិត្យសំណុំរឿងអ្នកជាប់ចោទ ដោយគ្រាន់តែស្នើសុំជាលាយលក្ខណ៍អក្សរនៅគ្រប់ដំណាក់កាលនៃនីតិវិធី ហើយអាចទទួលបានពីចៅក្រមនូវគ្រប់លទ្ធផលដែលបានមកអំពីការស៊ើបអង្កេត អំពីសេចក្តីរាយការណ៍របស់អ្នកជំនាញការ ឬអំពីសវនកម្មដែលខ្លួនយល់ថា មានប្រយោជន៍ក្នុងការ ការពារកូនក្តីរបស់ខ្លួន ។

### មាត្រា ២៤: មធ្យោបាយបង្ហាញភស្តុតាង

១. សាក្សីទាំងអស់ដែលមានឈ្មោះក្នុងសំណុំរឿង រួមទាំងបុគ្គលិកនគរបាលផងត្រូវតែបាននិយាយជូនតុលាការស្តាប់ ។ សាក្សីទាំងឡាយ អាចត្រូវសួរដេញដោលពីសំណាក់ ភាគីរដ្ឋប្បវេណី ឬទីប្រឹក្សារបស់គេ ជនជាប់ចោទ ឬទីប្រឹក្សារបស់គេ ហើយនិងពីសំណាក់រដ្ឋអាជ្ញា ។

២. ភស្តុតាងទាំងអស់ អាចលើកមកជជែកវែកញែកបាននៅពេលជំនុំជំរះ ដោយរួមទាំងរបាយការណ៍នគរបាលផង ដែលមិនអាចចាត់ទុកថាជាភស្តុតាងដែលច្រានចោលមិនបាននោះទេ។
៣. បណ្តាពាក្យសារភាពរបស់ជនជាប់ចោទទាំងឡាយ ដែលមិនស៊ីសង្វាក់គ្នាទៅនឹងដើមកំណើតនៃភស្តុតាងទេនោះ ទោះក្នុងករណីណាក៏ដោយ មិនអាចទុកជាមូលដ្ឋានសំរាប់ផ្តន្ទាទោសបានឡើយ។ ពាក្យសារភាពដែលបានមកអំពីការបង្ខិតបង្ខំតាមបែបណាមួយក៏ដោយ ត្រូវទុកជាមោឃៈ ។ ការសុំទុកជាមោឃៈនេះ ត្រូវស្នើសុំទៅចៅក្រម ដោយទីប្រឹក្សារបស់ជនជាប់ចោទនៅមុនពេលកាត់ក្តី។
៤. អ្នកការពារចុងចោទអាចយកសាក្សីខ្លួនមកបង្ហាញតុលាការហើយអាចជូនភស្តុតាងខ្លួនទៅតុលាការ ។
៥. សាក្សីទាំងអស់ ទាំងខាងដើមចោទ ទាំងខាងចុងចោទ អាចទទួលការបង្ខំអោយបង្ហាញខ្លួនចំពោះមុខតុលាការ តាមរយៈដីកានាំខ្លួនរបស់តុលាការ ដោយត្រូវពិន័យជាប្រាក់ពី ១០០,០០០ ទៅ ១,០០០,០០០ រៀល បើមិនព្រមប្រព្រឹត្តតាម។

**មាត្រា ២៥: ការសន្មត់ជាមុនថាគ្មានទោស**

គ្រប់ជនដែលគេសង្ស័យ គ្រប់ជនជាប់ពិរុទ្ធ គ្រប់ជនជាប់ចោទ ត្រូវទទួលការសន្មត់ជាមុនថា គ្មានកំហុសជាដាច់ខាត។

**មាត្រា៥៧: អំពើរំលោភលើសិទ្ធិបុគ្គល**

គ្រប់ភ្នាក់ងារសាធារណៈ រួមទាំងភ្នាក់ងារនគរបាល និងយោធិន ដែលរំលោភដោយមិនរួញរាទៅលើសិទ្ធិបូរណភាពបុគ្គល និងភាពមិនអាចរំលោភបាននៃលំនៅដ្ឋាន ដែលត្រូវបានការពារដោយបទប្បញ្ញត្តិនេះ នឹងត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៥ឆ្នាំ។

## ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (ថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ១៩៩៤)

### ជំពូកទី ១
### ការរៀបចំតួនាទី និងសមាសភាព នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

**មាត្រា ១:**

អនុលោមតាម មាត្រា ១១៣ និងមាត្រា ១១៥ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបង្កើតឱ្យមានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីជួយព្រះមហាក្សត្រក្នុងការធានាឯករាជ្យ នៃអំណាចតុលាការធានាវិន័យរបស់ចៅក្រម និងធានាការប្រព្រឹត្តទៅនៃសាលាជំរះក្តី នៃព្រះរាជាណាចក្រកម្ពុជា អោយដំណើរការបានល្អប្រសើរ។

**មាត្រា ២:**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានសមាសភាពដូចខាងក្រោមនេះ:

| | |
|---|---|
| ១. ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា | ប្រធាន |
| ២. រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | សមាជិក |
| ៣. ប្រធានតុលាការកំពូល | សមាជិក |
| ៤. អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល | សមាជិក |
| ៥. ប្រធានសាលាឧទ្ធរណ៍ | សមាជិក |
| ៦. អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ | សមាជិក |
| ៧. ចៅក្រម ០៣ រូប ដែលបោះឆ្នោតជ្រើសតាំងដោយចៅក្រម | សមាជិក |

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវមានសមាជិកបំរុង ០៣ រូបទៀត ដែលបោះឆ្នោតជ្រើសតាំងដោយចៅក្រមទូទាំងប្រទេស សំរាប់ជំនួសសមាជិកជាប់ឆ្នោតដែលអវត្តមាន ។

សមាជិកទាំងអស់ ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ ។

ក្នុងករណីមានវិសមិតភាព រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវបានជំនួស ដោយអ្នកដឹកនាំ មួយរូបទៀត នៃក្រសួងយុត្តិធម៌ ។

**មាត្រា ៣:**

ព្រះមហាក្សត្រទ្រង់ ជាប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ព្រះអង្គទ្រង់ អាចចាត់តាំងព្រះរាជតំណាងធ្វើជាអធិបតី នៃអង្គប្រជុំ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

**មាត្រា ៤:**

សមាជិកឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ដែលត្រូវបានបោះឆ្នោតជ្រើសតាំងមាន អាណត្តិ ៥ឆ្នាំ ហើយអាចឈរឈ្មោះ ជាបន្តបន្ទាប់សំរាប់អាណត្តិក្រោយទៀតបាន។

**មាត្រា ៥:**

ក្នុងករណី ដែលសមាជិកជ្រើសតាំងណាមួយ ដោយសារការបោះឆ្នោត លាឈប់ ឬអវត្តមាន លើស ៦ខែ សមាជិកបោះឆ្នោតជ្រើសតាំងនោះ ត្រូវជំនួសដោយសមាជិកបំរុង ដែលមានអតីតភាពចាស់ជាងគេ។ ក្នុងករណីនេះ ត្រូវបោះឆ្នោតជ្រើសរើសសមាជិកបំរុងបំពេញបន្ថែម។

**មាត្រា ៦:**

បែបបទ និងការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកពេញសិទ្ធិ និងសមាជិកបំរុង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

## ជំពូកទី ២

## ការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម

**មាត្រា ៧:**

ការប្រជុំ ត្រូវកោះប្រជុំដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ តាមព្រះរាជាបញ្ជានៃព្រះមហាក្សត្រ។ ការប្រជុំអាចស្នើឡើងដោយសមាជិក ៣រូប យ៉ាងតិច។

**មាត្រា ៨:**

ការប្រជុំរបស់ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម នឹងទុកជាការបាន លុះត្រាតែមានសមាជិក ៧រូប យ៉ាងតិចចូលរួមប្រជុំ។

**មាត្រា ៩:**

សេចក្តីសំរេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវយកតាមមតិភាគច្រើន នៃសមាជិកវត្តមាន និងតាមការបោះឆ្នោតជាសម្ងាត់។ ប្រធានអង្គប្រជុំ មិនចូលរួមក្នុងការបោះឆ្នោតនេះទេ។ ប៉ុន្តែក្នុងករណី ដែលមានការបែងចែកសំលេងជាពីរស្មើគ្នា ប្រធានអង្គប្រជុំជាអ្នកសម្រេច។

**មាត្រា ១០:**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវបានពិគ្រោះមតិជាចាំបាច់ ដើម្បីផ្តល់ទៅលើសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់ដែលទាក់ទងដល់ការរៀបចំវិស័យតុលាការ និងការប្រព្រឹត្តទៅនៃវិស័យនេះ។

យោបល់របស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវផ្តល់យ៉ាងយូរក្នុងរយៈពេល ៣០ថ្ងៃ គិតពីថ្ងៃដែលបានទទួលសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់ ពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ក្នុងករណីប្រញាប់ រយៈពេលនេះ អាចបន្ថយមកត្រឹម ១០ថ្ងៃ។

**មាត្រា ១១:**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សំរេច និងលើកសេចក្តីស្នើសុំថ្វាយព្រះមហាក្សត្រ អំពីការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់មុខពីមុខងារ ការដាក់ឱ្យនៅទំនេរ ការដាក់ឱ្យនៅក្រៅ ក្របខ័ណ្ឌ ការហួតងារចៅក្រម និងព្រះរាជអាជ្ញា ទាំងអស់។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឱ្យយោបល់ចំពោះការតម្លើងថ្នាក់ និងការតម្លើងឋានន្តរសក្តិ ឱ្យចៅក្រម និង ព្រះរាជអាជ្ញាទាំងអស់។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លើកសេចក្តីព្រាងព្រះរាជក្រឹត្យ ថ្វាយព្រះមហាក្សត្រ អំពីកិច្ចការខាងលើនេះ។

**មាត្រា ១២:**

ក្នុងមុខការដាក់ទោសវិន័យចំពោះចៅក្រម និងព្រះរាជអជ្ញា ឧត្តមក្រុមប្រឹក្សានៃអង្គចៅ ក្រមត្រូវប្រជុំក្រោម រូបភាពជាក្រុមប្រឹក្សាវិន័យ និងក្រោមអធិតីភាព នៃប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អាស្រ័យ ដោយករណីដាក់ទោសវិន័យ ទាក់ទងនឹងចៅក្រម ឬព្រះរាជអាជ្ញា។

ក្នុងករណីខាងលើនេះ ព្រះមហាក្សត្រ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មិនចូលរួមទេ។

សមាជិកជាប់ឆ្នោតដែលអវត្តមាន ត្រូវបានជំនួសដោយសមាជិកបំរុង។

ក្នុងករណីត្រូវដាក់វិន័យចំពោះប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ក្រុមប្រឹក្សាវិន័យ ត្រូវស្ថិតក្រោម ព្រះរាជអធិបតីភាពនៃព្រះមហាក្សត្រ ឬព្រះរាជតំណាង។

សំណុំឯកសារទាក់ទងដល់សាមីជនដែលត្រូវដាក់ទោសវិន័យ ត្រូវផ្ញើទៅជូនសមាជិកក្រុមប្រឹក្សាវិន័យទាំងអស់ ពិនិត្យយ៉ាងតិច ១៥ថ្ងៃ មុនថ្ងៃប្រជុំ។

**មាត្រា ១៣:**

ប្រធានក្រុមប្រឹក្សាវិន័យកំណត់ថ្ងៃ និង ធ្វើការកោះប្រជុំ។

**មាត្រា ១៤:**

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាវិន័យ ត្រូវធ្វើដូចសេចក្តីសំរេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលមានចែង ក្នុងមាត្រា ៩ ។

**មាត្រា ១៥:**

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាវិន័យ ត្រូវដាក់ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីពិនិត្យយល់ព្រម ។ សេចក្តីសំរេចនេះ ជាសេចក្តីសំរេចបិទការតវ៉ា ។

**មាត្រា ១៦:**

សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រមទាំងអ្នកដែលចូលរួម ត្រូវរក្សាការសម្ងាត់នៃអង្គប្រជុំ ។

**មាត្រា ១៧:**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវជ្រើសរើសចៅក្រមម្នាក់ និងក្រឡាបញ្ជី ឱ្យទទួលរ៉ាប់រងមុខងារជាលេខាធិការ ដែលមានភារកិច្ចធ្វើរបាយការណ៍ ធ្វើកំណត់ហេតុ រក្សាឯកសារ និងបំពេញកិច្ចការផ្សេងៗទៀត ។

**មាត្រា ១៨:**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវទទួលប្រាក់បំណាច់ម៉ោងប្រជុំ ដែលនឹងត្រូវកំណត់ដោយប្រកាសរួម របស់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ១៩:**

ការចំណាយសំរាប់ដំណើរការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវគ្រោងក្នុងថវិកា របស់ក្រសួងយុត្តិធម៌។

## ជំពូកទី ៣
## អន្តរប្បញ្ញត្តិ

**មាត្រា ២០:**

ក្រោយពីច្បាប់នេះចូលជាធរមាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីមានការព្រមព្រៀង ពីប្រធានតុលាការកំពូល ត្រូវស្នើសុំទៅព្រះមហាក្សត្រ តែងតាំងចៅក្រម ៣រូប ជាសមាជិក បណ្តោះអាសន្ននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សំរាប់អំឡុងពេលដែលពុំទាន់អាចរៀបចំបោះឆ្នោតជ្រើសរើសចៅក្រមសមាជិក តាមបទបញ្ញត្តិនៃមាត្រា ៤ ខាងលើបាន។

ចៅក្រមតែងតាំងនេះ ត្រូវចប់ភារកិច្ចជាស្វ័យប្រវត្តិ នៅពេលចៅក្រមសមាជិកជាប់ឆ្នោតចូលមកទទួលការងារ។

**មាត្រា ២១:**

ការរៀបចំបោះឆ្នោតជ្រើសរើសចៅក្រមជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវធ្វើក្រោយពីច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម ចូលជាធរមាន និងបន្ទាប់ពីមានការតែងតាំងចៅក្រម អោយចូលក្នុងក្រខ័ណ្ឌចៅក្រមរួច។

**មាត្រា ២២:**

ចៅក្រមទទួលការងារដែលចាត់តាំងតាមបទបញ្ញត្តិនៃមាត្រា ២០ ខាងលើ មានសិទ្ធបោះឆ្នោត និងឈរឈ្មោះជាបេក្ខជន ឱ្យសហសេរិកខ្លួន បោះឆ្នោតជ្រើសរើសបាន។

ប៉ុន្តែចៅក្រមនេះ ត្រូវលាឈប់ពីសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចាប់តាំងពីថ្ងៃដាក់ពាក្យសុំជាបេក្ខជន ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ២៣:**

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

## សំណើក្រមវិជ្ជាជីវៈសំរាប់អនុវត្តលើចៅក្រមខ្មែរ

ខាងក្រោមនេះ គឺជាវិធាននៃក្រមសីលធម៌ សំរាប់អនុវត្តទៅលើអ្នកដែលមានតួនាទីជាចៅក្រមគ្រប់លំដាប់ថ្នាក់នៃតុលាការ ។ អ្នកដែលបំពានជាលើកដំបូង លើវិធានណាមួយខាងក្រោម នឹងត្រូវព្យួរពីការងារជាបណ្តោះអាសន្ន ដោយគ្មានប្រាក់បៀវត្ស ទៅតាមរយៈពេលមួយ ដែលកំណត់ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយផ្អែកលើភាពធ្ងន់ធ្ងរនៃអំពើល្មើសនោះ ។ អ្នកដែលបំពានជាលើកទី ២ នឹងត្រូវបញ្ឈប់ជាអចិន្ត្រៃយ៍ មិនឱ្យកាន់តួនាទីណាមួយ ក្នុងស្ថាប័នយុត្តាធិការឡើយ ។

១. ចៅក្រមម្នាក់ៗត្រូវតែគោរព និង អនុវត្តតាមច្បាប់គ្រប់កាលៈទេសៈទាំងអស់ ។ ចៅក្រមត្រូវប្រកាន់អាកប្បកិរិយា និងអត្តចរិតណាដែលលើកស្ទួយជំនឿទុកចិត្តដល់សាធារណៈជន ក្នុងការកាត់ក្តីដោយឯករាជ្យ និង ដោយយុត្តិធម៌ឥតលំអៀង ។

២. ចៅក្រមមិនត្រូវអនុញ្ញាតឱ្យទំនាក់ទំនងគ្រួសារ, ទំនាក់ទំនងសង្គម និងទំនាក់ទំនងផ្សេងៗទៀត មកជ្រៀតជ្រែកដំណើរការតុលាការ ឬ ដំណើរការកាត់ក្តីឡើយ ។

៣. ចៅក្រម មិនត្រូវប្រើប្រាស់តួនាទីរបស់ខ្លួន ដើម្បីបំរើផលប្រយោជន៍ខ្លួនឯង ឬដើម្បីបំរើផលប្រយោជន៍នៃបុគ្គលផ្សេងទៀតឡើយ ។

៤. ចៅក្រមមិនត្រូវប្រឡូកក្នុងសកម្មភាពជាសមាជិកនៃអង្គការណាមួយ ដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធភាព របស់ចៅក្រមក្នុងការអនុវត្តនីទៅតាមគោលការណ៍យុត្តិធម៌ឥតលំអៀងឡើយ ។

៥. ចៅក្រមត្រូវផ្តើម ឬ ចាត់វិធានការដាក់វិន័យសមស្រប ចំពោះចៅក្រមគ្នាឯង ឬចំពោះមេធាវីដែលបានប្រព្រឹត្តអំពើល្មើសនឹងវិធាននៃវិជ្ជាជីវៈដែលចៅក្រមបានដឹង ។

៦. ចៅក្រមមិនត្រូវផ្តួចផ្តើមអនុញ្ញាត ឬ ពិចារណា ការប្រាស្រ័យទាក់ទងជាលក្ខណៈឯកជន ដែលធ្វើឡើងជា មួយចៅក្រមដោយគ្មានវត្តមាននៃភាគីទាំងអស់ដែលពាក់ព័ន្ធនឹងរឿងក្តី ដែលត្រូវដោះស្រាយឡើយ ។

៧. ចៅក្រមត្រូវចាត់ចែងកិច្ចការតុលាការឱ្យបានឆាប់រហ័ស ដោយមិនត្រូវពន្យាពេលឡើយ ។

៨. ចៅក្រមត្រូវជៀសវាងរាល់ការធ្វើបទអត្ថាធិប្បាយទៅលើរឿងក្តី ដែលកំពុងរង់ចាំការកាត់ក្តី ឬដែលមិនទាន់រង់ចាំការកាត់ក្តី នៅក្នុងតុលាការណាមួយឡើយ ។ ហើយត្រូវហាមឃាត់ផងដែរ ចំពោះមន្ត្រីតុលាការ ដែលស្ថិតនៅក្រោមបញ្ជានិងការគ្រប់គ្រងរបស់ចៅក្រម ។

៩. ចៅក្រមត្រូវអនុម័តយកនូវវិធីសាស្ត្រ ប្រក្រតីនិងអាចទទួលយកបានក្នុងការកាត់ក្តី ហើយក្នុងការកាត់ទោស ជនណាម្នាក់ចៅក្រមត្រូវជៀសវាងការដាក់ទណ្ឌកម្ម និងការដាក់វិន័យណា ដែលធ្វើឱ្យប៉ះពាល់ដល់សេចក្តី ថ្លៃថ្នូររបស់ចៅក្រម និងដែលច្បាប់ពុំអនុញ្ញាត ។ ចៅក្រម ត្រូវព្យាយាមអនុវត្តតាមគំរូនៃការដាក់ទណ្ឌកម្ម សមហេតុផល ហើយមិនត្រូវស្វែងរកប្រជាប្រិយភាព ឬធ្វើឱ្យសាធារណៈជនស្គាល់តាមរយៈការដាក់ទណ្ឌកម្ម ជនណាមួយធ្ងន់ហួសហេតុ ឬតាមរយៈការដាក់ទណ្ឌកម្មជនណាមួយ ដោយយោគយល់ជ្រុលពេកឡើយ ។

១០. ចៅក្រមត្រូវដកខ្លួនចេញដោយខ្លួនឯង ពីរឿងក្តីណាមួយ ដែលចៅក្រមធ្លាប់មានសម្ព័ន្ធភាពខាងជំនួញ ឬធ្លាប់មានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយភាគី ឬ មេធាវីម្ខាងដែលនៅក្នុងរឿងក្តីនោះ ។

១១. ចៅក្រមត្រូវដកខ្លួនចេញដោយខ្លួនឯង ពីរឿងក្តីណាមួយដែលចៅក្រមបានទទួលពត៌មានអ្វីក៏ដោយ ពីរភាគី ឬមេធាវីណាមួយមុនពេលដែលភាគី ឬ មេធាវីនោះដាក់ពាក្យបណ្តឹង ។

១២. ចៅក្រមអាចចូលរួមក្នុងសកម្មភាពស៊ីវិល និងសកម្មភាពសប្បុរសធម៌ទាំងឡាយណា ដែលមិនធ្វើឱ្យប៉ះពាល់ដល់ភាពយុត្តិធម៌មិនលំអៀងរបស់ចៅក្រម ឬដែលមិនជ្រៀតជ្រែកដល់ការអនុវត្តនីកិច្ចការតុលាការ ។ ចៅក្រម មិនត្រូវចូលប្រឡូកក្នុងគណៈបក្សនយោបាយឡើយ ។

១៣. ចៅក្រមត្រូវជៀសវាងការពាក់ព័ន្ធខាងជំនួញ និងខាងហិរញ្ញវត្ថុណាដែលអាចៈ

- ធ្វើឱ្យប៉ះពាល់ ដល់ភាពយុត្តិធម៌មិនលំអៀងរបស់ចៅក្រម ឬ ដល់តួនាទីរបស់ចៅក្រម
- ជ្រៀតជ្រែតដល់ការអនុវត្តនីកិច្ចការតុលាការ
- ឱ្យចៅក្រម ធ្វើអាជីវកម្មលើតួនាទីរបស់ខ្លួន
- ធ្វើឱ្យចៅក្រមពាក់ព័ន្ធនឹងកិច្ចការជាមួយមេធាវី ឬជាមួយមនុស្សផ្សេងទៀត ដែលមុខនឹងឡើង សវនាការដែលមានចៅក្រមនេះ ជាអ្នកកាត់ក្តី ។

ដោយត្រូវគោរពនូវការហាមឃាត់ខាងលើនេះ ចៅក្រមអាចកាន់កាប់ និង ចាត់ចែងការវិនិយោគទុន បានរួមទាំងការវិនិយោគទុនខាងអចលនទ្រព្យ ហើយអាចចូលរួមក្នុងសកម្មភាពផ្តល់ផលកំរៃ ប៉ុន្តែមិនអាចកាន់តួនាទី ជានាយក, អ្នកដែលមានអំណាចចាត់ចែង, ចាងហ្វាង, ទីប្រឹក្សា ឬតួនាទីជានិយោជិត ក្នុងកិច្ចការជំនួញនោះបានឡើយ ។ ចៅក្រមត្រូវដកខ្លួនចេញដោយខ្លួនឯង ពីការចូលរួមក្នុងរឿងក្តីណាមួយដែលអាចក្នុងរូបភាពណាមួយ ធ្វើឱ្យប៉ះពាល់ ដល់កាវិនិយោគទុនរបស់ចៅក្រម ។

១៤. ទាំងចៅក្រមទាំងសមាជិកក្នុងគ្រួសារ ដែលស្នាក់នៅផ្ទះជាមួយចៅក្រម មិនត្រូវអនុញ្ញាតឱ្យទទួលយកពីអ្នកណាមួយនូវអំណោយ, កេរ្តិ៍, ការជួយយកអាសារ, ឬការឱ្យខ្ចីអ្វីមួយបានឡើយ ។

១៥. ចៅក្រមមិនត្រូវប្រកបវិជ្ជាជីវៈច្បាប់ ដើម្បីបានទទួលនូវកំរៃតបស្នងឡើយ ។

១៦. ចៅក្រមមិនត្រូវទទួលយកនូវការតែងតាំងមុខងារ នៅក្នុងគណៈកម្មាធិការ ឬគណៈកម្មាការក្នុងជួររដ្ឋាភិបាល ឬ នៅក្នុងតំណែងផ្សេងទៀត ដែលពាក់ព័ន្ធនឹងបញ្ហាហេតុការណ៍ ឬបញ្ហានយោបាយដែលមិនទាក់ទងទៅនឹងការងារអភិវឌ្ឍន៍ វិស័យច្បាប់, ប្រព័ន្ធច្បាប់, ឬ ការគ្រប់គ្រងវិស័យយុត្តិធម៌ឡើយ ។

១៧. ចៅក្រមត្រូវរាយការណ៍អំពីកាលបរិច្ឆេទ ទីកន្លែង និងប្រភេទនៃរាល់ប្រាក់ចំណូល ដែលចៅក្រមបានទទួល ហើយត្រូវរាយការណ៍ អំពីឈ្មោះនៃអ្នកបង់ប្រាក់ និងអំពីចំនួនទឹកប្រាក់ដែលបានទទួលនោះ ។ សេចក្តីរាយការណ៍របស់ចៅក្រម ត្រូវធ្វើយ៉ាងហោចណាស់មួយឆ្នាំម្តង ហើយត្រូវតម្កល់ទុកជាឯកសារសាធារណៈ នៅឯទីស្នាក់ការរបស់ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

១៨. ចៅក្រមមិនត្រូវកាន់តំណែងណាមួយ ក្នុងគណៈបក្សនយោបាយ ឬថ្លែងសន្ទរកថាក្នុងនាមគណៈបក្សនយោបាយ ឬ រាយការណ៍ ឬពិគ្រោះយោបល់ជាមួយគណៈបក្សនយោបាយ ឬសមាជិកនៃរដ្ឋាភិបាលអំពីបញ្ហាណា មួយដែលស្ថិតនៅក្រោមការពិចារណារបស់តុលាការឡើយ ។

## ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី (ថ្ងៃទី ២៨ ខែមករា ឆ្នាំ ១៩៩៣)

**មាត្រា ៦:**

តុលាការខេត្ត-ក្រុង មានសមត្ថកិច្ចជំនុំជំរះ បើកផ្លូវឧទ្ធរណ៍ នូវរឿងព្រហ្មទណ្ឌ រឿងរដ្ឋប្បវេណី រឿងពាណិជ្ជកម្ម វិវាទរដ្ឋបាល និងវិវាទការងារ ។

តុលាការខេត្ត-ក្រុង ជំនុំជំរះក្តីមានចៅក្រមម្នាក់ និងត្រូវបំពេញដោយរដ្ឋអាជ្ញា ឬរដ្ឋអាជ្ញារងម្នាក់ និងក្រឡាបញ្ជីម្នាក់ ។

**មាត្រា ៧:**

សាលក្រមសំរេចសេចក្តីចំពោះមុខ បើកឱ្យប្តឹងឧទ្ធរណ៍ក្នុងរយៈពេលពីរខែ គិតពីថ្ងៃកាត់សេចក្តី ។ សាលក្រមកំបាំងមុខ បើកឱ្យប្តឹងជំទាស់ក្នុងរយៈពេល១៥ថ្ងៃ គិតពីថ្ងៃទទួលដំណឹង ។ បើផុតកំណត់ប្តឹងជំទាស់ អាចប្តឹងឧទ្ធរណ៍បានក្នុងរយៈពីរខែ គិតពីថ្ងៃផុតកំណត់ប្តឹងជំទាស់ ។

**មាត្រា ៨:**

បណ្តឹងឧទ្ធរណ៍ មានអានុភាពផ្អាកជាបណ្តោះអាសន្ននូវការអនុវត្តសាលក្រម ។

បណ្តឹងឧទ្ធរណ៍ ដែលទាក់ទងដល់សេចក្តីសំរេចរបស់តុលាការ របស់ចៅក្រម ឬរបស់រដ្ឋអាជ្ញា ពុំមានអានុភាពផ្អាកសេចក្តីសំរេចទាំងនោះទេ លើកលែងតែបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយរដ្ឋអាជ្ញា ក្នុងរឿងឃុំខ្លួន ឬដោះលែងឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ន ។

បណ្តឹងឧទ្ធរណ៍ ត្រូវធ្វើនៅសាលាជំរះក្តី ដែលបានចេញសាលក្រមនោះ ។

អ្នកដែលមានសិទ្ធិប្តឹងឧទ្ធរណ៍ ឬប្តឹងជំទាស់ គឺរដ្ឋអាជ្ញា ឬជនទាំងឡាយ ដែលមានប្រយោជន៍ក្នុងរឿងក្តីរួមមានគូក្តីដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវខាងបទរដ្ឋប្បវេណី ជនជាប់ទោស មេធាវី ឬ អ្នកការពារ ។

ក្រៅពីរឿងព្រហ្មទណ្ឌ បើរដ្ឋអាជ្ញាតាំងខ្លួនជាគូក្តីដើម ទើបមានសិទ្ធិប្តឹងឧទ្ធរណ៍បាន ។

**មាត្រា ៩:**

តុលាការយោធាមានសមត្ថកិច្ចជំនុំជំរះ បើកផ្លូវឧទ្ធរណ៍ នូវបទល្មើសយោធា ។

បទល្មើសយោធា គឺជាបទល្មើស ដែលប្រព្រឹត្តដោយយោធិននៅក្នុងជួរកងទ័ព ហើយដែលពាក់ព័ន្ធទៅនឹងវិន័យកងទ័ព ឬប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់កងកំលាំងប្រដាប់អាវុធ ។ ក្នុងករណី យោធិនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌសាមញ្ញ ត្រូវតុលាការខេត្ត-ក្រុងជំនុំជំរះ ។

នីតិវិធីរបស់តុលាការយោធា ដូចគ្នានឹងនីតិវិធី របស់តុលាការខេត្ត-ក្រុងដែរ ។

**មាត្រា ១០:**

សាលាឧទ្ធរណ៍មានសមត្ថកិច្ចជំនុំជំរះលើបណ្តឹងឧទ្ធរណ៍ អំពីសាលក្រមរបស់តុលាការខេត្ត ក្រុង នឹងតុលាការយោធា ដោយបើកផ្លូវឱ្យប្តឹងសាទុក្ខ។

**មាត្រា ១១:**

សមាសភាពជំនុំជំរះក្តីនៃសាលាឧទ្ធរណ៍ ត្រូវមានចៅក្រម ៣នាក់ ដែលម្នាក់ធ្វើជាប្រធាន ។ សមាសភាពនៃសាលាជំរះក្តីនេះ ត្រូវបំពេញដោយអគ្គរដ្ឋអាជ្ញា ឬអគ្គរដ្ឋអាជ្ញារង ឬរដ្ឋអាជ្ញាម្នាក់ នៃមហាអយ្យការ និងក្រឡាបញ្ជីម្នាក់។

ក្នុងករណីជំនុំជំរះជាថ្មីឡើងវិញ សមាសភាពជំនុំជំរះក្តីនេះ ត្រូវមានចៅក្រម ៣នាក់ ដែលម្នាក់ធ្វើជាប្រធាន ហើយសុទ្ធតែជាចៅក្រម ដែលមិនបានចូលរួមជំនុំជំរះលើកមុន។

**មាត្រា ១២:**

សាលដីកាសាលាឧទ្ធរណ៍ សំរេចសេចក្តីចំពោះមុខ អាចប្តឹងសាទុក្ខបានក្នុងរយៈពេល ២ខែ គិតពីថ្ងៃកាត់សេចក្តី។

សាលដីកាកំបាំងមុខ អាចប្តឹងជំទាស់បានក្នុងរយៈពេល ១៥ថ្ងៃ គិតពីថ្ងៃទទួលដំណឹង។

បើផុតកំណត់ប្តឹងជំទាស់ អាចប្តឹងសាទុក្ខបានក្នុងរយៈពេល ២ខែ គិតពីថ្ងៃផុតកំណត់ប្តឹងជំទាស់។

**មាត្រា ១៣:**

បណ្តឹងសាទុក្ខមានអានុភាពផ្អាកជាបណ្តោះអាសន្ន នូវការអនុវត្តសាលដីការបស់សាលាឧទ្ធរណ៍។ ប៉ុន្តែបណ្តឹងសាទុក្ខ ដែលទាក់ទងដល់ការឃុំខ្លួនជាបណ្តោះអាសន្ន ការដាក់ឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ន ការតំកល់រឿងមិនចាត់ការ និងការលើកលែងចោទប្រកាន់ ពុំមានអានុភាពផ្អាកការអនុវត្តសាលដីការបស់សាលាឧទ្ធរណ៍ឡើយ។ បណ្តឹងសាទុក្ខ ត្រូវធ្វើនៅសាលាជំរះក្តី ដែលបានចេញសាលដីកានោះ។ អ្នកដែលមានសិទ្ធិប្តឹងសាទុក្ខ និងប្តឹងជំទាស់ គឺអគ្គរដ្ឋអាជ្ញាអមសាលាឧទ្ធរណ៍ ឬជនដែលមានប្រយោជន៍ក្នុងរឿងទាំងឡាយរួមមានៈ គូក្តី ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវ ខាងបទរដ្ឋប្បវេណី ជនជាប់ទោស មេធាវី ឬអ្នកការពារ។

**មាត្រា ១៤:**

តុលាការកំពូល មានសមត្ថកិច្ចជំនុំជំរះលើបណ្តឹងសាទុក្ខ អំពីសាលដីការបស់សាលាឧទ្ធរណ៍ ដោយជំនុំជំរះតែលើអង្គច្បាប់ មិនជំនុំជំរះអំពីអង្គហេតុទេ ។

ប៉ុន្តែក្នុងរឿងក្តីដែលមានបណ្តឹងសាទុក្ខជាលើកទី២ សាលានេះត្រូវជំនុំជំរះរួមក្រុម ដោយជំនុំជំរះទាំង អង្គហេតុ និងអង្គច្បាប់។

**មាត្រា ១៥:**

បណ្តឹងសើរើធ្វើបានចំពោះសាលក្រម ឬសាលដីកាស្ថាពរ ហើយដែលមានអំណាចដាច់ខាត ហើយ។

បណ្តឹងសើរើធ្វើបានក្នុងរឿងមជ្ឈិម និងរឿងឧក្រិដ្ឋ ក្នុងករណីមួយចំនួន ដែលមានចែងក្នុងច្បាប់។

បណ្តឹងសើរើមិនអាចធ្វើបានចំពោះសាលក្រម ឬសាលដីកា ដែលសំរេចឱ្យរួចខ្លួននោះទេ។

អ្នកដែលអាចប្តឹងសើរើបាន គឺ :

- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- ជនជាប់ទោស ឬតំណាងស្របច្បាប់របស់ជនជាប់ទោស ក្នុងករណីដែលជននេះគ្មានសមត្ថភាព
- សហព័ទ្ធ ឪពុក ម្តាយ កូនរបស់ជនជាប់ទោស និយាយរួម គឺជនដែលមានប្រយោជន៍ខាងផ្នែកសំភារៈ ឬខាងផ្លូវចិត្ត បើជនជាប់ទោសនោះស្លាប់ ឬបាត់ខ្លួន ។

**មាត្រា ១៦:**

សមាសភាពជំនុំជំរះក្តីរបស់តុលាការកំពូល មានចៅក្រម ៥នាក់ ដែលម្នាក់ធ្វើជាប្រធាន។ ក្នុងករណីជំនុំជំរះរួមក្រុម សមាសភាពជំនុំជំរះក្តីនៃតុលាការនេះ ត្រូវមានចៅក្រម ៩នាក់ ដែលម្នាក់ធ្វើជាប្រធាន។ សមាសភាពនៃសាលាជំនុំជំរះក្តីនេះ ត្រូវបំពេញដោយអគ្គរដ្ឋអាជ្ញា ឬអគ្គរដ្ឋអាជ្ញារង ឬរដ្ឋអាជ្ញាម្នាក់ និងក្រឡាបញ្ជីម្នាក់។

**ច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល** (ថ្ងៃទី ២១ ខែតុលា ឆ្នាំ ១៩៩៤)

**មាត្រា ៥១:**

អ្នករាជការដែលជាប់បណ្តឹងពីបទមជ្ឈឹម ឬបទឧក្រិដ្ឋចំពោះមុខតុលាការ អាចត្រូវចោទប្រកាន់បាន លុះត្រាមានសេចក្តីអនុញ្ញាតបើកឱ្យចោទប្រកាន់ជាមុនពីគណៈរដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចំពោះមន្ត្រីដែលមានបៀវត្សស្មើ ឬលើសបៀវត្សឧត្តមមន្ត្រីថ្នាក់លេខ ៣ ឬមានឋានៈជាប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានី និងក្រុង អភិបាលខេត្ត ក្រុង ។ ចំពោះអ្នករាជការដែលមាន បៀវត្សទាបជាង បៀវត្សឧត្តមមន្ត្រីថ្នាក់លេខ ៣ វិញ សេចក្តីអនុញ្ញាតជាមុនឱ្យចោទប្រកាន់នោះត្រូវ សំរេចត្រឹមប្រធាន ស្ថាប័នសាមី។

ក្នុងករណីបទល្មើសជាក់ស្តែងតុលាការ អាចបង្គាប់ឱ្យឃុំខ្លួនភ្លាមមិនចាំបាច់មានសេចក្តីអនុញ្ញាតឱ្យចោទប្រកាន់ទេ ប៉ុន្តែត្រូវជូនដំណឹងអំពីរឿងនេះ ជាប្រញាប់ទៅប្រធានស្ថាប័នសាមី។

**ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី** (ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ១៩៩៥)

**មាត្រា ១:**

វិជ្ជាជីវៈមេធាវីជាវិជ្ជាជីវៈឯករាជ្យនិងសេរីដែលចូលរួមបំរើវិស័យយុត្តិធម៌។

វិជ្ជាជីវៈមេធាវី ប្រព្រឹត្តទៅបានតែក្នុងក្របខ័ណ្ឌនៃគណៈមេធាវី។

**មាត្រា ២:**

មេធាវីតំណាងកូនក្តីតាមការយល់ព្រមពីកូនក្តី ឬជួយការពារកូនក្តី នៅគ្រប់សាលាជម្រះក្តី និងគ្រប់ដំណាក់កាលនៃនីតិវិធីលើកលែងតែមានបទបញ្ញត្តិ ច្បាប់ចែងផ្ទុយពីនេះជាពិសេសក្នុងរឿងរដ្ឋ ឬវេណីពាណិជ្ជកម្មរដ្ឋបាលការងារសង្គមកិច្ច។

ក្នុងរឿងព្រហ្មទណ្ឌមេធាវីការពារជនជាប់ចោទ ហើយមិនអាចតំណាង ជនជាប់ចោទបានឡើយ លើកលែងតែក្នុងករណីអនុវត្តបទបញ្ញត្តិពិសេសនៃច្បាប់។ មេធាវីអាចតំណាងអ្នកទទួលខុសត្រូវ ក្នុងបទរដ្ឋប្បវេណីនិងដើមបណ្តឹងរដ្ឋប្បវេណីបាន។

មេធាវីអាចជួយការពារកូនក្តីបានដែរនៅចំពោះមុខក្រុមប្រឹក្សាវិន័យ។

**មាត្រា ៣:**

មេធាវីផ្តល់យោបល់ និងតាក់តែងលិខិតស្នាមផ្សេងៗក្នុងវិស័យគតិយុត្ត។

មេធាវីអាចត្រូវបានចាត់តាំងដោយគូក្តី ឬចៅក្រមឱ្យបំពេញមុខងារជាអ្នកផ្សះផ្សា ឬជាអ្នកសម្រុះសម្រួល ។ មេធាវី នឹងអាចត្រូវបានចាត់តាំងជាអាជ្ញាកណ្តាលបានលុះត្រាតែមានច្បាប់អនុញ្ញាត។

**មាត្រា ៤:**

ក្រៅពីមេធាវីដែលជាសមាជិកនៃគណៈមេធាវី គ្មានជនណាម្នាក់អាចប្រកបមុខរបរកម្រៃ ក្នុងការពិគ្រោះច្បាប់ ឬតាក់តែងលិខិតស្នាមគតិយុត្តបានឡើយ លើកលែងតែការពិគ្រោះច្បាប់ ឬការតាក់តែងលិខិតស្នាមនោះ ជាការងារបន្ទាប់បន្សំនៃមុខរបររបស់ខ្លួន ឬជាមុខងារដែលច្បាប់បានអនុញ្ញាត។

**មាត្រា ៨:**

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជាអង្គការប្រមូលផ្តុំមេធាវីទាំងអស់ដែលតាំងការិយាល័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ មេធាវីម្នាក់ៗ ត្រូវជាសមាជិកពេញសិទ្ធិនៃគណៈមេធាវីក្រោយ ពីចុះឈ្មោះក្នុងបញ្ជីគណៈមេធាវី។

**មាត្រា ២៩:**

មូលនីធិនៃគណៈមេធាវីបានមកពីការបង់ភាគទាន នៃសមាជិកទាំងអស់ និងវិភាគទានផ្សេងៗ។ នៅក្នុងមូលនីធិនេះ ត្រូវបង្កើតឱ្យមានបេឡាពិសេសមួយ សំរាប់ផ្តល់ប្រាក់កំរៃដល់មេធាវី ដែលការពារជនក្រីក្រ។

បេឡាពិសេសនេះ អាចទទួលអំណោយឬប្រាក់ជំនួយដែលឯកជនអង្គការអន្តរជាតិឬរដ្ឋាភិបាលនៃប្រទេសផ្សេងៗ ផ្តល់មកឱ្យដើម្បីការពារជនក្រីក្រ។

មេធាវីទាំងអស់មានកាតព្វកិច្ច ជួយការពារជនក្រីក្រតាមបែបបទនៃបទបញ្ជាផ្ទៃក្នុងហើយឱ្យដូចជា ជួយការពារអតិថិជនរបស់ខ្លួន។

**មាត្រា ៣១:**

ជនដែលអាចចូលប្រកបវិជ្ជាជីវៈជាមេធាវីបាន ត្រូវបំពេញល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ:

១. ត្រូវមានសញ្ជាតិជាខ្មែរ

២. ត្រូវមានបរិញ្ញាប័ត្រច្បាប់ ឬសញ្ញាប័ត្រច្បាប់ដែលបានប្រកាសថាមានតម្លៃសមមូល។

៣. ត្រូវមានវិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវី ។ វិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវីនេះ ត្រូវចេញឱ្យដោយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។ ការរៀបចំ និងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

៤. មិនដែលត្រូវបានផ្តន្ទាទោសជាបទបដ្ឋិម ឬឧក្រិដ្ឋ ឬផ្តន្ទាទោសជាបទវិន័យ ឬផ្តន្ទាទោសជាបទរដ្ឋ បាលដូចជាការលុបឈ្មោះចោលការបញ្ឈប់ពីមុខងារ ការហូតងារអំពីអំពើផ្ទុយនឹងកិត្តិយស ឬអំពើមិនស្អាតស្អំ។ មិនត្រូវមានធនក្ស័យផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ។

**មាត្រា ៣២:**

មិនចាំបាច់មានវិញ្ញាបនប័ត្រសម្បទាខាងវិជ្ជាជីវៈមេធាវី និងមិនចាំបាច់មានបរិញ្ញាប័ត្រច្បាប់:

- ចៅក្រមដែលបានបំរើការងារក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី ៥ឆ្នាំ និងអតីតចៅក្រមដែលមានញ្ញាប័ត្រមធ្យមសិក្សាច្បាប់ ហើយដែលបានបំរើក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី ២ឆ្នាំ។

មិនចាំបាច់មានវិញ្ញាបនប័ត្រវិជ្ជាជីវៈមេធាវី:

- អ្នកមានបរិញ្ញាប័ត្រច្បាប់ ហើយដែលបានបំរើការងារក្នុងវិស័យច្បាប់ ឬតុលាការលើសពី ២ឆ្នាំ
- មេធាវីដែលមានសញ្ជាតិដើមជាខ្មែរ ដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៅប្រទេសក្រៅ
- អ្នកមានសញ្ញាប័ត្របណ្ឌិតច្បាប់។

**មាត្រា ៣៣:**

ការយល់ព្រមឱ្យប្រកបវិជ្ជាជីវៈមេធាវី ត្រូវសំរេចដោយក្រុមប្រឹក្សាគណៈមេធាវីក្រោយពីបានត្រួតពិនិត្យលើការបំពេញលក្ខខណ្ឌសព្វគ្រប់ ដែលមានកំណត់ក្នុងច្បាប់នេះ និងក្រោយពីមានយោបល់របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

សេចក្តីសំរេចត្រូវអោយដំណឹងដល់សាមីខ្លួន និងដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

ក្រុមប្រឹក្សាគណៈមេធាវី មិនអាចសំរេចមិនយល់ព្រម ដោយគ្មានការកោះអញ្ជើញសាមីខ្លួនឱ្យចូលមកបញ្ចេញយោបល់ជាមុនយ៉ាងតិច១០ថ្ងៃបានឡើយ។ ការកោះអញ្ជើញនេះ ត្រូវធ្វើតាមលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃដោយមានសេចក្តីបញ្ជាក់ថាបានទទួល។

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី អាចត្រូវបានប្តឹងតវ៉ាតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា ២៥ ខាងលើ។

**មាត្រា ៣៤:**

មេធាវីដែលត្រូវបានទទួលឱ្យប្រកបវិជ្ជាជីវៈ ត្រូវធ្វើសច្ចាប្រណិធានជាមុននៅចំពោះ មុខសាលាឧទ្ធរណ៍ដោយមានវត្តមានប្រធានគណៈមេធាវីហើយដែលមានសេចក្ដីដូចតទៅ:

ខ្ញុំសូមសច្ចាប្រណិធានថា នឹងអនុវត្តវិជ្ជាជីវៈរបស់ខ្ញុំដោយសេចក្ដីថ្លៃថ្នូរដោយសតិសម្បជញ្ញៈដោយសេចក្ដី ទៀងត្រង់ ដោយមនុស្សធម៌ ដោយស្មារតីឯករាជ្យ និងដោយគោរពរដ្ឋធម្មនុញ្ញ និងច្បាប់ទាំងឡាយនៃ ព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣៥:**

មេធាវីដែលទើបបានចុះឈ្មោះ ត្រូវធ្វើកម្មសិក្សារយៈពេល ១ឆ្នាំតាមបែបបទ ដែលកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់គណៈមេធាវីលើកលែងតែមេធាវីណាដែលមានការអនុញ្ញាតឱ្យរួចផុតពីកម្មសិក្សាបែបបទនៃកម្មសិក្សាមាន ជាអាទិ៍ដូចតទៅ:

- ត្រូវទទួលការបំពាក់បំប៉នជាបន្ថែម ដែលរៀបចំឡើងដោយគណៈមេធាវី
- ត្រូវចូលរួមបំរើការងារឱ្យពិតប្រាកដជាសហការីក្នុងការិយាល័យមេធាវីណាមួយ។

**មាត្រា ៣៦:**

កម្មសិក្សាប្រព្រឹត្តទៅក្រោមការត្រួតពិនិត្យរបស់មេធាវីម្នាក់ ដែលក្រុមប្រឹក្សាគណៈមេធាវីចាត់តាំងជាប្រធានទទួលខុសត្រូវលើកម្មសិក្សានោះ។

**មាត្រា ៣៧:**

ក្រោយបញ្ចប់កម្មសិក្សា ក្រុមប្រឹក្សាគណៈមេធាវីសំរេចពីការចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីដោយផ្អែកលើរបាយ-ការណ៍របស់ប្រធានទទួលខុសត្រូវលើកម្មសិក្សា។ ក្រុមប្រឹក្សាគណៈមេធាវី អាចសំរេចឱ្យធ្វើកម្មសិក្សាបន្តទៀតបានតែមិនឱ្យលើសពី ១ឆ្នាំឡើយ ចំពោះកម្មសិក្សាការីណាដែលមិនទាន់មានសមត្ថភាពគ្រប់គ្រាន់។ ការសំរេចមិនចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីចាត់ទុកជាការលុបឈ្មោះមេធាវីនោះចោល។ ការសំរេចមិនចុះឈ្មោះក្នុងបញ្ជី ឬការបន្តកម្មសិក្សាពុំអាចធ្វើទៅបាន ឡើយបើគ្មានការកោះអញ្ជើញសាមីខ្លួន ឱ្យមកបញ្ចេញយោបល់តាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា ៣៣។ សេចក្ដីសំរេចនេះអាចនឹងប្ដឹងតវ៉ាបានតាមលក្ខខណ្ឌ និងនីតិវិធីដែលមានចែងក្នុងមាត្រ២៤ និង ២៥។

**មាត្រា ៣៨:**

រៀលរាល់ឆ្នាំក្រុមប្រឹក្សាគណៈមេធាវីបញ្ចប់បញ្ជីគណៈមេធាវី និងបញ្ជីមេធាវីកម្មសិក្សា ហើយផ្ញើបញ្ជីនោះជូនអគ្គព្រះរាជអាជ្ញា និងសាលាជម្រះក្ដីទាំងអស់។

បញ្ជីនោះមានដូចតទៅ :

- ឈ្មោះមេធាវីដែលបានចុះក្នុងបញ្ជីមេធាវី និងអាស័យដ្ឋានរបស់មេធាវីនេះ
- ឈ្មោះ និងអាស័យដ្ឋានរបស់មេធាវីកម្មសិក្សា។

**មាត្រា ៣៩:**

លេខរៀងនៃការចុះបញ្ជីរបស់មេធាវី ត្រូវកំណត់តាមកាលបរិច្ឆេទដែលបានធ្វើសច្ចាប្រណិធាន ហើយត្រូវបានកំណត់ដោយក្រុមប្រឹក្សាគណៈមេធាវីដែលបានសំរេចឱ្យចុះឈ្មោះ។

**មាត្រា ៥៣:**

វិជ្ជាជីវៈមេធាវីមានវិសមិតភាពជាមួយនឹងមុខងារសាធារណៈ និងការប្រកបមុខរបរ ពាណិជ្ជកម្មទោះការប្រកបនោះ ដោយប្រយោលក្ដី ឬដោយផ្ទាល់ក្ដី។

**មាត្រា ៥៤:**

មេធាវីដែលបានទទួលតួនាទីក្នុងរាជរដ្ឋាភិបាល ឬទទួលអាណត្តិជាអ្នកតំណាងរាស្ត្រនៃរដ្ឋសភា អាចនៅជាសមាជិកនៃគណៈមេធាវីបាន ប៉ុន្តែត្រូវឈប់ប្រកបវិជ្ជាជីវៈនេះរហូតដល់ចប់តួនាទី ឬ អាណត្តិនោះ។

**មាត្រា ៥៧:**

គ្រប់អំពើទាក់ទាញប្រកាសផ្សាយជាឯកត្តជន ឬទទួលសុំការពាររបស់មេធាវីចំពោះអតិថិជនត្រូវហាមឃាត់ ។ មានតែការប្រកាសផ្សាយវិជ្ជាជីវៈជាសមូហភាពទេ ដែលអនុញ្ញាតឱ្យធ្វើបាន។ ការប្រកាសផ្សាយនេះត្រូវធ្វើឱ្យបានត្រឹមត្រូវ ហើយមិនត្រូវឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មេធាវីឡើយ ។

**មាត្រា ៦៨:**

មេធាវីទទួលកំរៃទៅតាមការឯកភាពគ្នាជាមួយអតិថិជន តាមទំហំការងារ តាមទំហំសមត្ថភាព ដែលបានបញ្ចេញក្នុងការងារនេះ តាមការលំបាកនៃការងារតាមលទ្ធផលដែលសំរេចបាន ឬតាមតារាងប្រាក់ម៉ោងកំណត់ដោយគណៈមេធាវីរៀងរាល់ឆ្នាំ។ មេធាវីត្រូវចេញបង្កាន់ដៃអោយអតិថិជន នៅពេលបានប្រាក់កំរៃ។

## **ក្រមសីលធម៌នៃមេធាវី** ( ថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៥)

**មាត្រា ៧: អាថ៌កំបាំងវិជ្ជាជីវៈ**

មេធាវី ត្រូវប្រកាន់ខ្ជាប់ខ្លួនជាដាច់ខាតនូវអាថិកំបាំងវិជ្ជាជីវៈ ។ អាថិកំបាំងនេះ មិនត្រូវអាចឱ្យជនណាស្រង់យកបានឡើយ ទោះបីថាជាអតិថិជនក៏ដោយ ។

មេធាវី ត្រូវកំណត់ឱ្យបានច្បាស់តាមសម្បជញ្ញៈរបស់ខ្លួន នូវកត្តាចាំបាច់សំរាប់ធ្វើការការពារ ។

ពុំមានកាតព្វកិច្ចលាក់អាថិកំបាំងទេ ល្គឹកណាមេធាវីត្រូវឆ្លើយតបទៅនឹងបណ្តឹងរបស់អតិថិជនរបស់ខ្លួន ប៉ុន្តែត្រូវស្ថិតត្រឹមក្នុងកំរិតនៃការចាំបាច់នៃការការពាររបស់ខ្លួនតែប៉ុណ្ណោះ ។

**មាត្រា ១៩:**

នៅពេលដែលមេធាវី ត្រូវអតិថិជនច្រើនគ្នាពឹងពាក់ក្នុងរឿងក្តីតែមួយ ឬក្នុងការប្រតិបត្តិការតែមួយដូចគ្នា មេធាវីមិនត្រូវកាន់ជើងផ្តល់ប្រយោជន៍ឱ្យតែអតិថិជនណាមួយឡើយ ។ អ្វីៗត្រូវតែជូនដំណឹងទៅភាគីទាំងអស់គ្រប់គ្នា ។ មេធាវីមិនអាចផ្តល់យោបល់ ឬជួល ឬតំណាង ឬការពារភាគីច្រើនគ្នា បើប្រសិនជាមានកើតឡើងរវាងភាគីទាំងនោះ នូវទំនាស់ផលប្រយោជន៍គ្នាណាមួយ ។ បើសិនជារឿងនេះកើតឡើងមែន ក្នុងពេលដែលមេធាវីជា ឬធ្លាប់ជាទីប្រឹក្សារបស់ភាគីច្រើនគ្នានោះ មេធាវី នឹងអាចទទួលការពារប្រយោជន៍ភាគីណាមួយបាន លុះត្រាតែត្រូវជំរាបទៅភាគីឯទៀតឱ្យបានដឹងសិន ហើយត្រូវប្រុងប្រយ័ត្នកុំឱ្យបាត់បង់នូវភាពគួរសមថ្លៃថ្នូរ និងអាថិកំបាំងវិជ្ជាជីវៈផង ។

**មាត្រា ២២: កំរៃមេធាវី**

គេអាចធ្វើកិច្ចព្រមព្រៀងគ្នាមុនបញ្ជាក់អំពីចំនួនទឹកប្រាក់សរុបផ្តាច់តែម្តង ឬអំពីរបៀបកំណត់ប្រាក់កំរៃមេធាវី ។

បើមានការមិនចុះសំរុងគ្នា ប្រធានគណៈមេធាវីអាចត្រូវភាគីសុំឱ្យជួយសំរុះសំរួលគ្នាបាន ។

**មាត្រា ២៤: ទំនាក់ទំនងជាមួយចៅក្រម**

មេធាវីដែលត្រូវឡើងសាលាជាលើកដំបូង ត្រូវទៅបង្ហាញខ្លួនដល់ចៅក្រម ។

មេធាវីត្រូវសំដែងជូនចៅក្រមក្នុងភាពឯករាជ្យ និងភាពថ្លៃថ្នូរ នូវការគោរពទៅតាមមុខងារ ។

មេធាវីត្រូវគោរពតាមវិធាននៃនីតិវិធី ហើយនិងទំលាប់នៃតុលាការ ។ មេធាវីមិនត្រូវជាដាច់ខាត ប្រើវិធីមិនស្មោះត្រង់ ហើយត្រូវគោរពវិធីទល់មុខគ្នា ។ មេធាវី មានសិទ្ធិសំដែងឡើងនូវអ្វីៗដែលខ្លួនយល់ថាមានប្រយោជន៍ដល់អតិថិជនរបស់ខ្លួន ។

ក្នុងករណីមានកើតហេតុជាមួយចៅក្រម មេធាវីត្រូវសុំអន្តរាគមន៍ពីប្រធានគណៈមេធាវី ។

វិបត្តិទាំងឡាយដែលកើតឡើងរវាងសហភាគា ក្រៅតែអំពីការអនុវត្តន៍នៃវិធាននីតិវិធីតុលាការត្រូវឡើងទៅរកការសំរុះសំរួលនៃប្រធានគណៈមេធាវី ។

## បទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី ( ថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ១៩៩៥)

**មាត្រា ៩: គណៈមេប្រយោគ**

ប្រធានគណៈមេធាវី បង្កើតគណៈមេប្រយោគមួយ ដែលមានខ្លួនឯង ឬតំណាងរបស់ខ្លួន ជាប្រធាន និងសមាជិក ៣នាក់ គឺ:

- មេធាវី ១នាក់ ចាត់តាំងឡើងដោយប្រធានគណៈមេធាវី
- គ្រូបង្ហាត់ច្បាប់ ១នាក់ ចាត់តាំងឡើងដោយព្រឹទ្ធបុរសនៃមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- ចៅក្រម ១រូប ចាត់តាំងឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

គណៈមេប្រយោគ អាចអញ្ជើញមេប្រយោគជំនាញដើម្បីកែវិញ្ញាសារបាន ។

## ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ (ថ្ងៃទី ១៩ ខែមិនា ឆ្នាំ ១៩៩៨)

**មាត្រា ៣:**

សមាជិកទាំង៩រូប នៃក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវជ្រើសរើសក្នុងចំណោមឥស្សរជន ដែលមានសញ្ជាតិខ្មែរពីកំណើត មានអាយុយ៉ាងតិច ៤៥ឆ្នាំ មានសញ្ញាប័ត្រចាប់ពីឧត្តមសិក្សាឡើងទៅខាងច្បាប់ ខាងរដ្ឋបាល ខាងការទូត ឬខាងសេដ្ឋកិច្ច ហើយដែលមានបទពិសោធន៍ក្នុងការងារយ៉ាងតិច ១៥ឆ្នាំ ។

សមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញ ៣រូប ត្រូវតែងតាំងដោយព្រះមហាក្សត្រ ៣រូប ត្រូវតែងតាំងដោយក្រុមប្រឹក្សានៃអង្គចៅក្រម ហើយ៣រូបទៀតត្រូវតែងតាំងដោយរដ្ឋសភាតាមមតិភាគច្រើនដាច់ខាត នៃសមាជិកនៃរដ្ឋសភាទាំងមូល ។

ការជ្រើសតាំងដោយរដ្ឋសភា អាចធ្វើឡើងជាពីរលើកបាន ។ ក្នុងអាណត្តិទី១ បើការបោះឆ្នោតលើកទី១ មិនបានទទួលមតិភាគច្រើនដាច់ខាតនោះ ត្រូវបោះឆ្នោតជាលើកទី២ ដោយយកអ្នកដែលបានទទួលសំលេងច្រើនជាងគេ ចំនួនយ៉ាងច្រើន ៥រូប មកបោះឆ្នោតឡើងវិញ ។ ការបោះឆ្នោតលើកទី២នេះ ត្រូវយកតាមមតិភាគច្រើនដោយប្រៀប ។ អ្នកដែលទទួលបានសំលេងច្រើនជាងគេ ត្រូវតែងតាំង សំរាប់ ៩ឆ្នាំ អ្នកដែលទទួលបានសំលេងបន្ទាប់ ត្រូវតែងតាំងសំរាប់ ៦ឆ្នាំ និងអ្នកដែលទទួលបានសំលេង បន្ទាប់មកទៀត ត្រូវតែងតាំងសំរាប់ ៣ឆ្នាំ ។

ក្នុងអាណត្តិបន្តបន្ទាប់ បើការបោះឆ្នោតលើកទី១ មិនបានទទួលមតិភាគច្រើនដាច់ខាតនោះ ត្រូវបោះឆ្នោតជាលើកទី ២ ដោយយកអ្នកដែលបានទទួលសំលេងច្រើនជាងគេចំនួន ២នាក់ មកបោះឆ្នោត ឡើងវិញ ។ ការបោះឆ្នោតលើកទី២ នេះ ត្រូវយកតាមមតិភាគច្រើនដោយប្រៀប ។

ក្នុងករណីដែលបេក្ខជនទទួលបានសំលេងស្មើគ្នានោះ ត្រូវយកអ្នកដែលមានអាយុច្រើនជាងគេ ។

បេក្ខជនម្នាក់ៗ ដែលនឹងត្រូវជ្រើសតាំងដោយរដ្ឋសភា ត្រូវមានហត្ថលេខាគាំទ្រជាមុន ពីសមាជិករដ្ឋសភា ចំនួនមួយភាគដប់នៃសមាជិកទាំងមូល ។ សមាជិករដ្ឋសភា ១រូបមានសិទ្ធិគាំទ្របានតែបេក្ខជន ១រូបប៉ុណ្ណោះ ។

**មាត្រា ៥:**

មុខងារសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានវិសមិតភាពជាមួយនឹង មុខងារជាសមាជិករាជរដ្ឋាភិបាល សមាជិករដ្ឋសភា ប្រធាន អនុប្រធានគណបក្សនយោបាយ ប្រធាន អនុប្រធានសហជីព និងចៅក្រមក្នុងតំណែង ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មិនត្រូវបំពេញមុខតំណែង និងមុខរបរផ្សេងទៀតនៅក្នុងអាណត្តិរបស់ខ្លួន ឡើយ ។

អ្នកដែលបានតែងតាំងជាសមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញ មុនចូលកាន់តំណែង ត្រូវសុំលាឈប់ជាបណ្តោះអាសន្ន ពីតំណែង ឬមុខរបរទាំងអស់ ដែលបានចែងក្នុងវាក្យខ័ណ្ឌខាងលើ ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ សមាជិកដែលនៅក្នុងមុខតំណែង និងមុខរបរខាងលើ ឱ្យសុំលាឈប់ពីមុខតំណែង ឬមុខរបរនោះជាបន្ទាន់។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសុំដកខ្លួនចេញពីរឿងទាំងឡាយណា ដែលផលប្រយោជន៍ផ្ទាល់ខ្លួន ពាក់ព័ន្ធក្នុងរឿងនោះ ។ ការសុំដកខ្លួន ឬការតំរូវឱ្យដកខ្លួន ត្រូវសំរេចដោយក្រុមប្រឹក្សាធម្មនុញ្ញ តាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ។

**មាត្រា ១៤:**

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវកោះអញ្ជើញដោយប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ឬ ដោយសមាជិកដែលមានអាយុច្រើនជាងគេ បើប្រធានមានធុរៈមិនអាចធ្វើបាន។

កិច្ចប្រជុំនៃក្រុមប្រឹក្សាធម្មនុញ្ញអាចចាត់ទុកជាបានការ លុះត្រាតែមានសមាជិកចំនួន ៧រូបចូលរួមប្រជុំ។

**មាត្រា ១៥:**

ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលអនុម័តដោយរដ្ឋសភាក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ។

**មាត្រា ១៦:**

ច្បាប់រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងវិសោធនកម្មនៃច្បាប់រៀបចំអង្គការ និងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ក្រោយរដ្ឋសភាបានអនុម័ត ត្រូវដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដោយប្រធានរដ្ឋសភា ដើម្បីពិនិត្យតើច្បាប់ទាំងនោះស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ មុននឹងត្រូវបាន ប្រកាសឱ្យប្រើ។

**មាត្រា ១៧:**

ព្រះមហាក្សត្រ ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី ឬតំណាងរាស្ត្រចំនួនមួយភាគដប់ អាចបញ្ជូនច្បាប់ផ្សេងទៀតដែលរដ្ឋសភាបានអនុម័តទៅជូនក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងប្រកាស អោយប្រើ។

**មាត្រា ១៨:**

ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសអោយប្រើ ព្រះមហាក្សត្រ ប្រធានរដ្ឋសភា នាយក រដ្ឋមន្ត្រី ឬតំណាងរាស្ត្រចំនួនមួយភាគដប់ ឬតុលាការអាចសុំអោយក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ អំពីធម្មនុញ្ញ ភាពនៃច្បាប់នោះបាន។
ប្រជារាស្ត្រមានសិទ្ធិប្តឹងអំពីអធម្មនុញ្ញភាពនៃច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញបាន តាមរយៈប្រធានរដ្ឋសភា ឬតំណាងរាស្ត្រដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ។

**មាត្រា ១៩:**

បុគ្គលដែលជាប់ពាក់ព័ន្ធក្នុងរឿងក្តីណាមួយ ហើយរឿងក្តីនោះឡើងដល់តុលាការ បុគ្គលនោះ អាចលើកអំពីអធម្មនុញ្ញភាពនូវបទប្បញ្ញត្តិណាមួយនៃច្បាប់ ឬសេចក្តីសំរេចរបស់ស្ថាប័ននានា ដែលគេអះអាងថាប៉ះពាល់ដល់សិទ្ធិសេរីភាពជាសារវន្តណាមួយរបស់គេជូនតុលាការបាន ។

បើយល់ឃើញថាការលើកឡើងនេះមានមូលដ្ឋានគ្រប់គ្រាន់ តុលាការត្រូវលើកករណីនេះ ទៅតុលាការកំពូលក្នុងរយៈពេល ១០ថ្ងៃយ៉ាងយូរ។

តុលាការកំពូលត្រូវចាត់ការពិនិត្យ និងប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ១៥ថ្ងៃយ៉ាងយូរ លើកលែងតែតុលាការកំពូលយល់ឃើញថា ពាក្យប្តឹងតវ៉ានោះមិនអាចទទួលបាន ។

**មាត្រា ២១:**

ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិអញ្ជើញជនណាម្នាក់ ឬច្រើននាក់មកបំភ្លឺ ឬផ្តល់ឯកសារដែល ពាក់ព័ន្ធបាន ។

បុគ្គលគ្រប់រូប ស្ថាប័នរដ្ឋ ឬឯកជនទាំងឡាយ ត្រូវគោរព និងប្រតិបត្តិតាមការអញ្ជើញ និងការស្នើសុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

**មាត្រា ២២:**

ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសំរេចសេចក្តីជាលាយលក្ខណ៍អក្សរលើគ្រប់ករណី ដែលត្រូវបានដាក់ជូនក្នុងរយៈពេល ៣០ថ្ងៃ ។ ប្រសិនបើជាការប្រញាប់ រយៈពេលនេះត្រូវ បន្ថយមកត្រឹម ៨ថ្ងៃ ។

ក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យពិចារណាលើធម្មនុញ្ញភាព ដោយផ្អែកលើសេចក្តីរាយការណ៍របស់សមាជិក ដែលប្រធានបានប្រគល់ភារកិច្ចអោយពិនិត្យរាយការណ៍ ។

ក្រុមប្រឹក្សាធម្មនុញ្ញ សំរេចសេចក្តីតាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ។ ក្នុងករណីដែលបែកសំលេងជាពីរស្មើគ្នា សំលេងរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ជាសំលេងឧត្តមានុភាព ។

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបញ្ជាក់អំពីហេតុផល ។

**មាត្រា ២៣:**

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ គឺជាសេចក្តីសំរេចបិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២៤:**

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវធ្វើថ្វាយព្រះមហាក្សត្រ ជូនប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី និងប្រធានតុលាការកំពូល និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

ប្រធានរដ្ឋសភា ត្រូវជូនដំណឹងអំពីសេចក្តីសំរេចនេះដល់សមាជិករដ្ឋសភាទាំងអស់ ។

នាយករដ្ឋមន្ត្រី ត្រូវជូនដំណឹងទៅសមាជិករាជរដ្ឋាភិបាលទាំងអស់ ។

ប្រធានតុលាការកំពូល ត្រូវជូនដំណឹងដល់តុលាការសាមី ។

**មាត្រា ២៥:**

ក្រុមប្រឹក្សាធម្មនុញ្ញ សំរេចអំពីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំង តំណាងរាស្ត្រ ។

**មាត្រា ២៦:**

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសំរេច :

១. លើបណ្តឹងតវ៉ារបស់គណបក្សនយោបាយ ឬរបស់បេក្ខជន ប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសំរេចបដិសេធលើការតវ៉ាពីបេក្ខភាព ឬសំរេចបដិសេធ លើការតវ៉ាពីបញ្ជីរាយនាមបេក្ខជន ។ ការប្តឹងនេះត្រូវធ្វើឡើងក្នុងរយៈពេល ៧ថ្ងៃយ៉ាងយូរ ក្រោយពីបានទទួលលិខិត ជូនដំណឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

២. លើបណ្តឹងតវ៉ារបស់បុគ្គល ប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសំរេចបដិសេធការតវ៉ាសុំចុះឈ្មោះបោះឆ្នោត ។ ការប្តឹងនេះត្រូវធ្វើឡើងក្នុងរយៈពេល ៥ថ្ងៃយ៉ាងយូរ ក្រោយពីបានទទួលលិខិតជូនដំណឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

៣. លើបណ្តឹងតវ៉ារបស់បុគ្គល ឬអ្នកតំណាង ប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសំរេចបដិសេធអំពីការបាត់ឈ្មោះ ឬអំពីការជំទាស់នឹងការចុះឈ្មោះ ឬអំពីការរក្សាទុក ឈ្មោះក្នុងបញ្ជីបោះឆ្នោតនូវ

បុគ្គលណាម្នាក់ដែលគេយល់ឃើញថាមានលក្ខណៈមិនត្រឹមត្រូវតាមលក្ខខណ្ឌនៃច្បាប់បោះឆ្នោត ។ ការប្តឹងនេះ ត្រូវធ្វើឡើងក្នុងរយៈពេល ៥ថ្ងៃយ៉ាងយូរ ក្រោយពីបានទទួលលិខិតជូនដំណឹង ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសំរេចករណីខាងលើក្នុងរយៈ ១០ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យបណ្តឹង។

៤. លើបណ្តឹងតវ៉ារបស់គណបក្សនយោបាយពីការមិនព្រមចុះបញ្ជីគណបក្សនយោបាយ ។ បណ្តឹងនេះ ត្រូវធ្វើឡើងក្នុងរយៈពេល ៥ថ្ងៃយ៉ាងយូរ ក្រោយពីបានទទួលលិខិតជូនដំណឹងរបស់ក្រសួងមហាផ្ទៃ ។

ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសំរេចករណីនេះក្នុងរយៈពេល ៣០ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យបណ្តឹងរបស់សាមីគណបក្សនយោបាយ ។

**មាត្រា ២៧:**

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសំរេច :

១. លើបណ្តឹងតវ៉ាដោយផ្ទាល់អំពីលទ្ធផលនៃការបោះឆ្នោតដែលបុគ្គល ឬគណបក្សនយោបាយ ដែលបានឈរឈ្មោះបោះឆ្នោត មិនសុខចិត្តនឹងលទ្ធផលនៃការបោះឆ្នោត ។ បណ្តឹងនេះ ត្រូវធ្វើឡើងក្នុងរយៈពេល ៧២ម៉ោង យ៉ាងយូរ បន្ទាប់ពីការប្រកាសលទ្ធផលបណ្តោះអាសន្ន ។

២. លើបណ្តឹងតវ៉ារបស់បុគ្គល ឬគណបក្សដែលមិនសុខចិត្តនឹងសេចក្តីសំរេចរបស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលសំរេចបដិសេធការតវ៉ាអំពីលទ្ធផលនៃការបោះឆ្នោត ។ ការប្តឹងតវ៉ានេះ ត្រូវធ្វើឡើងក្នុងរយៈពេល ៤៨ម៉ោងយ៉ាងយូរ ក្រោយពីបានទទួលលិខិតជូនដំណឹង ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសំរេចករណីខាងលើក្នុងរយៈពេល ២០ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យបណ្តឹង។

**មាត្រា ២៨:**

បុគ្គលណា ឬគណបក្សនយោបាយណា ដែលមិនសុខចិត្តនឹងសេចក្តីសំរេច របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬមិនសុខចិត្តនឹងលទ្ធផលនៃការបោះឆ្នោត ត្រូវធ្វើពាក្យប្តឹងជាលាយលក្ខណ៍អក្សរ ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញ ។ ពាក្យសុំនេះត្រូវបញ្ជាក់:

១. ឈ្មោះបុគ្គល ឬឈ្មោះគណបក្សនយោបាយ ដែលជាអ្នកប្តឹងតវ៉ា

២. ឋានៈតាមផ្លូវច្បាប់របស់អ្នកប្តឹងតវ៉ា(ជាអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ឬជាបេក្ខជន ឬជាតំណាង គណបក្សនយោបាយ)

៣. ឈ្មោះមណ្ឌលបោះឆ្នោតដែលមានការប្តឹងតវ៉ា

៤. ឈ្មោះបុគ្គល ឬគណបក្សនយោបាយ ដែលត្រូវបានគេប្រកាសថាជាប់ឆ្នោត ហើយដែលគេប្តឹងតវ៉ា

៥. គ្រប់ឯកសារ ឬភស្តុតាងសំរាប់គាំទ្រការសុំបដិសេធ។

ក្រុមប្រឹក្សាធម្មនុញ្ញផ្អែកតាមឆន្ទានុសិទ្ធិរបស់ខ្លួន អាចទុកពេល ៥ថ្ងៃ ឱ្យបុគ្គល ឬគណបក្សនយោបាយ ដែលជាអ្នកប្តឹង ដើម្បីផ្តល់ភស្តុតាង ។

ក្រុមប្រឹក្សាធម្មនុញ្ញ អាចសំរេចមិនធ្វើការស៊ើបអង្កេតលើបណ្តឹងណាមួយ បើបណ្តឹងនោះមិនបំពេញលក្ខខណ្ឌកំណត់ក្នុងមាត្រានេះ។

គ្រប់ករណីទាំងអស់ដែលប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញ មិនតំរូវឱ្យបង់ប្រាក់ទេ ។

**មាត្រា ២៩:**

ពាក្យប្តឹងតវ៉ា គ្មានអានុភាពផ្អាកការអនុវត្តទេ ។ ប៉ុន្តែក្នុងពេលរង់ចាំ សេចក្តីសំរេចស្ថាពរ ក្រុមប្រឹក្សាធម្មនុញ្ញបើយល់ឃើញថាចាំបាច់ អាចចេញបញ្ជាជាបឋមមួយ ដើម្បីព្យួរជាបណ្តោះអាសន្ននូវលទ្ធផល នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រណាម្នាក់ ឬគណបក្សនយោបាយណាមួយ ដែលគេប្តឹងតវ៉ាបាន ។ បញ្ជានេះនឹងត្រូវបញ្ចប់អានុភាព នៅពេលដែលក្រុមប្រឹក្សាធម្មនុញ្ញ ចេញសេចក្តីសំរេចជាស្ថាពរ ។

**មាត្រា ៣០:**

ដើម្បីស្រាវជ្រាវស៊ើបអង្កេត អំពីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ក្រុមប្រឹក្សាធម្មនុញ្ញចែកចេញជា ៣ក្រុម ។ ក្រុមនីមួយៗមានសមាជិក ៣រូប ដែល ១រូប ជាសមាជិក តែងតាំងដោយព្រះមហាក្សត្រ ១រូបជាសមាជិកជ្រើសតាំងដោយរដ្ឋសភា និង ១រូបទៀត ជាសមាជិកតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ សមាជិកក្នុងក្រុមទាំង ៣ នេះត្រូវជ្រើសរើសដោយវិធីចាប់ឆ្នោត ក្រោមអធិបតីភាពនៃប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។

**មាត្រា ៣១:**

ក្រោយពីបានទទួលពាក្យបណ្តឹង ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវប្រគល់សិទ្ធិទៅឱ្យក្រុមណាមួយទទួលខុសត្រូវធ្វើការស៊ើបអង្កេត ។ ក្រុមនោះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ជាបន្ទាន់ដល់អ្នកប្តឹងតវ៉ា និងដល់ជន ឬគណបក្ស ដែលត្រូវគេប្តឹងតវ៉ាថា គេមានពេលយ៉ាងយូរ ១០ថ្ងៃ ដើម្បីពិនិត្យលើសេចក្តីប្តឹងតវ៉ា និងភស្តុតាងដែលភាគីបានផ្ញើជូនក្រុមប្រឹក្សា-ធម្មនុញ្ញ និងដើម្បី រៀបចំលិខិតឆ្លើយតបជាលាយ លក្ខណ៍អក្សរ ។

**មាត្រា ៣២:**

ក្រោយពីបានទទួលលិខិតឆ្លើយតបទាំងលើនេះ ឬក្រោយផុតកំណត់រយៈពេល ១០ថ្ងៃ និងក្រោយធ្វើការស៊ើបអង្កេតចប់សព្វគ្រប់ហើយ ក្រុមដែលទទួលបន្ទុកត្រូវដាក់លទ្ធផលនៃការស៊ើបអង្កេត ព្រមទាំងយោបល់របស់ក្រុមនេះ ជូនក្រុមប្រឹក្សាធម្មនុញ្ញពេញអង្គ ។ ក្រុមប្រឹក្សាធម្មនុញ្ញអាចអោយ ធ្វើការស៊ើបអង្កេតបន្ថែមទៀត ហើយអាចស្តាប់អ្នកប្តឹងតវ៉ា និងអ្នកដែលត្រូវគេប្តឹងតវ៉ា ដោយផ្ទាល់បាន ។

**មាត្រា ៣៣:**

ក្នុងពេលធ្វើការស៊ើបអង្កេត ក្រុមប្រឹក្សាធម្មនុញ្ញ ឬក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញ អាចធ្វើការសាកសួរលើគ្រប់បញ្ហាទាំងអស់ ទារឯកសារ និងរបាយការណ៍ផ្សេងៗ និងកោះអញ្ជើញ ជនទាំងឡាយដែលពាក់ព័ន្ធក្នុងការបោះឆ្នោត ។

ក្រុមប្រឹក្សាធម្មនុញ្ញ ឬក្រុម នៃក្រុមប្រឹក្សាធម្មនុញ្ញអាចចាត់តាំងបុគ្គលិករបស់ខ្លួន ឬបុគ្គលផ្សេងទៀត ឱ្យជួយក្នុងការស៊ើបអង្កេត ជាពិសេសនៅពេលទទួលចំលើយរបស់សាក្សី ដែលបានធ្វើសច្ចាប្រណិធានហើយ ។ កំណត់ហេតុជាលាយលក្ខណ៍អក្សរ នៃចំលើយរបស់សាក្សី ត្រូវតំកល់ទុកសំរាប់ភាគីទាំងអស់ ។ បើអ្នកស៊ើបអង្កេត ឬសមាជិកក្នុងក្រុមណាម្នាក់ដឹងថាសាក្សីមានការភ័យខ្លាចគេធ្វើបាប ឈ្មោះសាក្សីនោះ ត្រូវរក្សាទុកជាសំងាត់មិនឱ្យនរណាដឹងទាំងអស់ ក្រៅពីក្រុមប្រឹក្សាធម្មនុញ្ញ គឺឱ្យដឹងតែអំពីខ្លឹមសារនៃចំលើយ ប៉ុណ្ណោះ ។

**មាត្រា ៣៤:**

ក្រុមប្រឹក្សាធម្មនុញ្ញ សំរេចសេចក្តីក្នុងករណីដែលមានការតវ៉ា អំពីនិយតភាពនៃការបោះឆ្នោត អំពីភាពអាចជ្រើសតាំងបាននៃបេក្ខជនសំរាប់បោះឆ្នោត និងភាពអាចជ្រើសតាំងបាននៃបេក្ខជន ដែលប្រកាសថាជាប់ឆ្នោត ។

ក្រុមប្រឹក្សាធម្មនុញ្ញ អាចយល់ស្រប ឬមិនយល់ស្របតាមសេចក្តីសំរេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចប្រកាសមោឃភាពនៃការបោះឆ្នោតដែលគេប្តឹងតវ៉ា ឬប្រកាសថា បេក្ខជនជាប់ឆ្នោតដោយត្រឹមត្រូវ ។

ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសំរេចសេចក្តីតាមមតិភាគច្រើនដាច់ខាត នៃសមាជិកទាំងមូល ។ សេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបញ្ជាក់អំពីហេតុផល ។

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសំរេចស្ថាពរបិទផ្លូវតវ៉ា ។

សេចក្តីសំរេចនេះ ត្រូវថ្វាយព្រះមហាក្សត្រ បញ្ជូនទៅរដ្ឋសភា និងរាជរដ្ឋាភិបាល ហើយត្រូវចុះក្នុងរាជកិច្ច ។

**អនុក្រឹត្យស្តីពី ការផ្តល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**
( ថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០០១)

**មាត្រា ១:**

តែងតាំង លោក បែនសុន សម័យ សមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា មាន អត្តលេខ ៥៤ បន្ថែមលើមុខងារបច្ចុប្បន្នជា សារការី ដែលហៅថា "មេធាវីសារការី" ។

**មាត្រា ២:**

មេធាវីសារការី ជាមន្ត្រីសាធារណៈ ទទួលបាននូវអំណាចសាធារណៈតាមការតែងតាំងអនុក្រឹត្យនេះ ។

**មាត្រា ៣:**

មេធាវីសារការី មានសមត្ថកិច្ចការងារទូទៅក្នុងវិស័យផ្នែកគ្រួសារ ចលនវត្ថុ និងអចលនវត្ថុ ជាអាទិ៍មាន:

ក-ទទួល និងធ្វើ ឬចារឹកបញ្ជាក់ និងប្រថាប់ត្រា នូវលិខិតស្នាមគតិយុត្តិ ឬកិច្ចសន្យាទាំងឡាយ ដើម្បីជាបន្ទាល់ពេញលក្ខណៈតាមផ្លូវច្បាប់ ដែលតែងតែមានលិខិតរបស់រាជការអំណាចសាធារណៈ ។

ខ-ធ្វើការបញ្ជាក់លើការិយបរិច្ឆេទ ទទួលតំកល់ទុកឯកសារ និងចេញឱ្យនូវសេចក្តីដើម ឬសេចក្តីចម្លងនៃលិខិត ឬកិច្ចសន្យាទាំងឡាយនោះតាមមុខការ ។

គ-កិច្ចការនេះត្រូវពិនិត្យ អានឱ្យអស់សេចក្តី និងចុះហត្ថលេខានៃគូភាគីនៅចំពោះមុខ ទើប មេធាវីសារការី ចុះហត្ថលេខា ប្រថាប់ត្រា ចារឹកនាពេលនោះជាចុងក្រោយ ។

**មាត្រា ៤:**

មេធាវីសារការី ត្រូវតំកល់ប្រាក់ធានាចំនួន ៦០០, ០០០, ០០០,០០ ( ប្រាំមួយរយលានរៀល) នៅធានាគារជាតិនៃកម្ពុជា សំរាប់ទទួលខុសត្រូវក្នុងមុខការនេះ ។

**មាត្រា ៥:**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ** ( ថ្ងៃទី ២៨ ខែមករា ឆ្នាំ១៩៩៣)

**មាត្រា ៧:**

បណ្តឹងអាជ្ញាមិនអាចសំរុះសំរួលបានដោយកិច្ចការណាមួយឡើយ ។

សាលាជំរះក្តី បង្រ្កាបបទល្មើសព្រហ្មទណ្ឌ ដែលនឹងមានចែងក្នុងមាត្រាខាងមុខ កាលបើបានទទួលដឹងអំពីបទល្មើសព្រហ្មទណ្ឌណាមួយហើយ ត្រូវជំនុំជំរះបទល្មើសព្រហ្មទណ្ឌនោះ។ ការមិនគោរពតាមគោលការណ៍នេះ ត្រូវទុកជាបទល្មើសមិនព្រមជំនុំជំរះ ហើយបទល្មើសនេះ ត្រូវផ្តន្ទាទោសដាក់វិន័យរដ្ឋបាល ឬដាក់គុកពី ៦ថ្ងៃ ដល់ ១ខែ។

**មាត្រា ៨:**

ការធ្វើបណ្តឹងអាជ្ញា និងការជំរុញបណ្តឹងអាជ្ញានេះឱ្យមានដំណើរការ ជាមុខងាររបស់អយ្យការ។

តាមគោលការណ៍ នៅមហាអយ្យការ អគ្គរដ្ឋអាជ្ញារង និងរដ្ឋអាជ្ញាធ្វើការក្នុងនាម និងក្រោមការទទួលខុសត្រូវរបស់អគ្គរដ្ឋអាជ្ញា ទោះជានៅក្នុងពេលដែលអគ្គរដ្ឋអាជ្ញាវត្តមាន ឬអវត្តមានក៏ដោយ។ នៅអយ្យការខេត្ត-ក្រុង រដ្ឋអាជ្ញារងធ្វើការក្នុងនាម និងក្រោមការទទួលខុសត្រូវរបស់រដ្ឋអាជ្ញា ទោះជានៅក្នុងពេលដែលរដ្ឋអាជ្ញាវត្តមាន ឬអវត្តមានក៏ដោយ។

**មាត្រា ៩:**

បុគ្គលដែលយល់ឃើញថាខ្លួន ត្រូវបានរងគ្រោះដោយអំពើល្មើស អាចដាក់ពាក្យប្តឹងជាមួយ ការចោទប្រកាន់របស់រដ្ឋអាជ្ញា ដើម្បីទាមទារសំណងជម្ងឺចិត្ត។

**មាត្រា ១៣:**

មិនមែនគ្រាន់តែត្រូវអោយមានជាមួយគ្នានូវបទល្មើសព្រហ្មទណ្ឌ និងការខូចខាត ដែលបណ្តាលមកពីបទល្មើសព្រហ្មទណ្ឌនោះតែប៉ុណ្ណោះទេ ប៉ុន្តែត្រូវអោយមានថែមទៀតផងដែរ រវាងបទ ល្មើសទាំងពីរនេះ នូវទំនាក់ទំនងពីហេតុទៅផល ឬមានន័យម្យ៉ាងទៀតថា ត្រូវឱ្យការខូចខាតនោះជាលទ្ធផលផ្ទាល់នៃបទល្មើស ហើយវាកើតមានពិតប្រាកដ និងក្នុងបច្ចុប្បន្ន។

**មាត្រា ៤៧:**

មានតែក្នុងករណីបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែងប៉ុណ្ណោះទេ ទើបមន្ត្រីនគរបាលយុត្តិធមិមានសិទ្ធិចាប់ខ្លួនជនប្រព្រឹត្តបទល្មើស។ មន្ត្រីនគរបាលយុត្តិធមិត្រូវនាំខ្លួនជនល្មើសក្នុងរយៈពេល ៤៨ម៉ោងយ៉ាងយូរ ទៅប្រគល់ជូនចៅក្រមមានសមត្ថកិច្ច ដោយមិនគិតដល់ពេលវេលាចាំបាច់សំរាប់បញ្ជូនជនល្មើសតាមមធ្យោបាយយ៉ាងឆាប់បំផុតដែលអាចធ្វើបាន។

ក្នុងករណីមិនគោរពវិធានខាងលើនេះទេ នោះត្រូវទទួលការផ្តន្ទាទោសតាម មាត្រា ២២ និងមាត្រា ៥៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

**មាត្រា ៥៥:**

បន្ទាប់ពីបានដឹងថា មានការប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយភ្លាម រដ្ឋអាជ្ញាត្រូវចាត់ការខាងវិធានការស៊ើបអង្កេត ដែលច្បាប់បានប្រគល់អោយខ្លួន ហើយដែលជាវិធានចាំបាច់ក្នុងការរកឱ្យឃើញនូវការពិត។ ក្នុងករណីដែលមានបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលមានទម្ងន់ពិសេស រដ្ឋអាជ្ញាត្រូវជូនដំណឹងនេះភ្លាម ទៅអគ្គរដ្ឋអាជ្ញាអមសាលាឧទ្ធរណ៍ និងរដ្ឋមន្ត្រីក្រសួងយុត្តិធមិ។ រដ្ឋអាជ្ញាត្រូវចាត់ការតាមបង្គាប់ទាំងឡាយ ដែលខ្លួនបានទទួលពីអង្គការនេះ អំពីបទល្មើសខាងលើ។ ក្នុងករណីរដ្ឋអាជ្ញាមានធុរៈដោយមានជម្ងឺ ឬដោយមូលហេតុអ្វីផ្សេងទៀតនោះ រដ្ឋអាជ្ញារងត្រូវចាត់ការជំនួស។ ប្រសិនបើមានរដ្ឋអាជ្ញារងច្រើន រដ្ឋអាជ្ញារងដែលចាស់ជាងគេ ក្នុងបណ្តាសក្តិខ្ពស់ជាងគេ ត្រូវជំនួសរដ្ឋអាជ្ញា។

ប្រសិនបើគ្មានរដ្ឋអាជ្ញារងទេ រដ្ឋមន្ត្រីក្រសួងយុត្តិធមិត្រូវចេញសេចក្តីសំរេចអោយចៅក្រមណាមួយ នៅសាលា-ជំរះក្តីនោះ ទៅជំនួសរដ្ឋអាជ្ញាភ្លាម។ ក្នុងករណីដែលមានការប្រញាប់បំផុត ប្រធានតុលាការនៃសាលាជំរះក្តីនេះ អាចចាត់តាំងចៅក្រមម្នាក់ឱ្យជំនួយរដ្ឋអាជ្ញាបណ្តោះអាសន្នសិនបាន ហើយត្រូវជំរាបទៅរដ្ឋមន្ត្រីក្រសួងយុត្តិធមិភ្លាម។

**មាត្រា ៥៦:**

រដ្ឋអាជ្ញាមានបេសកកម្ម ត្រូវទទួលពាក្យបណ្តឹង និងពាក្យបណ្តឹងបរិហារទាក់ទងនឹង បទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ ទោះជាពាក្យនោះចេញមកពីជនណាម្នាក់ ចេញមកពីមន្ត្រីនគរបាលយុត្តិធមិ ឬក៏ចេញពីមន្ត្រីឯទៀត ដែលមានសមត្ថកិច្ចចាត់ការរឿងព្រហ្មទណ្ឌ។

រដ្ឋអាជ្ញាមានបេសកកម្មផងដែរ:

- ទទួលកំណត់ហេតុធ្វើដោយមន្ត្រីនគរបាលយុត្តិធមិ ដែលពិនិត្យបញ្ជាក់បទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ។
- ធ្វើដោយខ្លួនឯងនូវការស៊ើបអង្កេតបឋម បានតែក្នុងករណីបទឧក្រិដ្ឋ និងបទមជ្ឈិមជាក់ស្តែងប៉ុណ្ណោះ ទេ។
- កេណ្ឌកម្លាំងសាធារណៈ ដើម្បីបំពេញភារកិច្ចរបស់ខ្លួន។

**មាត្រា ៦១:**

ក្នុងករណីបទល្មើសមជ្ឈិម រដ្ឋអាជ្ញាអាច ឬមួយចោទប្រកាន់ជនល្មើសហើយបញ្ជូនផ្ទាល់ ទៅតុលាការព្រហ្មទណ្ឌដើម្បីជំនុំជំរះ ឬមួយចាត់ការដូចមានចែងក្នុង មាត្រា ៦០ ខាងលើនេះ។

រដ្ឋអាជ្ញាចោទប្រកាន់ និងបញ្ជូនជនល្មើសផ្ទាល់ទៅតុលាការ ដើម្បីជំនុំជំរះបាននោះ កាលខ្លួនឃើញថា សំណុំរឿងមូលសព្វគ្រប់ហើយ ហើយបទល្មើសមានធាតុផ្សំគ្រប់គ្រាន់។

រដ្ឋអាជ្ញាមានសិទ្ធិផងដែរ សួរយកព័ត៌មានបន្ថែម មុននឹងបញ្ជូនរឿងទៅតុលាការ។ ចំពោះករណីនេះ រដ្ឋអាជ្ញាអាចបញ្ជាឱ្យមន្ត្រីនគរបាលយុត្តិធម៌ ផ្តល់អោយខ្លួននូវពត៌មានចាំបាច់ទាំងឡាយ។ លុះបាន ទទួលព័ត៌មានសព្វគ្រប់ហើយ ទើបរដ្ឋអាជ្ញាបញ្ជូនរឿងទៅសាលាជំរះក្តីដើម្បីជំនុំជំរះ ដោយមាន មូលដ្ឋានច្បាស់លាស់។

**មាត្រា ៦២:**

ក្នុងករណីដែលមានបទឧក្រិដ្ឋជាក់ស្តែងកើតឡើងហើយ ប្រសិនបើចៅក្រមស៊ើបអង្កេត ពុំទាន់បានទទួលរឿងនៅឡើយទេ នោះរដ្ឋអាជ្ញាអាចចេញដីកានាំខ្លួនជនដែលសង្ស័យបាន។

រដ្ឋអាជ្ញាត្រូវសួរយកចម្លើយពីជននោះភ្លាម។ ប្រសិនបើជននោះ មានអ្នកការពារសិទ្ធិអមមកជាមួយផង រដ្ឋអាជ្ញាត្រូវសួរជននោះនៅចំពោះមុខអ្នកការពារសិទ្ធិរបស់គេ។ រដ្ឋអាជ្ញា អាចសួរយកចម្លើយសាក្សីដែលមានវត្តមាននៅទីនោះ និងចេញដីកាចាត់វិធានការបណ្តោះអាសន្នទាំងឡាយ ដើម្បីធានារក្សាឱ្យបាន នូវមុខសញ្ញាភស្តុតាងទាំងឡាយ។

រដ្ឋអាជ្ញាអាចចូលពិនិត្យក្នុងផ្ទះនៃឧក្រិដ្ឋជន ហើយធ្វើការរឹបអូសនូវវត្ថុតាងទាំងឡាយចាំបាច់សំរាប់បំភ្លឺ ការពិត។

រដ្ឋអាជ្ញាអាចសួរយកចម្លើយ ពីជនទាំងឡាយដែលអាចផ្តល់ព័ត៌មាន មានប្រយោជន៍ ប៉ុន្តែមិនអាចបង្គាប់ឱ្យគេហៅសាក្សី ឬបញ្ជាឱ្យអ្នកដែលខ្លួនសួរនោះស្បថឡើយ។ រដ្ឋអាជ្ញាមានសិទ្ធិស្នើឱ្យអ្នក បច្ចេកទេសវាយតម្លៃលើវត្ថុតាងអ្វីមួយដែលរដ្ឋអាជ្ញាយល់ឃើញថាចាំបាច់។

រដ្ឋអាជ្ញា មានសិទ្ធិហាមមិនឱ្យជនទាំងឡាយចេញពីកន្លែងកើតហេតុ។ បើមិនគោរពបំរាមនេះទេ រដ្ឋអាជ្ញាអាចចេញអាជ្ញាឃាត់ជននោះ ២៤ ម៉ោងបាន។

ក្រោយពីបានធ្វើកំណត់ហេតុរបស់ខ្លួនចប់ ស្តីពីការចុះដល់ទីកន្លែងនោះ រដ្ឋអាជ្ញាត្រូវបញ្ជូនជាប្រញាប់នូវសំណុំរឿង ព្រមទាំងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅចៅក្រម ដែលនឹងធ្វើការស៊ើបសួរបន្ថែម និងធ្វើវាល់លិខិតឯកសារឡើងវិញ កាលបើចៅក្រមនេះយល់ឃើញថានៅមានខ្វះចន្លោះ។

កាលណាចៅក្រមស៊ើបអង្កេតបានទទួលរឿង ហើយមានវត្តមាននៅនឹងកន្លែងកើតហេតុ នោះរដ្ឋអាជ្ញាក្តី មន្ត្រី-នគរបាលយុត្តិធម៌ក្តី ត្រូវប្រគល់ការងារស៊ើបអង្កេតទាំងស្រុងជូនចៅក្រម។

**មាត្រា ៦៣:**

ប្រសិនបើជនល្មើស ត្រូវបានចាប់ខ្លួនជាមុនដោយមានកំណត់ហេតុត្រឹមត្រូវ ហើយត្រូវបាននាំខ្លួនទៅជូនរដ្ឋអាជ្ញា រដ្ឋអាជ្ញាត្រូវពិនិត្យមើលជាបន្ទាន់ភ្លាមថា តើអំពើដែលគេដាក់បន្ទុកទៅលើជន នោះមានគ្រប់គ្រាន់ហើយឬទេ។ ប្រសិនបើអំពើប្រព្រឹត្តនោះ ជាអំពើប្រព្រឹត្តជាក់ស្តែង ហើយអំពើនោះ ចូលជាបទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសដាក់គុក រដ្ឋអាជ្ញាសួរយកចម្លើយពីជនល្មើស សួរជាអាទិ៍:

- អត្តសញ្ញាណគោត្តនាម និងនាម អាយុ វិជ្ជាជីវៈ និងទីលំនៅ ទីកន្លែង និងកាលបរិច្ឆេទនៃកំណើតរបស់ ជនល្មើស។
- គោត្តនាម និងនាមរបស់ឪពុក-ម្តាយនៃជនល្មើស។
- ប្រវត្តិរូបសង្ខេប ស្តីពីពត៌មានថា តើជននេះធ្លាប់មានទោសពីមុនមកដែរ ឬទេ។ បន្ទាប់មករដ្ឋអាជ្ញាសួរ យកចម្លើយអំពី:
- បទល្មើសដែលជាបន្ទុកទៅលើជនល្មើស
- កាលៈទេសៈទាំងឡាយទាក់ទងនឹងបទល្មើស

រដ្ឋអាជ្ញាត្រូវធ្វើកំណត់ហេតុ ហើយចុះហត្ថលេខាជាមួយក្រឡាបញ្ជីម្នាក់ ដែលជាអ្នកសរសេរកំណត់ហេតុនោះ។ កំណត់ហេតុនេះ ក៏ត្រូវឱ្យមានជនល្មើសចុះហត្ថលេខាដែរ ប្រសិនបើជនល្មើសមិនចេះចុះហត្ថលេខា ត្រូវចុះ និងនិទ្ទេសក្នុងកំណត់ហេតុហើយឱ្យជនល្មើសផ្តិតមេដៃជាសំគាល់។

**មាត្រា ៦៧:**

រដ្ឋអាជ្ញា នឹងអាចប្រើនីតិវិធីចោទប្រកាន់ផ្ទាល់ទៅតុលាការតែម្តងនោះបាន តែក្នុងករណីដែលជនជាប់ចោទអាចនឹងត្រូវផ្តន្ទាទោសដាក់គុក ដែលអតិបរមានៃទោសមិនលើសពី ១ឆ្នាំ បើពុំនោះទេ រដ្ឋអាជ្ញាត្រូវបញ្ជូនរឿងទៅចៅក្រមស៊ើបអង្កេតសិន។

**មាត្រា ៧៦:**

នៅពេលចូលខ្លួនជាលើកដំបូងនេះ ក្រោយពីបានបញ្ជាក់អំពីអត្តសញ្ញាណ និងក្រោយពីបានទទួលដំណឹងអំពីអំពើដែលខ្លួនត្រូវជាប់ចោទប្រកាន់ ប្រសិនបើជនជាប់ចោទជំរាបចៅក្រមអង្កេតថា: ខ្លួនសុំជ្រើសរើសមេធាវីមួយ ឬថាខ្លួនសុំឱ្យរដ្ឋចាត់តាំងមេធាវីមួយដើម្បីការពារខ្លួននោះ ចៅក្រមស៊ើបអង្កេតត្រូវផ្អាកការសួរយកចម្លើយសិន ហើយត្រូវហៅក្នុងរយៈពេលដ៏ខ្លីជាទីបំផុត នូវមេធាវីនោះ មកស្តាប់ការសួរយកចម្លើយលើជនជាប់ចោទ ដែលនឹងធ្វើនៅចំពោះមុខមេធាវីនោះ។

ការចាត់តាំងដោយឯកឯងនូវមេធាវី ត្រូវធ្វើដោយប្រធានតុលាការក្នុងករណីដូចតទៅ:

- ជនរងគ្រោះជាអនីតិជនគ្មានទីពឹង
- ជនជាប់ចោទជាអនីតិជនគ្មានទីពឹង
- ជនជាប់ចោទជាមនុស្ស គ ថ្លង់ មនុស្សខ្វាក់ ឬជនមានវិបត្តិស្មារតី
- ជនជាប់ចោទត្រូវជាប់ចោទពីបទប្រព្រឹត្តបទឧក្រិដ្ឋណាមួយ ហើយខ្លួនគ្មានលទ្ធភាពអាចពឹងអ្នកជួយ ការពារខ្លួនបាន។

ក្នុងករណីផ្សេងពីករណីដូចមានលើកខាងលើនេះ ចៅក្រមស៊ើបអង្កេត អាចសួរយកចម្លើយជនជាប់ចោទបានកាលណាជននេះសុខចិត្តការពារខ្លួនដោយខ្លួនឯង។

**មាត្រា ៩៨:**

ជាគោលការណ៍ មានវិសមិតភាពដាច់ខាតរវាងមុខងារចៅក្រម និងមុខងារតំណាងអយ្យការ។

តំណាងអយ្យការ ដែលបានបំពេញមុខងាររបស់ខ្លួននៅពេលណាក៏ដោយនៃនីតិវិធី ពុំអាចធ្វើជាចៅក្រម នៅក្នុងរឿងដដែលនោះបានឡើយ។

មានវិសមិតភាពផងដែរ រវាងមុខងារចៅក្រមស៊ើបអង្កេត និងមុខងារចៅក្រមជំនុំជំរះ។

**មាត្រា ១២៦:**

នៅតុលាការព្រហ្មទណ្ឌទាំងឡាយ ក្រឡាបញ្ជីត្រូវទទួលកត់ត្រានៅពេលសវនាការ សំដៅឱ្យសាលាឧទ្ធរណ៍ អាចធ្វើការត្រួតពិនិត្យមានប្រសិទ្ធភាព អំពីនីត្យានុកូលភាពនៃនីតិវិធី និងអាចបានដឹងយ៉ាងគ្រប់គ្រាន់តាមត្រូវការ នូវការស៊ើប-អង្កេតដោយផ្ទាល់មាត់ ដែលបានប្រព្រឹត្តទៅនាពេលសវនាការ ក្រឡាបញ្ជីត្រូវខិតខំស្រង់ដោយយកចិត្តទុកដាក់ខ្ពស់បំផុតនូវដំណើរការនៃនីតិវិធី ហើយកត់ត្រាចម្លើយសាក្សីទាំងឡាយ និងចម្លើយរបស់ជនល្មើស។

សេចក្តីកត់ត្រាខាងលើនេះ ត្រូវបានចុះហត្ថលេខាដោយក្រឡាបញ្ជី និងបញ្ជាក់ដោយចៅក្រម ក្រោយពីបានពិនិត្យពិច័យរួចក្នុងរយៈពេលដប់ថ្ងៃក្រោយសវនាការ ដែលសាលក្រមនោះបានប្រកាស ហើយកិច្ចការនេះបើមិនធ្វើទេ ក្រឡាបញ្ជីត្រូវទទួលវិន័យរដ្ឋបាល។

**មាត្រា ១២៧:**

សេចក្តីកត់ត្រាដែលមានចុះហត្ថលេខាដោយក្រឡាបញ្ជី និងបញ្ជាក់ដោយចៅក្រម ត្រូវទុកជាបន្ទាល់នូវខ្លឹមសាររបស់វា រហូតដល់មានភស្តុតាងផ្ទុយ។ ក្នុងករណីមានសេចក្តីមិនស្របគ្នារវាង សេចក្តីកត់ត្រា និងសាលក្រមដើម គេត្រូវយកសេចក្តីនៅក្នុងសាលក្រមដើមទុកជាបានការ។

**មាត្រា ១២៨:**

ការស៊ើបអង្កេតនៅពេលសវនាការត្រូវធ្វើជាសាធារណៈ បើពុំដូច្នោះទេ នឹងត្រូវទុកជាមោឃៈ។ ការផ្សាយជាសាធារណៈនេះ មិនមែនសំរាប់តែសវនាការ ដែលប្រកាសសាលក្រមទេ ប៉ុន្តែសំរាប់សវនាការដែលធ្វើការស៊ើបអង្កេតនិងការសួរដេញដោល។ ដូចនេះសាលក្រម ត្រូវតែមានបញ្ជាក់អំពីការផ្សាយជាសាធារណៈនេះ ពីព្រោះបើគ្មានសេចក្តីបញ្ជាក់នេះទេ សាលក្រមនោះ ត្រូវទុកជាមោឃៈ។

**មាត្រា ១២៩:**

ប៉ុន្តែការជំនុំជំរះ អាចធ្វើជាសម្ងាត់ កាលបើការធ្វើជាសាធារណៈអាចនាំឱ្យមាន គ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់ប្រពៃណីល្អ។ សវនាការជាសម្ងាត់ធ្វើតែទៅលើភាគមួយ នៃការសួរដេញដោលប៉ុណ្ណោះ។ មានន័យម្យ៉ាងទៀតថា ថេរៈវេលានៃការធ្វើជាសម្ងាត់ អាចត្រឹមតែក្នុងពេលស៊ើបអង្កេតប៉ុណ្ណោះ រីឯការប្រកាសសាលក្រម ត្រូវធ្វើជាសាធារណៈ បើពុំនោះទេត្រូវទុកជាមោឃៈ។

**ច្បាប់ស្តីពីរបបសារព័ត៌មាន** ( ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ១៩៩៥)

**មាត្រា ១០:**

ជនណាម្នាក់ដែលយល់ថាអត្ថបទណាមួយ ទោះជាសរសេរបញ្ជិតបញ្ចៀងក៏ដោយ រូបគំនូរណាមួយដែលមានលក្ខណៈខុសពីការពិត ធ្វើឱ្យខូចខាតដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្លួន មាន សិទ្ធិទាមទារឱ្យសារព័ត៌មាននោះ ធ្វើការកែតំរូវឬមានសិទ្ធិឆ្លើយតប និងធ្វើបណ្តឹងពីបទបរិហាកេរ្តិ៍ ពីបទមួលបង្កាច់ ឬពីបទជេរប្រមាថ ចំពោះការប៉ះពាល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្លួន។ ចម្លើយកែតំរូវ ឬឆ្លើយតបត្រូវចុះផ្សាយក្នុងរយៈពេលប្រាំពីរថ្ងៃ (៧ថ្ងៃ) យ៉ាងយូរឬនៅលេខបន្ទាប់ ក្រោយពីបានទទួលការទាមទារឱ្យកែតំរូវឬឆ្លើយតប។

ចំពោះករណីដែលពាក់ព័ន្ធដល់បុគ្គលសាធារណៈ គ្រប់ការពោលអះអាងឬការទំលាក់កំហុសដែលអ្នកសារព័ត៌មានយកមកចុះផ្សាយដោយផ្ទាល់ ឬក៏យកមកចុះផ្សាយបន្តខុសពីការពិតក្នុងបំណងបំផ្លាញបុគ្គលសាធារណៈនោះ គឺជាការមួល-បង្កាច់ដែលច្បាប់ហាមឃាត់។

បើតុលាការរកឃើញថា ការផ្សាយណាមានលក្ខណៈខុសពីការពិតតាមបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី តុលាការអាចបង្គាប់ឱ្យសារពតិមាននោះ :

- ចុះផ្សាយនូវការកែតំរូវ ឬ
- សងជំងឺចិត្ត ឬ
- ចុះផ្សាយនូវការកែតំរូវផង និងបង់ប្រាក់សងជំងឺចិត្តផង។

អត្ថបទកែតំរូវដែលអ្នកសារពតិមាន មានកាតព្វកិច្ចផ្សាយ ត្រូវចុះផ្សាយនៅទំព័រដូចគ្នា និងមានទំហំអក្សរប៉ុនគ្នា និងអត្ថបទដែលបានចាត់ទុកថាជាអត្ថបទធ្វើឱ្យខូចខាតកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្លួន។ លើសពីនេះ តុលាការអាចផ្តន្ទាទោសពិន័យជាប្រាក់ពី មួយលានរៀល (១.០០០.០០០រៀល) ទៅ ប្រាំលានរៀល (៥.០០០.០០០រៀល) ទៀតក៏បាន។

ម៉្យាងទៀត ក្នុងករណីដែលមានការវិនិច្ឆ័យអំពីអំពើណាមួយដែលមានចែងក្នុងកថាខ័ណ្ឌខាងលើ តុលាការអាចបញ្ជាឱ្យបិទផ្សាយសេចក្តីសំរេចរបស់ខ្លួននៅទីកន្លែងទាំងឡាយ ដែលតុលាការនឹងបញ្ជាក់ ដោយអោយជនជាប់ចោទទទួលបន្ទុកចេញសោហ៊ុយ ហើយតុលាការអាចចុះផ្សាយសាលក្រមនេះក្នុងសារព័ត៌មានមួយ ឬច្រើននិងអោយជនជាប់ចោទទទួលបន្ទុកចេញសោហ៊ុយទាំងអស់ ដោយកំរិតត្រឹម មួយលាន រៀល (១.០០០.០០០រៀល) យ៉ាងច្រើនបំផុត។

**ច្បាប់ស្តីពីគណបក្សនយោបាយ** ( ថ្ងៃទី ២៨ ខែតុលា ឆ្នាំ ១៩៩៧)

**មាត្រា ៣៨:**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនបីលានរៀល(៣.០០០.០០០រៀល) ចំពោះគណបក្សនយោបាយណា ដែលបានប្រព្រឹត្តល្មើសនឹងមាត្រា៣១ នៃច្បាប់នេះ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ទ្វេមួយជាពីរ ហើយអាចផ្តន្ទាទោសផ្អាកសកម្មភាពគណបក្សនយោបាយនោះជាបណ្តោះអាសន្ន។

# គ) ពន្ធារច្បាប់

## ពន្ធារក្រមនីតិវិធីរដ្ឋប្បវេណី (ឆ្នាំ ២០០៣)

**មាត្រា ៣៨: បណ្តឹងជំទាស់ចៅក្រម**

១. ក្នុងករណី ដែលមានកាលៈទេសៈដែលបណ្តាលឱ្យមានការលំអៀងក្នុងការជម្រះក្តីចំពោះចៅក្រមណាម្នាក់ នោះភាគីអាចប្តឹងជំទាស់ចៅក្រមនោះបាន ។

២. ក្នុងករណីដែលភាគីបានឆ្លើយទាញហេតុផលចំពោះមុខចៅក្រម ឬបានធ្វើសេចក្តីដោះសានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលចំពោះមុខចៅក្រមរួចហើយ នោះភាគីមិនអាចប្តឹងជំទាស់ចៅក្រមនោះបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីនោះមិនបានដឹងអំពីមូលហេតុដែល អាចប្តឹងជំទាស់ ឬករណីដែលមូលហេតុនៃបណ្តឹងជំទាស់បានកើតឡើងនៅពេលក្រោយ ។

## ពន្ធារក្រមនីតិវិធីព្រហ្មទណ្ឌ (ឆ្នាំ ២០០០)

**មាត្រា ៤៧៦:**

ភាគីដែលចង់សុំបដិសេធចៅក្រម ត្រូវតែជូនពាក្យប្តឹងតាំងតែពីពេលដែលខ្លួនបានដឹងពីមូលហេតុនៃការសុំបដិសេធ បើពុំដូច្នេះទេនោះ មិនអាចទទួលបានឡើយ ។

នៅក្នុងករណីណាក៏ដោយ ពាក្យប្តឹងសុំបដិសេធចៅក្រម មិនអាចធ្វើបានទេ នៅក្រោយពេលបិទការពិភាក្សាដេញដោល ។

**មាត្រា ៤៧៧:**

ភាគី ត្រូវជូនពាក្យបណ្តឹង:

- ទៅសាលាឧទ្ធរណ៍ កាលណាបណ្តឹងសុំបដិសេធនោះទាក់ទង ដល់ប្រធាន អនុប្រធាន ឬចៅក្រមតុលាការជាន់ដំបូង ឬចៅក្រមសាលាឧទ្ធរណ៍ ។
- ទៅប្រធានតុលាការកំពូល កាលណាពាក្យបណ្តឹងសុំបដិសេធនោះទាក់ទងដល់ចៅក្រមនៃតុលាការកំពូល ដល់ប្រធានសាលាឧទ្ធរណ៍ ឬ អនុប្រធានសាលាឧទ្ធរណ៍ ។

ពាក្យបណ្តឹងត្រូវតែចង្អុលអោយច្បាស់លាស់អំពីមូលហេតុនៃការប្តឹងសុំបដិសេធ ហើយត្រូវមានភស្តុតាងបញ្ជាក់ច្បាស់លាស់។

**មាត្រា ៤៧៨:**

ពាក្យបណ្តឹងត្រូវជូនដំណឹងដល់ចៅក្រមដែលគេសុំបដិសេធ ។ ចៅក្រមនេះ ត្រូវផ្អាកការចូលរួមក្នុងការស៊ើបសួរ ឬក្នុងការជំនុំជំរះរឿង។

ក្នុងករណីបន្ទាន់ចៅក្រមនេះត្រូវបានជំនួសដោយចៅក្រមម្នាក់ទៀត ដែលត្រូវចាត់តាំងដោយ ប្រធានតុលាការដែលសាមីខ្លួននៅក្រោមឱវាទ។

**មាត្រា ៤៧៩:**

ក្នុងរយៈពេល ៨ថ្ងៃ បន្ទាន់ពីការជូនដំណឹងនេះ ចៅក្រមពាក់ព័ន្ធ ត្រូវប្រាប់ឱ្យដឹងនៅក្នុងរបាយការណ៍មានសំអាងហេតុថា ខ្លួនយល់ព្រមតាមការសុំបដិសេធនេះ ។ របាយការណ៍នេះ ត្រូវបញ្ជូនទៅប្រធានសាលាឧទ្ធរណ៍ ឬប្រធានតុលាការកំពូលយោងទៅតាមករណី ដើម្បីសំរេចលើពាក្យបណ្តឹងសុំបដិសេធនេះ។

ប្រសិនបើចៅក្រមនេះ យល់ព្រមតាមការសុំបដិសេធ សាមីខ្លួនត្រូវបានចៅក្រមផ្សេងជំនួសភ្លាម ។

ប្រសិនបើចៅក្រមនេះ ជំទាស់នឹងការបដិសេធ នោះត្រូវធ្វើការសំរេចលើមូលភាពនៃពាក្យបណ្តឹងនេះ ។

**មាត្រា ៤៨០:**

ពាក្យបណ្តឹង ត្រូវបានពិនិត្យដោយមិនចាំបាច់ស្តាប់ភាគី ឬ ចៅក្រមពាក់ព័ន្ធទេ ។

ប្រសិនបើ ការសុំបដិសេធត្រូវបានយល់ព្រម នោះត្រូវធ្វើការចាត់តាំងជំនួសចៅក្រមពាក់ព័ន្ធ ។

នៅក្នុងករណីផ្ទុយ អ្នកប្តឹងបដិសេធអាចត្រូវផ្តន្ទាទោសពិន័យចំនួន ២០០.០០០រៀល ដោយមិនទាន់គិតដល់ជំងឺចិត្តដែលអាចត្រូវផ្តល់អោយចៅក្រមដែលត្រូវប្តឹងសុំបដិសេធនោះទេ ។

**មាត្រា ៤៨១:**

អង្គាធរមានចែងនៅមាត្រា ៤៧៧ សំរេចតាមដីកាមួយដែលមិនអាចប្តឹងតវ៉ាបាន ។ ដីកានេះ ត្រូវជូនដំណឹងដោយក្រឡាបញ្ជីដល់ចៅក្រមពាក់ព័ន្ធ និងដល់អ្នកប្តឹងសុំបដិសេធ ។

**មាត្រា ៤៨២:**

កិច្ចដែលបានបំពេញដោយចៅក្រម ដែលត្រូវបដិសេធមុនការជូនដំណឹងអំពីពាក្យប្តឹងសុំបដិសេធនោះ មិនអាចត្រូវសើរើបានឡើយ ។

**មាត្រា ៤៨៣:**

កាលណាអ្នកប្តឹងចង់សុំបដិសេធចៅក្រមច្រើនរូប ដែលឡើងជំនុំជំរះនៅក្នុងក្រុមសមូហភាពជាមួយគ្នានោះ អ្នកប្តឹងអាចដាក់ពាក្យប្តឹងតែមួយគត់ ។ អ្នកប្តឹងអាចដាក់បន្ថែម ប្រសិនបើ មានមូលហេតុថ្មីនៃការបដិសេធបានលេចឡើងតាមក្រោយ ។

**មាត្រា ៤៨៤:**

កាលណាពាក្យប្តឹងសុំបដិសេធពាក់ព័ន្ធទៅលើប្រធានតុលាការកំពូលនោះ ប្រធានតុលាការកំពូល ត្រូវសម្រេចតាមសម្បជញ្ញៈ ថាតើត្រូវ ឬ មិនត្រូវវៀរចាកការជំនុំជំរះ ។

## ពង្រាងច្បាប់ស្តីពីវិសោធនកម្មលើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

**មាត្រា ថែ១:**

មាត្រា ៦-៧-៨-១០-១១-១៧-១៨ និង ១៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវកែប្រែដូចតទៅ:

**មាត្រា ៦ថ្មី:**

បែបបទនៃការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកពេញសិទ្ធិ និងសមាជិកបំរុង ត្រូវកំណត់ ដោយសេចក្តីសំរេចរបស់ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ។

**មាត្រា ៧ថ្មី:**

ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម មានអគ្គលេខាធិការដ្ឋានមួយជាជំនួយការ ។

អគ្គលេខាធិការ ១រូប ត្រូវជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងចំណោមចៅក្រម ដែលមិនមែនជាសមាជិកឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ។

**មាត្រា ៧ស្ទួន:**

ការប្រជុំ ត្រូវកោះប្រជុំដោយអគ្គលេខាធិការ តាមព្រះរាជបញ្ជា នៃព្រះមហាក្សត្រ ។

ការប្រជុំ និង កម្មវត្ថុ នៃអង្គប្រជុំ អាចស្នើឡើងដោយសមាជិកយ៉ាងតិច ៣រូប ។

**មាត្រា ៨ថ្មី:**

ការប្រជុំរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នឹងទុកជាបានការ លុះត្រាតែមានសមាជិក ៧រូបយ៉ាងតិច ចូលរួមប្រជុំ រាប់ទាំងប្រធានផង ។

**មាត្រា ១០ថ្មី:**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវបានពិគ្រោះមតិជាចាំបាច់ ដើម្បីផ្តល់យោបល់ទៅលើ សេចក្តីស្នើច្បាប់ ឬ សេចក្តីព្រាងច្បាប់ ដែលទាក់ទងដល់វិស័យតុលាការ និងការប្រព្រឹត្តទៅនៃវិស័យនេះ ។

ជាគោលការណ៍ យោបល់របស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវផ្តល់ក្នុងរយៈពេល ៦០ថ្ងៃ គិតពីថ្ងៃដែលបានទទួលសេចក្តីស្នើច្បាប់ពីរដ្ឋសភា ឬ សេចក្តីព្រាងច្បាប់ពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬពីរាជរដ្ឋាភិបាល ។

ក្នុងករណីប្រញាប់រយៈពេលនេះ អាចបន្ថយមកត្រឹម ១០ថ្ងៃ ។

**មាត្រា ១១ថ្មី:**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រ អំពីការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការដាក់ឱ្យនៅទំនេរ ការដាក់ឱ្យនៅក្រៅក្របខ័ណ្ឌ ការដាក់ឱ្យចូលនិវត្តន៍ ការហូតចៅក្រម និង ព្រះរាជអាជ្ញាទាំងអស់ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ពិនិត្យ និងសំរេច អំពីការតម្លើងថ្នាក់ និង ការតម្លើងឋានន្តរសក្តិឱ្យ ចៅក្រម និង ព្រះរាជអាជ្ញាទាំងអស់ ។

អគ្គលេខាធិការនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រ អំពីកិច្ចការខាងលើនេះ ។

**មាត្រា ១៧ថ្មី:** ( មាត្រា ១៧ ចាស់ត្រូវទុកជាមោឃៈទាំងមូល)

**មាត្រា ១៨ថ្មី:**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវទទួលប្រាក់បំណាច់ម៉ោងប្រជុំ ដែលនឹងត្រូវកំណត់ ដោយប្រកាសរបស់ក្រសួងហិរញ្ញវត្ថុ តាមសំណើរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

**មាត្រា ១៩ថ្មី:**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានថវិការបស់ខ្លួន ដែលផ្តល់ដោយថវិកាជាតិ ។

អគ្គលេខាធិការនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាអណាប័ក ផ្ទេរសិទ្ធិពីព្រះមហាក្សត្រ ។